クメール（カンボジア）語版

# សៀវភៅមគ្គុទេសក៍សម្រាប់ការរស់នៅ និងការធ្វើការ

## ～ជូនចំពោះពលរដ្ឋបរទេសដែលរស់នៅប្រទេសជប៉ុនទាំងអស់～



ពិនិត្យផ្ទៀងផ្ទាត់ដោយ ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

កំណែទី ៧

# អារម្ភកថា

នៅចុងខែមិថុនា ឆ្នាំ 2023 ពលរដ្ឋបរទេសដែលស្នាក់នៅប្រទេសជប៉ុន មានចំនួនច្រើនដដែល ប្រហែល 3.22 លាននាក់ ហើយនឹងមានកំណើនបន្តទៀត។

នៅជប៉ុន ដើម្បីសម្រេចនូវសង្គមមួយដែលប្រជាពលរដ្ឋបរទេសនិងជប៉ុន អាចរស់នៅជាមួយគ្នា ដោយគ្មានការបារម្ភបាន ប្រជាពលរដ្ឋជប៉ុនត្រូវមានការយល់ដឹងអំពីជនបរទេស ក៏ជាកត្តាមួយ សំខាន់ដែរ តែការទទួលបាននូវព័ត៌មានអោយបានទាន់ពេលវេលាស្តីពីវិន័យនិងទម្លាប់ជប៉ុន ដោយ ប្រជាពលរដ្ឋបរទេស ក៏សំខាន់ដែរ។

ដោយផ្អែកលើ “វិធានការទូទៅដើម្បីទទួលយកធនធានមនុស្សបរទេសនិងសហាត្ថិភាព” ដែល ត្រូវបានធ្វើសេចក្តីសម្រេចនៅក្នុង “កិច្ចប្រជុំគណរដ្ឋមន្ត្រីពាក់ព័ន្ធនឹងការទទួលយកធនធានមនុស្ស បរទេស និងសហាត្ថិភាព” ដែលបានធ្វើឡើងនៅខែធ្នូ ឆ្នាំ 2018 ក្រសួងនីមួយៗបានសហការគ្នាជា ផ្លូងមួយ ប្រមូលផ្តុំនូវព័ត៌មានមូលដ្ឋាននានាដែលចាំបាច់សម្រាប់ប្រជាពលរដ្ឋបរទេស ដែលរស់នៅ ជប៉ុន អាចមានជីវភាពរស់នៅ និងធ្វើការងារប្រកបដោយសុវត្ថិភាព និងគ្មានការបារម្ភ ហើយចងក្រង ជាសៀវភៅនេះ។ ស្តីពីសៀវភៅមគ្គុទេសក៍នេះ ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុនបានបញ្ចូល ក្នុង “វេបសាយត៍គាំទ្រការរស់នៅរបស់ប្រជាពលរដ្ឋបរទេស” ក្នុងគេហទំព័ររបស់ខ្លួន ដោយមាន ការបកប្រែជាភាសាច្រើនប្រទេស (16 ភាសា)។

ពេលថ្មីៗនេះ ក្រសួងពាក់ព័ន្ធបានសហការគ្នាធ្វើបច្ចុប្បន្នភាពខ្លឹមសារនៃកំណែទី5 ដោយបន្ថែម នូវរបបថ្មីៗ និងកែលំអ កែសម្រួលនូវខ្លឹមសារចាស់ រៀបចំជាកំណែទី 6 នេះ។

យើងសង្ឃឹមថាពលរដ្ឋបរទេសទាំងអស់នឹងប្រើប្រាស់ព័ត៌មានដែលមាននៅក្នុងសៀវភៅមគ្គុទេសក៍នេះអោយមានប្រយោជន៍ ដើម្បីអោយការរស់នៅប្រទេសជប៉ុនអាចធ្វើទៅបានដោយរលូន។

ខែកុម្ភៈ ឆ្នាំ2024
ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

សៀវភៅមគ្គុទេសក៍នេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហប្រតិបត្តិការរបស់ក្រសួងស្ថាប័ន ខាងក្រោម។

តារាងនៃក្រសួងនិងស្ថាប័នរដ្ឋ

| | | |
|---|---|---|
| អគ្គលេខាធិការដ្ឋានរដ្ឋាភិបាល | ក្រសួងយុត្តិធម៌ | ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម |
| ទីស្តីការគណៈរដ្ឋមន្ត្រី | ក្រសួងការបរទេស | ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ |
| អគ្គស្នងការប៉ូលីស | ក្រសួងហិរញ្ញវត្ថុ | ក្រសួងបរិស្ថាន |
| អគ្គនាយកដ្ឋានសេវាកម្មហិរញ្ញវត្ថុ | ក្រសួងអប់រំវប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | |
| ទីភ្នាក់ងារកុមារ និងគ្រួសារ | ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព | |
| អគ្គនាយកដ្ឋានអ្នកប្រើប្រាស់ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| ក្រសួងមហាផ្ទៃ | | |

# តារាងមាតិកា

អារម្ភកថា

## ជំពូកទី1 នីតិវិធីអន្តោប្រវេសន៍ និងស្នាក់នៅប្រទេសជប៉ុន


1 ប័ណ្ណស្នាក់នៅ ..... 1
1-1 ការផ្តល់ប័ណ្ណស្នាក់នៅ ..... 2
1-2 ការជូនដំណឹងអំពីកន្លែងស្នាក់នៅ (ការជូនដំណឹងអំពីការផ្លាស់លំនៅចូល) ..... 2
1-3 ការបាត់ប័ណ្ណស្នាក់នៅ ..... 3
1-4 ការសងប័ណ្ណស្នាក់នៅ ..... 3
2 បែបបទទាក់ទងនឹងលក្ខណ:សម្បត្តិស្នាក់នៅ ..... 4
2-1 ការបន្តរយ:ពេលស្នាក់នៅ (នៅពេលចង់បន្តថ្ងៃកំណត់រយ:ពេលស្នាក់នៅ) ..... 4
2-2 ការប្តូរលក្ខណ:សម្បត្តិស្នាក់នៅ (នៅពេលចង់ប្តូរគោលបំណងស្នាក់នៅប្រទេសជប៉ុន) ..... 4
2-3 ការអនុញ្ញាតស្នាក់នៅជាអចិន្ត្រៃយ៍ ..... 5
2-4 ការទទួលបានលក្ខណ:សម្បត្តិស្នាក់នៅ (ក្នុងករណីផ្តល់កំណើតកូន) ..... 5
2-5 ការអនុញ្ញាតលើសកម្មភាពក្រៅលក្ខណ:សម្បត្តិ ..... 6
2-6 ការជូនដំណឹងទៅការិយាល័យអន្តោប្រវេសន៍តាមតំបន់ ..... 6
(1) ការជូនដំណឹងអំពីស្ថាប័នធ្វើសកម្មភាព
(2) ការជូនដំណឹងអំពីស្ថាប័នជាប់កិច្ចសន្យា
(3) ការជូនដំណឹងអំពីសហព័ទ្ធ
3 ការអនុញ្ញាតអោយចូលប្រទេសជប៉ុនសារជាថ្មី (ចូលប្រទេសជប៉ុនសារជាថ្មីដោយរក្សាទុកលក្ខណ:សម្បត្តិស្នាក់នៅបច្ចុប្បន្ននៅដដែល) ..... 9
(1) ការអនុញ្ញាតអោយចូលប្រទេសជប៉ុនសារជាថ្មីដោយចាត់ទុក (ក្នុងករណីត្រឡប់មកប្រទេសជប៉ុនវិញក្នុងអំឡុង1ឆ្នាំ)
(2) ការអនុញ្ញាតអោយចូលប្រទេសជប៉ុនសារជាថ្មី (ក្នុងករណីត្រឡប់មកប្រទេសជប៉ុនវិញក្រោយ1ឆ្នាំ)
4 នីតិវិធីទទួលស្គាល់ជនភៀសខ្លួននិងទទួលស្គាល់ផ្សេងទៀត ..... 9
4-1 "ជនភៀសខ្លួន" គឺជា ..... 10
4-2 និយមន័យនៃបុគ្គលដែលស្ថិតនៅក្រោមការការពារបន្ថែម ..... 10
4-3 ពាក្យស្នើសុំទទួលស្គាល់ស្ថានភាពជនភៀសខ្លួន ឬសិទ្ធិទទួល ..... 10
4-4 បានការការពារបន្ថែម ..... 10
4-5 ការស្នើសុំអោយត្រួតពិនិត្យ ..... 11
5 នីតិវិធីបញ្ជូនទៅប្រទេសដើមវិញដោយបង្ខំជាដើម ..... 11
5-1 មូលហេតុសំខាន់ៗនៃការបញ្ជូនទៅប្រទេសដើមវិញ ..... 11
5-2 ក្នុងករណីត្រូវបានបញ្ជូនទៅប្រទេសដើមវិញ ..... 11

5-3 ប្រព័ន្ធបញ្ជាអោយចាកចេញ ..... 12
5-4 ការអនុញ្ញាតអោយស្នាក់នៅពិសេស ..... 12
6 អាសយដ្ឋានទំនាក់ទំនងអំពីនីតិវិធីអន្តោប្រវេសន៍និងស្នាក់នៅជាដើម ..... 13
7 ការផ្សាយព័ត៌មានពីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន ..... 15
7-1 គេហទំព័រជាផ្លូវការរបស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន ..... 15
7-2 SNS ជាផ្លូវការរបស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន ..... 15
7-3 វិបផតថលសម្រាប់គាំទ្រជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន ..... 16
7-4 វីដេអូតម្រង់ទិសជីវិត ..... 16

## ជំពូកទី2 ការបំពេញបែបបទនៅភូមិឃុំស្រុក

1 ការជូនដំណឹងចាំបាច់ ..... 17
1-1 ការជូនដំណឹងអំពីអាសយដ្ឋានស្នាក់នៅ ..... 17
(1) ក្នុងករណីចូលមកប្រទេសជប៉ុនដោយបានទទួលការអនុញ្ញាតថ្មី
(2) ក្នុងករណីផ្លាស់លំនៅចេញ
1-2 ការសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ..... 18
(1) ឯកសារចាំបាច់សម្រាប់ការសុំចុះបញ្ជីអាពាហ៍ពិពាហ៍
(2) សុពលភាពនៅប្រទេសរបស់ខ្លួន
1-3 ការជូនដំណឹងអំពីការលែងលះគ្នា ..... 19
(1) សុពលភាពនៅប្រទេសសាមី
(2) ក្នុងករណីដែលមានការបារម្ភថា ភាគីម្ខាងទៀតទៅជូនដំណឹងអំពីការលែងលះតាមទំនើងចិត្ត
1-4 ការជូនដំណឹងអំពីមរណភាព ..... 20
(1) ឯកសារចាំបាច់សម្រាប់ការជូនដំណឹងអំពីមរណភាព
(2) ការសងប័ណ្ណស្នាក់នៅ
1-5 ការចុះបញ្ជីត្រា ..... 21
(1) នីតិវិធីចុះបញ្ជីត្រា
(2) លិខិតបញ្ជាក់ការចុះបញ្ជីត្រា
2 ប្រព័ន្ធលេខសំគាល់បុគ្គល ..... 21
2-1 តើអ្វីជាប្រព័ន្ធលេខសំគាល់បុគ្គល ..... 21
2-2 កាតលេខផ្ទាល់ខ្លួន (កាតលេខរបស់ខ្ញុំ) ..... 22
(1) កំណត់ត្រា
(2) តើគេប្រើលេខសំគាល់បុគ្គលនៅពេលណា
(3) វិធីស្នើសុំ
(4) វិធីទទួលយក
2-3 ប្រការប្រុងប្រយ័ត្នក្នុងការប្រើកាតលេខសំគាល់បុគ្គល ..... 24
2-4 ផ្សេងៗ ..... 24

## ជំពូកទី3 ការជួល និងការធ្វើការ


1 ចំណេះដឹងមូលដ្ឋានមុនពេលធ្វើការ ........ 25
1-1 លក្ខណៈសម្បត្តិស្នាក់នៅ ........ 25
1-2 របៀបស្វែងរកការងារ ........ 25
(1) ហេឡូវើក (hello work)
(2) នៅពេលប្រើក្រុមហ៊ុនណែនាំ
1-3 ប្រភេទនៃកម្មករនិយោជិត ........ 26
(1) កម្មករនិយោជិតបញ្ជូន (បុគ្គលិកបញ្ជូន)
(2) បុគ្គលិកមានថេរវេលាកំណត់ (បុគ្គលិកដែលមានកិច្ចសន្យាកំណត់ថេរវេលា)
(3) កម្មករនិយោជិតមិនពេញម៉ោង
(4) អ្នកធ្វើការដោយមានកិច្ចសន្យាប្រគល់ការងារ (មៅការងារ)
1-4 កិច្ចសន្យាការងារ ........ 28
(1) ព្រំដែននៃ "កម្មករនិយោជិត"
(2) ការបញ្ជាក់អោយច្បាស់នូវលក្ខខណ្ឌការងារ
1-5 ប្រាក់ឈ្នួល ........ 30
(1) ប្រាក់ឈ្នួលអប្បបរមាគឺ
(2) លក្ខណៈពិសេសនៃប្រាក់ឈ្នួលអប្បបរមា
(3) ប្រាក់ឧបត្ថម្ភសម្រាកការងារ
2 បទបញ្ញត្តិនៅពេលធ្វើការ ........ 31
2-1 ការបើកប្រាក់ឈ្នួល ........ 31
2-2 ថេរវេលាធ្វើការ / ការសម្រាក / ថ្ងៃឈប់សម្រាក ........ 32
(1) ថេរវេលាធ្វើការ
(2) ការសម្រាក
(3) ថ្ងៃឈប់សម្រាក
(4) កាតព្វកិច្ចទាក់ទងនឹងការសម្រេចលក្ខខណ្ឌការងាររបស់បុគ្គលិកបញ្ជូន
2-3 ការងារបន្ថែមម៉ោង និងការងារថ្ងៃឈប់សម្រាក ........ 33
(1) ការងារបន្ថែមម៉ោង និងការងារថ្ងៃឈប់សម្រាក
(2) ប្រាក់ខែបន្ថែម
2-4 ការថែទាំសុខភាពមាតា / ការឈប់សម្រាកលំហែមាតុភាព / ការឈប់សម្រាកចិញ្ចឹមកូន / ការឈប់សម្រាកថែទាំ ........ 34
(1) នៅពេលមានផ្ទៃពោះ
(2) ការឈប់សម្រាកលំហែមាតុភាព
(3) ការឈប់សម្រាកចិញ្ចឹមកូន
(4) ការឈប់សម្រាកថែទាំ
2-5 ការលាឈប់ និងការបញ្ឈប់ការងារជាដើម ........ 36
(1) ការលាឈប់
(2) ការបញ្ឈប់ការងារ

(3) ការក្ស័យធនរបស់សហគ្រាស
(4) របបនិកម្មភាពការងារ (ប្រាក់ឧបត្ថម្ភមូលដ្ឋាន)
(5) សកម្មភាពរកការងារ
3 សុខភាពនិងសុវត្ថិភាពការងារ ..... 41
3-1 សុវត្ថិភាព និងបរិស្ថានកន្លែងធ្វើការល្អ ..... 41
(1) ខ្លឹមសារនៃច្បាប់ស្តីពីសុវត្ថិភាពនិងអនាម័យ
(2) ការពិនិត្យសុខភាព។ល។
(3) ការសម្ភាសន៍និងណែនាំពីគ្រូពេទ្យ
3-2 តាវកាលិកសម្រាប់គ្រោះថ្នាក់ការងារ ឬជំងឺជាដើម (របបហានិភ័យការងារ) ..... 42
(1) ការទទួលតាវកាលិកពីរបបហានិភ័យការងារ
(2) ចំណុចសំគាល់ផ្សេងទៀត
3-3 ការហាមឃាត់មិនអោយរើសអើងភេទ ..... 43
(1) នៅពេលស្វែងរកការងារ
(2) ក្រោយពេលចូលធ្វើការ
3-4 វិធានការទប់ស្កាត់ការបៀតបៀន ..... 44
3-5 គោលការណ៍ណែនាំក្នុងការគ្រប់គ្រងការជួលពលរដ្ឋបរទេស ..... 44
4 របបសន្តិសុខសង្គម និងការធានារ៉ាប់រងការងារ ..... 45
4-1 របបថែទាំសុខភាព និងរបបថែទាំសុខភាពពលរដ្ឋ ..... 45
4-2 របបប្រាក់សោធនពលរដ្ឋ និងរបបប្រាក់សោធនសុខុមាលភាព ..... 45
4-3 របបធានារ៉ាប់រងលើការគាំពារ ..... 46
4-4 របបនិកម្មភាពការងារ ..... 46
(1) គោលដៅអនុវត្ត
(2) បន្ទុកនៃភាគទាន
4-5 របបហានិភ័យការងារ ..... 46

## ជំពូកទី4 ការសម្រាលកូន និងការចិញ្ចឹមកូន

1 បែបបទបំពេញនៅពេលមានផ្ទៃពោះ ..... 47
1-1 ការផ្តល់ដំណឹងអំពីការមានផ្ទៃពោះនិងការផ្តល់សៀវភៅសុខភាពមាតាជាដើម ..... 47
1-2 ការពិនិត្យផ្ទៃពោះមុនសម្រាល ..... 47
1-3 ការណែនាំដល់ផ្ទះពីគិលានុបដ្ឋាយិកាសុខភាពសាធារណៈនិងឆ្មបជាដើម ..... 48
1-4 វគ្គណែនាំ ម្តាយនិងឪពុក (វគ្គណែនាំម្តាយ វគ្គណែនាំឪពុក) ..... 48
2 ការបំពេញបែបបទក្រោយសម្រាលកូន ..... 49
2-1 ការចុះបញ្ជីកំណើត ..... 49
(1) ឯកសារចាំបាច់សម្រាប់ការចុះបញ្ជីកំណើត
(2) ការបំពេញបែបបទផ្សេងទៀត
2-2 ការចុះបញ្ជីកំណើតទៅប្រទេសខ្លួន ..... 49

3 ថ្លៃសម្រាលកូន និងប្រាក់ឧបត្ថម្ភផ្សេងៗ ....50
3-1 ប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូន ....50
3-2 ប្រាក់ឧបត្ថម្ភសម្រាលកូន....50
3-3 ប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូន(ការឧបត្ថម្ភអំឡុងពេលឈប់សម្រាកចិញ្ចឹមកូន) .51
(1) ប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូន
(2) ប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូននៅពេលសម្រាល
3-4 ប្រាក់ឧបត្ថម្ភសម្រាប់កុមារ ....53
(1) អ្នកមានសិទ្ធិទទួល
(2) វិធីទទួល
(3) ទឹកប្រាក់ទទួលបាន
(4) ពេលវេលាទទួល
4 ការចិញ្ចឹមកូន ....54
4-1 សេវាថែទាំក្រោយសម្រាល....54
4-2 ការពិនិត្យសុខភាពទារក និងកុមារ ....54
4-3 ការចាក់វ៉ាក់សាំង....54
4-4 ថ្លៃព្យាបាលកុមារ....55
4-5 កន្លែងទទួលកុមារមុនចូលរៀន ....55
(1) ទារកដ្ឋាន
(2) មត្តេយ្យសាលា
(3) មជ្ឈមណ្ឌលអប់រំកុមារតូចមានការទទួលស្គាល់
4-6 ក្លឹបកុមារក្រោយម៉ោងសិក្សា (សកម្មភាពក្រោយម៉ោងសិក្សា)....56
4-7 មជ្ឈមណ្ឌលគាំពារគ្រួសារ (Family support center) ....56
5 សេវាពិគ្រោះយោបល់សម្រាប់ការមានផ្ទៃពោះ ការសម្រាលកូន និងការចិញ្ចឹមកូន ....57
5-1 មជ្ឈមណ្ឌលកុមារ និងគ្រួសារ។ល។....57
5-2 មជ្ឈមណ្ឌលគាំពារកុមារតាមតំបន់....57

## ជំពូកទី5 ការអប់រំ

1 ប្រព័ន្ធអប់រំរបស់ជប៉ុន ....58
1-1 សាលាបឋមសិក្សា និងអនុវិទ្យាល័យ ....59
1-2 វិទ្យាល័យ....59
1-3 សាលាសម្រាប់ពលរដ្ឋបរទេស ....60
1-4 អនុវិទ្យាល័យរៀនវេនយប់ ....60
1-5 ការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាកម្រិត 1....60
1-6 ការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាកម្រិត 2....61
1-7 ស្ថាប័នឧត្តមសិក្សា (សកលវិទ្យាល័យជាដើម)....61
1-8 ការប្រឡងចូលស្ថាប័នឧត្តមសិក្សា ....62

2 ជំនួយហិរញ្ញវត្ថុលើថ្លៃសិក្សា ....... 63
2-1 ឧបត្ថម្ភធនលើចំណាយសិក្សា ....... 63
2-2 ប្រាក់ឧបត្ថម្ភចំណាយសិក្សានៅវិទ្យាល័យជាដើម ....... 63
2-3 ប្រាក់ឧបត្ថម្ភសម្រាប់សិស្សវិទ្យាល័យជាដើម ....... 64
2-4 អាហារូបករណ៍សម្រាប់កម្រិតឧត្តមសិក្សា ....... 64
3 ការសិក្សាភាសាជប៉ុន ....... 65
3-1 ស្តីពីការសិក្សាភាសាជប៉ុន ....... 65
3-2 ក្របខ័ណ្ឌយោងក្នុងការសិក្សាភាសាជប៉ុន ....... 65
3-3 កន្លែងសិក្សាភាសាជប៉ុន ....... 66
(1) សាលាភាសាជប៉ុន
(2) ថ្នាក់រៀនភាសាជប៉ុននៅក្នុងសហគមន៍
(3) ការអប់រំដោយឆ្លើយឆ្លង ឬពីចំងាយ
3-4 គេហទំព័រសម្រាប់សិក្សាភាសាជប៉ុន"ផ្សារភ្ជាប់ ពង្រីក ការរស់នៅដោយប្រើភាសាជប៉ុន" (ឈ្មោះហៅធម្មតា Tsunahiro) ....... 67
3-5 "Nihongo Check!" ដែលជាឧបករណ៍វាយតម្លៃដោយខ្លួនឯងជាភាសាជប៉ុនដោយផ្អែកលើក្របខ័ណ្ឌឯកសារយោងសម្រាប់ការអប់រំជាភាសាជប៉ុន ....... 68

## ជំពូកទី6 ការថែទាំនិងព្យាបាលផ្នែកវេជ្ជសាស្ត្រ

1 ស្ថាប័នវេជ្ជសាស្ត្រ ....... 69
1-1 ប្រភេទនៃស្ថាប័នវេជ្ជសាស្ត្រ ....... 69
1-2 ការស្វែងរកស្ថាប័នវេជ្ជសាស្ត្រ ....... 70
2 របបធានារ៉ាប់រងសុខភាព ....... 71
2-1 របបថែទាំសុខភាព ....... 71
(1) លក្ខខណ្ឌចូលជាសមាជិក
(2) ភាគទាន
(3) ខ្លឹមសារនៃតារកាលិក
2-2 របបថែទាំសុខភាពពលរដ្ឋ ....... 73
(1) លក្ខខណ្ឌចូលជាសមាជិក
(2) បែបបទក្នុងការចូលនិងចាកចេញ
(3) ភាគទាន
(4) ខ្លឹមសារនៃតារកាលិក
2-3 របបថែទាំសុខភាពមនុស្សចាស់ ....... 75
(1) លក្ខខណ្ឌចូលជាសមាជិក
(2) បែបបទក្នុងការចូលនិងចាកចេញ
(3) ភាគទាន
(4) ខ្លឹមសារនៃតារកាលិក

3 ថ្នាំពេទ្យ......77
3-1 ឱសថស្ថាន......77
3-2 Drugstore......77

## ជំពូកទី7 របបប្រាក់សោធន និងសុខុមាលភាព

1 របបប្រាក់សោធន......78
1-1 របបប្រាក់សោធនពលរដ្ឋ......79
(1) សមាជិក (អ្នកចូលក្នុងរបប) និងនីតិវិធីចូលជាសមាជិក
(2) ភាគទាន
(3) តាវកាលិក
1-2 របបប្រាក់សោធនសុខុមាលភាព......82
(1) សមាជិក (អ្នកចូល)
(2) ភាគទាន
(3) តាវកាលិក
1-3 ប្រាក់សោធនពេលចាកចេញ......85
2 របបធានារ៉ាប់រងលើការគាំពារ......86
2-1 សមាជិកគោលដៅ......86
2-2 ភាគទាន......86
2-3 ការប្រើប្រាស់សេវាគាំពារ......87
3 សុខុមាលភាពកុមារ......87
3-1 ប្រាក់ឧបត្ថម្ភសម្រាប់កុមារ......87
3-2 ប្រាក់ឧបត្ថម្ភចិញ្ចឹមកុមារ......87
3-3 ប្រាក់ឧបត្ថម្ភចិញ្ចឹមកុមារពិសេស......88
3-4 ប្រាក់ឧបត្ថម្ភសុខុមាលភាពកុមារពិការ......88
4 សុខុមាលភាពជនពិការ......89
4-1 សៀវភៅ......89
4-2 សេវារដ្ឋបាលចំពោះជនពិការ និងកុមារពិការ......89
5 របបជំនួយសង្គម......90
5-1 លក្ខខណ្ឌក្នុងការទទួលបានរបបជំនួយសង្គម......90
(1) ការប្រើប្រាស់ទ្រព្យសម្បត្តិ
(2) ការប្រើប្រាស់សមត្ថភាព
(3) តាវកាលិកផ្សេងទៀតជាដើម
(4) ការចិញ្ចឹមដោយអ្នកមានកាតព្វកិច្ចចិញ្ចឹម
5-2 ប្រភេទនិងខ្លឹមសារនៃជំនួយ......91
6 ប្រព័ន្ធគាំទ្រអ្នកមានជីវភាពក្រីក្រអោយពឹងផ្អែកលើខ្លួនឯង......92

## ជំពូកទី8 ពន្ធ


1 ពន្ធលើប្រាក់ចំណូល ..... 93

1-1 អ្នកមានកាតព្វកិច្ចបង់ពន្ធនិងប្រាក់ចំណូលដែលជាគោលដៅត្រូវបង់ពន្ធ ..... 94

(1) និវាសនជន

(2) អ្នកមិនស្នាក់នៅអចិន្ត្រៃយ៍

(3) អនិវាសនជន

1-2 ការប្រកាសសម្រេច សម្រាប់ពន្ធលើប្រាក់ចំណូល និងការបង់ពន្ធ ..... 95

(1) អ្នកដែលត្រូវប្រកាសសម្រេច

(2) អ្នកដែលអាចទទួលបានពន្ធលើប្រាក់ចំណូលមកវិញក្រោយធ្វើការប្រកាសសម្រេច

(3) កាលកំណត់នៃការប្រកាសសម្រេចនិងការបង់ពន្ធ

(4) ក្នុងករណីចាកចេញពីប្រទេសជប៉ុន

1-3 ប្រាក់ដកពីប្រាក់ចំណូលសំខាន់ៗ ..... 96

(1) ក្នុងករណីចិញ្ចឹមគ្រួសារ

(2) ក្នុងករណីមានសហព័ទ្ធ

(3) ក្នុងករណីបង់ភាគទានរបបសន្តិសុខសង្គម

(4) ក្នុងករណីបង់ប្រាក់ធានារ៉ាប់រងជីវិតជាដើម

(5) ក្នុងករណីបានបង់ថ្លៃព្យាបាល

1-4 ពន្ធកាត់ទុក និងការទូទាត់ពន្ធនៅចុងឆ្នាំ ..... 98

1-5 បញ្ញត្តិពិសេសក្រោមសន្ធិសញ្ញាពន្ធ ..... 98

2 ពន្ធលើនិវាសនជន ..... 99

2-1 តើអ្វីជាពន្ធលើនិវាសនជន ..... 99

2-2 ការបង់ពន្ធលើនិវាសនជន ..... 99

2-3 ផ្សេងៗ ..... 99

3 អាករលើតំលៃបន្ថែម ..... 100

4 ពន្ធដែលម្ចាស់រថយន្តត្រូវបង់ ..... 100

4-1 ពន្ធលើរថយន្ត និងពន្ធលើរថយន្តធុនស្រាល ..... 100

(1) ពន្ធលើរថយន្ត ឬពន្ធលើរថយន្តធុនស្រាលតាមសមត្ថភាពបរិស្ថាន

(2) ពន្ធលើរថយន្ត និងពន្ធលើរថយន្តធុនស្រាលតាមប្រភេទ

4-2 ពន្ធលើរថយន្តតាមទម្ងន់ ..... 101

5 ពន្ធលើអចលនទ្រព្យ ..... 101

6 អាសយដ្ឋានទំនាក់ទំនងសួរអំពីពន្ធ ..... 101

6-1 សំណួរអំពីពន្ធរដ្ឋ ..... 101

(1) មជ្ឈមណ្ឌលពិគ្រោះតាមទូរស័ព្ទ

(2) Tax answer (សំណួរញឹកញាប់អំពីពន្ធ)

(3) ការណែនាំអំពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ

6-2 សំណួរអំពីពន្ធមូលដ្ឋាន ..... 102

## ជំពូកទី9 ចរាចរណ៍


1 ច្បាប់ចរាចរណ៍ ..... 103
1-1 ប្រការត្រូវប្រុងប្រយ័ត្ននៅពេលធ្វើដំណើរដោយថ្មើរជើង ..... 103
(1) នៅពេលធ្វើដំណើរទៅមុខ
(2) វិធីឆ្លងផ្លូវ
(3) នៅពេលធ្វើដំណើរដោយថ្មើរជើងនៅពេលយប់
1-2 ប្រការត្រូវប្រុងប្រយ័ត្ននៅពេលជិះកង់ ..... 104
(1) ការគោរពច្បាប់ធ្វើដំណើរដោយកង់ "ច្បាប់ប្រើប្រាស់កង់ដោយសុវត្ថិភាពទាំង 5"
(2) វិធីឆ្លងផ្លូវប្រសព្វ
1-3 គោលការណ៍ណែនាំស្ដីពីសុវត្ថិភាពសម្រាប់អ្នកជិះ "កង់អគ្គិសនីខ្នាតតូចជាក់លាក់" (កង់អគ្គិសនី/កង់ស្គី។ល។) ..... 106
1-4 នៅពេលបើកបរយានយន្ត (រួមទាំងម៉ូតូ) ..... 107
2 ប័ណ្ណបើកបរ ..... 108
2-1 ការយកប័ណ្ណបើកបររបស់ប្រទេសជប៉ុន ..... 108
2-2 ការបន្តសុពលភាពប័ណ្ណបើកបររបស់ប្រទេសជប៉ុនជាដើម ..... 109
2-3 ប្រព័ន្ធដាក់ពិន្ទុលើប័ណ្ណបើកបរ ..... 109
3 ការធ្វើជាម្ចាស់យានយន្ត (រួមទាំងម៉ូតូ) ..... 109
3-1 ការចុះបញ្ជីយានយន្ត ..... 109
(1) កាលៈទេសៈដែលត្រូវធ្វើបែបបទចុះបញ្ជីនិងឈ្មោះនៃបែបបទចុះបញ្ជី
(2) ទីកន្លែងដែលអាចធ្វើបែបបទចុះបញ្ជីនិងអាសយដ្ឋានទំនាក់ទំនង
3-2 លិខិតបញ្ជាក់កន្លែងទុកយានយន្ត ..... 110
3-3 ការត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្ត (រួមទាំងម៉ូតូប្រភេទខ្លះផង) ..... 111
3-4 ធានារ៉ាប់រងលើយានយន្ត ..... 112
(1) ធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត (ជួយគ្នាទៅវិញទៅមក)
(2) ធានារ៉ាប់រងស្ម័គ្រចិត្តលើយានយន្ត (ជួយគ្នាទៅវិញទៅមក)
4 ដំណោះស្រាយនៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង ..... 114
4-1 បញ្ឈប់ការបើកបរយានជំនិះ ..... 114
4-2 ការជូនដំណឹងទៅក្រុមសង្គ្រោះបន្ទាន់ និងប៉ូលីសចរាចរណ៍ ..... 114
4-3 ការពិនិត្យវិនិច្ឆ័យដោយគ្រូពេទ្យ ..... 114
4-4 ការស្នើសុំលិខិតបញ្ជាក់គ្រោះថ្នាក់ចរាចរណ៍ ..... 115


## ជំពូកទី10 អាសន្ន និងគ្រោះមហន្តរាយ


1 លេខទូរស័ព្ទទំនាក់ទំនងពេលមានអាសន្ន ..... 116
1-1 ជំងឺឬរបួសបន្ទាន់ ឬអគ្គីភ័យ (លេខ 119) ..... 116
1-2 គ្រោះថ្នាក់ចរាចរណ៍ ឬការរងគ្រោះពីបទល្មើសផ្សេងៗ (លេខ 110) ..... 117

2 គ្រោះមហន្តរាយ ....118
2-1 ព្យុះ ឬភ្លៀងធ្លាក់ខ្លាំង ....118
(1) ទឹកជន់ពីទន្លេ
(2) គ្រោះបាក់ដី
2-2 គ្រោះរញ្ជួយដី....120
2-3 គ្រោះរលកស៊ូណាមិ ....122
2-4 គ្រោះផ្ទុះភ្នំភ្លើង....123
3 ការភៀសខ្លួន ....125
3-1 កន្លែងភៀសខ្លួន ....125
3-2 ព័ត៌មានសម្រាប់ការភៀសខ្លួន....125
3-3 វិធីភៀសខ្លួន....127
3-4 ការទទួលព័ត៌មានអំពីអាកាសធាតុមានប្រយោជន៍នៅពេលមានគ្រោះមហន្តរាយ ....129

## ជំពូកទី11 លំនៅដ្ឋាន

1 អំពីលំនៅដ្ឋាននៅប្រទេសជប៉ុន ....132
1-1 ផ្ទះឯកជន ....132
1-2 ផ្ទះរបស់រដ្ឋ....132
1-3 ផ្ទះជួលរបស់ UR....132
1-4 ផ្ទះជួលឯកជន ....132
2 អំពីការចូលរស់នៅ ....133
2-1 ផ្ទះរបស់រដ្ឋ....133
2-2 ផ្ទះជួលរបស់ UR....133
2-3 ផ្ទះជួលឯកជន ....133

## ជំពូកទី12 ច្បាប់ និងទំនៀមទំលាប់ក្នុងការរស់នៅប្រចាំថ្ងៃ

1 ច្បាប់នៃការរស់នៅ ....136
1-1 សំរាម ....136
(1) ច្បាប់មូលដ្ឋានក្នុងការចោលសំរាម
(2) ការចោលសំរាមខុសច្បាប់ជាដើម (ការចោលសំរាមដោយខុសច្បាប់)
1-2 សំលេងរំខាន ....138
1-3 បង្គន់....138
1-4 ការប្រើប្រាស់ទូរស័ព្ទចល័ត....138
1-5 នៅក្នុងរថភ្លើងឬរថយន្តក្រុង....138
1-6 អុនសេន និងសេនតូ....139
1-7 សញ្ញាបង្ហាញការហាមឃាត់....139
2 ការបង្ការជម្ងឺឆ្លង ....140
2-1 ការលាងដៃ ....140

2-2 សុជីវធម៌ពេលភ្ញាក ..... 141
2-3 សំណើម ..... 141
2-4 ការសម្រាកនិងការញុាំឱ្យមានជីវជាតិ ..... 141
2-5 ការចេញទៅក្រៅ ..... 141
3 អ្វីដែលចាំបាច់ក្នុងការរស់នៅ ..... 142
3-1 ជីវភាពក្នុងសហគមន៍ ..... 142
(1) សហគមន៍មូលដ្ឋាន (សមាគមមូលដ្ឋាន សមាគមអ្នកជិតខាង)
(2) ការរាប់អានអ្នកជិតខាង
3-2 ការការពារបទល្មើស ..... 142
3-3 សេវាកម្មចាំបាច់សម្រាប់ជីវភាព ..... 143
(1) អគ្គិសនី
(2) ហ្គាស
(3) ទឹកស្អាត
3-4 ការប្រើប្រាស់ទូរស័ព្ទចល័ត ..... 146
(1) កិច្ចសន្យាទូរស័ព្ទចល័ត
(2) ចំណុចប្រុងប្រយ័ត្ននៅពេលធ្វើកិច្ចសន្យា និងនៅពេលប្រើប្រាស់
3-5 គណនីធនាគារ ..... 147
(1) បើកគណនីធនាគារ
(2) ពេលប្តូរអាសយដ្ឋាន ឬមានការប្រែប្រួលអំពីកម្លុងពេលស្នាក់នៅ ត្រូវជូនដំណឹងប្រាប់ធនាគារភ្លាមៗ
(3) ការបិទគណនីធនាគារមិនប្រើប្រាស់
(4) កុំប្រើប្រាស់ធនាគារខុសច្បាប់
(5) ផ្សេងៗ
3-6 ការិយាល័យប្រៃសណីយ៍ ..... 148
4 ចរាចរណ៍សាធារណៈ ..... 149
4-1 កាត IC ..... 149
(1) មុខងារមូលដ្ឋាន
(2) កាតមានឈ្មោះ
(3) កាតគ្មានឈ្មោះ
(4) ប្រាក់កក់ (deposit)
4-2 ផ្លូវដែក ..... 150
(1) ការប្រើប្រាស់បណ្តាញផ្លូវដែក
(2) ប្រភេទនៃសំបុត្រ
(3) សំបុត្រផ្សេងទៀត
4-3 រថយន្តក្រុង ..... 151
(1) រថយន្តក្រុងធ្វើដំណើរផ្លូវឆ្ងាយ (រថយន្តក្រុងផ្លូវឆ្ងាយ)
(2) រថយន្តក្រុងធ្វើដំណើរតាមផ្លូវកំណត់នៅតំបន់រស់នៅ (រថយន្តក្រុងក្នុងតំបន់)

ជំពូកទី1

# នីតិវិធីអន្តោប្រវេសន៍ និង ស្នាក់នៅប្រទេសជប៉ុន




## 1 ប័ណ្ណស្នាក់នៅ

គឺជាប័ណ្ណសំគាល់ខ្លួនពលរដ្ឋបរទេសដែលរស់នៅប្រទេសជប៉ុន។ នៅលើប័ណ្ណមានសរសេរចូលនូវព័ត៌មានអំពីអត្តសញ្ញាណរបស់ម្ចាស់ រយៈពេលអាចស្នាក់នៅប្រទេសជប៉ុនបាន (រយៈពេលស្នាក់នៅ) សកម្មភាពដែលអាចធ្វើបាននៅប្រទេសជប៉ុនបាន (លក្ខណៈសម្បត្តិស្នាក់នៅ) ជាដើម។




- អ្នកដែលមានអាយុចាប់ពី 16ឆ្នាំឡើងទៅ សូមដាក់តាមខ្លួនជានិច្ច។
- ជាប័ណ្ណសំគាល់ខ្លួនផងដែរដែលត្រូវបង្ហាញនៅពេលធ្វើបែបបទសម្រាប់និតិវិធីនៅសាលាក្រុង កិច្ចសន្យា។ល។

### អ្នកដែលអាចទទួលបានប័ណ្ណស្នាក់នៅ

ប័ណ្ណស្នាក់នៅគឺគេផ្តល់អោយពលរដ្ឋបរទេសដែលស្នាក់នៅប្រទេសជប៉ុនលើសពី 3ខែ។ (អ្នកដែលអាចទទួលបានប័ណ្ណស្នាក់នៅគេហៅថា “អ្នកស្នាក់នៅរយៈពេលមធ្យមឬវែង”។)

### [ករណីទាំង 6ដែលប័ណ្ណស្នាក់នៅមិនត្រូវបានផ្តល់]

① អ្នកដែលស្នាក់នៅក្នុងរយៈពេលតិចជាង “3ខែ (3ខែ)”
② អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅ “ការស្នាក់នៅរយៈពេលខ្លី”
③ អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅ “ការទូត” ឬ “ផ្លូវការ”
④ អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅណាមួយខាងក្រោម "សកម្មភាពដែលបានកំណត់"
- ជាសមាជិកបុគ្គលិកឬក៏គ្រួសាររបស់គាត់ របស់សមគមទំនាក់ទំនងរវាងតៃវ៉ាន់និងជប៉ុន (ការិយាល័យតំណាងសេដ្ឋកិច្ច និងវប្បធម៌តៃវ៉ាន់នៅជប៉ុនជាដើម)
- សមាជិកបុគ្គលិកឬក៏គ្រួសាររបស់ពួកគាត់នៃសកកម្មទូទៅអចិន្ត្រៃយ៍របស់ប៉ាឡេស្ទីននៅក្នុងប្រទេសជប៉ុនដែលមានស្ថានភាពស្នាក់នៅ"សកម្មភាពដែលបានកំណត់"។
- ឈ្មោះឌីជីថល (អ្នកដែលស្នាក់នៅប្រទេសជប៉ុនសម្រាប់គោលបំណងនៃការងារពីចម្ងាយអន្តរជាតិ។ល។) និងប្តី/ប្រពន្ធ/កូនរបស់គាត់

⑤ អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស
⑥ អ្នកដែលគ្មានលក្ខណៈសម្បត្តិស្នាក់នៅ

## 1-1 ការផ្តល់ប័ណ្ណស្នាក់នៅ

នៅពេលដែលផ្តល់ប័ណ្ណស្នាក់នៅជាចំបងគឺមានដូចខាងក្រោម៖

① នៅពេលទទួលបានការអនុញ្ញាតអោយចូលប្រទេសជប៉ុនថ្មី ហើយចូលប្រទេសជប៉ុនតាមព្រលានយន្តហោះណារិតា ព្រលានយន្តហោះហាណេដា ព្រលានយន្តហោះឈីប៊ុ ព្រលានយន្តហោះកាន់សៃ ព្រលានយន្តហោះស៊ីនឈិតុសេ ព្រលានយន្តហោះហ៊ិរ៉ុស៊ិម៉ា ព្រលានយន្តហោះហ្វ៊ឹគុអុកា

➡ គេផ្តល់ប័ណ្ណស្នាក់នៅអោយនៅព្រលានយន្តហោះផ្ទាល់តែម្តង។

② នៅពេលទទួលបានការអនុញ្ញាតអោយចូលប្រទេសជប៉ុនថ្មី ហើយចូលប្រទេសជប៉ុនតាមព្រលានយន្តហោះឬច្រកកំពង់ផែសមុទ្រក្រៅពីក្នុង①

➡ បន្ទាប់ពីចូលប្រទេសជប៉ុន សូមដាក់ "ការជូនដំណឹងអំពីទីកន្លែងស្នាក់នៅ (ការជូនដំណឹងអំពីការផ្លាស់ទីលំនៅចូល)"ទៅភូមិឃុំស្រុកដែលអ្នកស្នាក់នៅ។ ក្រោយពេលនោះប័ណ្ណស្នាក់នៅនឹងត្រូវបានផ្ញើមកផ្ទះរបស់អ្នកតាមប្រៃសណីយ៍។

③ នៅពេលទទួលបានការអនុញ្ញាតអោយបន្តរយៈពេលស្នាក់នៅ

➡ មុនពេលរយៈពេលស្នាក់នៅផុតកំណត់ ត្រូវដាក់ពាក្យសុំបន្តរយៈពេលស្នាក់នៅ (សូមមើលត្រង់ 2-1) ទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់ (រួមទាំងការិយាល័យរង និងសាខាផង។ ខាងក្រោមនឹងត្រូវសង្ខេប)នៅពេលដែលទទួលបានការអនុញ្ញាតនឹងទទួលបានប័ណ្ណស្នាក់នៅថ្មី។

④ នៅពេលទទួលបានការអនុញ្ញាតប្តូរលក្ខណៈសម្បត្តិស្នាក់នៅ

➡ ឯករណីចង់ប្តូរគោលបំណងស្នាក់នៅប្រទេសជប៉ុន ត្រូវដាក់ពាក្យសុំប្តូរលក្ខណៈសម្បត្តិស្នាក់នៅ(សូមមើលត្រង់ 2-2) ទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់ នៅពេលដែលទទួលបានការអនុញ្ញាតនឹងទទួលបានប័ណ្ណស្នាក់នៅថ្មី។

⑤ នៅពេលទទួលបានលក្ខណៈសម្បត្តិស្នាក់នៅ

➡ ឯករណីដែលទារកកើតនៅប្រទេសជប៉ុនហើយគ្មានសញ្ជាតិជប៉ុន ក្នុងករណីចង់បន្តស្នាក់នៅប្រទេសជប៉ុនក្រោយ 60ថ្ងៃចាប់ពីថ្ងៃកើត ត្រូវដាក់ពាក្យសុំទទួលលក្ខណៈសម្បត្តិស្នាក់នៅក្នុងចន្លោះ 30ថ្ងៃបន្ទាប់ពីថ្ងៃកើត (សូមមើលត្រង់ 2-4) ទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់ ហើយនៅពេលដែលទទួលបានការអនុញ្ញាតនឹងទទួលបានប័ណ្ណស្នាក់នៅថ្មី។

## 1-2 ការជូនដំណឹងអំពីកន្លែងស្នាក់នៅ (ការជូនដំណឹងអំពីការផ្លាស់លំនៅចូល)

អ្នកដែលបានទទួលប័ណ្ណស្នាក់នៅ ចាំបាច់ត្រូវជូនដំណឹងទៅភូមិឃុំស្រុកដែលអ្នករស់នៅ (ការជូនដំណឹងអំពីការផ្លាស់លំនៅចូល) ក្នុងអំឡុងពេល 14ថ្ងៃរាប់ចាប់ពីថ្ងៃកំណត់កន្លែងរស់នៅ (កន្លែងស្នាក់នៅ, អាសយដ្ឋាន) រួច។

នៅពេលធ្វើការជូនដំណឹងសូមកុំភ្លេចយកមកជាមួយនូវប័ណ្ណស្នាក់នៅ (ក្នុងករណី①នៃ1-1) ឬលិខិតឆ្លងដែន (ក្នុងករណី② នៃ 1-1) ដែលជាតម្រូវការចាំបាច់។

→សូមយោងទៅតាមខ្លឹមសារនៃ ជំពូកទី2 1-1 ការជូនដំណឹងអំពីអាសយដ្ឋានស្នាក់នៅ។

## 1-3 ការបាត់ប័ណ្ណស្នាក់នៅ

សូមដាក់ពាក្យសុំការចេញប័ណ្ណស្នាក់នៅថ្មី ទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់ក្នុងអំឡុងពេល 14ថ្ងៃរាប់ចាប់ពីថ្ងៃដែលដឹងថាបានបាត់ប័ណ្ណស្នាក់នៅ។

### ឯកសារចាំបាច់

- លិខិតឆ្លងដែន
- រូបថត1សន្លឹក (បណ្ដោយ4សង់ទីម៉ែត្រ × ទទឹង3 សង់ទីម៉ែត្រ ដែលបានថតក្នុងអំឡុង 6ខែចុងក្រោយ ចំពោះអ្នកមានអាយុក្រោម 16ឆ្នាំមិនចាំបាច់ឡើយ)
- ឯកសារបញ្ជាក់ការបាត់ប័ណ្ណស្នាក់នៅ (របាយការណ៍នៃការបាត់ទ្រព្យសម្បត្តិ សេចក្ដីជូនដំណឹងអំពីចោរកម្ម លិខិតបញ្ជាក់ការជួបគ្រោះមហន្តរាយជាដើម)
- ពាក្យសុំការចេញប័ណ្ណស្នាក់នៅថ្មី

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។

https://www.moj.go.jp/isa/applications/procedures/nyuukokukanri10_00010.html

## 1-4 ការសងប័ណ្ណស្នាក់នៅ

ចាំបាច់ត្រូវសងប័ណ្ណស្នាក់នៅទៅអោយការិយាល័យអន្តោប្រវេសន៍តាមតំបន់វិញ។

### ការចាកចេញសាមញ្ញ (នៅពេលចាកចេញពីប្រទេសជប៉ុនក្រោយបញ្ចប់សកម្មភាពនៅប្រទេសជប៉ុន)

- សូមសងត្រឡប់ទៅអោយមន្ត្រីត្រួតពិនិត្យអន្តោប្រវេសន៍នៅព្រលានយន្តហោះ ឬច្រកកំពង់ផែសមុទ្រនៅពេលចាកចេញពីប្រទេសជប៉ុន។

- នៅពេលគ្រួសារឬមនុស្សរស់នៅជាមួយគ្នាបានទទួលមរណភាព
- បានចាកចេញពីប្រទេសជប៉ុនដោយមានការអនុញ្ញាតអោយចូលប្រទេសជប៉ុននិងការអនុញ្ញាតអោយចូលប្រទេសជប៉ុនពិសេសសារជាថ្មី ហើយមិនបានចូលមកប្រទេសជប៉ុនវិញក្នុងអំឡុងពេលមានសុពលភាពនៃការអនុញ្ញាតអោយចូលប្រទេសជប៉ុនសារជាថ្មី
- នៅពេលទទួលបានសញ្ជាតិជប៉ុន

សូមសងមកវិញក្នុងអំឡុងពេល14ថ្ងៃ តាមវិធីណាមួយក្នុងចំណោមខាងក្រោម៖



- កាន់យកទៅការិយាល័យអន្តោប្រវេសន៍តាមតំបន់ដែលនៅក្បែរនោះ។
- ផ្ញើតាមប្រៃសណីយ៍ទៅកាន់អាសយដ្ឋានខាងក្រោម៖

អាសយដ្ឋានផ្ញើ៖ 〒135-0064 Tokyo-To, Koto-Ku, Aomi 2-7-11, Tokyo Port Joint Government Building 9F Tokyo Regional Immigration Services Office, Online Inspection Department Odaiba Branch Office (សូមសរសេរនៅខ្នងសំបុត្រថា “The residence card to be returned (សងប័ណ្ណស្នាក់នៅវិញ)”។)

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។

https://www.moj.go.jp/isa/applications/procedures/nyuukokukanri10_00020.html

# 2 បែបបទទាក់ទងនឹងលក្ខណៈសម្បត្តិស្នាក់នៅ

## 2-1 ការបន្តរយៈពេលស្នាក់នៅ (នៅពេលចង់បន្តថ្ងៃកំណត់រយៈពេលស្នាក់នៅ)

ក្នុងករណីមានបំណងចង់បន្តស្នាក់នៅប្រទេសជប៉ុនលើសពីរយៈពេលស្នាក់នៅដែលបានទទួលការអនុញ្ញាតបច្ចុប្បន្ន ចាំបាច់ត្រូវស្នើសុំបន្តរយៈពេលស្នាក់នៅទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់។



### ឯកសារចាំបាច់

- លិខិតឆ្លងដែន
- ប័ណ្ណស្នាក់នៅ (ក្នុងករណីបានទទួល)
- រូបថត1សន្លឹក (បណ្តោយ4សង់ទីម៉ែត្រ × ទទឹង3 សង់ទីម៉ែត្រ ដែលបានថតក្នុងអំឡុង 6ខែចុងក្រោយ ចំពោះអ្នកមានអាយុក្រោម 16ឆ្នាំមិនចាំបាច់ឡើយ)
- ពាក្យសុំការអនុញ្ញាតបន្តរយៈពេលស្នាក់នៅនិងឯកសារ
  https://www.moj.go.jp/isa/applications/procedures/16-3.html

## 2-2 ការប្តូរលក្ខណៈសម្បត្តិស្នាក់នៅ (នៅពេលចង់ប្តូរគោលបំណងស្នាក់នៅប្រទេសជប៉ុន)

ឯករណីមានបំណងចង់ស្នាក់នៅដោយប្តូរគោលបំណងស្នាក់នៅប្រទេសជប៉ុនបច្ចុប្បន្នរបស់អ្នក ចាំបាច់ត្រូវស្នើសុំប្តូរលក្ខណៈសម្បត្តិស្នាក់នៅទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់។



### ឯកសារចាំបាច់

- លិខិតឆ្លងដែន
- ប័ណ្ណស្នាក់នៅ (ក្នុងករណីបានទទួល)
- រូបថត1សន្លឹក (បណ្តោយ4សង់ទីម៉ែត្រ × ទទឹង3 សង់ទីម៉ែត្រ ដែលបានថតក្នុងអំឡុង6ខែ ចំពោះអ្នកមានអាយុក្រោម16ឆ្នាំមិនចាំបាច់ឡើយ)
- ឯកសារបញ្ជាក់អោយច្បាស់អំពីសកម្មភាពដែលមានគំរោងធ្វើ។ល។
  https://www.moj.go.jp/isa/applications/procedures/16-2.html

ស្វែងរកពីលក្ខណៈសម្បត្តិស្នាក់នៅ
https://www.moj.go.jp/isa/applications/status/index.html

## 2-3 ការអនុញ្ញាតស្នាក់នៅជាអចិន្ត្រៃយ៍

ចំពោះអ្នកដែលមានបំណងចង់ស្នាក់នៅប្រទេសជប៉ុនជាអចិន្ត្រៃយ៍ គឺត្រូវការសុំការអនុញ្ញាតស្នាក់នៅជាអចិន្ត្រៃយ៍។ ក្នុងករណីដែលទទួលបានការអនុញ្ញាតអោយស្នាក់នៅជាអចិន្ត្រៃយ៍ នោះនឹងលែងមានការកំណត់ព្រំដែនលើសកម្មភាពនិងរយៈពេលស្នាក់នៅប្រទេសជប៉ុន ហើយក៏មិនចាំបាច់ធ្វើបែបបទស្នើសុំបន្តរយៈពេលស្នាក់នៅឬសុំប្តូរលក្ខណៈសម្បត្តិស្នាក់នៅដែរ។

### ឯកសារចាំបាច់

- លិខិតឆ្លងដែន
- ប័ណ្ណស្នាក់នៅ
- រូបថត1សន្លឹក (បណ្តោយ4សង់ទីម៉ែត្រ × ទទឹង3 សង់ទីម៉ែត្រ ដែលបានថតក្នុងអំឡុង 6ខែចុងក្រោយ ចំពោះអ្នកមានអាយុក្រោម16ឆ្នាំមិនចាំបាច់ឡើយ)
- ពាក្យសុំការអនុញ្ញាតស្នាក់នៅជាអចិន្ត្រៃយ៍
- ឯកសារត្រូវការចាំបាច់ផ្សេងទៀត

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។

https://www.moj.go.jp/isa/applications/procedures/16-4.html

## 2-4 ការទទួលបានលក្ខណៈសម្បត្តិស្នាក់នៅ (ក្នុងករណីផ្តល់កំណើតកូន)

ក្នុងករណីដែលទារកកើតនៅប្រទេសជប៉ុនហើយគ្មានសញ្ជាតិជប៉ុន ក្នុងករណីចង់នៅបន្តស្នាក់នៅប្រទេសជប៉ុនក្រោយ 60ថ្ងៃចាប់ពីថ្ងៃកើត ត្រូវដាក់ពាក្យសុំទទួលលក្ខណៈសម្បត្តិស្នាក់នៅក្នុងចន្លោះ 30ថ្ងៃបន្ទាប់ពីថ្ងៃកើត ទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់។

* ដោយសារចាំបាច់ត្រូវការឯកសារដូចជា "សំបុត្របញ្ជាក់កំណើត" សូមទៅធ្វើបែបបទចុះបញ្ជីកំណើតនៅភូមិឃុំស្រុកជាមុនសិនមុននឹងទៅបំពេញបែបបទនេះនៅការិយាល័យអន្តោប្រវេសន៍តាមតំបន់។

សូមមើលត្រង់ការចុះបញ្ជីកំណើត ក្នុងចំណុច2 2-1 នៃជំពូកទី4

### ឯកសារចាំបាច់

- លិខិតឆ្លងដែន (ក្នុងករណីបានទទួល)
- ពាក្យសុំការអនុញ្ញាតទទួលបានលក្ខណៈសម្បត្តិស្នាក់នៅ
- ឯកសារបញ្ជាក់កំណើត ដូចជាសំបុត្របញ្ជាក់កំណើត (អាចសុំបាននៅភូមិឃុំស្រុក។)
- ឯកសារបញ្ជាក់អោយច្បាស់អំពីសកម្មភាពដែលមានគំរោងធ្វើ
  https://www.moj.go.jp/isa/applications/procedures/16-10.html
- សេចក្តីចំលងលិខិតបញ្ជាក់ការស្នាក់នៅ ឬលិខិតបញ្ជាក់កំណត់ត្រានៃការស្នាក់នៅ (អាចសុំបាននៅភូមិឃុំស្រុក។)

## 2-5 ការអនុញ្ញាតលើសកម្មភាពក្រៅលក្ខណៈសម្បត្តិ

ចំពោះអ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅដែលមិនអាចធ្វើការបាន (និស្សិតបរទេស ស្នាក់នៅជាមួយគ្រួសារ) ឬអ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅដែលមានព្រំដែនកំណត់ក្នុងការធ្វើការ ហើយចង់ធ្វើការក្រៅលក្ខណៈសម្បត្តិស្នាក់នៅដើម្បីរកកំរៃឬប្រាក់រង្វាន់ ចាំបាច់ត្រូវស្នើសុំយកការអនុញ្ញាតលើសកម្មភាពក្រៅលក្ខណៈសម្បត្តិ ទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់ (ដើម្បីបញ្ជាក់ថាតើលក្ខណៈសម្បត្តិស្នាក់នៅរបស់អ្នកអនុញ្ញាតអោយធ្វើការបានត្រឹមកម្រិតណា សូមត្រួតពិនិត្យក្នុងជំពូកទី3 ចំណុច1 1-1 លក្ខណៈសម្បត្តិស្នាក់នៅ។)។

### ឯកសារចាំបាច់




- លិខិតឆ្លងដែន
- ប័ណ្ណស្នាក់នៅ
- ពាក្យសុំការអនុញ្ញាតលើសកម្មភាពក្រៅលក្ខណៈសម្បត្តិ
- ឯកសារបញ្ជាក់អោយច្បាស់អំពីសកម្មភាពដែលមានគំរោងធ្វើដើម្បីទទួលបានកំរៃឬប្រាក់រង្វាន់

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.moj.go.jp/isa/applications/procedures/16-8.html

## 2-6 ការជូនដំណឹងទៅការិយាល័យអន្តោប្រវេសន៍តាមតំបន់

ក្នុងចំណោមអ្នកមានប័ណ្ណស្នាក់នៅ ចំពោះអ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅដូចខាងក្រោម ក្នុងករណីដែលមានការផ្លាស់ប្តូរដូចជាអង្គភាពរបស់ខ្លួនជាដើម ចាំបាច់ត្រូវជូនដំណឹងទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់។

### (1) ការជូនដំណឹងអំពីស្ថាប័នធ្វើសកម្មភាព

| | |
|---|---|
| លក្ខណៈសម្បត្តិស្នាក់នៅដែលពាក់ព័ន្ធ | សាស្ត្រាចារ្យ ឯកទេសជាន់ខ្ពស់ទី1គ ឯកទេសជាន់ខ្ពស់ទី2 (ក្នុងករណីធ្វើសកម្មភាពដែលមានចែងក្នុងទី2គ) ដឹកនាំឬគ្រប់គ្រង ការងារច្បាប់ឬគណនេយ្យ វេជ្ជសាស្ត្រ អប់រំ ការប្តូរការងារក្នុងសហគ្រាស កម្មសិក្សាជំនាញ និស្សិតបរទេស កម្មសិក្សា |
| ខ្លឹមសារនៃការជូនដំណឹង | • នៅពេលដែលឈ្មោះរបស់ស្ថាប័នធ្វើសកម្មភាពបានផ្លាស់ប្តូរ<br>• នៅពេលដែលអាសយដ្ឋានរបស់ស្ថាប័នធ្វើសកម្មភាពបានផ្លាស់ប្តូរ<br>• នៅពេលដែលស្ថាប័នធ្វើសកម្មភាពបានរលាយបាត់<br>• នៅពេលដែលបានចាកចេញពីស្ថាប័នធ្វើសកម្មភាព<br>• នៅពេលដែលបានផ្ទេរចេញពីស្ថាប័នធ្វើសកម្មភាព |
| អំឡុងពេលជូនដំណឹង | សូមធ្វើការជូនដំណឹងក្នុងអំឡុងពេល 14ថ្ងៃ។ |

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖
https://www.moj.go.jp/isa/applications/procedures/nyuukokukanri10_00014.html

## (2) ការជូនដំណឹងអំពីស្ថាប័នជាប់កិច្ចសន្យា

| | |
|---|---|
| លក្ខណៈសម្បត្តិស្នាក់នៅដែលពាក់ព័ន្ធ | ឯកទេសជាន់ខ្ពស់ទី1ក ឯកទេសជាន់ខ្ពស់ទី1ខ ឯកទេសជាន់ខ្ពស់ទី2 (ក្នុងករណីធ្វើសកម្មភាពដែលមានចែងក្នុងទី2ក ឬខ) ស្រាវជ្រាវ បច្ចេកវិទ្យា ឬចំណេះដឹងមនុស្សសាស្ត្រឬការងារអន្តរជាតិ ថែទាំ កំសាន្ត (ចំពោះតែក្នុងករណីធ្វើសកម្មភាពដោយផ្អែកលើកិច្ចសន្យាជាមួយស្ថាប័នសាធារណៈ ឬឯកជនរបស់ជប៉ុន) ជំនាញ ពលករជំនាញ |
| ខ្លឹមសារនៃការជូនដំណឹងពាក់ព័ន្ធ | • នៅពេលដែលឈ្មោះរបស់ស្ថាប័នជាប់កិច្ចសន្យាបានផ្លាស់ប្តូរ<br>• នៅពេលដែលអាសយដ្ឋានរបស់ស្ថាប័នជាប់កិច្ចសន្យាបានផ្លាស់ប្តូរ<br>• នៅពេលដែលស្ថាប័នជាប់កិច្ចសន្យាបានរលាយបាត់<br>• នៅពេលដែលបានបញ្ចប់កិច្ចសន្យាជាមួយស្ថាប័នជាប់កិច្ចសន្យា<br>• នៅពេលដែលបានចុះកិច្ចសន្យាថ្មីជាមួយស្ថាប័នជាប់កិច្ចសន្យា |
| អំឡុងពេលជូនដំណឹង | សូមធ្វើការជូនដំណឹងក្នុងអំឡុងពេល 14ថ្ងៃ។ |

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://www.moj.go.jp/isa/applications/procedures/nyuukokukanri10_00015.html

## (3) ការជូនដំណឹងអំពីសហព័ទ្ធ

| | |
|---|---|
| លក្ខណៈសម្បត្តិស្នាក់នៅដែលពាក់ព័ន្ធ | ក្នុងចំណោមលក្ខណៈសម្បត្តិស្នាក់នៅ ស្នាក់នៅជាមួយគ្រួសារ សហព័ទ្ធរបស់ជនជាតិជប៉ុន ជាដើម សហព័ទ្ធរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍ជាដើម ក្នុងករណីស្នាក់នៅក្នុងនាមជាសហព័ទ្ធ |
| ខ្លឹមសារនៃការជូនដំណឹងពាក់ព័ន្ធ | • លែងលះជាមួយសហព័ទ្ធ<br>• សហព័ទ្ធបានទទួលមរណភាព |
| អំឡុងពេលជូនដំណឹង | សូមធ្វើការជូនដំណឹងក្នុងអំឡុងពេល 14ថ្ងៃ។ |

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://www.moj.go.jp/isa/applications/procedures/nyuukokukanri10_00016.html

ចំពោះការជូនដំណឹងទាំងនេះ ក្រៅពីការយកទៅដាក់ផ្ទាល់នៅបញ្ជរឬផ្ញើរតាមរយៈប្រៃសណីយ៍ក៏អាចធ្វើការជូនដំណឹងអេឡិចត្រូនិចតាមអ៊ីនធើណែតបានដែរ ។

ចំពោះខ្លឹមសារលំអិត នៃការជូនដំណឹងអេឡិចត្រូនិច

https://www.moj.go.jp/isa/publications/materials/i-ens_index.html

ចំណុចគួរដឹង៖

## ការព្យាបាលជាអាទិភាពសម្រាប់អ្នកជំនាញបរទេសដែលមានជំនាញខ្ពស់

ចំពោះពលរដ្ឋបរទេសដែលមានសមត្ថភាពនិងគុណសម្បត្តិកម្រិតខ្ពស់ដែលមានសក្តានុពលអាចចូលរួមចំណែកធ្វើអោយសេដ្ឋកិច្ចប្រទេសជប៉ុនលូតលាស់ជាដើម គេទទួលស្គាល់អោយមានវិធានការផ្តល់អាទិភាពចំពោះខ្លឹមសារនៃសកម្មភាពនិងរយ:ពេលស្នាក់នៅប្រទេសជប៉ុន។

គេធ្វើការដាក់ពិន្ទុសម្រាប់ចំណុចនិមួយៗដូចជា "កម្រិតសិក្សា" "ប្រវត្តិការងារ" "ចំនូលប្រចាំឆ្នាំ" ជាដើមទៅតាមលក្ខណ:ពិសេសនៃសកម្មភាព ហើយតាមរយ:ការស្នើសុំទៅកាន់ការិយាល័យអន្តោប្រវេសន៍តាមតំបន់ នៅពេលពិន្ទុសរុបបានដល់ 70ពិន្ទុឡើងទៅ និងត្រូវបានទទួលស្គាល់ជា"ធនធានមនុស្សបរទេសកម្រិតខ្ពស់" គឺអាចទទួលបាននូវវិធានការផ្តល់អាទិភាពដូចខាងក្រោម៖

- ការផ្តល់ការអនុញ្ញាតអោយមានសកម្មភាពស្នាក់នៅច្រើនមុខដំណាលគ្នា
- ផ្តល់រយ:ពេលស្នាក់នៅគឺ "5ឆ្នាំ"
- ក្នុងចំណោមលក្ខខណ្ឌចាំបាច់ដើម្បីទទួលបានការអនុញ្ញាតស្នាក់នៅជាអចិន្ត្រៃយ៍ លក្ខខណ្ឌទាក់ទងនឹងរយ:ពេលដែលបានស្នាក់នៅប្រទេសជប៉ុនត្រូវបានបន្ធូរបន្ថយ ជាអាទិ៍

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://www.moj.go.jp/isa/publications/materials/newimmiact_3_index.html

ប្រព័ន្ធថ្មីមួយដែលហៅថា "ប្រព័ន្ធសម្រាប់អ្នកជំនាញដែលមានជំនាញខ្ពស់ពិសេសរបស់ជប៉ុន" (J-Skip) ត្រូវបានដាក់ឱ្យប្រើនៅកាលពីខែមេសា ឆ្នាំ 2023។ បេក្ខជនរបស់ប្រព័ន្ធនេះបំពេញតាមលក្ខខណ្ឌតម្រូវស្តីពីសារតារសិក្សាជាក់លាក់ លក្ខខណ្ឌតម្រូវស្តីពីអាជីពវិជ្ជាជីវ: និងមានចំណូលលើសពីប្រាក់ចំណូលប្រចាំឆ្នាំជាក់លាក់ ពួកគេត្រូវបានចាត់ទុកថាជា "អ្នកជំនាញដែលមានជំនាញខ្ពស់ពិសេស" និងមានសិទ្ធិទទួលបានការអនុគ្រោះបន្ថែម។ នេះគឺជាប្រព័ន្ធដែលបានបំបែកចេញពីប្រព័ន្ធវិជ្ជាជីវ:បរទេសដែលមានជំនាញខ្ពស់ផ្អែកលើចំណុចខាងលើ។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://www.moj.go.jp/isa/publications/materials/nyuukokukanri01_00009.html

# 3 ការអនុញ្ញាតអោយចូលប្រទេសជប៉ុនសារជាថ្មី (ចូលប្រទេសជប៉ុនសារជាថ្មីដោយរក្សាទុកលក្ខណៈសម្បត្តិស្នាក់នៅបច្ចុប្បន្ននៅដដែល)

នៅពេលចេញពីប្រទេសជប៉ុន ប្រសិនបើប្រើប្រព័ន្ធចូលប្រទេសជប៉ុនសារជាថ្មី គេអាចចូលប្រទេសជប៉ុនសារជាថ្មីដោយរក្សាទុកលក្ខណៈសម្បត្តិស្នាក់នៅ និងរយៈពេលស្នាក់នៅដដែលបាន។

## (1) ការអនុញ្ញាតអោយចូលប្រទេសជប៉ុនសារជាថ្មីដោយចាត់ទុក (ក្នុងករណីត្រឡប់មកប្រទេសជប៉ុនវិញក្នុងអំឡុង1ឆ្នាំ)

ចំពោះអ្នកដែលមានប័ណ្ណស្នាក់នៅ មានលិខិតឆ្លងដែនដែលមានសុពលភាព នៅពេលចេញពីប្រទេសជប៉ុនហើយត្រឡប់មកប្រទេសជប៉ុនវិញក្នុងអំឡុងពេល1ឆ្នាំ (ក្នុងករណីដែលកាលកំណត់នៃរយៈពេលស្នាក់នៅនៅសល់តិចជាង1ឆ្នាំ នោះបានត្រឹមកាលកំណត់នៃរយៈពេលស្នាក់នៅនោះ) នោះមិនចាំបាច់សុំការអនុញ្ញាតចូលប្រទេសជប៉ុនសារជាថ្មីនៅការិយាល័យអន្តោប្រវេសន៍តាមតំបន់ជាមុនឡើយ។នៅពេលចាកចេញពីប្រទេសជប៉ុន សូមបំពេញកាត ED សម្រាប់ការចូលប្រទេសជប៉ុនម្តងទៀត ហើយបង្ហាញវាទៅអធិការអន្តោប្រវេសន៍ រួមជាមួយលិខិតឆ្លងដែនរបស់អ្នក (និងកាតស្នាក់នៅ)។

## (2) ការអនុញ្ញាតអោយចូលប្រទេសជប៉ុនសារជាថ្មី (ក្នុងករណីត្រឡប់មកប្រទេសជប៉ុនវិញក្រោយ1ឆ្នាំ)

តាមរយៈការសុំការអនុញ្ញាតចូលប្រទេសជប៉ុនសារជាថ្មីនៅការិយាល័យអន្តោប្រវេសន៍តាមតំបន់ជិតកន្លែងរស់នៅជាមុន គេអាចចូលប្រទេសជប៉ុនសារជាថ្មីដោយរក្សាទុកលក្ខណៈសម្បត្តិស្នាក់នៅនិងរយៈពេលស្នាក់នៅដដែលបាន (វែងបំផុត5ឆ្នាំ។ ក្នុងករណីដែលកាលកំណត់នៃរយៈពេលស្នាក់នៅនៅសល់តិចជាង5ឆ្នាំ នោះបានត្រឹមកាលកំណត់នៃរយៈពេលស្នាក់នៅនោះ)។នៅពេលចាកចេញពីប្រទេសជប៉ុន សូមបំពេញកាត ED សម្រាប់ការចូលប្រទេសជប៉ុនម្តងទៀត ហើយបង្ហាញវាទៅអធិការអន្តោប្រវេសន៍ រួមជាមួយលិខិតឆ្លងដែនរបស់អ្នក (និងកាតស្នាក់នៅ)។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://www.moj.go.jp/isa/applications/procedures/16-5.html

# 4 នីតិវិធីទទួលស្គាល់ជនភៀសខ្លួននិងទទួលស្គាល់ផ្សេងទៀត

ប្រទេសជប៉ុនបានចូលជាសមាជិកនៃអនុសញ្ញាស្តីអំពីជនភៀសខ្លួនជាដើម (អនុសញ្ញាស្តីអំពីឋានៈជាជនភៀសខ្លួននិងពិធីសារពាក់ព័ន្ធឋានៈជាជនភៀសខ្លួន) យើងទទួលស្គាល់ស្ថានភាពជនភៀសខ្លួន ដូចដែលបានកំណត់នៅក្រោមសន្និសញ្ញាទាំងនេះ ហើយផ្តល់ការការពារផ្សេងៗដល់ជនភៀសខ្លួន។

## 4-1 ”ជនភៀសខ្លួន” គឺជា

យោងតាមអ្វីដែលមានចែងនៅក្នុងមាត្រាទី1នៃអនុសញ្ញាស្តីអំពីជនភៀសខ្លួន ឬមាត្រាទី1នៃពិធីសារពាក់ព័ន្ធឋានៈជាជនភៀសខ្លួន ជនភៀសខ្លួនដែលត្រូវនឹងអនុសញ្ញាស្តីអំពីជនភៀសខ្លួន ត្រូវបានអោយនិយមន័យដូចតទៅ៖

- គឺជាមនុស្សដែលនៅក្រៅប្រទេសដែលខ្លួនមានសញ្ជាតិដោយសារមានការភ័យខ្លាចដែលមានមូលហេតុគ្រប់គ្រាន់ថាអាចទទួលរងការធ្វើទុក្ខបុកម្នេញក្រោមហេតុផលនិន្នាការនយោបាយ ឬភាពជាសមាជិកនៃពូជសាសន៍ សាសនា សញ្ជាតិ ជាសមាជិកនៃក្រុមសង្គមណាមួយ ហើយមិនអាចឬមិនចង់ទទួលការគាំពារពីប្រទេសដែលខ្លួនមានសញ្ជាតិជាដើម

## 4-2 និយមន័យនៃបុគ្គលដែលស្ថិតនៅក្រោមការការពារបន្ថែម

បុគ្គលដែលស្ថិតនៅក្រោមការការពារបន្ថែម អ្នកទទួលផលត្រូវបានកំណត់ដូចខាងក្រោម។

- បុគ្គលដែលមិនមែនជាជនភៀសខ្លួននៅក្រោមអនុសញ្ញាជនភៀសខ្លួន (សូមមើល 4-1) ប៉ុន្តែបំពេញតាមតម្រូវការទាំងអស់ ក្រៅពីការប្រឈមនឹងហានិភ័យនៃ "ការធ្វើទុក្ខបុកម្នេញដោយហេតុផលពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាពនៃក្រុមសង្គមជាក់លាក់ ឬមតិនយោបាយ"។

## 4-3 ពាក្យស្នើសុំទទួលស្គាល់ស្ថានភាពជនភៀសខ្លួន ឬសិទ្ធិទទួលបានការការពារបន្ថែម

- គឺជាប្រព័ន្ធសម្រាប់អ្នកដែលបានភៀសខ្លួនចេញពីប្រទេសកំណើតរបស់ពួកគេ (សូមមើល៖ 4-1) និងស្វែងរកការការពារពីប្រទេសជប៉ុន។ ជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុនអាចដាក់ពាក្យសុំឋានៈនេះបាន។ ជនបរទេសដែលត្រូវបានទទួលស្គាល់ថាជាជនភៀសខ្លួនត្រូវបានចេញជាមួយនឹងវិញ្ញាបនបត្រទទួលស្គាល់ស្ថានភាពជនភៀសខ្លួន ហើយអ្នកដែលត្រូវបានទទួលស្គាល់ថាជាបុគ្គលដែលស្ថិតក្រោមការការពារបន្ថែមត្រូវបានចេញជាមួយនឹងវិញ្ញាបនបត្រទទួលស្គាល់សិទ្ធិទទួលបានការការពារបន្ថែម។ ក្នុងករណីណាក៏ដោយ ជាក្បួនទូទៅ ស្ថានភាពលំនៅដ្ឋានរបស់ "អ្នកស្នាក់នៅរយៈពេលវែង" នឹងត្រូវបានផ្តល់ឱ្យ។
- ជនបរទេសដែលត្រូវបានទទួលស្គាល់ថាជាជនភៀសខ្លួន ដោយផ្អែកលើពាក្យសុំរបស់គាត់ នឹងទទួលបានឯកសារធ្វើដំណើររបស់ជនភៀសខ្លួនជំនួសលិខិតឆ្លងដែន។
- ជនបរទេស និងគ្រួសាររបស់គាត់ដែលត្រូវបានទទួលស្គាល់ថាជាជនភៀសខ្លួន ឬបុគ្គលដែលស្ថិតក្រោមការការពារបន្ថែម អាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយការតាំងទីលំនៅ ដែលរួមមានការអប់រំភាសាជប៉ុន ការណែនាំសម្រាប់ការរស់នៅក្នុងប្រទេសជប៉ុន និងការស្វែងរកការងារធ្វើ។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://www.moj.go.jp/isa/applications/procedures/16-6.html

## 4-4 ការស្នើសុំអោយត្រួតពិនិត្យ

ចំពោះអ្នកដែលបានទទួលការវិនិច្ឆ័យមិនទទួលស្គាល់ថាជាជនភៀសខ្លួនឬមនុស្សដែលស្ថិតនៅក្រោមការការពារបន្ថែម ហើយមិនអាចទទួលយកបាន អាចធ្វើការស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អោយត្រួតពិនិត្យបាន។ នៅពេលដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ធ្វើការវិនិច្ឆ័យទៅលើការស្នើសុំអោយត្រួតពិនិត្យ គឺត្រូវស្តាប់យោបល់របស់ទីប្រឹក្សាត្រួតពិនិត្យវាយតំលៃជនភៀសខ្លួនដែលមានចំណេះដឹងអំពីច្បាប់និងស្ថានការណ៍អន្តរជាតិជាដើម។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖
ស្តីអំពីសំណើសម្រាប់ការត្រួតពិនិត្យរដ្ឋបាល
https://www.moj.go.jp/isa/refugee/procedures/nanmin_00001.html#midashi04

# 5 នីតិវិធីបញ្ជូនទៅប្រទេសដើមវិញដោយបង្ខំជាដើម

## 5-1 មូលហេតុសំខាន់ៗនៃការបញ្ជូនទៅប្រទេសដើមវិញ

- បានបន្តស្នាក់នៅជប៉ុនហួសកាលកំណត់នៃរយៈពេលស្នាក់នៅ (ទោះជាលើសតែ1ថ្ងៃក៏ដោយ នឹងក្លាយទៅករណីបន្តស្នាក់នៅខុសច្បាប់ ហើយក្លាយជាកម្មវត្ថុនៃនីតិវិធីបញ្ជូនទៅប្រទេសដើមវិញ ដូច្នេះសូមប្រុងប្រយ័ត្ន)
- បានធ្វើសកម្មភាពក្រៅពីលក្ខណៈសម្បត្តិស្នាក់នៅដែលខ្លួនមាន ដើម្បីរកកំរៃឬប្រាក់រង្វាន់ ដោយមិនបានសុំការអនុញ្ញាតលើសកម្មភាពក្រៅលក្ខណៈសម្បត្តិ
- ក្នុងករណីបានទទួលទោសព្រហ្មទណ្ឌក្នុងកម្រិតមួយ

## 5-2 ក្នុងករណីត្រូវបានបញ្ជូនទៅប្រទេសដើមវិញ

ការិយាល័យអន្តោប្រវេសន៍តាមតំបន់ធ្វើការស្រាវជ្រាវ ក្នុងករណីត្រូវបានបញ្ជូនទៅប្រទេសដើមវិញ ជាទូទៅក្នុងអំឡុងពេល 5ឆ្នាំ ឬ10ឆ្នាំ មិនអាចចូលប្រទេសជប៉ុនបានឡើយ។ ហើយក្នុងករណីត្រូវបានបញ្ជូនទៅប្រទេសដើមវិញក្រោយទទួលទោសព្រហ្មទណ្ឌក្នុងកម្រិតមួយ ជាទូទៅគឺលែងអាចចូលប្រទេសជប៉ុនបានជារៀងរហូត។

ទោះបីជាក្នុងករណីដែលការនិរទេសត្រូវបានបញ្ចប់ក៏ដោយ ក៏រយៈពេលនៃការបដិសេធនៃការចុះចតអាចត្រូវបានកាត់បន្ថយមកត្រឹមមួយឆ្នាំតាមការស្នើសុំ ប្រសិនបើជនបរទេសត្រូវបានអនុញ្ញាតឱ្យចាកចេញពីប្រទេសដោយចំណាយផ្ទាល់ខ្លួន។

## 5-3 ប្រព័ន្ធបញ្ជាអោយចាកចេញ

គឺជាប្រព័ន្ធអាចចាកចេញពីប្រទេសជប៉ុនដោយបំពេញបែបបទងាយស្រួល គ្មានការឃុំខ្លួនអ្នកបន្តស្នាក់នៅខុសច្បាប់ ក្នុងករណីដែលលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញ។

ក្នុងករណីចាកចេញពីប្រទេសជប៉ុនក្រោមប្រព័ន្ធបញ្ជាអោយចាកចេញ ជាទូទៅក្នុងអំឡុងពេល 1ឆ្នាំគឺមិនអាចចូលប្រទេសជប៉ុនបានឡើយ។

### លក្ខខណ្ឌនៃប្រព័ន្ធបញ្ជាអោយចាកចេញ

ដើម្បីអនុវត្តប្រព័ន្ធបញ្ជាអោយចាកចេញគឺត្រូវបំពេញលក្ខខណ្ឌខាងក្រោម។

(1).ទាំង (a) ឬ (b) ត្រូវតែពេញចិត្ត

(a) មុនពេលការស៊ើបអង្កេតនៃការរំលោភនេះបានចាប់ផ្តើមជនជាតិបរទេសមានឆន្ទៈហើយបានចូលខ្លួនទៅកាន់ការិយាល័យអន្តោប្រវេសន៍ប្រចាំតំបន់ក្នុងបំណងចាកចេញពីប្រទេសជប៉ុន។

(b) បន្ទាប់ពីការស៊ើបអង្កេតលើការរំលោភនេះបានចាប់ផ្តើមជនជាតិបរទេសបានបង្ហាញពីចេតនាចង់ចាកចេញពីប្រទេសជប៉ុនភ្លាមៗទៅកាន់អធិការអន្តោប្រវេសន៍ ឬមន្ត្រីសន្តិសុខអន្តោប្រវេសន៍ មុនពេលទទួលបានការជូនដំណឹងអំពីការទទួលស្គាល់ដោយអធិការអន្តោប្រវេសន៍។



(2) គ្មានហេតុផលសម្រាប់ការនិរទេសក្រៅពីការស្នាក់នៅហួសកំណត់ដោយខុសច្បាប់។

(3) ជនជាតិបរទេសគ្មានការកាត់ទោសឬ ជាប់ពន្ធនាគារ ដោយបទល្មើសក្នុងកម្រិតមួយនៅប្រទេសជប៉ុន ដូចជាចោរកម្មជាដើម

(4) ជនជាតិបរទេសមិនធ្លាប់ត្រូវបានបញ្ជូនឬមិនធ្លាប់ចាកចាកចេញពីប្រទេសជប៉ុនដោយបានទទួលបញ្ជាអោយចាកចេញ

(5) ជនជាតិបរទេសអាចប៉ាន់ស្មានឃើញថាសមីខ្លួនប្រាកដជាចាកចេញពីប្រទេសជប៉ុនដោយឆាប់រហ័ស

## 5-4 ការអនុញ្ញាតអោយស្នាក់នៅពិសេស

ប្រសិនបើនីតិវិធីបញ្ជូនទៅប្រទេសដើមវិញត្រូវបានធ្វើក៏ដោយ មានករណីខ្លះអាចទទួលបានការអនុញ្ញាតអោយស្នាក់នៅជាលក្ខណៈពិសេសដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ យោងតាមការពិចារណាលើប្រវត្តិនៃការរស់នៅប្រទេសជប៉ុន ស្ថានភាពគ្រួសារជាដើម។

# 6 អាសយដ្ឋានទំនាក់ទំនងអំពីនីតិវិធីអន្តោប្រវេសន៍ និងស្នាក់នៅជាដើម

## ការិយាល័យអន្តោប្រវេសន៍តាមតំបន់

| | | | | |
|---|---|---|---|---|
| អាគាររដ្ឋាភិបាលរួមទី 3 តំបន់សាប់ប៉ូរ៉ូ | 〒060-0042 | 12 Odori-Nishi, Chuo-ku, Sapporo City, Hokkaido, Sapporo 3rd Joint Government Building | | 0570-003259 (ទូរស័ព្ទIP និងមកពីបរទេស៖ 011-211-5701) |
| អាគាររដ្ឋាភិបាលកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ទីពីរ តំបន់សេនដៃ | 〒983-0842 | 1-3-20 Gorin, Miyagino-ku, Sendai City, Miyagi, Sendai Second Legal Affairs Joint Government Building | | TEL 0570-022259 (ទូរស័ព្ទIP និងមកពីបរទេស៖ 022-256-7025) |
| ការិយាល័យអន្តោប្រវេសន៍តំបន់តូក្យូ | 〒108-8255 | 5-5-30 Konan, Minato-ku, Tokyo | | TEL 0570-034259 (ទូរស័ព្ទIP និងមកពីបរទេស៖ 03-5796-7234) |
| ការិយាល័យអន្តោប្រវេសន៍តំបន់តូក្យូ សាខាយ៉ុតស៊ុយយ៉ា | 〒160-0004 | 13F, 14 Yotsuya Tower, 1-6-1 Yotsuya, Shinjuku-ku, Tokyo | | TEL 0570-011000 |
| | ស្ថានភាពនៃការិយាល័យចុះបញ្ជីនិវេសនដ្ឋាន | | ជូនដំណឹងស្តីពីស្ថាប័នចំណុះ, ជូនដំណឹងតាមរយៈស្ថាប័នចំណុះ | TEL 03-5363-3032 (លេខចំបង) |
| | នាយកដ្ឋានត្រួតពិនិត្យតាមអនឡាញ | | នីតិវិធីដាក់ពាក្យស្នាក់នៅតាមអនឡាញ | TEL 03-5363-3030 |
| | ផ្នែកគ្រប់គ្រងព័ត៌មាន | | កត់ត្រានិងគ្រប់គ្រងការពិនិត្យ | TEL 03-5363-3039 |
| ការិយាល័យរងព្រលានយន្តណារិតា | 〒282-0004 | 1-1, Aza-Furugome, Furugome, Narita-shi, Chiba, Narita airport, Terminal2, អគារ 6F | | TEL 0476-34-2222 (លេខចំបង) TEL 0476-34-2211 |
| ការិយាល័យរងព្រលានយន្តហោះហាណេដា | 〒144-0041 | 2-6-4 អគារ Hanedakuko, Ota-ku , Tokyo, Haneda airport, CIQ building | | TEL 03-5708-3202 |
| ការិយាល័យរងយ៉ូកូហាម៉ា | 〒236-0002 | 10-7 Torihama-cho, Kanazawa-ku, Yokohama City, Kanagawa | | TEL0570-045259 (ទូរស័ព្ទIP និងមកពីបរទេស៖ 045-769-1729) |
| ការិយាល័យអន្តោប្រវេសន៍តំបន់ណាហ្គោយ៉ា | 〒455-8601 | 5-18, Shoho-cho, Minato-ku, Nagoya City, Aichi | | TEL 0570-052259 (ទូរស័ព្ទIP និងមកពីបរទេស៖ 052-217-8944) |
| ការិយាល័យរងឈឺប៊ុ | 〒479-0881 | CIQ Bldg.អគារ 3F, 1-1 Centrair, Tokoname, Aichi | | TEL 0569-38-7410 (លេខចំបង) |
| ការិយាល័យអន្តោប្រវេសន៍តំបន់អូសាកា | 〒559-0034 | 1-29-53 Nankou Kita, Suminoe-ku, Osaka City, Osaka | | TEL 0570-064259 (ទូរស័ព្ទIP និងមកពីបរទេស៖ 06-4703-2050) |
| ការិយាល័យរងព្រលានយន្តហោះកាន់សៃ | 〒549-0011 | 1 Senshu-Kuko-Naka, Tajiri-cho, Sennan-gun, Osaka | | TEL 072-455-1453 (លេខចំបង) |
| អគាររដ្ឋាភិបាលរួមក្នុងតំបន់ កូបេ | 〒650-0024 | 29 Kaigan-dori, Chuo-ku, Kobe City, Hyogo, Kobe Regional Joint Government Building | | TEL 078-391-6377 (លេខចំបង) |
| អគារការិយាល័យកិច្ចការច្បាប់តំបន់ហ៊ិរ៉ូស៊ីម៉ា | 〒730-0012 | 2-31 Kami-hacchobori, Naka-ku, Hiroshima City, Hiroshima, Hiroshima Legal Affairs Government Building | | TEL 082-221-4411 (លេខចំបង) |
| អគាររដ្ឋាភិបាល សម្ព័ន្ធកិច្ចការច្បាប់តំបន់តាកាម៉ាត្សឹ(នាយកដ្ឋានកិច្ចការទូទៅ នាយកដ្ឋានអនុវត្តច្បាប់) | 〒760-0033 | 1-1 Marunouchi, Takamatsu City, Kagawa, Takamatsu Legal Affairs Joint Government Building (General Affairs Division, Enforcement Department) | | TEL 087-822-5852 (លេខចំបង) |
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍ប្រចាំតំបន់តាកាម៉ាត្សឹ ការិយាល័យសាខា ហាម៉ាណូចូ (ផ្នែកវិនិច្ឆ័យ) | 〒760-0011 | 72-9 Hamanocho, Takamatsu-shi, Kagawa, Hamanomachi Branch Office (Judging Section) | | TEL 087-822-5851 (លេខចំបង) |
| អគារការិយាល័យកិច្ចការច្បាប់ទីមួយតំបន់ហ្វ៊ុគុអុកា | 〒810-0073 | 3-5-25 Maizuru, Chuo-ku, Fukuoka City, Fukuoka | | TEL 092-717-5420 (លេខចំបង) |

| | | | |
|---|---|---|---|
| ការិយាល័យរងណាហា | 〒900-0022 | 1-15-15 Higawa, Naha City, Okinawa, Naha First Regional Joint Government Building | TEL 098-832-4185 (លេខចំបង) |
| មជ្ឈមណ្ឌលអន្តោប្រវេសន៍ផ្នែកខាងកើត | 〒300-1288 | 1766-1 Kuno-cho, Ushiku, Ibaraki | TEL 029-875-1291 (លេខចំបង) |
| មជ្ឈមណ្ឌលអន្តោប្រវេសន៍អូមុរ៉ា | 〒856-0817 | 644-3 Kogashima-machi, Oomura, Nagasaki | TEL 0957-52-2121 (លេខចំបង) |

## មជ្ឈមណ្ឌលជំនួយចំពោះជនបរទេសស្នាក់នៅជប៉ុន(FRESC)

| | | | |
|---|---|---|---|
| មជ្ឈមណ្ឌលជំនួយចំពោះជនបរទេសស្នាក់នៅជប៉ុន | 〒160-0004 | 13F Yotsuya Tower, 1-6-1 Yotsuya, Shinjuku-ku, To-kyo | TEL 0570-011000 (ទូរស័ព្ទ IP និងមកពីបរទេស៖ 03-5363-3013) |

## មជ្ឈមណ្ឌលព័ត៌មានទូទៅអំពីការស្នាក់នៅរបស់ពលរដ្ឋបរទេស។ល។មជ្ឈមណ្ឌលព័ត៌មានអំពីការស្នាក់នៅរបស់ពលរដ្ឋបរទេស។បរទេស

| | |
|---|---|
| ការមកជួបពិគ្រោះយោបល់ | ការិយាល័យត្រួតពិនិត្យអន្តោរប្រវេសន៍នៅតាមតំបន់ផ្សេងៗដែលបានរៀបរាប់ខាងលើ។ (លើកលែងតែការិយាល័យសេវាកម្មអន្តោប្រវេសន៍ប្រចាំតំបន់តូក្យូ ការិយាល័យសាខា Yotsuya ការិយាល័យសាខាព្រលានយន្តហោះនីមួយៗ និងមជ្ឈមណ្ឌលត្រួតពិនិត្យអន្តោប្រវេសន៍នីមួយៗ) |
| ការពិគ្រោះយោបល់តាមទូរស័ព្ទ | TEL 0570-013904 (ទូរស័ព្ទ IP ឬ PHS និងមកពីបរទេស៖ TEL 03-5796-7112) |

# 7 ការផ្សព្វផ្សាយព័ត៌មានពីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

## 7-1 គេហទំព័រជាផ្លូវការរបស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

នៅក្នុងគេហទំព័រជាផ្លូវការរបស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន មានសេចក្ដីណែនាំអំពីនីតិវិធីស្នាក់នៅ ជាអាទិ៍។ បន្ថែមពីលើភាសាជប៉ុន យើងផ្ដល់ព័ត៌មានដែលបកប្រែដោយម៉ាស៊ីនជាជាង 100 ភាសា។

គេហទំព័រជាផ្លូវការរបស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

https://www.moj.go.jp/isa/index.html

*តម្លៃសម្រាប់នីតិវិធីស្នាក់នៅ។ល។ នឹងត្រូវកែសម្រួលចាប់ពីថ្ងៃទី 1 ខែមេសា ឆ្នាំ 2025

https://www.moj.go.jp/isa/01_00518.html

## 7-2 SNS ជាផ្លូវការរបស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុនបានបង្កើត SNS នានា ជាអាទិ៍ ដើម្បីផ្សព្វផ្សាយព័ត៌មានណែនាំអំពីរបបថ្មីៗ ឬព័ត៌មានដែលមានប្រយោជន៍សម្រាប់ការរស់នៅរបស់ជនបរទេសដែលស្នាក់នៅជប៉ុន។

គណនីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ X (អតីត Twitter)៖

https://x.com/MOJ_IMMI

គណនី Facebook របស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន៖

https://www.facebook.com/ImmigrationServicesAgency.MOJ/

ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍នៃប្រទេសជប៉ុន គណនី Instagram៖

https://www.instagram.com/isa__Japan/

សេវាកម្មផ្ញើមែល៖

https://www.moj.go.jp/isa/publications/publications/mail-service.html

គណនី X របស់ការិយាល័យសេវាកម្មអន្តោប្រវេសន៍ក្នុងតំបន់ (អតីត Twitter) ផ្ដល់ព័ត៌មានអំពីភាពមមាញឹករបស់បញ្ជរសេវារបស់ពួកគេ។

គណនីការិយាល័យ សេវាអន្តោប្រវេសន៍ប្រចាំតំបន់៖

https://www.moj.go.jp/isa/publications/publications/nyuukokukanri01_00184.html

## 7-3 វិបផតថលសម្រាប់គាំទ្រជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន

នេះគឺជាគេហទំព័រដែលជូនដំណឹងដល់ជនបរទេសអំពីអ្វីដែលចាំបាច់ និងសំខាន់ក្នុងការរស់នៅក្នុងប្រទេសជប៉ុនប្រកបដោយសុវត្ថិភាព និងផាសុកភាព។ព័ត៌មានពីរដ្ឋាភិបាលដែលសរសេរជាភាសាផ្សេងៗអាចរកបាននៅលើគេហទំព័រ។

វិបផតថលដើម្បីគាំទ្រជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន៖
https://www.moj.go.jp/isa/support/portal/index.html

## 7-4 វីដេអូតម្រង់ទិសជីវិត

យើងបានបង្កើតវីដេអូតម្រង់ទិសជីវិតដែលណែនាំអំពីច្បាប់នៃការរស់នៅរបស់ជនជាតិជប៉ុន និងព័ត៌មានផ្សេងទៀត ដើម្បីជួយជនបរទេសដែលកំពុងពិចារណារស់នៅក្នុងប្រទេសជប៉ុន ឬអ្នកដែលរស់នៅក្នុងប្រទេសជប៉ុនរួចហើយ ឱ្យរស់នៅដោយរលូននៅក្នុងប្រទេសជប៉ុន។

វីដេអូនេះណែនាំអំពីព័ត៌មានជាមូលដ្ឋាន និងច្បាប់ចាំបាច់សម្រាប់ការរស់នៅក្នុងប្រទេសជប៉ុន ដូចជាច្បាប់របៀបរស់នៅ ការងារ និងពន្ធ ជាច្រើនភាសា។

វីដេអូតម្រង់ទិសជីវិត៖
https://www.moj.go.jp/isa/support/coexistence/04_00078.html

ជំពូកទី2

# ការបំពេញបែបបទនៅភូមិឃុំស្រុក



## 1 ការជូនដំណឹងចាំបាច់

### 1-1 ការជូនដំណឹងអំពីអាសយដ្ឋានស្នាក់នៅ

ពលរដ្ឋបរទេសដូចខាងក្រោមចាំបាច់ត្រូវជូនដំណឹងអំពីអាសយដ្ឋានស្នាក់នៅទៅភូមិឃុំស្រុក។

**អ្នកដែលត្រូវធ្វើការជូនដំណឹង**

- អ្នកដែលបានទទួលប័ណ្ណស្នាក់នៅ (អ្នកស្នាក់នៅរយៈពេលមធ្យមឬវែង)
- អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស
- អ្នកដែលបានទទួលការអនុញ្ញាតអោយជ្រកកោន ឬការអនុញ្ញាតអោយស្នាក់នៅបណ្តោះអាសន្ន
- អ្នកទើបនឹងកើត ឬអ្នកបន្តស្នាក់នៅដោយបាត់សញ្ជាតិជប៉ុន

#### (1) ក្នុងករណីចូលមកប្រទេសជប៉ុនដោយបានទទួលការអនុញ្ញាតថ្មី

- ក្នុងអំឡុងពេល 14ថ្ងៃរាប់ចាប់ពីថ្ងៃកំណត់កន្លែងរស់នៅ ចាំបាច់ត្រូវជូនដំណឹងទៅភូមិឃុំស្រុកដែលខ្លួនរស់នៅអំពីការផ្លាស់លំនៅចូល។
- នៅពេលទៅធ្វើការជូនដំណឹង សូមយកប័ណ្ណស្នាក់នៅ (ចំពោះអ្នកដែលនឹងទទួលបាននៅពេលក្រោយគឺលិខិតឆ្លងដែន) ទៅជាមួយ។
- ក្នុងករណីរស់នៅជាមួយគ្រួសារ គឺត្រូវការឯកសារផ្លូវការសម្រាប់បញ្ជាក់ទំនាក់ទំនងជាមួយគ្រួសារដូចជាសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់កំណើតជាដើមផងដែរ។
- ដំណើរការក្រោយការជូនដំណឹងអំពីការផ្លាស់លំនៅចូលរួច គឺដូចខាងក្រោម។

① នៅពេលធ្វើការជូនដំណឹងអំពីការផ្លាស់លំនៅចូល អាសយដ្ឋានស្នាក់នៅដែលត្រូវបានចុះបញ្ជីក្នុងប័ណ្ណស្នាក់នៅក៏នឹងត្រូវចុះបញ្ជីចប់ក្នុងពេលជាមួយគ្នាដែរ។

② លិខិតបញ្ជាក់ការស្នាក់នៅត្រូវបានធ្វើឡើង។

- មានចុះកំណត់ត្រាអំពីឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ អាសយដ្ឋានជាដើម។
- ចាប់ពីពេលនោះទៅ អាចស្នើសុំអោយចេញសេចក្តីចំលងលិខិតបញ្ជាក់ការស្នាក់នៅ ដើម្បីបញ្ជាក់ស្ថានភាពនៃការរស់នៅជាដើម។ (គិតថ្លៃ)

* ប្រសិនបើអ្នកបរាជ័យក្នុងការដាក់ពាក្យសុំពន្យាររយៈពេលស្នាក់នៅនៅការិយាល័យសេវាកម្មអន្តោប្រវេសន៍ក្នុងតំបន់ ហើយរយៈពេលនៃការស្នាក់នៅរបស់អ្នកផុតកំណត់ ស្ថានភាពស្នាក់នៅរបស់អ្នកនឹងត្រូវបានដកហូត ហើយកាតស្នាក់នៅរបស់អ្នកនឹងមិនមានសុពលភាព។ សូមប្រាកដថាយកចិត្តទុកដាក់នីតិវិធីទាំងអស់ដែលទាក់ទងនឹងស្ថានភាពស្នាក់នៅរបស់អ្នក។

③ ភូមិឃុំស្រុកនឹងប្រាប់អ្នកនូវលេខសំគាល់បុគ្គល។

* លេខសំគាល់បុគ្គល៖ គឺជាលេខ 12ខ្ទង់ដើម្បីសំគាល់អត្តសញ្ញាណរបស់អ្នកនៅពេលធ្វើបែបបទអំពីសន្តិសុខសង្គម/ពន្ធ/វិធានការគ្រោះមហន្តរាយ។

ចំពោះខ្លឹមសារលំអិត សូមមើលគ្រង់ប្រព័ន្ធលេខសំគាល់បុគ្គល។

④ ចំពោះអ្នកដែលមិនទាន់បានស្នើសុំកាតលេខសំគាល់បុគ្គលសូមប្រើប្រាស់ពាក្យសុំដែលមានភ្ជាប់ជាមួយឯកសារជូនដំណឹងអំពីលេខសំគាល់បុគ្គល។

## (2) ក្នុងករណីផ្លាស់លំនៅចេញ

① ក្នុងករណីផ្លាស់លំនៅទៅភូមិឃុំស្រុកផ្សេង



- មុនពេលផ្លាស់លំនៅ
  → ជូនដំណឹងទៅភូមិឃុំស្រុកដែលខ្លួនរស់នៅអំពីផ្លាស់លំនៅចេញ
- ក្រោយពេលផ្លាស់លំនៅ
  → ជូនដំណឹងទៅភូមិឃុំស្រុកដែលខ្លួនរស់នៅថ្មីក្នុងអំឡុងពេល14ថ្ងៃ អំពីការផ្លាស់លំនៅចូល

② ក្នុងករណីផ្លាស់លំនៅទៅភូមិឃុំស្រុកដដែល
ជូនដំណឹងទៅភូមិឃុំស្រុកដែលខ្លួនរស់នៅក្នុងអំឡុងពេល14ថ្ងៃក្រោយពេលផ្លាស់លំនៅ

③ ក្នុងករណីផ្លាស់លំនៅទៅបរទេស
មុនពេលផ្លាស់លំនៅ ត្រូវជូនដំណឹងទៅភូមិឃុំស្រុកដែលខ្លួនរស់នៅអំពីផ្លាស់លំនៅចេញ

ចំពោះសេចក្តីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។

https://www.soumu.go.jp/main_sosiki/jichi_gyousei/c-gyousei/zairyu/english/move-in_move-out.html

# 1-2 ការសុំចុះបញ្ជីអាពាហ៍ពិពាហ៍



## នៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍នៅប្រទេសជប៉ុន

- ជូនដំណឹងអំពីការសុំចុះបញ្ជីអាពាហ៍ពិពាហ៍ទៅភូមិឃុំស្រុក។
- នៅពេលដែលគេពិនិត្យឃើញថាមនុស្សទាំងពីរនាក់ដែលចង់ចុះបញ្ជីអាពាហ៍ពិពាហ៍មានលក្ខណ:សម្បត្តិគ្រប់គ្រាន់ក្នុងការចុះបញ្ជីអាពាហ៍ពិពាហ៍ នោះការជូនដំណឹងត្រូវបានទទួលយក ហើយអាពាហ៍ពិពាហ៍ត្រូវបានចុះក្នុងបញ្ជី។

### (1) ឯកសារចាំបាច់សម្រាប់ការសុំចុះបញ្ជីអាពាហ៍ពិពាហ៍

| | |
|---|---|
| ជនជាតិជប៉ុន | សៀវភៅអត្រានុកូលដ្ឋាន<br>* សូមពិនិត្យមើលគេហទំព័ររបស់សាលាក្រុង ដែលអ្នកនឹងធ្វើការចុះបញ្ជីអាពាហ៍ពិពាហ៍របស់អ្នក ដើម្បីទទួលបានព័ត៌មានអំពីទម្រង់បែបបទចុះឈ្មោះអាពាហ៍ពិពាហ៍ និងឯកសារ (ដូចជាឯកសារអត្តសញ្ញាណ) ដែលត្រូវតែបង្ហាញនៅបញ្ជរ |
| ពលរដ្ឋបរទេស | • លិខិតបញ្ជាក់ការបំពេញលក្ខខណ្ឌចុះបញ្ជីអាពាហ៍ពិពាហ៍<br>* អាចទទួលបានដោយបំពេញបែបបទនៅស្ថានទូត ឬស្ថាន (អគ្គ)កុងស៊ុលរបស់ប្រទេសខ្លួននៅប្រទេសជប៉ុន (សំគាល់1)។<br>• នៅពេលដាក់ជូននូវឯកសារដូចជាលិខិតបញ្ជាក់ការបំពេញលក្ខខណ្ឌចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលសរសេរជាភាសាបរទេស ចាំបាច់ត្រូវដាក់ភ្ជាប់ជាមួយនូវឯកសារបកប្រែជាភាសាជប៉ុនទាំងអស់ (សំគាល់2)។ |

(សំគាល់1) ប្រទេសខ្លះមិនចេញលិខិតបញ្ជាក់នេះឡើយ។ ក្នុងករណីនោះសូមដាក់ជូននូវឯកសារផ្សេងដែលអាចជំនួសបាន។
(សំគាល់2) សូមសរសេរឈ្មោះអ្នកបកប្រែនៅក្នុងឯកសារបកប្រែ។ អ្នកបកប្រែអាចជាសមីខ្លួនផ្ទាល់។

### (2) សុពលភាពនៅប្រទេសរបស់ខ្លួន

អាពាហ៍ពិពាហ៍ដែលត្រូវបានចុះបញ្ជីនៅប្រទេសជប៉ុនគឺមានសុពលភាពនៅប្រទេសជប៉ុន ប៉ុន្តែមិនប្រាកដថាមានសុពលភាពនៅប្រទេសរបស់ខ្លួនឡើយ។ ដើម្បីបញ្ជាក់ថាការចុះបញ្ជីអាពាហ៍ពិពាហ៍នៅប្រទេសជប៉ុនមានសុពលភាពនៅប្រទេសរបស់ខ្លួនដែរឬអត់ សូមទាក់ទងទៅស្ថានទូតឬស្ថាន (អគ្គ)កុងស៊ុលប្រចាំនៅប្រទេសជប៉ុន។

## 1-3 ការជូនដំណឹងអំពីការលែងលះគ្នា

#### នៅជប៉ុន ពេលលែងលះគ្នា

- ក្នុងករណីដែលមានការព្រមព្រាងក្នុងការលែងលះគ្នា ត្រូវជូនដំណឹងទៅភូមិឃុំស្រុក។
- អាចខុសៗគ្នាទៅតាមកន្លែងរស់នៅ និងតាមសញ្ជាត់ ដូច្នេះ សូមទាក់ទងសួរសាលសស្រុកឃុំភូមិ។
- ក្នុងករណីដែលភាគីណាមួយមិនយល់ព្រមលែងលះគ្នា ត្រូវទៅតុលាការគ្រួសារ សុំលែងលះដោយសន្ទានកម្ម ឬដោយបណ្ដឹងសុំលែងលះ។

### (1) សុពលភាពនៅប្រទេសសាមី

ការលែងលះដែលបានសម្រេចនៅប្រទេសជប៉ុន មានសុពលភាពនៅប្រទេសជប៉ុន ក៏ប៉ុន្តែមិនមែនដាច់ខាត មានសុពលភាពនៅប្រទេសសាមីទេ។ ស្តីពីសុពលភាពនៅប្រទេសសាមី នៃការលែងលះដែលបានធ្វើនៅជប៉ុន សូមសួរទៅស្ថានទូត ឬ (ស្ថាន) កុងស៊ុល ដែលនៅជប៉ុន។

### (2) ក្នុងករណីដែលមានការបារម្ភថា ភាគីម្ខាងទៀតទៅជូនដំណឹងអំពីការលែងលះតាមទំនើងចិត្ត

បើសិនជាមានការបារម្ភថា ភាគីម្ខាងទៀត (ជនជាតិជប៉ុន) ទៅជូនដំណឹងភូមិឃុំស្រុក អំពីការលែងលះគ្នាតាមទំនើងចិត្តគេ អ្នកអាចទៅភូមិឃុំស្រុកដែលមានគោលបញ្ជីអាត្រានុកូលដ្ឋានរបស់ភាគីម្ខាងទៀត (ជនជាតិជប៉ុន) ឬនៅលំនៅដ្ឋានដែលអ្នករស់នៅ ហើយដាក់ពាក្យស្នើសុំកុំឱ្យគេទទួលលិខិតជូនដំណឹងអំពីការលែងលះគ្នាបាន ដើម្បីបង្ការកុំឱ្យការលែងលះគ្នានោះបានសម្រេច។

## 1-4 ការជូនដំណឹងអំពីមរណភាព

#### នៅពេលទទួលមរណភាពនៅប្រទេសជប៉ុន

- គ្រួសារ ឬអ្នករស់នៅជាមួយជាដើមត្រូវធ្វើការជូនដំណឹងអំពីមរណភាព។
- ការជូនដំណឹងនេះចាំបាច់ត្រូវធ្វើនៅក្នុងអំឡុង 7ថ្ងៃ រាប់ចាប់ពីថ្ងៃដែលបានដឹងអំពីមរណភាព។
- ការជូនដំណឹងនេះត្រូវដាក់ជូនទៅភូមិឃុំស្រុកនៃកន្លែងទទួលមរណភាព ឬកន្លែងដែលអ្នកជូនដំណឹងរស់នៅ។

### (1) ឯកសារចាំបាច់សម្រាប់ការជូនដំណឹងអំពីមរណភាព

- លិខិតបញ្ជាក់ការស្លាប់ឬលិខិតពិនិត្យសាកសព
- ចំពោះឯកសារចាំបាច់ផ្សេងទៀត សូមសាកសួរទៅភូមិឃុំស្រុកដែលត្រូវធ្វើការជូនដំណឹង។

### (2) ការសងប័ណ្ណស្នាក់នៅ

សូមធ្វើការសងត្រឡប់មកវិញនូវប័ណ្ណស្នាក់នៅរបស់ពលរដ្ឋបរទេសដែលបានទទួលមរណភាព ក្នុងអំឡុងពេល14ថ្ងៃ តាមវិធីណាមួយក្នុងចំណោមខាងក្រោម៖

- យកទៅការិយាល័យអន្តោប្រវេសន៍តាមតំបន់ដែលនៅក្បែរ
- ផ្ញើតាមប្រៃសណីយ៍ទៅកាន់អាសយដ្ឋានខាងក្រោម៖

> អាសយដ្ឋានផ្ញើ៖ 〒135-0064 Tokyo-To, Koto-Ku, Aomi 2-7-11,
> Tokyo Regional Immigration Services Bureau 9F
> Online Inspection Department Odaiba Branch Office
> (សូមកាខ្វងសំបុត្រថា “The residence card to be returned
> (សងត្រឡប់ប័ណ្ណស្នាក់នៅ)”។)

## 1-5 ការចុះបញ្ជីត្រា



### ការចុះបញ្ជីត្រាគឺ

- នីតិវិធីចុះបញ្ជីត្រា (ត្រាហាងកុ) នៅភូមិឃុំស្រុក គឺជាការចុះបញ្ជីត្រា។
  → មានករណីត្រូវការចាំបាច់នៅកាលៈទេសៈសំខាន់ៗ (ដូចជាកិច្ចសន្យាទិញលក់អចលនទ្រព្យជាដើម)។

### (1) នីតិវិធីចុះបញ្ជីត្រា

#### របស់ចាំបាច់សម្រាប់នីតិវិធី

- ពាក្យសុំចុះបញ្ជីត្រា
- ត្រា (ត្រាហាងកុ)
- ឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួន (1ក្នុងចំណោម កាតលេខសំគាល់បុគ្គល ប័ណ្ណស្នាក់នៅ ប័ណ្ណបើកបរជាដើម)

* ក្រោយបញ្ចប់ការចុះបញ្ជីនឹងទទួលបានប័ណ្ណចុះបញ្ជីត្រា។
* ចំពោះខ្លឹមសារលំអិតនៃនីតិវិធី សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

### (2) លិខិតបញ្ជាក់ការចុះបញ្ជីត្រា




- ជាឯកសារបញ្ជាក់ថាជាត្រា (ត្រាហាងកុ) ដែលបានចុះបញ្ជី
  → សូមធ្វើការស្នើសុំទៅភូមិឃុំស្រុកដែលអ្នករស់នៅ ដោយបង្ហាញប័ណ្ណចុះបញ្ជីត្រាជាដើម។
- មានភូមិឃុំស្រុកខ្លះ អាចទទួលបាននៅផ្សារម៉ាត ដោយប្រើកាតលេខសំគាល់បុគ្គល។

# 2 ប្រព័ន្ធលេខសំគាល់បុគ្គល

## 2-1 តើអ្វីជាប្រព័ន្ធលេខសំគាល់បុគ្គល



- គេត្រូវការលេខសំគាល់បុគ្គលសម្រាប់ករណីដូចតទៅៈ

① នៅពេលទទួលប្រាក់សោធន ឬប្រាក់ឧបត្ថម្ភសម្រាប់ចិញ្ចឹមកូន ឬទទួលសេវាព្យាបាល
② នៅពេលផ្ញើប្រាក់ទៅបរទេស ឬនៅពេលទទួលប្រាក់ដែលផ្ញើមកពីបរទេស
③ នៅពេលបង្កើតគណនីនៅធនាគារ

- នៅពេលប្រើលេខសំគាល់បុគ្គល

① តើលេខនោះពិតជាលេខសំគាល់បុគ្គលរបស់អ្នកពិតប្រាកដមែនដែរឬទេ
② គេធ្វើការពិនិត្យបញ្ជាក់ថាតើអ្នកនិងមនុស្សដែលនៅក្នុងលិខិតបញ្ជាក់មានរូបថតដូចជា លិខិតឆ្លងដែនជាដើម ពិតជាមនុស្សតែម្នាក់ដែរឬទេ។ ហេតុដូច្នេះហើយ គ្មាននរណាម្នាក់អាចបន្លំប្រើលេខសំគាល់បុគ្គលរបស់អ្នកបានឡើយ។

## 2-2 កាតលេខផ្ទាល់ខ្លួន (កាតលេខរបស់ខ្ញុំ)

កាតលេខសំគាល់បុគ្គលជាកាតដែលមានបង្កប់ ឈីបដែលគេត្រូវការដើម្បីអោយការរស់នៅប្រទេសជប៉ុនមានភាពងាយស្រួល។

### (1) កំណត់ត្រា

ផ្ទៃខាងមុខ៖ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ភេទ រូបថត សុពលភាព
ផ្ទៃខាងក្រោយ៖ លេខសំគាល់បុគ្គល




ផ្ទៃខាងមុខ៖




ផ្ទៃខាងក្រោយ៖

### (2) តើគេប្រើលេខសំគាល់បុគ្គលនៅពេលណា

- ប្រើប្រាស់ជាលិខិតបញ្ជាក់អត្តសញ្ញាណសាមីខ្លួនជាផ្លូវការ
- ធ្វើការប្រកាសពន្ធលើប្រាក់ចំណូលតាមអនឡាញ
- ធ្វើការស្នើសុំតាមអនឡាញនូវប្រាក់ឧបត្ថម្ភពាក់ព័ន្ធនឹងកូន ឬស្នើសុំចូលទារកដ្ឋាន
- ទទួលយកសេចក្ដីចម្លងលិខិតបញ្ជាក់ការស្នាក់នៅ វិញ្ញាបនបត្រផ្សេងៗនៅផ្សារម៉ាត (ថ្ងៃសម្រាកក៏បាន។ មានស្រុកឃុំភូមិខ្លះដែលមិនអាចយកសេចក្ដីចម្លងលិខិតបញ្ជាក់ការស្នាក់នៅតាមផ្សារម៉ាតក៏មានដែរ)
- ប្រើប្រាស់ធ្វើជាប័ណ្ណសមាជិករបបថែទាំសុខភាព (ការប្រើកាតលេខបុគ្គលរបស់អ្នកនៅតាមគ្រឹះស្ថានវេជ្ជសាស្ត្រ និងឱសថស្ថាននឹងអនុញ្ញាតឱ្យអ្នកចែករំលែកព័ត៌មានសុខភាព និងព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពសម្រាប់ការថែទាំសុខភាពកាន់តែប្រសើរឡើង។)

ស្ថាប័នពេទ្យ និងឱសថស្ថានដែលអាចប្រើបាន មាននៅក្នុងគេហទំព័រខាងក្រោមនេះ។
https://www.mhlw.go.jp/stf/index_16743.html

## (3) វិធីស្នើសុំ

នៅពេលដែលមានអាសយដ្ឋានរស់នៅប្រទេសជប៉ុនដាក់លាក់រួច ហើយទៅជូនដំណឹងដល់ភូមិឃុំស្រុកអំពីការផ្លាស់លំនៅចូល អាចដាក់ពាក្យស្នើសុំកាតលេខសំគាល់បុគ្គល (លើកលែងមួយភាគ)។

នៅពេលស្នើសុំលើកដំបូងគឺមិនមានការគិតប្រាក់ឡើយ។

ចំពោះអ្នកដែលមិនអាចស្នើសុំបាននៅពេលទៅជូនដំណឹងដល់ភូមិឃុំស្រុកអំពីការផ្លាស់លំនៅចូល នឹងបានទទួលពាក្យស្នើសុំកាតលេខសំគាល់បុគ្គលដែលនឹងត្រូវបានផ្ញើទៅដល់ផ្ទះ សូមប្រើប្រាស់ពាក្យស្នើសុំនោះដើម្បីធ្វើការស្នើសុំតាមវិធីខាងក្រោម៖

1 ការស្នើសុំតាមទូរស័ព្ទស្មាតហ្វូន
ថតរូបមុខដោយទូរស័ព្ទស្មាតហ្វូន ហើយចូលទៅកាន់ វែបសាយសម្រាប់ស្នើសុំ តាមរយៈ QR កូដនៅក្នុងពាក្យស្នើសុំ

2 ការស្នើសុំតាមកុំព្យូទ័រ
ថតរូបមុខដោយកាមេរ៉ាឌីជីថល ហើយចូលទៅកាន់ វែបសាយសម្រាប់ស្នើសុំ

3 ការស្នើសុំតាមប្រៃសណីយ៍
បិទរូបថតនៅលើពាក្យស្នើសុំ ហើយបំពេញព័ត៌មានចាំបាច់ ដាក់ចូលក្នុងស្រោមសំបុត្រសម្រាប់ផ្ញើ ហើយដាក់ចូលក្នុងប្រអប់ប្រៃសណីយ៍

4 ការស្នើសុំតាមម៉ាស៊ីនថតរូបសម្រាប់បញ្ជាក់ (ចំពោះតែប្រភេទម៉ាស៊ីនដែលមានមុខងារនោះប៉ុណ្ណោះ)
ចុចលើប្រដាប់បញ្ជាលើអេក្រង់ ដាក់ប្រាក់ចូល ដាក់ QR កូដនៅក្នុងពាក្យស្នើសុំអោយប្រដាប់អានបាកូដអាន។ បំពេញព័ត៌មានត្រូវការចំបាច់ ថតរូប ហើយបញ្ជូន។

5 ការស្នើសុំនៅបញ្ជរទទួលភ្ញៀវរបស់រដ្ឋបាលភូមិឃុំស្រុក (លើកលែងករណីខ្លះ)
បំពេញព័ត៌មានត្រូវការចំបាច់នៅក្នុងពាក្យស្នើសុំ ហើយដាក់ជូនទៅអោយភូមិឃុំស្រុកដែលខ្លួនរស់នៅ

* នៅពេលធ្វើការស្នើសុំនៅភូមិឃុំស្រុកបន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណសាមីខ្លួន គេអាចទទួលយកកាតលេខសំគាល់បុគ្គលតាមប្រៃសណីយ៍បាន។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖
https://www.kojinbango-card.go.jp/en-kofushinse/

## (4) វិធីទទួលយក

1ខែក្រោយពីការស្នើសុំ គេនឹងទទួលបានកាតប៉ុស្តាល់ពីភូមិឃុំស្រុក។

សូមយកមកជាមួយនូវកាតប៉ុស្តាល់នោះនិងឯកសារត្រូវកាចាំបាច់ដើម្បីទៅទទួលយកកាតលេខសំគាល់បុគ្គលរបស់អ្នក។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖
https://www.kojinbango-card.go.jp/en-uketori/

## 2-3 ប្រការប្រុងប្រយ័ត្នក្នុងការប្រើកាតលេខសំគាល់បុគ្គល

- ក្នុងករណីដែលមានការផ្លាស់ប្តូរនូវឈ្មោះ អាសយដ្ឋាន ជាដើម សូមធ្វើការជូនដំណឹងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។
- កាលកំណត់សុពលភាពនៃកាតលេខសំគាល់បុគ្គល គឺដូចគ្នានឹងថ្ងៃបញ្ចប់នៃកម្លុងពេលនៃការស្នាក់នៅដែរ។
- បន្ទាប់ពីបន្តរយៈពេលនៃការស្នាក់នៅរបស់អ្នក សូមបន្តសុពលភាពនៃប័ណ្ណលេខបុគ្គលរបស់អ្នកនៅការិយាល័យក្រុងដែលអ្នករស់នៅ មុនពេលវាផុតកំណត់។

* ទោះជាសុពលភាពនៃរយៈពេលស្នាក់នៅត្រូវបានបន្តក៏ដោយ ក៏សុពលភាពនៃកាតលេខសំគាល់បុគ្គលមិនត្រូវបានបន្តដោយស្វ័យប្រវត្តិឡើយ។ ប្រសិនបើកាតលេខបុគ្គលរបស់អ្នកផុតកំណត់ កាតនេះនឹងត្រូវគិតថ្លៃ ដើម្បីចេញកាតឡើងវិញ។

* ត្រូវប្រយ័ត្នអំពីកម្លុងពេលពិសេស ដែលកើតមានឡើងនៅពេលសុំការស្នាក់នៅ។
ក្នុងករណីដែលមិនអាចទទួលការអនុញ្ញាតការពន្យារការស្នាក់នៅ ឱ្យបានមុនពេលផុតសុពលភាពកាតលេខសម្គាល់បុគ្គល ចាំបាច់ត្រូវទៅសុំពន្យារសុពលភាពកាតលេខសម្គាល់បុគ្គល 2ខែ (កម្លុងពេលពិសេស)។
នៅពេលដែលបានទទួលប័ណ្ណស្នាក់នៅថ្មី ចាំបាច់ទៅពន្យារសុពលភាពនៃកាតលេខសម្គាល់បុគ្គលឱ្យបានស្មើនឹងថ្ងៃបញ្ចប់នៃកម្លុងពេលនៃការស្នាក់នៅថ្មី ម្តងទៀត។

ចំពោះសេចក្តីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.soumu.go.jp/main_sosiki/jichi_gyousei/c-gyousei/zairyu/english/basic_resident_registration_card.html

## 2-4 ផ្សេងៗ

ចំពោះខ្លឹមសារផ្សេងទៀត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

ប្រព័ន្ធលេខសំគាល់បុគ្គល
https://www.digital.go.jp/policies/mynumber/

កាតលេខសំគាល់បុគ្គល
https://www.kojinbango-card.go.jp/en/

យើងទទួលការសាកសួរតាមទូរស័ព្ទផងដែរ។

សេវាព័ត៌មានតាមទូរស័ព្ទ
(ច័ន្ទ ~ សុក្រ 9:30 - 20:00 ថ្ងៃសៅរ៍ ថ្ងៃអាទិត្យនិងថ្ងៃបុណ្យ 9:30 - 17:30)

◎ ភាសាជប៉ុន

TEL 0120-95-0178

◎ អង់គ្លេស ចិន កូរ៉េ ស្ប៉ាញ ប័រទុយហ្គាល់ វៀតណាម ថៃ ឥណ្ឌូណេស៊ី តាកាឡុក នេប៉ាល់

TEL 0120-0178-26

ជំពូកទី3

# ការជួល និងការធ្វើការ



## 1 ចំណេះដឹងមូលដ្ឋានមុនពេលធ្វើការ

### 1-1 លក្ខណៈសម្បត្តិស្នាក់នៅ

ពលរដ្ឋបរទេសអាចធ្វើសកម្មភាពនៅប្រទេសជប៉ុន នៅក្នុងព្រំដែនកំណត់នៅក្នុងលក្ខណៈសម្បត្តិស្នាក់នៅដែលទទួលបានការអនុញ្ញាត។

គេអាចបែងចែកជា 3ប្រភេទធំៗទៅតាមលក្ខណៈសម្បត្តិស្នាក់នៅ ដែលទទួលបានការអនុញ្ញាតអោយធ្វើការឬអត់។

**លក្ខណៈសម្បត្តិស្នាក់នៅដែលទទួលបានការអនុញ្ញាតអោយធ្វើការនៅក្នុងព្រំដែនកំណត់**

ការទូត ផ្លូវការ សាស្ត្រាចារ្យ សិល្បៈ សាសនា សារព័ត៌មាន ឯកទេសជាន់ខ្ពស់ ដឹកនាំឬគ្រប់គ្រង ការងារច្បាប់ឬគណនេយ្យ វេជ្ជសាស្ត្រ ស្រាវជ្រាវ អប់រំ បច្ចេកវិទ្យាឬចំណេះដឹងមនុស្សសាស្ត្រឬការងារអន្តរជាតិ ការប្តូរការងារក្នុងសហគ្រាស ថែទាំ កំសាន្ត ជំនាញ កម្មសិក្សាជំនាញ និស្សិតបរទេស សកម្មភាពកំណត់ (ធ្វើការពេលវិស្សមកាល  គិលានុបដ្ឋាកឬអ្នកថែទាំសុខុមាលភាពតាមប្រព័ន្ធ EPA ជាដើម)

**លក្ខណៈសម្បត្តិស្នាក់នៅដែលជាទូទៅគេមិនអនុញ្ញាតអោយធ្វើការ**

សកម្មភាពវប្បធម៌ ការស្នាក់នៅរយៈពេលខ្លី និស្សិតបរទេស កម្មសិក្សា ស្នាក់នៅជាមួយគ្រួសារ

**លក្ខណៈសម្បត្តិស្នាក់នៅដែលគ្មានការកំណត់ព្រំដែនសកម្មភាពធ្វើការ**

អ្នកស្នាក់នៅអចិន្ត្រៃយ៍ សហព័ទ្ធរបស់ជនជាតិជប៉ុនជាដើម សហព័ទ្ធរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍ជាដើម អ្នកតាំងលំនៅអចិន្ត្រៃយ៍

### 1-2 របៀបស្វែងរកការងារ

#### (1) ហេឡូវើក (hello work)

Hello Work (ការិយាល័យសន្តិសុខការងារសាធារណៈ) អាចណែនាំអ្នកអំពីការងារ ដោយមិនគិតថ្លៃ។ សូមមើលជំពូកទី 3 2-5(5).សម្រាប់ព័ត៌មានលម្អិតអំពី Hello Work ។

## (2) នៅពេលប្រើក្រុមហ៊ុនណែនាំ

- ប្រសិនបើអ្នកប្រើភ្នាក់ងារស្វែងរកការងារដែលគិតថ្លៃសេវា សូមជ្រើសរើសក្រុមហ៊ុន ដែលត្រឹមត្រូវ ដើម្បីជៀសវាងបញ្ហានៅពេលស្វែងរកការងារ។

តើមានចំណាយលុយដើម្បីណែនាំការងារទេ?

អ្នកមិនចាំបាច់ចំណាយប្រាក់ដើម្បីទទួលបានការផ្តល់ជូនការងារ ឬដើម្បីធ្វើការ។ ប្រសិនបើចំណាយ សូមរក្សាភស្តុតាងនៃការទូទាត់។

តើក្រុមហ៊ុនមានលិខិតអនុញ្ញាត ឬអាចបញ្ជាក់បានទេ?

អាជ្ញាប័ណ្ណត្រូវបានទាមទារដើម្បីណែនាំការងារ (ការស្វែងរកការងារធ្វើ)។ ពិនិត្យលេខអាជ្ញា. ប័ណ្ណហើយធ្វើការកំណត់ចំណាំ។

តើអ្នកត្រូវបានប្រាប់ត្រឹមត្រូវអំពីលក្ខខណ្ឌការងារទេ?

ព័ត៌មានលម្អិតអំពីការងារ ប្រាក់ខែ កន្លែងធ្វើការ និងលក្ខខណ្ឌផ្សេងទៀតនៃការងារត្រូវបង្ហាញជាលាយលក្ខណ៍អក្សរ ដូច្នេះត្រូវប្រាកដថាពិនិត្យ និងរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព។

- អាជ្ញាប័ណ្ណ និងការជូនដំណឹងអាចត្រូវបានបញ្ជាក់នៅលើ "គេហទំព័រទូទៅនៃសេវាកម្មធនធានមនុស្ស"។

https://jinzai.hellowork.mhlw.go.jp/JinzaiWeb/GICB101010.do?action=initDisp&screenId=GICB101010

# 1-3 ប្រភេទនៃកម្មករនិយោជិត

## (1) កម្មករនិយោជិតបញ្ជូន (បុគ្គលិកបញ្ជូន)

- បញ្ជូនមានន័យថា ធ្វើការក្នុងរូបភាពដូចខាងក្រោម។

① កម្មករនិយោជិតចុះកិច្ចសន្យាការងារជាមួយសហគ្រាសបញ្ជូន (ប្រភពបញ្ជូន)។ (សហគ្រាសបញ្ជូនគឺជានិយោជក ហើយជាអ្នកបង់ប្រាក់ឈ្នួល។)

② កម្មករនិយោជិតត្រូវបានបញ្ជូនទៅសហគ្រាស (សហគ្រាសទទួល) ដែលបានចុះកិច្ចសន្យាបញ្ជូនកម្មករនិយោជិតជាមួយសហគ្រាសបញ្ជូន។

③ កម្មករនិយោជិតធ្វើការដោយទទួលបញ្ជាពីសហគ្រាសទទួល។

- នៅក្នុងច្បាប់ស្តីពីការបញ្ជូនកម្មករនិយោជិត មានចែងអំពីបទបញ្ញត្តិ ដែលសហគ្រាសបញ្ជូននិងសហគ្រាសទទួលត្រូវគោរពដើម្បីការពារកម្មករនិយោជិតបញ្ជូន។
- ក្នុងករណីដែលមានបញ្ហាកើតឡើងនៅពេលធ្វើការដោយការបញ្ជូន ទាំងសហគ្រាសបញ្ជូននិងសហគ្រាសទទួលមានអ្នកទទួលបន្ទុកទទួលការពិគ្រោះ ដូច្នេះគឺអាចពិគ្រោះបាន។
- ក្នុងករណីធ្វើការដោយបញ្ជូន សហគ្រាសបញ្ជូននិងសហគ្រាសទទួលបែងចែកបន្ទុកគ្នាលើទំនួលខុសត្រូវពាក់ព័ន្ធនឹងស្តង់ដារការងារ និងសុវត្ថិភាពនិងសុខភាព។

## (2) បុគ្គលិកមានថេរវេលាកំណត់ (បុគ្គលិកដែលមានកិច្ចសន្យាកំណត់ថេរវេលា)

- បុគ្គលិកមានថេរវេលាកំណត់ គឺជាកម្មករនិយោជិតដែលបានបង្កើតកិច្ចសន្យាការងារមានថេរវេលាកំណត់មួយ ជាមួយនឹងនិយោជក។
- ក្នុងករណីដែលបានចុះកិច្ចសន្យាការងារដែលកំណត់ថេរវេលានៃកិច្ចសន្យាជាមុន នៅពេលដែលថេរវេលានៃកិច្ចសន្យាបានបញ្ចប់ កិច្ចសន្យានោះក៏បញ្ចប់ដោយស្វ័យប្រវត្តិដែរ។
  ប៉ុន្តែក្នុងករណីដែលកម្មករនិយោជិតនិងសហគ្រាសព្រមព្រៀងគ្នាចុះកិច្ចសន្យាជាថ្មី (បន្តកិច្ចសន្យា) នោះគេអាចបន្តថេរវេលានៃកិច្ចសន្យាបាន។
- ថេរវេលានៃកិច្ចសន្យាក្នុង1ដង (លើកលែងករណីខ្លះ) គឺវែងបំផុតត្រឹម 3ឆ្នាំ។

## (3) កម្មករនិយោជិតមិនពេញម៉ោង

- កម្មករនិយោជិតមិនពេញម៉ោងគឺជាកម្មករនិយោជិតដែលត្រូវគេជួលឱ្យធ្វើការដោយមានម៉ោងធ្វើការក្នុងមួយអាទិត្យ ខ្លីជាងអ្នកធ្វើការធម្មតា (កម្មករនិយោជិតមានក្របខ័ណ្ឌ) នៅកន្លែងធ្វើការនោះ។
  ទោះបីជាមានរបៀបហៅផ្សេងៗដូចជា “អ្នកធ្វើការមិនពេញម៉ោង” “អ្នកធ្វើការក្រៅម៉ោង” “បុគ្គលិកក្នុងកិច្ចសន្យា” “បុគ្គលិកបណ្ដោះអាសន្ន” “បុគ្គលិកមិនពេញសិទ្ធិ” ជាដើមក៏ដោយ អោយតែជាកម្មករនិយោជិតដែលបំពេញតាមលក្ខខណ្ឌនេះគឺជាកម្មករនិយោជិតមិនពេញម៉ោង។

(*) ថេរវេលាធ្វើការកំណត់ក្នុង1សប្តាហ៍ គឺជាថេរវេលាធ្វើការដោយរាប់ចាប់ពីម៉ោងចាប់ផ្តើមការងាររហូតដល់ម៉ោងបញ្ចប់ការងារដោយមិនរាប់បញ្ចូលនូវម៉ោងសម្រាកតាមដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងជាដើម។

- កម្មករនិយោជិតមិនពេញម៉ោងក៏ស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ការងារផ្សេងៗ ផងដែរ។ ហេតុដូច្នេះហើយក្នុងករណីបំពេញលក្ខខណ្ឌ
  ① អាចទទួលបានការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល។
  ② របបនិកម្មភាពការងារ របបថៃទាំសុខភាព និងរបបប្រាក់សោធនសុខុមាលភាពត្រូវបានអនុវត្ត។
- នៅពេលជួលកម្មករនិយោជិត សហគ្រាសមានកាតព្វកិច្ចដូចខាងក្រោម៖
  ① បញ្ជាក់អោយច្បាស់នូវលក្ខខណ្ឌការងារ។
  ② ជាពិសេសចំពោះលក្ខខណ្ឌសំខាន់ទាំង6 ជាទូទៅត្រូវធ្វើឯកសារជាលាយល័ក្ខណ៍អក្សរ (សូមមើលត្រង់ 1-4 (2))
  បន្ថែមពីលើនេះ ក្នុងករណីកម្មករនិយោជិតមិនពេញម៉ោង ឬបុគ្គលិកក្នុងកិច្ចសន្យា (បុគ្គលិកដែលមានកិច្ចសន្យាការងារមានថេរវេលាកំណត់) ជាគោលការណ៍ ត្រូវបញ្ជាក់អោយច្បាស់លាស់ដោយប្រគល់នូវឯកសារជាលាយល័ក្ខណ៍អក្សរជាដើម អំពី “មានការតម្លើងប្រាក់ឈ្នួលឬអត់” “មានការផ្តល់ប្រាក់បំណាច់ (bonus)ឬអត់” “មានការផ្តល់ប្រាក់បំណាច់ពេលឈប់ពីការងារឬអត់” “មានច្រកពិគ្រោះទាក់ទងនឹងការកែលំអការគ្រប់គ្រងការជួលបុគ្គលិកជាដើមឬអត់” ផងដែរ។

ស្តីពីព័ត៌មានលំអិត សូមសួរទៅកាន់ផ្នែកបរិស្ថាន-សមភាពការងារ (ការិយាល័យរង) នៃនាយកដ្ឋានការងាររាជធានីខេត្តឬកន្លែងពិគ្រោះទូទៅអំពីការងារ។

* សូមមើលគេហទំព័ររាជធានីខេត្ត ឬតារាងទីតាំងនៃផ្នែកបរិស្ថាន-សមភាពការងារ (ការិយាល័យរង) ក្នុងគេហទំព័រខាងក្រោមនេះ។.

https://www.mhlw.go.jp/content/000177581.pdf

## (4) អ្នកធ្វើការដោយមានកិច្ចសន្យាប្រគល់ការងារ (មៅការងារ)

**ករណីទូទៅ**

- ក្នុងករណីធ្វើការក្រោមឈ្មោះ “ប្រគល់ការងារ” ឬ “មៅការងារ” គឺប្រាក់រង្វាន់ត្រូវបានបង់ដោយអ្នកផ្ដល់ការងារចំពោះការសម្រេចនៃការងារ ហេតុដូច្នេះហើយគេចាត់ទុកថាជា “ម្ចាស់អាជីវកម្ម” ដែលមិនទទួលការបញ្ជាពីអ្នកផ្ដល់ការងារ ជាទូទៅគឺមិនអាចទទួលបានការគាំពារក្នុងនាមជា “កម្មករនិយោជិត” ឡើយ។

**ករណីពិសេស**

- ប៉ុន្តែទោះបីជាបានចុះកិច្ចសន្យាក្នុងនាម “ប្រគល់ការងារ” ឬ “មៅការងារ” ក៏ដោយ បើគេវិនិច្ឆ័យថាទម្រង់នៃការជួលជាក់ស្ដែងគឺ “កម្មករនិយោជិត” ដែលទទួលបញ្ជាពីអ្នកផ្ដល់ការងារ នោះអាចទទួលបានការគាំពារក្នុងនាមជា “កម្មករនិយោជិត” បាន។
- ក្នុងករណីមានការលំបាកក្នុងការវិនិច្ឆ័យថាជា "កម្មករនិយោជិត" ឬអត់ សូមពិគ្រោះជាមួយការិយាល័យស្តង់ដារការងារ។

* អ្នកដែលធ្វើការក្រោមកិច្ចសន្យាបន្ត (កិច្ចព្រមព្រៀងកិច្ចសន្យា) អាចជាកម្មវត្ថុនៃ "ច្បាប់ស្ដីពីការធានានូវប្រតិបត្តិការត្រឹមត្រូវដែលពាក់ព័ន្ធនឹងប្រតិបត្តិករអាជីវកម្មដែលបានប្រគល់ឱ្យជាក់លាក់" ចាប់ពីខែវិច្ឆិកា ឆ្នាំ 2024 តទៅ។ សូមពិនិត្យមើលនៅទីនេះសម្រាប់ព័ត៌មានលម្អិត។
https://www.mhlw.go.jp/stf/seisakunitsuite/bunya/koyou_roudou/koyoukintou/zaitaku/index_00002.html

# 1-4 កិច្ចសន្យាការងារ

## (1) ព្រំដែននៃ “កម្មករនិយោជិត”

- “កម្មករនិយោជិត” គឺជាអ្នកធ្វើការដោយទទួលបញ្ជាពីនិយោជក ហើយទទួលរង្វាន់ជាប្រាក់ឈ្នួល និងអាចទទួលបានការគាំពារពីច្បាប់ការងារមួយចំនួនដូចជាច្បាប់ស្តង់ដារការងារជាដើម។
- ជា “កម្មករនិយោជិត” ឬមិនមែនគឺមិនទាក់ទងនឹងប្រភេទការងារទេ។ មិនត្រឹមតែបុគ្គលិកពេញសិទ្ធិនោះទេ បុគ្គលិកបញ្ជូន បុគ្គលិកមានថេរវេលាកំណត់ អ្នកធ្វើការមិនពេញម៉ោង អ្នកធ្វើការក្រៅម៉ោង ជាទូទៅគឺជា “កម្មករនិយោជិត”។

## (2) ការបញ្ជាក់អោយច្បាស់នូវលក្ខខណ្ឌការងារ

- នៅក្នុងច្បាប់ស្តង់ដារការងាររបស់ជប៉ុន (ជាច្បាប់មួយទាក់ទងនឹងការធ្វើការ) នៅពេលចុះកិច្ចសន្យាការងារ សហគ្រាសមានកាតព្វកិច្ចបញ្ជាក់ទៅកាន់កម្មករនិយោជិតអោយបានច្បាស់អំពីលក្ខខណ្ឌការងារ ដើម្បីជៀសវាង កម្មករនិយោជិតចាប់ផ្ដើមធ្វើការដោយមិនដឹងពីលក្ខខណ្ឌការងារដូចជាប្រាក់ឈ្នួល ថេរវេលាធ្វើការជាដើម ហើយបង្កជាវិវាទជាមួយសហគ្រាសនៅពេលក្រោយ។
- ជាពិសេសចំពោះចំណុចសំខាន់ខាងក្រោម ជាទូទៅគឺតម្រូវអោយសហគ្រាសធ្វើការបញ្ជាក់អោយច្បាស់ទៅកាន់កម្មករនិយោជិតជាលាយល័ក្ខណ៍អក្សរ (ក្នុងករណីពិសេសដែលកម្មករនិយោជិតចង់បានការបញ្ជាក់តាម FAX ឬអ៊ីម៉ែល (ចំពោះតែករណីអាចបញ្ចេញជាឯកសារបាន។) ក៏បាន)។

① តើកិច្ចសន្យាចាប់ពីពេលណាដល់ពេលណា (ទាក់ទងនឹងថេរវេលានៃកិច្ចសន្យា)

* នៅពេលចុះកិច្ចសន្យាការងារ មានករណីកំណត់ថេរវេលានៃកិច្ចសន្យានិងមិនកំណត់ថេរវេលានៃកិច្ចសន្យា។ តាមរយៈឈ្មោះនៃទម្រង់នៃការជួលតែមួយមុខដូចជា បុគ្គលិកពេញសិទ្ធិទេ បុគ្គលិកមានថេរវេលាកំណត់ អ្នកធ្វើការមិនពេញម៉ោង ឬ អ្នកធ្វើការក្រៅម៉ោង គេមិនអាចវិនិច្ឆ័យថាមានការកំណត់ថេរវេលានៃកិច្ចសន្យាឬអត់ឡើយ។ មិនត្រឹមតែឈ្មោះនៃទម្រង់នៃការជួលប៉ុណ្ណោះទេ ត្រូវបញ្ជាក់អោយច្បាស់ពីថេរវេលានៃកិច្ចសន្យាផងដែរ។

② ងករណីចុះកិច្ចសន្យាដែលមានកំណត់ថេរវេលានៃកិច្ចសន្យា គឺលក្ខខណ្ឌនៃការបន្តកិច្ចសន្យា (មានការបន្តឬអត់កំណត់ចំនួននៃការបន្ត, វិធីវិនិច្ឆ័យក្នុងករណីមានការបន្តជាដើម)

③ ធ្វើការងារអ្វីនៅទីណា (កន្លែងធ្វើការងារ ខ្លឹមសារនៃការងារ)

④ ការកំណត់លើថេរវេលាធ្វើការ និងការសម្រាក (គឺម៉ោងចាប់ផ្តើមធ្វើការនិងម៉ោងបញ្ចប់ការងារ តើមានថែមម៉ោងឬអត់ រយៈពេលសម្រាក ថ្ងៃឈប់សម្រាក និងការឈប់សម្រាក ការផ្លាស់ប្តូរវេន ក្នុងករណីធ្វើការដោយមានការផ្លាស់ប្តូរវេន)

⑤ ប្រាក់ឈ្នួលប៉ុន្មាន បើកនៅពេលណា យ៉ាងដូចម្តេច (ការសម្រេចលើប្រាក់ឈ្នួល វិធីគណនា វិធីបើក អំឡុងពេលគណនានិងពេលវេលាបើក)

⑥ លក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា (រួមទាំងមូលហេតុនៃការបញ្ឈប់)

- លើសពីនេះទៀត នៅពេលចូលទៅក្នុងកិច្ចសន្យាដែលមានកាលកំណត់ ប្រសិនបើការបន្តកិច្ចសន្យាផ្តល់នូវការកើនឡើងដល់ "សិទ្ធិស្នើសុំការបំប្លែងទៅជាការងារមិនកំណត់" វាត្រូវបានចែងថា និយោជិតអាចស្នើសុំការបំប្លែងទៅជាការងារមិនកំណត់ ហើយលក្ខខណ្ឌការងារបន្ទាប់ពីការបំប្លែងត្រូវតែបញ្ជាក់យ៉ាងច្បាស់។
- ចំពោះខ្លឹមសារផ្សេងក្រៅពីលក្ខខណ្ឌការងារទាំងនេះ ច្បាប់ស្តីពីកិច្ចសន្យាការងារមានចែងថា និយោជក និងកម្មករនិយោជិតគួរតែបញ្ជាក់គ្នាជាលាយល័ក្ខណ៍អក្សរអោយបានច្រើនបំផុត។

ចំណុចគួរដឹង៖

## ប្រការហាមឃាត់នៅក្នុងកិច្ចសន្យាការងារ

នៅក្នុងច្បាប់ស្តង់ដារការងារ ប្រការដែលនិយោជកមិនអាចបញ្ចូលនៅក្នុងកិច្ចសន្យាការងារបានក៏មានចែងផងដែរ។

1. ការកំណត់ទុកជាមុនអោយបង់ប្រាក់ល្មើសកិច្ចសន្យា ឬទឹកប្រាក់សំណងលើការខូចខាតក្នុងករណីដែលកម្មករនិយោជិតល្មើសនឹងកិច្ចសន្យាការងារ។ *នេះគឺជាការហាមឃាត់មិនអោយកំណត់ប្រាក់ល្មើសកិច្ចសន្យា ឬទឹកប្រាក់សំណងលើការខូចខាតជាមុន។ គឺមិនត្រូវធ្វើការសន្យាអំពីទឹកប្រាក់សំណងលើការខូចខាត ចំពោះការខូចខាតដែលជាក់ស្តែងកើតឡើងដោយចេតនា ឬការមិនប្រុងប្រយ័ត្នរបស់កម្មករនិយោជិត គឺគ្មានការហាមឃាត់មិនអោយសហគ្រាសទាមទារសំណងនោះទេ។
2. ការយកការធ្វើការជាលក្ខខណ្ឌអោយកម្មករនិយោជិតខ្ចីប្រាក់ជាមុន ហើយអោយសងតាមរូបភាពកាត់ដកពីប្រាក់បៀវត្សរៀងរាល់ខែជាអត្តនោម័ត
3. ការអោយកម្មករនិយោជិតសន្សំប្រាក់ទុកក្នុងសហគ្រាសដោយបង្ខំ
   ទោះជាមូលហេតុនៃការសន្សំយ៉ាងណាក៏ដោយ ទោះបីជាដើម្បីសុខុមាលភាពរបស់កម្មករនិយោជិតដូចជាដំណើរកំសាន្តរបស់បុគ្គលិកជាដើមក៏ដោយ ការបង្ខំអោយសន្សំទុកត្រូវបានហាមឃាត់។ ប៉ុន្តែក្នុងករណីដែលកម្មករនិយោជិតស្ម័គ្រចិត្តអោយសហគ្រាសធ្វើការគ្រប់គ្រងប្រាក់សន្សំ នោះគេអាចទទួលស្គាល់ក្នុងលក្ខខណ្ឌកំណត់មួយ ទោះបីជាកិច្ចសន្យាការងារយ៉ាងណាក៏ដោយ។

ចំណុចគួរដឹង៖

**ប្រសិនបើលក្ខខណ្ឌការងារខុសពីការសន្យានៅពេលចុះកិច្ចសន្យាការងារ…**

- នៅពេលចាប់ផ្តើមធ្វើការ ប្រសិនបើចាប់អារម្មណ៍ថាលក្ខខណ្ឌការងារខុសពីការសន្យា កម្មករនិយោជិតអាចបញ្ចប់កិច្ចសន្យាដោយមូលហេតុនោះភ្លាមៗបាន។
- លក្ខខណ្ឌការងារកំណត់ឡើងដោយកិច្ចសន្យាការងារដែលធ្វើឡើងរវាងនិយោជកនិងកម្មករនិយោជិត និងបទបញ្ជាផ្ទៃក្នុងជាដើម ហើយច្បាប់ស្តង់ដារការងារកំណត់បទដ្ឋានទាបបំផុត (លក្ខខណ្ឌការងារណាដែលមិនគោរពតាមបទដ្ឋានកំណត់ដោយច្បាប់ស្តង់ដារការងារគឺគ្មានសុពលភាពឡើយ ហើយផ្នែកដែលគ្មានសុពលភាពនោះត្រូវជំនួសដោយស្តង់ដារដែលកំណត់ដោយច្បាប់ស្តង់ដារការងារ។)។
- ក្រោយចាប់ផ្តើមធ្វើការងារជាក់ស្តែង ជាទូទៅសហគ្រាសមិនអាចប្តូរបទប្បញ្ញត្តិការងារ ធ្វើអោយកម្មករនិយោជិតខាតបង់ប្រយោជន៍ជាអត្តនោម័តដោយគ្មានការយល់ព្រមពីកម្មករនិយោជិតបានឡើយ។

# 1-5 ប្រាក់ឈ្នួល

## (1) ប្រាក់ឈ្នួលអប្បបរមាគឺ

ប្រាក់ឈ្នួលអប្បបរមាគឺជាប្រាក់ឈ្នួលទាបបំផុតដែលសហគ្រាសត្រូវបង់ និងត្រូវបានកំណត់ដោយច្បាប់ស្តីអំពីប្រាក់ឈ្នួលអប្បបរមា។

## (2) លក្ខណៈពិសេសនៃប្រាក់ឈ្នួលអប្បបរមា

① មានវិសាលភាពអនុវត្តចំពោះកម្មករនិយោជិតទាំងអស់ទោះជាមានទម្រង់នៃការជួលខុសគ្នាក៏ដោយ។

② កិច្ចសន្យាការងារដែលមានប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលអប្បបរមាគឺគ្មានសុពលភាពឡើយ។ ទោះបីជាក្នុងករណីដែលបានចុះកិច្ចសន្យាតាមសហគ្រាសប្រាប់ក៏ដោយក៏អាចទាមទារមកវិញនូវ [ទឹកប្រាក់ខុសគ្នាជាមួយប្រាក់ឈ្នួលអប្បបរមា] x [ចំនួនម៉ោងដែលបានធ្វើការ] នៅពេលក្រោយបានដែរ។

## (3) ប្រាក់ឧបត្ថម្ភសម្រាកការងារ

**ក្នុងករណីអោយកម្មករនិយោជិតឈប់សម្រាកដោយសារមូលហេតុមកពីសហគ្រាស**

សហគ្រាសត្រូវផ្តល់ប្រាក់ឧបត្ថម្ភសម្រាកការងារចំនួនចាប់ពី 60% នៃប្រាក់ឈ្នួលមធ្យមដើម្បីធានាជីវភាពអប្បបរមារបស់កម្មករនិយោជិត។ ហេតុដូច្នេះហើយ ក្នុងករណីដែលមានមូលហេតុមកពីសហគ្រាសគឺមានការធានាផ្តល់ប្រាក់បៀវត្សក្នុងកម្រិតមួយ។

# 2 បទបញ្ញត្តិនៅពេលធ្វើការ

## 2-1 ការបើកប្រាក់ឈ្នួល

បញ្ញត្តិទូទៅចំនួន 4ត្រូវបានកំណត់ ដើម្បីធានាថាប្រាក់ឈ្នួលត្រូវបានបើកទៅអោយកម្មករនិយោជិតបានគ្រប់ចំនួន។

| | | |
|---|---|---|
| ① បញ្ញត្តិទូទៅអំពីការបើកជាសាច់ប្រាក់ | បញ្ញត្តិទូទៅ | ប្រាក់ឈ្នួលត្រូវបើកជាសាច់ប្រាក់។ |
| | ករណីលើកលែង | ក្នុងករណីដែលកម្មករនិយោជិតយល់ព្រម អាចបើកតាមរយៈការផ្ទេរប្រាក់តាមគណនីធនាគារក៏បាន។<br>ក្នុងករណីដែលមានការសន្យារវាងសហគ្រាសនិងសហជីព អាចផ្តល់ជា វត្ថុ (ផលិតផលរបស់សហគ្រាសជាដើម) បាន។ |
| ② បញ្ញត្តិទូទៅអំពីការបើកប្រាក់ដោយផ្ទាល់ | ប្រាក់ឈ្នួលចាំបាច់ត្រូវបើកអោយទៅសមីខ្លួនកម្មករនិយោជិតដោយផ្ទាល់។ | |
| ③ បញ្ញត្តិទូទៅអំពីការបើកប្រាក់ទាំងអស់ | បញ្ញត្តិទូទៅ | ប្រាក់ឈ្នួលត្រូវបើកទាំងអស់គ្រប់ចំនួន។ |
| | ករណីលើកលែង | ការដកទៅលើការកាត់ពន្ធលើប្រាក់ចំណូលឬភាគទានរបបសន្តិសុខសង្គមជាដើមដែលកំណត់ដោយច្បាប់<br>ការកាត់មួយភាគក្នុងករណីបានចុះកិច្ចព្រមព្រៀងជាមួយសហជីព ឬអ្នកតំណាងកម្មករនិយោជិតភាគច្រើន |
| ④ បញ្ញត្តិទូទៅអំពីការបើកទៀងទាត់លើសពី 1ដងរៀងរាល់ខែ | បញ្ញត្តិទូទៅ | ប្រាក់ឈ្នួលត្រូវបានបើកនៅថ្ងៃកំណត់ណាមួយ លើសពី1ដងរៀងរាល់ខែ។<br>➡ ឧទាហរណ៍ ច្បាប់មិនអនុញ្ញាតអោយបើកប្រាក់ឈ្នួលសរុប 2ខែនៃប្រាក់ឈ្នួលតែម្តងទេ។ ម្យ៉ាងទៀតច្បាប់មិនអនុញ្ញាតអោយធ្វើការកំណត់ថ្ងៃបើកប្រាក់តាមរបៀបដែលមិនអាចកំណត់ថ្ងៃបើកប្រាក់ជាក់លាក់បានដូចជា ״រៀងរាល់ខែពីថ្ងៃទី20ដល់ថ្ងៃទី25״ ឬ ״រៀងរាល់ថ្ងៃសុក្រទី4នៃខែ״ ដែលមានការប្រែប្រួលក្នុងចន្លោះ 7ថ្ងៃ។ |
| | ករណីលើកលែង | ប្រាក់ឈ្នួលបណ្តោះអាសន្នឬប្រាក់បំណាច់ (bonus) |

## 2-2 ថេរវេលាធ្វើការ / ការសម្រាក / ថ្ងៃឈប់សម្រាក

### (1) ថេរវេលាធ្វើការ

- ថេរវេលាធ្វើការ គឺមានព្រំដែនដែលកំណត់ដោយច្បាប់។
- នៅក្នុងច្បាប់ស្តង់ដារការងារ ជាគោលការណ៍កំណត់ត្រឹម 8ម៉ោងក្នុង1ថ្ងៃ 40ម៉ោងក្នុង1សប្តាហ៍ (ថេរវេលាធ្វើការកំណត់ដោយច្បាប់)។
- ក្នុងករណីអោយកម្មករនិយោជិតធ្វើការងារបន្ថែមម៉ោង សហគ្រាសត្រូវផ្តល់ប្រាក់ឈ្នួលបន្ថែម។

### (2) ការសម្រាក

នៅក្នុងអំឡុងពេលធ្វើការ ក្នុងករណីថេរវេលាធ្វើការក្នុង1ថ្ងៃលើសពី6ម៉ោង សហគ្រាសត្រូវផ្តល់ការសម្រាកយ៉ាងតិច45នាទី ក្នុងករណីលើសពី 8ម៉ោងត្រូវផ្តល់ការសម្រាកយ៉ាងតិច 60នាទី។

### (3) ថ្ងៃឈប់សម្រាក

សហគ្រាសត្រូវផ្តល់ថ្ងៃឈប់សម្រាកយ៉ាងតិច1ថ្ងៃរៀងរាល់សប្តាហ៍ដល់កម្មករនិយោជិត ឬសរុបចាប់ពី4ថ្ងៃឡើងសម្រាប់រយៈពេល4សប្តាហ៍ (ថ្ងៃឈប់សម្រាកកំណត់ដោយច្បាប់)។

### (4) កាតព្វកិច្ចទាក់ទងនឹងការសម្រេចលក្ខខណ្ឌការងាររបស់បុគ្គលិកបញ្ជូន

ចំពោះការសម្រេចនូវលក្ខខណ្ឌការងាររបស់បុគ្គលិកបញ្ជូនគឺសហគ្រាសបញ្ជូនជាអ្នកទទួលខុសត្រូវ ប៉ុន្តែការគោរពថេរវេលាធ្វើការ ការសម្រាក ថ្ងៃឈប់សម្រាកជាដើម គឺជាទំនួលខុសត្រូវរបស់សហគ្រាសទទួល។

ចំណុចគួរដឹង៖

#### ចំណុចគួរដឹង៖ ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល

ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលគឺការឈប់សម្រាកដោយបានទទួលប្រាក់ឈ្នួល ទោះបីជាឈប់សម្រាកនៅថ្ងៃកំណត់ត្រូវធ្វើការក៏ដោយ។ ជាទូទៅអាចទទួលបានសម្រាប់ថ្ងៃណាដែលកម្មករនិយោជិតប្រាថ្នាចង់បាន ហើយគោលបំណងនៃការប្រើប្រាស់គឺដោយសេរី។ កម្មករនិយោជិតដែលបន្តធ្វើការបាន 6ខែ ហើយមកធ្វើការលើសពី 80%នៃថ្ងៃធ្វើការទាំងអស់ អាចធ្វើការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលបានចំនួន10ថ្ងៃ។ នៅពេលដែលចំនួនឆ្នាំបន្តធ្វើការកាន់តែច្រើន ហើយនៅតែបំពេញលក្ខខណ្ឌមកធ្វើការលើសពី80% ចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដែលអាចប្រើបានកាន់តែច្រើនឡើង (ច្រើនបំផុត 20ថ្ងៃ)។ សហគ្រាសត្រូវតែផ្តល់ 5ថ្ងៃរៀងរាល់ឆ្នាំ ដោយជ្រើសរើសពេលវេលាជាដើម ទៅអោយកម្មករនិយោជិតដែលបានទទួលការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលចំនួនលើសពី10ថ្ងៃ។

ចំពោះកម្មករនិយោជិតដែលមានទម្រង់នៃការជួលក្រៅពីបុគ្គលិកពេញសិទ្ធិដូចជា បុគ្គលិកបញ្ជូន កម្មករនិយោជិតមិនពេញម៉ោង ក្នុងករណី

- បន្តធ្វើការបាន6ខែ(*)
- មកធ្វើការលើសពី 80%នៃថ្ងៃធ្វើការទាំងអស់
- ធ្វើការលើសពី 5ថ្ងៃក្នុង1សប្តាហ៍ ឬលើសពី217ថ្ងៃក្នុង1ឆ្នាំ

ប្រសិនបើបំពេញលក្ខខណ្ឌ 3នេះ ចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលនឹងត្រូវបានផ្តល់ដូចបុគ្គលិកពេញសិទ្ធិដែរ (ទោះជាធ្វើការមិនលើសពី4ថ្ងៃក្នុង1សប្តាហ៍ ឬមិនលើសពី216ថ្ងៃក្នុង1ឆ្នាំក៏ដោយ ប្រសិនបើថេរវេលាធ្វើការកំណត់ក្នុង1សប្តាហ៍លើសពី 30ម៉ោង នោះនឹងទទួលបានចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលដូចបុគ្គលិកពេញសិទ្ធិដែរ។

ក្នុងករណីដែលថេរវេលាធ្វើការកំណត់ក្នុង1សប្តាហ៍មិនលើសពី 4ថ្ងៃ ហើយចំនួនថ្ងៃធ្វើការកំណត់ក្នុង1ឆ្នាំមិនលើសពី 216ថ្ងៃ ថេរវេលាធ្វើការកំណត់ក្នុង1សប្តាហ៍តិចជាង 30ម៉ោង នឹងទទួលបានចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលទៅតាមចំនួនថ្ងៃធ្វើការកំណត់នោះ។

(*) ចំពោះរបៀបគិតសម្រាប់បុគ្គលិកដែលមានកិច្ចសន្យាកំណត់ថេរវេលានៅពេលបន្តកិច្ចសន្យា ក្នុងករណីដែលការបន្តកិច្ចសន្យាមិនមានភាពខុសគ្នាពីការជួលបន្តឥតដាច់ នោះអំឡុងពេលធ្វើការមុនបន្តក៏រាប់បញ្ចូលដែរ។

# 2-3 ការងារបន្ថែមម៉ោង និងការងារថ្ងៃឈប់សម្រាក

## (1) ការងារបន្ថែមម៉ោង និងការងារថ្ងៃឈប់សម្រាក

- ក្នុងករណីខាងក្រោម សហគ្រាសត្រូវចុះកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ (ខាងក្រោមហៅថា "កិច្ចព្រមព្រៀង 36") ជាមួយសហជីពដែលមានកម្មករនិយោជិតភាគច្រើនជាសមាជិក ឬក្នុងករណីដែលគ្មានសហជីពដែលមានកម្មករនិយោជិតភាគច្រើនជាសមាជិក គឺបុគ្គលដែលតំណាងអោយកម្មករនិយោជិតភាគច្រើន។

① ក្នុងករណីអោយកម្មករនិយោជិតធ្វើការលើសថេរវេលាធ្វើការកំណត់ដោយច្បាប់
② ក្នុងករណីអោយធ្វើការនៅថ្ងៃឈប់សម្រាកកំណត់ដោយច្បាប់

- ចំនួនម៉ោងច្រើនបំផុតនៃការងារបន្ថែមម៉ោងត្រូវបានកំណត់ដោយច្បាប់។
- ច្បាប់ស្តង់ដារការងាកំណត់ចំនួនម៉ោងច្រើនបំផុតនៃការងារបន្ថែមម៉ោងជាទូទៅត្រឹម 45ម៉ោងក្នុង១ខែ 360ម៉ោងក្នុង១ឆ្នាំ។ (ទោះបីជាក្នុងករណីដែលមានមូលហេតុពិសេសបណ្តោះអាសន្នក៏ដោយ កម្រិតខ្ពស់បំផុតត្រឹម 720ម៉ោងក្នុង១ឆ្នាំ 100ម៉ោងក្នុង១ខែ(រួមទាំងការងារថ្ងៃឈប់សម្រាក) គិតជាមធ្យមសម្រាប់ច្រើនខែគឺ 80ម៉ោងក្នុង១ខែ(រួមទាំងការងារថ្ងៃឈប់សម្រាក) ហើយខែដែលអាចធ្វើការងារបន្ថែមម៉ោងលើសពី 45ម៉ោងបានមានត្រឹម 6ដងក្នុង១ឆ្នាំ។)

## (2) ប្រាក់ខែបន្ថែម

នៅពេលអោយធ្វើការលើសពីថេរវេលាធ្វើការកំណត់ដោយច្បាប់ ឬធ្វើការនៅថ្ងៃឈប់សម្រាកកំណត់ដោយច្បាប់ ក្រោមកិច្ចព្រមព្រៀង 36 សហគ្រាសត្រូវតែផ្តល់ប្រាក់ឈ្នួលបន្ថែម។



ចំណុចគួរដឹង៖

### វិធីគណនាប្រាក់ឈ្នួលបន្ថែម

① បន្ថែម25% នៅពេលអោយធ្វើការលើសថេរវេលាធ្វើការកំណត់ដោយច្បាប់
* ចំពោះការងារបន្ថែមម៉ោងដែលលើសពី 60ម៉ោងក្នុង1ខែ ត្រូវផ្តល់ប្រាក់ឈ្នួលបន្ថែមលើសពី 50%។
② នៅពេលអោយធ្វើការនៅថ្ងៃឈប់សម្រាកកំណត់ដោយច្បាប់ (ធ្វើការថ្ងៃឈប់សម្រាក) ត្រូវផ្តល់35%បន្ថែម
③ នៅពេលអោយធ្វើការនៅពេលយប់ចាប់ពីម៉ោង 10យប់រហូតដល់ម៉ោង 5ព្រឹក (ការងារវេនយប់) ត្រូវផ្តល់25%បន្ថែម
* ឧទាហរណ៍ក្នុងករណីធ្វើការបន្ថែមម៉ោងនិងការងារពេលយប់ (①+③) ត្រូវផ្តល់ប្រាក់ឈ្នួលបន្ថែមលើសពី50%។

ចំពោះប្រាក់ឈ្នួលបន្ថែមក៏មិនអាស្រ័យលើទម្រង់នៃការជួលដែរ គឺអនុវត្តចំពោះគ្រប់កម្មករនិយោជិតទាំងអស់។ ហេតុដូច្នេះហើយត្រូវផ្តល់ដល់ បុគ្គលិកបញ្ជូន បុគ្គលិកមានថេរវេលាកំណត់ កម្មករនិយោជិតមិនពេញម៉ោង អ្នកធ្វើការក្រៅម៉ោង ផងដែរ។

# 2-4 ការថែទាំសុខភាពមាតា / ការឈប់សម្រាកលំហែមាតុភាព / ការឈប់សម្រាកចិញ្ចឹមកូន / ការឈប់សម្រាកថែទាំ

## (1) នៅពេលមានផ្ទៃពោះ

- កម្មករនិយោជិតស្ត្រីដែលកំពុងពរពោះ (មួយភាគ, រួមទាំងកម្មការនីនិយោជិតក្រោយសម្រាលកូនដែលមិនទាន់បានពេញមួយឆ្នាំ។ ក្នុងករណីនេះ បន្ទាប់ពីនេះហៅថា "ស្ត្រីពរពោះឬស្ត្រីសម្រាលកូន") អាចស្នើសុំប្រការខាងក្រោមបាន៖



① ប្តូរទៅធ្វើការងារផ្សេងដែលមានភាពធូរស្រាល (តែនៅពេលពរពោះ)
② ថេរវេលាធ្វើការក្នុង1សប្តាហ៍ ឬក្នុង1ថ្ងៃមិនលើសពីថេរវេលាកំណត់ដោយច្បាប់ (រួមទាំងប្រព័ន្ធម៉ោងការងារមិនទៀងទាត់) (ស្ត្រីពរពោះឬស្ត្រីសម្រាលកូន)
③ មិនត្រូវធ្វើការងារបន្ថែមម៉ោង ការងារថ្ងៃឈប់សម្រាក ឬការងារពេលយប់ (ស្ត្រីពរពោះឬស្ត្រីសម្រាលកូន)

* សហគ្រាសត្រូវចាត់វិធានការខាងក្រោម។

① រកពេលវេលាអោយកម្មករនិយោជិតជាស្ត្រីអាចទៅទទួលការណែនាំសុខភាពសម្រាប់ស្ត្រីពរពោះ ឬទៅពិនិត្យសុខភាព
② ក្នុងករណីដែលកម្មករនិយោជិតជាស្ត្រីបានទទួលការណែនាំពីគ្រូពេទ្យឬឆ្មប នៅពេលទៅពិនិត្យសុខភាពជាដើម ត្រូវចាត់វិធានការដូចជាប្តូរម៉ោងធ្វើការឬសម្រាលការងារជាដើម ដើម្បីអោយកម្មករនិយោជិតជាស្ត្រីនោះអាចគោរពតាមសេចក្តីណែនាំរបស់គ្រូពេទ្យបាន។

* ប្រសិនបើអ្នកទទួលបានការណែនាំពីវេជ្ជបណ្ឌិត ឬឆ្មប សូមដាក់បញ្ជូនកាតណែនាំ និងគ្រប់គ្រងសុខភាពមាតុភាពទៅកាន់ក្រុមហ៊ុនរបស់អ្នក។
កាតណែនាំ និងគ្រប់គ្រងសុខភាពមាតុភាព គឺមានជាភាសាអង់គ្លេស ចិន និងព័រទុយហ្គាល់និងវៀតណាម ពីគេហទំព័រដូចខាងក្រោម៖

អំពីការថែទាំសុខភាពមាតុភាពសម្រាប់កម្មករនិយោជិតជាស្ត្រី
https://www.mhlw.go.jp/stf/seisakunitsuite/bunya/koyou_roudou/koyoukintou/seisaku05/index.html

- ក្រុមហ៊ុនត្រូវបានហាមឃាត់នូវករណីដូចខាងក្រោម៖

① មានគំរោងប្រើប្រាស់ការរៀបការ ការពរពោះ ឬការសម្រាលកូនរបស់កម្មករនិយោជិតជាស្ត្រីធ្វើជាហេតុផលឈប់ពីការងារ
② បញ្ឈប់ការងារដោយសារកម្មករនិយោជិតជាស្ត្រីរៀបការ
③ បញ្ឈប់ការងារ ឬអនុវត្តន៍ធ្វើអោយខាតបង់ប្រយោជន៍ដល់កម្មករនិយោជិតជាស្ត្រី ដោយសារកម្មករនិយោជិតស្ត្រីបានពរពោះ បានសម្រាលកូន បានស្នើសុំសម្រាកមុននិងក្រោយពេលសម្រាលកូនជាដើម

* ការបញ្ឈប់ការងារកម្មករនិយោជិតស្ត្រីកំពុងពរពោះ ឬស្ត្រីសម្រាលកូនគ្មានសុពលភាពឡើយ។ ប៉ុន្តែក្នុងករណីដែលសហគ្រាសអាចបញ្ជាក់បានថាការបញ្ឈប់ការងារនោះគឺមិនមែនដោយសារការពរពោះឬការសម្រាលកូននោះជាករណីដោយឡែក។

ធានានូវឱកាស និងផ្តល់អោយ ស្មើៗគ្នាសម្រាប់បុរស និងស្ត្រីក្នុងការងារ
https://www.mhlw.go.jp/stf/seisakunitsuite/bunya/koyou_roudou/koyoukintou/danjokintou/index.html

## (2) ការឈប់សម្រាកលំហែមាតុភាព

- ក្រុមហ៊ុនមិនត្រូវជួលកម្មករនិយោជិតស្ត្រីក្នុងអំឡុងពេលដូចខាងក្រោម៖

① ប្រសិនបើមានការស្នើរសុំដោយផ្ទាល់របស់កម្មករនិយោជិតស្ត្រី 6សប្តាហ៍មុនពេលគម្រោងនឹងសម្រាលកូន (ក្នុងករណីពរពោះកូនច្រើន 14 សប្តាហ៍)
② អំឡុងពេលមិនអាចអោយធ្វើការបានគឺ8សប្តាហ៍ក្រោយសម្រាលកូនរួច (ប៉ុន្តែ6សប្តាហ៍ក្រោយសម្រាលកូនរួច បើសាមីខ្លួនស្នើសុំ គឺអាចធ្វើការងារដែលគ្រូពេទ្យទទួលស្គាល់ថាគ្មានការប៉ះពាល់បាន)

## (3) ការឈប់សម្រាកចិញ្ចឹមកូន

- ការឈប់សម្រាកចិញ្ចឹមកូនគឺជាការឈប់សម្រាកដែលកម្មករនិយោជិតបុរសឬស្ត្រីអាចស្នើសុំបានមុនពេលកូនមានអាយុ1ឆ្នាំ (ក្នុងករណីខ្លះអាចដល់2ឆ្នាំ)។អាចបែងចែកឈប់ជា2 ដង។
- ការឈប់សម្រាកក្រោយសម្រាលប៉ាប៉ាគឺជាការឈប់ សម្រាកដែលកម្មករនិយោជិតបុរសឬស្ត្រី អាចស្នើរសុំបាន4សប្តាហ៍ក្នុងកំឡុងពេលក្រោយសម្រាលកូន8សប្តាហ៍។បន្ថែមពីការឈប់សម្រាកចិញ្ចឹមកូន អាចបែងចែកឈប់ជា2ដង។
- សហគ្រាស (រួមទាំងសហគ្រាសទទួលបុគ្គលិកបញ្ជូនផង) មិនត្រូវធ្វើរឿងខាងក្រោមឡើយ៖

① បដិសេធមិនអោយច្បាប់ឈប់សម្រាកចិញ្ចឹមកូន ការឈប់សម្រាកក្រោយសម្រាលប៉ាប៉ា
② បញ្ឈប់ការងារ ឬអនុវត្តន៍ធ្វើអោយខាតបង់ប្រយោជន៍ដោយសារការសុំច្បាប់ឈប់សម្រាកចិញ្ចឹមកូន ការឈប់សម្រាកក្រោយសម្រាលប៉ាប៉ា

## (4) ការឈប់សម្រាកថែទាំ

- កម្មករនិយោជិតអាចសុំច្បាប់ឈប់សម្រាកខាងក្រោមបាន (ច្បាប់ស្តីអំពីការឈប់សម្រាកចិញ្ចឹមកូននិងឈប់សម្រាកថែទាំ)

① ការឈប់សម្រាកដើម្បីថែទាំសមាជិកគ្រួសារគោលដៅដែលចាំបាច់ត្រូវការការថែទាំ
② ចំពោះរយៈពេលគឺសរុប 93ថ្ងៃសម្រាប់សមាជិកគ្រួសារគោលដៅ1នាក់ ដែលអាចបែងចែកបានរហូតដល់3ដង

- សហគ្រាស (អនុវត្តចំពោះសហគ្រាសទទួលការបញ្ជូនផងដែរ) មិនត្រូវធ្វើរឿងខាងក្រោមឡើយ។

① បដិសេធមិនអោយច្បាប់ឈប់សម្រាកថែទាំ
② បញ្ឈប់ការងារ ឬអនុវត្តន៍ធ្វើអោយខាតបង់ប្រយោជន៍ដោយសារការសុំច្បាប់ឈប់សម្រាកថែទាំ

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងការិយាល័យបរិស្ថានការងារ-នាយកដ្ឋានសមភាពនៃការិយាល័យការងារខេត្ត (ការិយាល័យ) ឬសេវាប្រឹក្សាការងារសម្រាប់ពលករបរទេស
* សូមមើលគេហទំព័ររាជធានីខេត្ត ឬតារាងទីតាំងនៃផ្នែកបរិស្ថាន-សមភាពការងារ (ការិយាល័យរង) ក្នុងគេហទំព័រខាងក្រោមនេះ។
នៅពេលអ្នកមកការិយាល័យរបស់យើងសម្រាប់ការពិគ្រោះយោបល់ យើងអាចជួយអ្នកក្នុង 13 (នៅពេលអ្នកពិគ្រោះជាមួយយើងតាមទូរស័ព្ទ យើងអាចជួយអ្នកបានតែជាភាសាជប៉ុនប៉ុណ្ណោះ។)
https://www.mhlw.go.jp/content/000177581.pdf

ចំណុចគួរដឹង៖

### ប្រាក់ឧបត្ថម្ភផ្សេងៗ

- អ្នកដែលកំពុងឈប់សម្រាកលំហែមាតុភាពហើយបំពេញលក្ខខណ្ឌចាំបាច់ អាចទទួលបានប្រាក់ឧបត្ថម្ភសម្រាលកូន។
  →សូមយោងទៅតាម 3-2 នៃជំពូកទី4។
- អ្នកដែលសុំច្បាប់ឈប់សម្រាកចិញ្ចឹមកូន ហើយបំពេញលក្ខខណ្ឌចាំបាច់ អាចទទួលបានប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូន។
  →សូមយោងទៅតាម 3-3 នៃជំពូកទី4 (1) និង (2)
- អ្នកដែលសុំច្បាប់ឈប់សម្រាកថែទាំ ហើយបំពេញលក្ខខណ្ឌចាំបាច់ អាចទទួលបានប្រាក់ឧបត្ថម្ភឈប់សម្រាកថែទាំ។
  ប្រាក់ឧបត្ថម្ភឈប់សម្រាកថែទាំ មានចំនួនស្មើនឹង 67%នៃប្រាក់ឈ្នួលមុនពេលឈប់សម្រាក ហើយសម្រាប់សមាជិកគ្រួសារគោលដៅ1នាក់បានត្រឹម3ដង សរុប93ថ្ងៃប៉ុណ្ណោះ។

## 2-5 ការលាឈប់ និងការបញ្ឈប់ការងារជាដើម

### (1) ការលាឈប់

- ការលាឈប់ពីសហគ្រាសគឺជាសិទ្ធិសេរីភាពរបស់កម្មករនិយោជិត ប៉ុន្តែការលាឈប់ដោយគោរពតាមសីលធម៌របស់បុគ្គលជាសមាជិកនៃសង្គមដូចខាងក្រោមក៏សំខាន់ដែរ។

① ត្រូវប្រាប់ទៅថ្នាក់លើអំពីបំណងចង់លាឈប់
② ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរ
③ ត្រូវប្រគល់ការងារទៅអ្នកផ្សេង



- នៅពេលសម្រេចចិត្តថាលាឈប់ ដំបូងវាជាការសំខាន់ដែលត្រូវស្រាវជ្រាវមើលថាតើនីតិវិធីលាឈប់នៃសហគ្រាសដែលខ្លួនធ្វើការយ៉ាងដូចម្តេច។
- ក្នុងករណីដែលនីតិវិធីនៃការលាឈប់ត្រូវបានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គឺត្រូវធ្វើតាមនោះ។
- នៅពេលស្នើសុំលាឈប់ បញ្ញត្តិនៃច្បាប់គឺខុសគ្នារវាងករណីមានការកំណត់ថេរវេលានៃកិច្ចសន្យានិងករណីគ្មាន។

### ក្នុងករណីគ្មានការកំណត់ថេរវេលានៃកិច្ចសន្យានៅក្នុងកិច្ចសន្យាការងារ

- ជាទូទៅ2សប្តាហ៍ក្រោយពេលស្នើសុំលាឈប់ កិច្ចសន្យាការងារនឹងត្រូវបញ្ចប់។

### ក្នុងករណីមានការកំណត់ថេរវេលានៃកិច្ចសន្យានៅក្នុងកិច្ចសន្យាការងារ

- ប្រសិនបើគ្មានមូលហេតុចាំបាច់ខានមិនបាន គឺមិនអាចលាឈប់នៅក្នុងអំឡុងពេលនៃកិច្ចសន្យាឡើយ។ ប៉ុន្តែក្នុងករណីដែលកិច្ចសន្យាកន្លងទៅបាន1ឆ្នាំ បើស្នើសុំលាឈប់គេអាចឈប់ពេលណាក៏បាន។
- ក្រោយការបញ្ចប់ថេរវេលានៃកិច្ចសន្យា ដើម្បីធ្វើការងារនៅកន្លែងដដែលបន្តទៅទៀត ចាំបាច់ត្រូវចុះកិច្ចសន្យាការងារថ្មី (បន្ត) (សូមមើលត្រង់ 1-3 (2))
 ដើម្បីបន្តកិច្ចសន្យាបែបនេះ គឺត្រូវការការយល់ព្រមពីភាគីទាំងពីរគឺសហគ្រាសនិងកម្មករនិយោជិត។

## (2) ការបញ្ឈប់ការងារ

### ការបញ្ឈប់ការងារ

- គឺជាការបញ្ចប់កិច្ចសន្យាការងារជាអត្តនោម័ត ដោយសហគ្រាស។
- ក្នុងករណីដែលការបញ្ឈប់ដោយខ្វះមូលហេតុសមស្របបែបវត្ថុវិស័យ និងមិនអាចទទួលយកបានតាមសុភវិនិច្ឆ័យនៃសង្គម ការបញ្ឈប់ការងារនោះគ្មានសុពលភាពឡើយ។ បានន័យថាការបញ្ឈប់ការងារ គឺសហគ្រាសមិនអាចធ្វើទៅបានដោយសេរីឡើយ។
- ហើយសហគ្រាសត្រូវចែងទុកជាមុននៅក្នុងបទបញ្ជាផ្ទៃក្នុង អំពីមូលហេតុបញ្ឈប់ការងារ (មូលហេតុអាចបញ្ឈប់ការងារ)។
- ក្នុងករណីដែលសហគ្រាសចង់បញ្ឈប់ការងាររបស់កម្មករនិយោជិត លើកលែងតែករណីលែងអាចបន្តអាជីវកម្មដោយសារមូលហេតុជៀសមិនបានដូចជាគ្រោះធម្មជាតិជាដើម ឬមានមូលហេតុបណ្តាលមកពីកម្មករនិយោជិត ត្រូវជូនដំណឹងអោយបានយ៉ាងហោច 30ថ្ងៃមុន ឬបង់ប្រាក់ឈ្នួលមធ្យមចំនួនលើសពី 30ថ្ងៃ (គេនិយមហៅថាសំណងសម្រាប់ការបញ្ឈប់ការងារ)។

### ការព្យួរការងារ

- ការព្យួរការងារគឺការមិនចុះ (មិនបន្ត) កិច្ចសន្យាការងារម្តងទៀតជាមួយកម្មករនិយោជិត នៅពេលដែលកិច្ចសន្យាការងារដែលមានកំណត់ថេរវេលា បានមកដល់កាលកំណត់។ (សូមមើលត្រង់ 1-3 (2))
- ការព្យួរការងារគឺខុសគ្នាជាមួយការបញ្ឈប់ការងារដែលសហគ្រាសបញ្ចប់កិច្ចសន្យាការងារជាអត្តនោម័ត នៅក្នុងអំឡុងពេលនៃកិច្ចសន្យា។
- នៅពេលដែលសហគ្រាសមានបំណងចង់ព្យួរការងារបុគ្គលខាងក្រោម ត្រូវជូនដំណឹងអោយបានយ៉ាងហោច30ថ្ងៃជាមុន៖

① អ្នកដែលបានបន្តកិច្ចសន្យាលើសពី3ដង
② អ្នកដែលបានបន្តធ្វើការលើសពី1ឆ្នាំ

- ក្នុងករណីដែលគ្មានមូលហេតុសមស្របបែបវត្ថុវិស័យក្នុងការព្យួរការងារ និងមិនអាចទទួលយកបានតាមសុភវិនិច្ឆ័យនៃសង្គម សហគ្រាសមិនអាចព្យួរការងារបានឡើយ ដូចជាក្នុងករណីខាងក្រោម៖

① ជាក់ស្តែងគឺអាចចាត់ទុកដូចជាការបញ្ឈប់ការងារ ដោយសារបានបន្តកិច្ចសន្យាជាច្រើនដងរួចមកហើយ

② កម្មករនិយោជិតមានមូលហេតុសមស្របក្នុងការរំពឹងថានឹងទទួលបានការបន្តការងារ

- ក្នុងករណីដែលគេមិនទទួលស្គាល់ការព្យួរការងារ នោះកិច្ចសន្យាការងារដែលមានថេរវេលាកំណត់នឹងបន្តក្រោមលក្ខខណ្ឌការងារដូចមុនពេលព្យួរការងារ។

ចំណុចគួរដឹង៖

### ការបញ្ឈប់ការងារដើម្បីរៀបចំរចនាសម្ព័ន្ធ



- ការបញ្ឈប់ការងារដើម្បីរៀបចំរចនាសម្ព័ន្ធគឺការបញ្ឈប់ការងារដើម្បីកាត់បន្ថយចំនួនកម្លាំងពលកម្ម ដោយសារស្ថានភាពសេដ្ឋកិច្ចមិនល្អ ឬស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសមិនល្អជាដើម។
- ការបញ្ឈប់ការងារដើម្បីរៀបចំរចនាសម្ព័ន្ធមានសុពលភាពឬគ្មាន នឹងត្រូវបានវិនិច្ឆ័យលើប្រការខាងក្រោម។
  - ① ភាពចាំបាច់ក្នុងការកាត់បន្ថយកម្មករនិយោជិត
    ការកាត់បន្ថយកម្មករនិយោជិតដោយសារស្ថានភាពសេដ្ឋកិច្ចមិនល្អ ឬស្ថានភាពហិរញ្ញវត្ថុមិនល្អ ផ្អែកលើការចាំបាច់ខ្លាំងក្នុងការគ្រប់គ្រងសហគ្រាស
  - ② ការខិតខំប្រឹងប្រែងបញ្ចៀសការបញ្ឈប់ការងារ
    បានខិតខំបញ្ចៀសការបញ្ឈប់ការងារ ដោយប្រើមធ្យោបាយផ្សេងក្រៅពីការបញ្ឈប់ការងារ (ឧទាហរណ៍: ការផ្លាស់ប្តូរកន្លែងការងារ ប្រកាសរកអ្នកមានបំណងលាឈប់ជាដើម)
  - ③ ភាពសមស្របនៃការជ្រើសរើសកម្មករនិយោជិតគោលដៅសម្រាប់ការបញ្ឈប់ការងារដើម្បីរៀបចំរចនាសម្ព័ន្ធ
    គោលការណ៍ក្នុងការជ្រើសរើសកម្មករនិយោជិតគោលដៅសម្រាប់ការបញ្ឈប់ការងារដើម្បីរៀបចំរចនាសម្ព័ន្ធមានភាពវត្ថុវិស័យ សមស្រប ហើយការអនុវត្តន៍មានភាពស្មើភាពគ្នា
  - ④ ភាពត្រឹមត្រូវនៃនីតិវិធីបញ្ឈប់ការងារ
    ធ្វើការពន្យល់អោយយល់ព្រមអំពីភាពចាំបាច់នៃការបញ្ឈប់ការងារ ពេលវេលា ចំនួន វិធី ទៅកាន់សហជីព និងកម្មករនិយោជិត។

## (3) ការក្ស័យធនរបស់សហគ្រាស

យោងតាមច្បាប់ទាក់ទងនឹងការធានាអោយមានប្រាក់ឈ្នួលសម្រាប់បើកជាដើម គេបានបង្កើតប្រព័ន្ធដែលរដ្ឋាភិបាលបើកប្រាក់ឈ្នួលដែលសហគ្រាសមិនទាន់បើកអោយជំនួសសិន នៅពេលដែលសហគ្រាសក្ស័យធនហើយមិនអាចបើកប្រាក់បៀវត្សបាន។

ដោយសារប្រាក់ឈ្នួលមួយផ្នែកដែលមិនត្រូវបានបើក អាចត្រូវបានបង់ជំនួស សូមពិគ្រោះជាមួយការិយាល័យស្តង់ដារការងារ។

## (4) របបនិកម្មភាពការងារ (ប្រាក់ឧបត្ថម្ភមូលដ្ឋាន)

### ក្នុងករណីបាត់បង់ការងារ

អ្នកដែលចូលក្នុងរបបនិកម្មភាពការងារ ក្នុងករណីដែលបានបំពេញលក្ខខណ្ឌខាងក្រោម ជាទូទៅអាចទទួលបានប្រាក់ឧបត្ថម្ភមូលដ្ឋានពីរបបនិកម្មភាពការងារ៖

- លក្ខខណ្ឌអាចទទួលប្រាក់ឧបត្ថម្ភមូលដ្ឋាន
  ① អ្នកកំពុងបាត់បង់ការងារធ្វើ
  ② អ្នកស្ថិតនៅក្នុងស្ថានភាពអាចធ្វើការងារបាន ហើយមានឆន្ទៈចង់រកការងារ
  ③ អ្នកដែលបានធ្វើការក្នុងមួយខែ ស្មើឬច្រើនជាង 11ថ្ងៃ ឬបានធ្វើការដោយគិតជាម៉ោងមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួល ពី 80ម៉ោងឡើងទៅក្នុងមួយខែ ហើយចំនួនខែទាំងនោះមានយ៉ាងតិច 12ខែ ក្នុងកម្លុងពេល 2ឆ្នាំ មុនថ្ងៃឈប់ពីសហគ្រាស
  (ប៉ុន្តែក្នុងករណីដែលមូលហេតុនៃការឈប់គឺដោយសារការក្ស័យធន ឬដោយសារការបញ្ឈប់ការងារដោយមូលហេតុរបស់សហគ្រាស ឬដោយសារកិច្ចសន្យាការងារមានថេរវេលាកំណត់មិនត្រូវបានបន្តជាដើម គឺអ្នកដែលបានធ្វើការក្នុងមួយខែ ស្មើឬច្រើនជាង 11ថ្ងៃ ឬបានធ្វើការដោយគិតជាម៉ោងមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួល ពី 80ម៉ោងឡើងទៅក្នុងមួយខែ ហើយចំនួនខែទាំងនោះមានយ៉ាងតិច 6ខែ ក្នុងកម្លុងពេល 1ឆ្នាំ មុនថ្ងៃឈប់ពីសហគ្រាស។)

## ពេលវេលាចាប់ផ្តើមទទួលប្រាក់ឧបត្ថម្ភ

ពេលវេលាចាប់ផ្តើមផ្តល់ប្រាក់ឧបត្ថម្ភខុសគ្នាទៅតាមមូលហេតុនៃការបាត់បង់ការងារ។

① ក្នុងករណីត្រូវបានបញ្ឈប់ការងារដោយមូលហេតុរបស់សហគ្រាស ឬលាឈប់ពីការងារតាមការណែនាំរបស់សហគ្រាស
ក្រោយពេលចុះឈ្មោះស្វែងរកការងារ (*1)នៅ Hello Work (ការិយាល័យស្ថេរភាពការងារសាធារណៈ) ហើយទទួលបង្កាន់ដៃបញ្ជាក់ការលាចាកពីការងារ ក្រោយពេលដែលថ្ងៃដែលស្ថិតក្នុងស្ថានភាពគ្មានការងារធ្វើសរុប7ថ្ងៃបានកន្លងទៅ។

② ក្នុងករណីលាឈប់ពីការងារដោយមូលហេតុផ្ទាល់ខ្លួនឬត្រូវបានបញ្ឈប់ការងារដោយសារមូលហេតុបណ្តាលមកពីសមីខ្លួន
ក្រោយពេលចុះឈ្មោះស្វែងរកការងារ (*1) នៅ Hello Work ហើយទទួលបង្កាន់ដៃបញ្ជាក់ការលាចាកពីការងារ ក្រោយពេលដែលថ្ងៃដែលស្ថិតក្នុងស្ថានភាពគ្មានការងារធ្វើសរុប7ថ្ងៃបានកន្លងទៅ និងក្រោយរយៈពេល 2ខែបន្ថែមទៀតបានកន្លងផុត (ត្រឹម 2ដង ក្នុងកម្លុងពេល 5ឆ្នាំ សម្រាប់ការឈប់ពីការងារដោយមូលហេតុផ្ទាល់ខ្លួន) (*2)។

(*1) ស្តីពី HelloWork នៅកន្លែងអ្នកស្នាក់នៅឬសកម្មភាពរកការងារក្រោយពេលដាក់ពាក្យស្នើសុំហើយ សូមមើលក្នុង “(5) សកម្មភាពរកការងារ”។

(*2) គឺ 3 ខែសម្រាប់ករណីឈប់ពីការងារដោយមូលហេតុផ្ទាល់ខ្លួន ពីលើកទី 3 ទៅក្នុងកម្លុងពេល 5ឆ្នាំ

③ ក្នុងករណីដែលត្រូវគេបញ្ឈប់ពីការងារដោយសារតែមូលហេតុធ្ងន់ធ្ងរក្នុងទំនួលខុសត្រូវរបស់សាមីខ្លួន
ក្រោយថ្ងៃដែលបានដាក់ពាក្យសុំរកការងារ ហើយបានទទួលបង្កាន់ដៃបញ្ជាក់ការលាចាកពីការងារ, 7កន្លងផុតពីថ្ងៃដែលបាត់បង់ការងារ, និងក្រោយ 3ខែកន្លងផុត។

នៅពេលលាឈប់ពីការងារ ប្រសិនបើដាក់មូលហេតុនៃការលាឈប់ថាមកពីមូលហេតុផ្ទាល់ខ្លួន ដែលតាមការពិត ត្រូវបានបញ្ឈប់ការងារដោយមូលហេតុរបស់សហគ្រាស ឬធ្វើតាមការណែនាំរបស់សហគ្រាស នោះនឹងមានការខាតប្រយោជន៍នៅពេលទទួលប្រាក់ឧបត្ថម្ភមូលដ្ឋាន ហេតុដូច្នេះហើយនៅពេលទទួលយកបង្កាន់ដៃបញ្ជាក់ការលាចាកពីការងារ ត្រូវពិនិត្យអោយបានជាក់លាក់ត្រង់កន្លែងមូលហេតុនៃការលាចាកពីការងារ។

## រយៈពេលនៃការផ្តល់តារាកាលិក

មានការប្រែប្រួលទៅតាមមូលហេតុនៃការលាឈប់ពីការងារ និងអាយុជាដើម។ ជាទូទៅគឺបានត្រឹម 90 ទៅ 330 ថ្ងៃ។

## (5) សកម្មភាពរកការងារ

អាចទៅធ្វើសកម្មភាពរកការងារថ្មី តាម HelloWork ជាដើម។

នៅតាមកន្លែងពិគ្រោះអំពីការងារនៃ Hello Work គេអាចទទួលនូវសេវាកម្មទាំងអស់ ដូចខាងក្រោមនេះបាន ដោយមិនយកកម្រៃ។



① ការពិគ្រោះអំពីការងារ

គេឆ្លើយតបចំពោះការពិគ្រោះផ្សេងៗពាក់ព័ន្ធនឹងការរកការងារឬការងារ។សូមទៅពិគ្រោះមើលសិន ទោះជាបញ្ហាអ្វីក៏ដោយ។

② ការរកក្រុមហ៊ុនដែលចង់ធ្វើការ

នៅ Hello Work គេមានព័ត៌មានជាច្រើនស្តីពីការរកបុគ្គលិកធ្វើការរបស់ក្រុមហ៊ុន។ ព័ត៌មានរកបុគ្គលិកធ្វើការទាំងនេះ អាចមើលតាមកុំព្យូទ័ររបស់ Hello Work ឬក៏តាមស្មាតហ្វូនរបស់អ្នកបាន។

③ ការណែនាំទៅឱ្យក្រុមហ៊ុនដែលអ្នកចង់ធ្វើការ

ពេលដែលរកឃើញក្រុមហ៊ុនដែលចង់ចូលធ្វើការ សូមទៅ Hello Work។ គេនឹងផ្តល់មតិយោបល់ស្តីពីក្រុមហ៊ុននោះ និងចំណុចសំខាន់ៗនៃការរកបុគ្គលិកធ្វើការ។ ក្រៅពីនេះ គេនឹងជូន "លិខិតណែនាំ" ជូនអ្នក ដើម្បីយកទៅទទួលការសម្ភាសន៍ជ្រើសរើសបុគ្គលិកធ្វើការ។

④ ជំនួយក្នុងការរកការងារ

នៅ Hello Work គេមានការណែនាំ និងពិនិត្យមើលឯកសារដាក់ពាក្យសុំធ្វើការទៅក្រុមហ៊ុន ដូចជាឯកសារប្រវត្តិរូប ឬប្រវត្តិការងារ ជាដើម ហើយក៏ការណែនាំស្តីពីសុភាវធម៌ របៀបទទួលការសម្ភាសន៍ ធ្វើការសាកល្បងសម្ភាសន៍ ព្រមទាំងមានរៀបចំនូវសិក្ខាសាលាផ្សេងៗផងដែរ។

សូមឆែកមើល Hello Work នៅតាមកន្លែងអ្នករស់នៅ។

https://www.mhlw.go.jp/content/000637894.pdf

មាន Hello Work ដែលមានអ្នកបកប្រែផងដែរ។

https://www.mhlw.go.jp/content/000592865.pdf

បើសិនជាមិនអាចទៅ Hello Work ផ្ទាល់ អាចទូរស័ព្ទទៅ Hello Work ជាភាសាបរទេសបាន។

https://www.mhlw.go.jp/content/000673000.pdf

អ្វីៗដែលមានពន្យល់ក្នុង 2-5 នេះ មានពន្យល់លំអិតក្នុង “តារាងពិនិត្យ ពេលប្រើសេវាកម្ម Hello Work សម្រាប់ជនបរទេស” ។

https://www.mhlw.go.jp/content/000678121.pdf

បើសិនជាចង់ពិគ្រោះអំពីប្រាក់ឈ្នួល ការបញ្ឈប់ពីការងារ ជាដើម ឬអំពីលក្ខខណ្ឌការងារជាដើមសូមមើលខាងក្រោមនេះ។

https://www.check-roudou.mhlw.go.jp/soudan/foreigner.html

ក្នុងករណីដែលមិនយល់ពាក្យពាក់ព័ន្ធនឹងការងារ ឬសន្តិសុខសង្គម អាចស្រាវជ្រាវមើលតាម “កម្រងពាក្យដែលមានផលប្រយោជន៍សម្រាប់ការគ្រប់គ្រងការងារ ជាពហុភាសា” តាមឯកសារខាងក្រោមនេះ។

https://www.mhlw.go.jp/seisakunitsuite/bunya/koyou_roudou/koyou/jigyounushi/tagengoyougosyu/index.html

# 3 សុខភាពនិងសុវត្ថិភាពការងារ

## 3-1 សុវត្ថិភាព និងបរិស្ថានកន្លែងធ្វើការល្អ

មានច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារដើម្បីធានាអោយបាននូវសុវត្ថិភាព និងសុខភាពរបស់កម្មករនិយោជិត។ ច្បាប់នេះដាក់កាតព្វកិច្ចអោយសហគ្រាសចាត់វិធានការចាំបាច់ធ្វើយ៉ាងណាកុំអោយកម្មករនិយោជិតមានគ្រោះថ្នាក់ ឬមានជំងឺជាដើមដោយសារការងារ។

### (1) ខ្លឹមសារនៃច្បាប់ស្តីពីសុវត្ថិភាពនិងអនាម័យ

សហគ្រាសមានកាតព្វកិច្ចខាងក្រោម៖

- ត្រូវចាត់វិធានការចាំបាច់ដើម្បីបង្ការគ្រោះថ្នាក់ដោយម៉ាស៊ីន ឧបករណ៍ និងសម្ភារៈផ្សេងៗ ជាអាទ៍។
- ត្រូវធ្វើការពិនិត្យសុខភាពដោយគ្រូពេទ្យនៅពេលចូលធ្វើការដំបូង និង1ដងក្នុង1ឆ្នាំក្រោយចូលធ្វើការ (កម្មករនិយោជិតត្រូវតែទទួលយកការពិនិត្យសុខភាពនោះ)
- ធ្វើការត្រួតពិនិត្យកម្រិតស្ត្រេសរបស់កម្មករនិយោជិត ហើយត្រូវចាត់វិធានការចាំបាច់ដូចជាប្តូរភារកិច្ចការងារជាដើមដោយយោងតាមលទ្ធផលនោះ (ចំពោះសហគ្រាសដែលមានចំនួនកម្មករនិយោជិតតិចជាង 50 នាក់គឺមានកាតព្វកិច្ចខិតខំប្រឹងប្រែង)
- ត្រូវក្តាប់អោយបាននូវថេរវេលាធ្វើការរបស់កម្មករនិយោជិតក្នុងគោលបំណងថែទាំសុខភាព
- ចំពោះកម្មករនិយោជិតដែលមានការនឿយហត់រយៈពេលយូរអង្វែងដោយសារការធ្វើការរយៈពេលវែង ត្រូវទទួលការសម្ភាសន៍និងណែនាំពីគ្រូពេទ្យ ហើយត្រូវចាត់វិធានការចាំបាច់ដូចជាប្តូរភារកិច្ចការងារជាដើមដោយយោងតាមលទ្ធផលនោះ ។ល។

### (2) ការពិនិត្យសុខភាព។ល។

ការពិនិត្យសុខភាព និងការត្រួតពិនិត្យកំរិតស្ត្រេសរបស់កម្មករនិយោជិតយោងតាមច្បាប់ស្តីអំពីសុវត្ថិភាពនិងសុខភាពការងារ ក្រៅពីអនុវត្តចំពោះបុគ្គលិកពេញសិទ្ធិ ក៏ត្រូវអនុវត្តចំពោះ បុគ្គលិកបញ្ជូន បុគ្គលិកមានថេរវេលាកំណត់ កម្មករនិយោជិតមិនពេញម៉ោង និងអ្នកធ្វើការក្រៅម៉ោង ដែលបំពេញ 2 ចំណុចខាងក្រោមផងដែរ៖

- ត្រូវបានជួលដោយកិច្ចសន្យាដែលគ្មានការកំណត់ថេរវេលា (ក្នុងករណីត្រូវបានជួលដោយកិច្ចសន្យាដែលមានការកំណត់ថេរវេលា គឺនៅពេលដែលគេមានគំរោងជួលលើសពី1ឆ្នាំ ឬត្រូវបានជួលលើសពី1ឆ្នាំតាមរយៈការបន្តកិច្ចសន្យា)
- ថេរវេលាធ្វើការកំណត់ក្នុង1សប្តាហ៍ មានចំនួនលើសពី 3 ភាគ 4 នៃថេរវេលាធ្វើការកំណត់ក្នុង1សប្តាហ៍របស់កម្មករនិយោជិតទូទៅដែលធ្វើការងារប្រភេទដូចគ្នា នៅក្នុងសហគ្រាសជាមួយគ្នា។

### (3) ការសម្ភាសន៍និងណែនាំពីគ្រូពេទ្យ

ការសម្ភាសន៍និងណែនាំពីគ្រូពេទ្យដល់កម្មករនិយោជិតធ្វើការរយៈពេលវែងយោងតាមច្បាប់ស្តីអំពីសុវត្ថិភាពនិងសុខភាព ក្រៅពីអនុវត្តន៍ចំពោះបុគ្គលិកពេញសិទ្ធិ ក៏ត្រូវអនុវត្តចំពោះ បុគ្គលិកបញ្ជូន បុគ្គលិកមានថេរវេលាកំណត់ កម្មករនិយោជិតមិនពេញម៉ោង ឬអ្នកធ្វើការក្រៅម៉ោង ដែលបំពេញលក្ខខណ្ឌខាងក្រោមផងដែរ៖

- ការងារបន្ថែមម៉ោង និងការងារថ្ងៃឈប់សម្រាកមានចំនួនម៉ោងលើសពី 80ម៉ោងក្នុង1ខែ និងត្រូវបានគេទទួលស្គាល់ថាមានការនឿយហត់យូរអង្វែង (តាមរយៈការផ្តល់ដំណឹង)
  ប៉ុន្តែចំពោះបុគ្គលក្នុងករណីខាងក្រោម ទោះជាមិនផ្តល់ដំណឹងក៏ជាគោលដៅត្រូវទទួលការសម្ភាសន៍និងណែនាំពីគ្រូពេទ្យដែរ។

① អ្នកធ្វើការងារទាក់ទងនឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលការងារបន្ថែមម៉ោង និងការងារថ្ងៃឈប់សម្រាកមានចំនួនម៉ោងលើសពី 100ម៉ោង

② បុគ្គលដែលជាកម្មវត្ថុនៃប្រព័ន្ធអ្នកមានវិជ្ជាជីវៈកម្រិតខ្ពស់ ដែលនៅក្នុងករណីដែលចំនួនម៉ោងថែទាំសុខភាពក្នុង1សប្តាហ៍ (ម៉ោងសរុបទាំងធ្វើការនៅក្នុងសហគ្រាស និងម៉ោងធ្វើការនៅក្រៅសហគ្រាស) លើសពី 40ម៉ោង ហើយម៉ោងដែលលើសនោះមានចំនួនចាប់ពី 100ម៉ោងក្នុង1ខែ

នេះគឺជាកន្លែងទទួលការពិគ្រោះអំពីសុខភាព ឬសុវត្ថិភាពការងារ
(ការិយាល័យប្រឹក្សា និងគាំទ្រជនបរទេស)
https://jsite.mhlw.go.jp/tokyo-roudoukyoku/fresc.html

## 3-2 តាវកាលិកសម្រាប់គ្រោះថ្នាក់ការងារ ឬជំងឺជាដើម (របបហានិភ័យការងារ)

ក្នុងករណីដែលកម្មករនិយោជិតមានរបួស ឬជំងឺជាដើមដោយសារការងារ គឺអាចទទួលបានតាវកាលិកពីរបបហានិភ័យការងារ។

### (1) ការទទួលតាវកាលិកពីរបបហានិភ័យការងារ

- ក្នុងករណីព្យាបាលនៅមន្ទីរពេទ្យកំណត់សម្រាប់ហានិភ័យការងារ ជាទូទៅមិនអស់ថ្លៃព្យាបាលឡើយ (ក្នុងករណីក្រៅពីមន្ទីរពេទ្យដៃគូ សមីខ្លួនត្រូវបង់ថ្លៃចំណាយសិន ទើបទទួលបានថ្លៃចំណាយដែលបានរ៉ាប់រងជាក្រោយតាមរយៈការទាមទារទៅការិយាល័យស្តង់ដារការងារ។)។
- ក្នុងករណីត្រូវឈប់សម្រាកពីការងារគឺអាចទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃឈប់សម្រាកការងារ (និយោជកផ្តល់60%នៃប្រាក់ឈ្នួលមធ្យមសម្រាប់ការឈប់សម្រាកត្រឹមថ្ងៃទី3 របបហានិភ័យការងារផ្តល់តាវកាលិកស្មើនឹង80%នៃប្រាក់ឈ្នួលមធ្យមចាប់ពីថ្ងៃឈប់សម្រាកទី4)។
- ក្នុងករណីដែលកម្មករនិយោជិតបានបាត់បង់ជីវិត មានការផ្តល់តាវកាលិកឧត្តរជីវី (សំណង) ដល់សិទ្ធិវន្តជាអាទ៍។
- សហគ្រាសមិនអាចបញ្ឈប់ការងារកម្មករនិយោជិតក្នុងអំឡុងពេលឈប់សម្រាកការងារ ដើម្បីព្យាបាលរបួស ឬជំងឺដោយសារគ្រោះថ្នាក់ការងារ និងអំឡុងពេល 30ថ្ងៃបន្ទាប់បានឡើយ។

## (2) ចំណុចសំគាល់ផ្សេងទៀត

- ក្រៅពីរបួស ឬជំងឺក្នុងពេលធ្វើការងារជាដើម របួសក្នុងពេលធ្វើដំណើរទៅមកធ្វើការជាដើម ក៏ជាកម្មវត្ថុផងដែរ។
- រោគផ្លូវចិត្តដូចជាជំងឺបាក់ទឹកចិត្ត (Depression) ជាដើមដែលកើតឡើងដោយសារការងារ ដូចជាការធ្វើការរយៈពេលវែងជាដើមក៏ជាកម្មវត្ថុនៃរបបហានិភ័យការងារផងដែរ។
- ទោះជាករណីដែលមានជម្ងឺ ដោយមូលហេតុការងារនៅជប៉ុន ក្រោយពេលត្រឡប់ទៅវិញក៏ដោយ ក៏ជាកម្មវត្ថុនៃរបបហានិភ័យការងារដែរ ។
- ក្នុងករណីមានរបួស ឬជំងឺដោយសារការធ្វើការងារ គេមិនអាចប្រើរបបថែទាំសុខភាពបានឡើយ។
- នៅពេលមានបញ្ហាទាក់ទងនឹងរបួស ឬជំងឺក្នុងពេលធ្វើការងារ ឬពេលធ្វើដំណើរទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការជាដើម សូមពិគ្រោះជាមួយការិយាល័យស្តង់ដារការងារ។
- របបហានិភ័យការងារ ក្រៅពីអនុវត្តចំពោះបុគ្គលិកពេញសិទ្ធិ ក៏អនុវត្តចំពោះបុគ្គលិកបញ្ជូន បុគ្គលិកមានថេរវេលាកំណត់ កម្មករនិយោជិតមិនពេញម៉ោង និងអ្នកធ្វើការក្រៅម៉ោង ផងដែរ។
- ជាទូទៅសហគ្រាសដែលជួលកម្មករនិយោជិតតែ1នាក់ក៏ដោយ គឺមានកាតព្វកិច្ចចុះបញ្ជិកាក្នុងរបបហានិភ័យការងារ ហើយភាគទានគឺជាបន្ទុកទាំងស្រុងរបស់សហគ្រាស។

ខ្លឹមសារលំអិតស្តីពីនីតិវិធីនៃរបបហានិភ័យការងារ មានសរសេរនៅក្នុងគេហទំព័រខាងក្រោមនេះ ។

https://www.mhlw.go.jp/stf/seisakunitsuite/bunya/koyou_roudou/roudoukijun/gyousei/rousai/gaikoku-pamphlet.html

## 3-3 ការហាមឃាត់មិនអោយរើសអើងភេទ

## (1) នៅពេលស្វែងរកការងារ

- ការរើសអើងភេទក្នុងការជ្រើសរើសនិងផ្តល់ការងារដល់កម្មករនិយោជិត ត្រូវបានហាមឃាត់។

## (2) ក្រោយពេលចូលធ្វើការ

- ការរើសអើងភេទត្រូវបានហាមឃាត់ ទាក់ទងនឹងប្រការខាងក្រោម៖

① ការបែងចែកកន្លែងធ្វើការ ការដំឡើងឋានៈ ការបន្ទាបឋានៈ ការអប់រំហ្វឹកហ្វឺន
② អត្ថប្រយោជន៍សុខុមាលភាពក្នុងកំរិតមួយ
③ ការប្តូរប្រភេទការងារ ឬទម្រង់នៃការជួល
④ ការណែនាំអោយលាឈប់ពីការងារ ការចូលនិវត្តន៍ ការបញ្ឈប់ការងារ ការបន្តកិច្ចសន្យាការងារ

- ការយកភាពជាស្ត្រីមកធ្វើជាហេតុផលក្នុងការផ្តល់ប្រាក់ឈ្នួលតិចជាងបុរស ឬច្រើនជាងបុរសត្រូវបានហាមឃាត់។

ស្តីពីព័ត៌មានលំអិត សូមសួរទៅកាន់ផ្នែកបរិស្ថាន-សមភាពការងារ (ការិយាល័យរង) នៃនាយកដ្ឋានការងាររាជធានីខេត្តឬកន្លែងពិគ្រោះទូទៅអំពីការងារ។
*នៅពេលអ្នកមកការិយាល័យរបស់យើងសម្រាប់ការពិគ្រោះយោបល់ យើងអាចជួយអ្នកក្នុង 13 ភាសា។ (នៅពេលអ្នកពិគ្រោះជាមួយយើងតាមទូរស័ព្ទ យើងអាចជួយអ្នកបានតែជាភាសាជប៉ុនប៉ុណ្ណោះ។)

https://www.mhlw.go.jp/content/000177581.pdf

## 3-4 វិធានការទប់ស្កាត់ការបៀតបៀន

សហគ្រាសមានកាតព្វកិច្ចចាត់វិធានការដូចជារៀបចំរចនាសម្ព័ន្ធចាំបាច់ ដោយទទួលការពិគ្រោះពីកម្មករនិយោជិត ហើយឆ្លើយតបអោយបានសមស្រប ដើម្បីកុំអោយខូចខាតបរិស្ថានការងាររបស់កម្មករនិយោជិតដោយសារអំពើបៀតបៀនដូចខាងក្រោម (ស្ដីពី④ការបៀតបៀនដោយអំណាច រហូតដល់ថ្ងៃទី 31 ខែមីនា ឆ្នាំ 2022 សម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម គឺជាកាតព្វកិច្ចខំប្រឹងប្រែង) ៖

① ការបៀតបៀនផ្លូវភេទ
② ការបៀតបៀនពាក់ព័ន្ធនឹងការមានផ្ទៃពោះ ការសម្រាលកូនជាដើម
③ ការបៀតបៀនពាក់ព័ន្ធនឹងការឈប់សម្រាកចិញ្ចឹមកូននឹងការថែទាំជាដើម
④ ការបៀតបៀនដោយអំណាច (*)




(*) ការធ្វើអោយខូចខាតបរិស្ថានការងារដោយសារអកប្បកិរិយាលើសពីព្រំដែនចាំបាច់និងសមស្របសម្រាប់ការងារ ដោយសំអាងលើតួនាទីការងារ

ការពិគ្រោះយោបល់គឺ មានទទួលនៅ ផ្នែកបរិស្ថាន-សមភាពការងារ (ការិយាល័យរង) នៃនាយកដ្ឋានការងាររាជធានីខេត្ត ឬកន្លែងប្រឹក្សាយោបល់លើបញ្ហាការងារទូទៅ។
*នៅពេលអ្នកមកការិយាល័យរបស់យើងសម្រាប់ការពិគ្រោះយោបល់ យើងអាចជួយអ្នកក្នុង ១៣ ភាសា។
(នៅពេលអ្នកពិគ្រោះជាមួយយើងតាមទូរស័ព្ទ យើងអាចជួយអ្នកបានតែជាភាសាជប៉ុនប៉ុណ្ណោះ។)
(ផ្នែកបរិស្ថាន-សមភាពការងារ (ការិយាល័យរង) នៃនាយកដ្ឋានការងាររាជធានីខេត្ត)
https://www.mhlw.go.jp/content/000177581.pdf

(កន្លែងពិគ្រោះទូទៅអំពីការងារ)
https://www.mhlw.go.jp/general/seido/chihou/kaiketu/soudan.html

ខិតប័ណ្ណរបស់យើងស្ដីពីវិធានការប្រឆាំងនឹងការបៀតបៀនមានជា 13 ភាសានៅលើគេហទំព័រខាងក្រោម។
https://www.mhlw.go.jp/stf/seisakunitsuite/bunya/koyou_roudou/koyoukintou/seisaku06/index.html

## 3-5 គោលការណ៍ណែនាំក្នុងការគ្រប់គ្រងការជួលពលរដ្ឋបរទេស

- កម្មករនិយោជិតបរទេសដែលកំពុងធ្វើការក្នុងវិស័យជំនាញនិងបច្ចេកទេស ឬពលរដ្ឋបរទេសដែលមានបំណងចង់ធ្វើការនៅប្រទេសជប៉ុននៅពេលខាងមុខ ត្រូវការអោយមានការយកចិត្តទុកដាក់អោយបានសមស្រប អោយមានការរៀបចំបរិស្ថានដែលខ្លួនអាចបញ្ចេញសមត្ថភាពរបស់ខ្លួនបានដោយគ្មានការព្រួយបារម្ភ នៅពេលធ្វើការនៅប្រទេសជប៉ុន។
- “ជាគោលការណ៍ណែនាំអោយម្ចាស់សហគ្រាសដោះស្រាយអោយបានសមស្របពាក់ព័ន្ធនឹងការកែលំអលើការគ្រប់គ្រងការជួលពលរដ្ឋបរទេស” (ហៅថាគោលការណ៍ណែនាំក្នុងការគ្រប់គ្រងការជួលពលរដ្ឋបរទេស) គឺជាបញ្ញត្តិដើម្បីអោយម្ចាស់សហគ្រាសដោះស្រាយអោយបានសមស្របពាក់ព័ន្ធនឹងការកែលំអលើការគ្រប់គ្រងការជួលពលរដ្ឋបរទេស និងការគាំទ្រដល់ការរកការងារជាថ្មី។

- Hello Work ធ្វើការផ្តល់យោបល់ ឬណែនាំដោយផ្អែកលើគោលការណ៍ណែនាំនេះ នៅពេលចុះទៅពិនិត្យនៅសហគ្រាសដែលជួលកម្មករនិយោជិតបរទេសជាដើម។

គោលការណ៍ណែនាំក្នុងការគ្រប់គ្រងការជួលពលរដ្ឋបរទេស

https://www.mhlw.go.jp/content/000601382.pdf

ខិត្តប័ណ្ណទាក់ទងនឹងច្បាប់ស្តីពីការជួលជនបរទេស

https://www.mhlw.go.jp/content/001261967.pdf

ចំពោះការពិគ្រោះយោបល់លើបញ្ហាការងារមានទទួលនៅកន្លែងពិគ្រោះ
ទូទៅអំពីការងារ។ប្រសិនបើមិនដឹងថាត្រូវទាក់ទងទៅផ្នែកណានៅអ្វីដែលមានសរសេរនៅក្នុង
1 ដល់ 3សូមទាក់មកយើងខ្ញុំ។នៅបញ្ជរពិគ្រោះយោបល់យើងទទួលពិគ្រោះយោបល់ជា 13 ភាសា។
ការិយាល័យអាចជួយភ្ញៀវដែលមកពិគ្រោះជា 13 ភាសាផ្សេងៗគ្នា។
(ការប្រឹក្សាតាមទូរសព្ទគឺមានតែជាភាសាជប៉ុនប៉ុណ្ណោះ។)

https://www.mhlw.go.jp/general/seido/chihou/kaiketu/soudan.html

# 4 របបសន្តិសុខសង្គម និងការធានារ៉ាប់រងការងារ

របបសន្តិសុខសង្គម និងការធានារ៉ាប់រងការងារ គឺជាប្រព័ន្ធត្រៀមសម្រាប់ហានិភ័យផ្សេងៗក្នុងជីវិត ដោយធ្វើការប្រមូលប្រាក់ជាសាធារណៈ (ភាគទាន) ពីកម្មករនិយោជិតនិងសហគ្រាស ឬទាំងសងខាង ហើយផ្តល់តាវកាលិកដល់អ្នកដែលបាត់បង់ការងារ មានរបួស ស្លាប់ជាដើមពិតប្រាកដ។

## 4-1 របបថែទាំសុខភាព និងរបបថែទាំសុខភាពពលរដ្ឋ

របបថែទាំសុខភាព និងរបបថែទាំសុខភាពពលរដ្ឋ (សូមមើលត្រង់លេខ2 2-1 2-2 នៃជំពូកទី6) ផ្តល់តាវកាលិកថែទាំសុខភាព និងប្រាក់ឧបត្ថម្ភចាំបាច់ដល់កម្មករនិយោជិតនិងគ្រួសាររបស់គេក្នុងករណីដូចខាងក្រោម៖

① នៅពេលមានរបួសឬមានជំងឺ
② នៅពេលសម្រាលកូន
③ នៅពេលទទួលមរណភាព ។ល។




## 4-2 របបប្រាក់សោធនពលរដ្ឋ និងរបបប្រាក់សោធនសុខុមាលភាព

របបប្រាក់សោធនពលរដ្ឋ និងរបបប្រាក់សោធនសុខុមាលភាព (សូមមើលត្រង់លេខ1 1-1 1-2 នៃជំពូកទី7) ផ្តល់ប្រាក់សោធនរហូតអស់ជីវិតសម្រាប់ជរាភាព ពិការភាព ឬមរណភាព។

## 4-3 របបធានារ៉ាប់រងលើការគាំពារ

របបធានារ៉ាប់រងលើការគាំពារ គឺជាប្រព័ន្ធធានារ៉ាប់រងដែលមានយន្តការទ្រទ្រង់មនុស្សចាស់ជរាជាដើម ដោយសង្គមទាំងមូល នៅពេលត្រូវការការថែទាំ។

សូមមើលត្រង់លេខ2 នៃជំពូកទី7 របបធានារ៉ាប់រងលើការគាំពារ។

## 4-4 របបនិកម្មភាពការងារ

របបនិកម្មភាពការងារ (សូមមើលត្រង់ 2-5 (4))គឺជាប្រព័ន្ធធានារ៉ាប់រងដែលផ្តល់តាវកាលិកនិកម្មភាពការងារជាដើម ដើម្បីអោយមានលំនឹងជីវភាពនិងជំរុញការចូលធ្វើការងារជាថ្មី ក្នុងករណីដែលកម្មករនិយោជិតបាត់បង់ការងារជាដើម។

### (1) គោលដៅអនុវត្ត

① អ្នកដែលចូលក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមខាងក្រោម ជាទូទៅគឺជាកម្មវត្ថុអនុវត្តន៍។
- អ្នកដែលមានថេរវេលាធ្វើការកំណត់ក្នុង1សប្តាហ៍លើសពី 20ម៉ោង
- អ្នកដែលមានរំពឹងថាទទួលបានការជួលអោយធ្វើការលើសពី 31ថ្ងៃ

② អ្នកដែលជាគោលដៅអនុវត្តក្នុង① គឺអនុវត្តដោយមិនគិតពីទំហំសហគ្រាសធ្វើការឡើយ។

③ អ្នកដែលជាគោលដៅអនុវត្តក្នុង① គឺអនុវត្តចំពោះ បុគ្គលិកបញ្ជូន បុគ្គលិកមានថេរវេលាកំណត់ និងកម្មករនិយោជិតមិនពេញម៉ោង ឬអ្នកធ្វើការក្រៅម៉ោងផងដែរ។

### (2) បន្ទុកនៃភាគទាន

① ការចុះបញ្ជិកាក្នុងរបបនិកម្មភាពការងារ គឺជាកាតព្វកិច្ចរបស់សហគ្រាស។

② ភាគទានគឺជាបន្ទុករបស់ភាគីទាំងពីរគឺកម្មករនិយោជិតនិងសហគ្រាស។

របបនិកម្មភាពការងារ
https://www.hellowork.mhlw.go.jp/insurance/insurance_summary.html

## 4-5 របបហានិភ័យការងារ

របបហានិភ័យការងារ (សូមមើលត្រង់ 3-2) គឺជាប្រព័ន្ធសាធារណៈដែលរដ្ឋផ្តល់តាវកាលិកចាំបាច់ក្នុងករណីខាងក្រោម៖

① ក្នុងករណីដែលកម្មករនិយោជិតមានរបួស ជំងឺ មរណភាព ដោយសារការងារ (គ្រោះថ្នាក់ការងារ)

② ក្នុងករណីដែលរងរបួស ឬមានជម្ងឺ ឬទទួលមរណភាពដោយសារការងារច្រើនមុខ ដែលជួលដោយសហគ្រាសច្រើន (គ្រោះថ្នាក់ដោយសារការងារច្រើន)

③ ក្នុងករណីមានគ្រោះថ្នាក់នៅពេលធ្វើដំណើរទៅមកកន្លែងធ្វើការ (គ្រោះថ្នាក់ពេលធ្វើដំណើរទៅមកធ្វើការ)

ជំពូកទី4

# ការសម្រាលកូន និង ការចិញ្ចឹមកូន



## 1 បែបបទបំពេញនៅពេលមានផ្ទៃពោះ

### 1-1 ការផ្តល់ដំណឹងអំពីការមានផ្ទៃពោះនិងការផ្តល់សៀវភៅសុខភាពមាតាជាដើម

- នៅពេលដឹងថាមានផ្ទៃពោះ សូមប្រញាប់ជូនដំណឹងអំពីការមានផ្ទៃពោះទៅភូមិឃុំស្រុកដែលអ្នករស់នៅ។
- ភូមិឃុំស្រុកមានការផ្តល់ជូនដូចខាងក្រោមចំពោះអ្នកដែលបានជូនដំណឹងអំពីការមានផ្ទៃពោះ៖

① ការផ្តល់សៀវភៅសុខភាពមាតា

② ការផ្តល់ប័ណ្ណពិនិត្យ ឬប័ណ្ណជំនួយដែលអាចប្រើសម្រាប់ពិនិត្យផ្ទៃពោះមុនសម្រាល ដោយមានជំនួយពីថវិកាសាធារណៈ

③ ការពិគ្រោះជាមួយគិលានុបដ្ឋាយិកាសុខភាពសាធារណៈ

④ ផ្តល់ព័ត៌មានអំពីវគ្គណែនាំ ម្តាយនិងឪពុក (វគ្គណែនាំម្តាយ វគ្គណែនាំឪពុក)

* សៀវភៅសុខភាពមាតាប្រើសម្រាប់កត់ត្រាបន្តគ្នាអំពីស្ថានភាពសុខភាពតាំងពីពេលម្តាយមានផ្ទៃពោះរហូតដល់ក្រោយសម្រាល ហើយក៏ជាសៀវភៅណែនាំអាណាព្យាបាលទារកអំពីរបៀបចិញ្ចឹមទារក។ សៀវភៅនេះត្រូវបានរៀបចំអោយអាណាព្យាបាលកត់ត្រានិងគ្រប់គ្រងដោយខ្លួនឯងតាមការចាំបាច់ និងក៏អាចអោយបុគ្គលិកវេជ្ជសាស្ត្រអាចបំពេញ និងមើលបានដែរ។

* កាលពីខែមករា ឆ្នាំ 2023 យើងបានដំណើរការ "ទីតាំង និងព័ត៌មានជំនួយនៃសៀវភៅណែនាំស្តីពីសុខភាពមាតា និងទារក" របស់យើងរួមជាមួយនឹងព័ត៌មានស្តីពីការថែទាំកុមារ និងប្រធានបទពាក់ព័ន្ធ។

(ទីតាំង និងព័ត៌មានជំនួយនៃសៀវភៅណែនាំស្តីពីសុខភាពមាតា និងទារក)

https://mchbook.cfa.go.jp

### 1-2 ការពិនិត្យផ្ទៃពោះមុនសម្រាល

- នៅពេលមានផ្ទៃពោះ គឺត្រូវការអោយថែរក្សាសុខភាពលើសពេលធម្មតាមួយកម្រិតទៀត។
  សូមទៅពិនិត្យផ្ទៃពោះមុនសម្រាលអោយបានទៀងទាត់ ហើយទទួលយកនូវសេចក្តីណែនាំរបស់គ្រូពេទ្យនិងឆ្មបជាដើមនិងធ្វើការគ្រប់គ្រងសុខភាព។
- គួរធ្វើការពិនិត្យផ្ទៃពោះមុនសម្រាលអោយបានប្រហាក់ប្រហែលក្នុងកម្រិតដូចខាងក្រោម៖

① 4សប្តាហ៍1ដងសម្រាប់ពេលចាប់ផ្តើមមានផ្ទៃពោះរហូតដល់អាទិត្យទី23
② 2សប្តាហ៍1ដងសម្រាប់ពេលមានផ្ទៃពោះពីអាទិត្យទី24 រហូតដល់អាទិត្យទី35
③ 1សប្តាហ៍1ដងសម្រាប់ពេលមានផ្ទៃពោះពីអាទិត្យទី36 រហូតដល់ថ្ងៃសម្រាលកូន



## 1-3 ការណែនាំដល់ផ្ទះពីគិលានុបដ្ឋាយិកាសុខភាពសាធារណៈនិងឆ្មបជាដើម

គិលានុបដ្ឋាយិកាសុខភាពសាធារណៈនិងឆ្មបជាដើមទៅពិនិត្យនៅផ្ទះ ហើយធ្វើការពិគ្រោះនិងណែនាំដូចខាងក្រោម៖

① ការណែនាំអំពីជីវភាពរស់នៅនិងអាហារជាដើម
② ការពិគ្រោះលើកង្វល់ និងការព្រួយបារម្ភអំពីការមានផ្ទៃពោះ និងការសម្រាលកូន
③ ការពិគ្រោះយោបល់ទាក់ទងនឹងការថែទាំកុមារសម្រាប់ទារកទើបនឹងកើត និងទារក

* ការណែនាំដល់ផ្ទះនេះគឺមិនគិតថ្លៃឡើយ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។



## 1-4 វគ្គណែនាំ ម្តាយនិងឪពុក (វគ្គណែនាំម្តាយ វគ្គណែនាំឪពុក)

ភូមិឃុំស្រុកមានបើកវគ្គណែនាំអំពីការមានផ្ទៃពោះ ការសម្រាលកូន ការចិញ្ចឹមកូន អាហារូបត្ថម្ភជាដើម ហើយក៏ជាកន្លែងប្រាស្រ័យទាក់ទងរវាងឪពុកម្តាយដូចគ្នាផងដែរ។



# 2 ការបំពេញបែបបទក្រោយសម្រាលកូន

## 2-1 ការចុះបញ្ជីកំណើត



### នៅពេលកូនកើតនៅប្រទេសជប៉ុន

- ឪពុកឬម្ដាយត្រូវចុះបញ្ជីកំណើត។
- ការចុះបញ្ជីនេះត្រូវធ្វើឡើងក្នុងអំឡុង14ថ្ងៃរាប់ចាប់ពីថ្ងៃដែលកូនកើត។
- ការចុះបញ្ជីនេះត្រូវដាក់ជូនទៅភូមិឃុំស្រុកនៃកន្លែងដែលកូនកើត ឬកន្លែងដែលអ្នកជូនដំណឹងរស់នៅ។

### (1) ឯកសារចាំបាច់សម្រាប់ការចុះបញ្ជីកំណើត

- សំបុត្របញ្ជាក់កំណើត
- ចំពោះឯកសារចាំបាច់ផ្សេងទៀត សូមទាក់ទងសួរទៅភូមិឃុំស្រុកដែលធ្វើការជូនដំណឹង។

### (2) ការបំពេញបែបបទផ្សេងទៀត

ក្នុងករណីមិនបានទទួលលក្ខណៈសម្បត្តិស្នាក់នៅក្រោយរយៈពេល 60 ថ្ងៃរាប់ចាប់ពីថ្ងៃដែលកូនកើត លិខិតបញ្ជាក់ការស្នាក់នៅត្រូវបានលុបចេញ ហើយមានករណីមិនអាចទទួលបានសេវារដ្ឋបាលដូចជា របបថែទាំសុខភាពពលរដ្ឋ ប្រាក់ឧបត្ថម្ភសម្រាប់កុមារជាដើម។ ចំពោះខ្លឹមសារលំអិត សូមមើលត្រង់ ជំពូកទី1 2-4 ការទទួលបានលក្ខណៈសម្បត្តិស្នាក់នៅ។

## 2-2 ការចុះបញ្ជីកំណើតទៅប្រទេសខ្លួន

ក្នុងករណីដែលឪពុកនិងម្ដាយមានសញ្ជាតិបរទេស កូននោះមិនអាចទទួលបានសញ្ជាតិជប៉ុនបានឡើយទោះជាបានកើតនៅប្រទេសជប៉ុនក៏ដោយ។ ក្នុងករណីនេះ សូមធ្វើបែបបទចុះបញ្ជីកំណើតកូនទៅប្រទេសរបស់ខ្លួន។ ចំពោះខ្លឹមសារលំអិតនៃនីតិវិធីនេះ សូមទាក់ទងសួរទៅស្ថានទូត ឬស្ថាន(អគ្គ)កុងស៊ុលនៃប្រទេសដែលឪពុកឬម្ដាយមានសញ្ជាតិ។



ហើយសូមធ្វើការស្នើសុំយកលិខិតឆ្លងដែនរបស់កូន ជាមួយគ្នាផង។

# 3 ថ្លៃសម្រាលកូន និងប្រាក់ឧបត្ថម្ភផ្សេងៗ

ដោយសារការមានផ្ទៃពោះ និងការសម្រាលកូនមិនមែនជាជំងឺ ជាទូទៅគឺមិននៅក្នុងរបបថែទាំសុខភាពឡើយ។

ចំពោះករណីពិសេសដូចជាថ្លៃវះកាត់នៅពេលសម្រាលកូនដោយវះកាត់ គឺមាននៅក្នុងរបបថែទាំសុខភាព។

## 3-1 ប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូន

គឺជាប្រព័ន្ធផ្តល់ប្រាក់ 500,000 យ៉េន សម្រាប់ជាសោហ៊ុយសម្រាលកូន នៅពេលដែលសមាជិកនៃរបបថែទាំសុខភាព ឬរបបថែទាំសុខភាពពលរដ្ឋសម្រាលកូន។ ប៉ុន្តែក្នុងករណីដែលការសម្រាលកូនមិនមែនជាកម្មវត្ថុនៃប្រព័ន្ធផ្តល់ការឧបត្ថម្ភសម្រាប់ផ្ទៃកសម្ភព ដូចជាការពរពោះមិនទាន់គ្រប់ 22អាទិត្យជាដើម នោះអាចទទួលបាន 488,000 យ៉េន។

ប្រព័ន្ធផ្តល់នេះមាន2ប្រភេទ។

① ប្រព័ន្ធផ្តល់ដោយផ្ទាល់
ជាប្រព័ន្ធដែលស្ថាប័នវេជ្ជសាស្ត្រជាដើមធ្វើការស្នើសុំនិងទទួលប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូនជំនួសស្ត្រីមានផ្ទៃពោះ។ ដោយសារប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូនត្រូវបានបើកដោយផ្ទាល់ទៅអោយស្ថាប័នវេជ្ជសាស្ត្រជាដើម ហេតុដូច្នេះនៅពេលទូទាត់ប្រាក់ចេញពីមន្ទីរពេទ្យ គឺមិនចាំបាច់បង់ថ្លៃសម្រាលកូនទាំងអស់ឡើយ។

② ប្រព័ន្ធទទួលជំនួស
ជាប្រព័ន្ធដែលនៅពេលស្ត្រីមានផ្ទៃពោះស្នើសុំប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូនទៅសហជីពធានារ៉ាប់រងសុខភាពជាដើម តាមរយៈការដាក់ឈ្មោះស្ថាប័នវេជ្ជសាស្ត្រជាដើមដែលខ្លួននឹងសម្រាលកូនអោយទទួលជំនួស ពេលនោះប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូននឹងត្រូវបានបើកទៅអោយស្ថាប័នវេជ្ជសាស្ត្រជាដើមដោយផ្ទាល់។

## 3-2 ប្រាក់ឧបត្ថម្ភសម្រាលកូន

នៅពេលដែលសមីខ្លួនជាសមាជិកនៃរបបថែទាំសុខភាពឈប់សម្រាកពីការងារដើម្បីសម្រាលកូន ហើយក្នុងអំឡុងពេលនោះមិនអាចទទួលបានប្រាក់បៀវត្ស គឺអាចទទួលប្រាក់ឧបត្ថម្ភសម្រាលកូនសម្រាប់រយៈពេលឈប់សម្រាកពីសហគ្រាសក្នុងចន្លោះត្រឹម 42ថ្ងៃ (98 ថ្ងៃក្នុងករណីពរពោះកូនភ្លោះ)មុនថ្ងៃ (គ្រោង) សម្រាលកូនរហូតដល់ 56ថ្ងៃក្រោយថ្ងៃសម្រាលកូន។ ប្រាក់ឧបត្ថម្ភសម្រាលកូន ក្នុង1ថ្ងៃ ជាទូទៅ អាចទទួលបាននូវទឹកប្រាក់ស្មើនឹង 2/3នៃប្រាក់ឈ្នួលពីរបបថែទាំសុខភាពក្នុងអំឡុងពេលឈប់សម្រាកមុនក្រោយសម្រាល។ ប៉ុន្តែក្នុងករណីដែលសហគ្រាសផ្តល់ប្រាក់បៀវត្សក្នុងអំឡុងពេលឈប់សម្រាក ដែលមានចំនួនច្រើនជាងប្រាក់ឧបត្ថម្ភសម្រាលកូន នោះមិនអាចទទួលប្រាក់ឧបត្ថម្ភសម្រាលកូនឡើយ។

ថ្ងៃសម្រាលគឺរាប់បញ្ចូលក្នុងរយៈពេលមុនថ្ងៃសម្រាលកូន។ ហើយក្នុងករណីដែលការសម្រាលកូនមានការយឺតយ៉ាវជាងថ្ងៃគ្រោងទុក រយៈពេលយឺតយ៉ាវនោះក៏អាចទទួលប្រាក់ឧបត្ថម្ភសម្រាលកូនបានដែរ។

# 3-3 ប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូន(ការឧបត្ថម្ភអំឡុងពេលឈប់សម្រាកចិញ្ចឹមកូន)

## (1) ប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូន

សមាជិកនៃរបបនិកម្មភាពការងារដែលប្រើប្រាស់ការឈប់សម្រាកចិញ្ចឹមកូន ដើម្បីចិញ្ចឹមកូនដែលមានអាយុមិនដល់1ឆ្នាំ (1ឆ្នាំ2ខែ ក្នុងករណីបំពេញលក្ខខណ្ឌកំណត់មួយ។ 1ឆ្នាំ6ខែ ឬ2ឆ្នាំក្នុងករណីបំពេញលក្ខខណ្ឌកំណត់ផ្សេងទៀត) ហើយអ្នកដែលបំពេញលក្ខខណ្ឌខាងក្រោម ជាទូទៅអាចទទួលបានប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូនតាមរយៈការស្នើសុំទៅ Hellow Work។ (67%នៃប្រាក់ឈ្នួលមុនឈប់សម្រាកសម្រាប់ 180ថ្ងៃដំបូង ហើយក្រោយមកទៀតគឺមានចំនួនស្មើនឹង50%)

- លក្ខខណ្ឌដើម្បីទទួលបានប្រាក់ឧបត្ថម្ភ

① ការដែលបានធ្វើការក្នុងមួយខែ ស្មើឬច្រើនជាង 11ថ្ងៃ ឬបានធ្វើការដោយគិតជាម៉ោងមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួល ពី 80ម៉ោងឡើងទៅក្នុងមួយខែ ហើយចំនួនខែទាំងនោះមានយ៉ាងតិច 12ខែ ក្នុងកម្លុងពេល 2ឆ្នាំ មុនពេលចាប់ផ្តើមការឈប់សម្រាកចិញ្ចឹមកូន

② ការដែលបំពេញលក្ខខណ្ឌកំណត់ដូចជាប្រាក់ឈ្នួលក្នុងអំឡុងពេលឈប់សម្រាកចិញ្ចឹមកូនបានធ្លាក់មកដល់តិចជាង 80%នៃប្រាក់ឈ្នួលមុនពេលចាប់ផ្តើមឈប់សម្រាកចិញ្ចឹមកូនជាដើម

③ ត្រូវតែមានថ្ងៃធ្វើការចំនួន 10 ថ្ងៃ ឬតិចជាងនេះក្នុងមួយខែក្នុងអំឡុងពេលនៃការឈប់សម្រាក (ឬប្រសិនបើលើសពី 10 ថ្ងៃនៃថ្ងៃធ្វើការ ចំនួនម៉ោងធ្វើការត្រូវតែមានចំនួន 80 ម៉ោង ឬតិចជាងនេះ)

លើសពីនេះ ទោះបីជាការឈប់សម្រាកត្រូវបានទទួលដោយបែងចែកក៏ដោយ ជាគោលការណ៍ការឈប់លើកទី2ក៏ត្រូវទទួលបានប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូន។

* ចំពោះបុគ្គលិកមានកាលកំណត់ (កម្មករនិយោជិតមានកិច្ចសន្យាកំណត់ថេរវេលា)
ចំពោះបុគ្គលិកមានកាលកំណត់ (កម្មករនិយោជិតមានកិច្ចសន្យាកំណត់ថេរវេលា) បន្ថែមពីលើលក្ខខណ្ឌខាងលើ នៅពេលចាប់ផ្តើមការឈប់សម្រាក នៅក្នុងអំឡុងពេលមុនកូនមានអាយុ1ឆ្នាំ6ខែ (មុនរយៈពេល2ឆ្នាំចំពោះការចាប់ផ្តើមឈប់សម្រាកក្រោយកូនមានអាយុ1ឆ្នាំ6ខែ ក្នុងករណីមានមូលហេតុដូចជាមិនអាចចូលទារកដ្ឋានជាដើម)ក៏ត្រូវបំពេញលក្ខខណ្ឌដែលមិនច្បាស់ថាកិច្ចសន្យាការងារនិងផុតកំណត់។



## (2) ប្រាក់ឧបត្ថម្ភឈប់សម្រាកចិញ្ចឹមកូននៅពេលសម្រាល

សមាជិកធានារ៉ាប់រងការងារអ្នកដែលបំពេញតាមតម្រូវការខាងក្រោមអាចចំណាយពេលរហូតដល់ 4 សប្តាហ៍នៃការឈប់សម្រាកចិញ្ចឹមកូនរបស់ពួកគេ (ការឈប់សម្រាកចិញ្ចឹមកូនក្រោយសម្រាលប៉ាប៉ា) ក្នុងរយៈពេល 8 សប្តាហ៍បន្ទាប់ពីសម្រាលកូន មនុស្សម្នាក់អាចទទួលបានប្រាក់ឧបត្ថមការឈប់សម្រាកចិញ្ចឹមកូននៅពេលសម្រាលដោយការដាក់ពាក្យស្នើសុំ ការទូទាត់ទៅ Hello Work ។ (ចំនួនស្មើនឹង 67% នៃប្រាក់ឈ្នួលមុនពេលចាប់ផ្តើមការឈប់សម្រាក។ ចំនួនថ្ងៃដែលប្រាក់ឧបត្ថនៃការឈប់សម្រាកចិញ្ចឹមកូនពេលសម្រាលបានបង់គឺ3- 3 (1) ប្រាក់ឧបត្ថម្ភនៃការឈប់សម្រាកចិញ្ចឹមកូនគឺ 67% មានចំនួនសរុបដល់ 180 ថ្ងៃ ។

- លក្ខខណ្ឌដើម្បីទទួលបានប្រាក់ឧបត្ថម្ភ

① អ្នកដែលបានធ្វើការក្នុងមួយខែ ស្មើឬច្រើនជាង 11ថ្ងៃ ឬបានធ្វើការដោយគិតជាម៉ោងមូលដ្ឋានក្នុងការគណនាប្រាក់ឈ្នួល ពី 80ម៉ោងឡើងទៅក្នុងមួយខែ ហើយចំនួនខែទាំងនោះមានយ៉ាងតិច 12ខែ ក្នុងអំឡុងពេល 2ឆ្នាំ មុនពេលចាប់ផ្តើមការឈប់សម្រាកចិញ្ចឹមកូន

② ក្នុងករណីបំពេញលក្ខខណ្ឌកំណត់ដូចជាប្រាក់ឈ្នួលក្នុងអំឡុងពេលឈប់សម្រាកចិញ្ចឹមកូនបានធ្លាក់មកដល់តិចជាង 80%នៃប្រាក់ឈ្នួលមុនពេលចាប់ផ្តើមឈប់សម្រាកចិញ្ចឹមកូនជាដើម

③ ចំនួនថ្ងៃធ្វើការអតិបរមាក្នុងអំឡុងពេលឈប់សម្រាកគឺ 10 ថ្ងៃ (ប្រសិនបើរយៈពេលឈប់សម្រាកលើសពី 10 ថ្ងៃ ចំនួនម៉ោងធ្វើការគឺ 80 ម៉ោង) (ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើរយៈពេលឈប់សម្រាកខ្លីជាង 28 ថ្ងៃ វាអាចធ្វើការនៅក្នុង សមាមាត្រទៅនឹងចំនួនថ្ងៃនោះ ចំនួនថ្ងៃ និងម៉ោងដែលត្រូវការនឹងត្រូវបានកាត់បន្ថយផងដែរ។)

លើសពីនេះ បើទោះបីជាការឈប់សម្រាកថៃទាំកូនក្រោយសម្រាលប៉ាប៉ាត្រូវបានបែងចែកក៏ដោយ ក៏ប្រាក់ឧបត្ថម្ភសម្រាប់ការឈប់សម្រាកចិញ្ចឹមកូននៅពេលសម្រាលនឹងត្រូវបានអនុវត្តរហូតដល់លើកទីពីរ។

លើសពីនេះទៀត ប្រាក់ឧបត្ថម្ភនឹងមិនត្រូវបានបង់សម្រាប់ការឈប់សម្រាកដែលស្ថិតនៅក្រោម①② ណាមួយខាងក្រោម។

① ការឈប់សំរាកចិញ្ចឹមកូនពេលសម្រាលសម្រាប់កូនដដែលចាប់ពីលើកទី 3

② ផ្នែកដែលចំនួនថ្ងៃឈប់សម្រាកចិញ្ចឹមកូនពេលសម្រាលសម្រាប់កូនដដែលសរុបលើសពី 28 ថ្ងៃ

* ក្នុងករណីនិយោជិតមានកាលកំណត់ (កម្មករជាប់កិច្ចសន្យារយៈពេលកំណត់)
សម្រាប់និយោជិតដែលមានកាលកំណត់ (អ្នកដែលធ្វើការក្នុងកំឡុងពេលកំណត់) គឺចាំបាច់បំពេញលក្ខខណ្ឌដែលវាមិន ច្បាស់ថាកិច្ចសន្យាការងារនឹងផុតកំណត់ក្នុងរយៈពេលប្រាំមួយខែចាប់ពីថ្ងៃបន្ទាប់ពី 8 សប្តាហ៍ក្រោយសម្រាលកូន។

## 3-4 ប្រាក់ឧបត្ថម្ភសម្រាប់កុមារ

ប្រាក់ឧបត្ថម្ភសម្រាប់កុមារគឺជាប្រាក់ឧបត្ថម្ភដែលមានគោលបំណងអោយមានលំនឹងជីវភាពនៅផ្ទះជាដើម និងដើម្បីអោយកុមារលូតលាស់ប្រកបដោយសុខភាពល្អ។

ប្រាក់ឧបត្ថម្ភនេះអាចទទួលបានក្នុងករណីដែលទាំងកុមារនិងអ្នកចិញ្ចឹមកុមារ រស់នៅក្នុងប្រទេសជប៉ុន។

### (1) អ្នកមានសិទ្ធិទទួល

អ្នកដែលចិញ្ចឹមកុមាររហូតដល់ថ្ងៃទី31 ខែមីនាដំបូងក្រោយថ្ងៃកំណើតអាយុ15ឆ្នាំ។

### (2) វិធីទទួល

- ដំបូងសូមដាក់ពាក្យស្នើសុំទទួលទៅភូមិឃុំស្រុកដែលអ្នករស់នៅ។
- ជាទូទៅ គេអាចទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ខែបន្ទាប់ពីខែដែលបានស្នើសុំ។
- នៅពេលមានកូនផ្សេងទៀត ឬនៅពេលផ្លាស់ទីលំនៅទៅភូមិឃុំស្រុកផ្សេង គឺត្រូវស្នើសុំម្តងទៀត។

### (3) ទឹកប្រាក់ទទួលបាន

| អាយុកុមារ (*) | | ប្រាក់ឧបត្ថម្ភសម្រាប់កុមារ (ទឹកប្រាក់ក្នុងម្នាក់ក្នុង១ខែ) |
|---|---|---|
| កូនទីមួយកូនទីពីរ | អាយុក្រោម3ឆ្នាំ | 15,000 យ៉េន |
| | អាយុចាប់ពី 3ឆ្នាំ រហូតដល់ចុងបញ្ចប់នៃឆ្នាំសារពើពន្ធដំបូងបន្ទាប់ពីឈានដល់អាយុ 18 ឆ្នាំ | 10,000 យ៉េន |
| កូនទីបីនិងកូនបន្តបន្ទាប់ | ចាប់ពីអាយុ 0ឆ្នាំ រហូតដល់ចុងបញ្ចប់នៃឆ្នាំសារពើពន្ធដំបូងបន្ទាប់ពីឈានដល់អាយុ 18 ឆ្នាំ | 30,000 យ៉េន |

* អំពីកូនដែលមានបំណុលសេដ្ឋកិច្ចរហូតដល់ចុងបញ្ចប់នៃឆ្នាំសារពើពន្ធដំបូងបន្ទាប់ពីឈានដល់អាយុ 22ឆ្នាំ គេរាប់តាមលំដាប់កំណើតជា កូនទី១ កូនទី២ កូនទី៣...។

### (4) ពេលវេលាទទួល

ជាទូទៅទទួលបានសរុបចំនួន 2 ខែគិតដល់មុន១ខែនៃខែទទួលគឺខែមេសា មិថុនាសីហា ខែតុលា ធ្នូ និងខែកុម្ភៈ។

# 4 ការចិញ្ចឹមកូន

## 4-1 សេវាថែទាំក្រោយសម្រាល

យើងផ្តល់ការថែទាំរាងកាយ និងផ្លូវចិត្ត និងការថែទាំកុមារដល់ម្តាយ និងទារកភ្លាមៗបន្ទាប់ពីចេញពីមន្ទីរពេទ្យ។

- វិធីសាស្រ្តនិងទីតាំងនៃការអនុវត្ត

I លំនៅដ្ឋាន៖ អ្នកអាចស្នាក់នៅមន្ទីរពេទ្យ ឬមណ្ឌលសម្ភព ដើម្បីទទួលបានការថែទាំ និងជំនួយ។
ii សេវាពេលថ្ងៃ៖ អ្នកអាចទៅមើលកន្លែងថែទាំក្នុងពេលថ្ងៃ ដើម្បីទទួលបានការថែទាំ និងជំនួយតាមមូលដ្ឋានអ្នកជំងឺទូទៅ។
iii ការផ្សព្វផ្សាយ៖ បុគ្គលិកម្នាក់នឹងទៅលេងផ្ទះរបស់អ្នក ដើម្បីផ្តល់ការថែទាំ និងការគាំទ្រ។

ព័ត៌មានលម្អិតប្រែប្រួលអាស្រ័យលើសាលាក្រុង ដូច្នេះសូមទាក់ទងសាលាក្រុងក្នុងតំបន់របស់អ្នកសម្រាប់ព័ត៌មានបន្ថែម។

## 4-2 ការពិនិត្យសុខភាពទារក និងកុមារ

ភូមិឃុំស្រុកធ្វើការពិនិត្យសុខភាពទារក និងកុមារដោយឥតគិតថ្លៃដូចខាងក្រោម៖

- ការពិនិត្យសុខភាពទារកអាយុ 1ឆ្នាំ 6ខែ
- ការពិនិត្យសុខភាពកុមារអាយុ 3ឆ្នាំ
- ចំពោះភូមិឃុំស្រុកខ្លះ មានករណីខ្លះ ទោះជាទារក និងកុមារមានអាយុផ្សេងពីនេះក៏អាចទទួលការពិនិត្យសុខភាពបានដែរ។

* ខ្លឹមសារនៃការពិនិត្យសុខភាពមានដូចជា៖
ការពិនិត្យការលូតលាស់និងអភិវឌ្ឍន៍, ការវាស់កំពស់និងទម្ងន់, ការពិគ្រោះអំពីការចិញ្ចឹមកូន។
សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

## 4-3 ការចាក់វ៉ាក់សាំង

ការចាក់វ៉ាក់សាំងអាចបង្ការមិនអោយកើតជំងឺបាន។ ការចាក់វ៉ាក់សាំងមាន 2ប្រភេទ។

① ការចាក់វ៉ាក់សាំងដែលភូមិឃុំស្រុករស់នៅណែនាំ។
ចំពោះការចាក់វ៉ាក់សាំងដែលភូមិឃុំស្រុករស់នៅណែនាំ មានករណីខ្លះមិនគិតថ្លៃឡើយ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

② ការចាក់វ៉ាក់សាំងដែលខ្លួនប្រាថ្នា
ចំពោះការចាក់វ៉ាក់សាំងដែលខ្លួនប្រាថ្នាគឺត្រូវចេញថ្លៃដោយខ្លួនឯង។
នៅពេលចាក់វ៉ាក់សាំង សូមសម្រេចដោយពិគ្រោះជាមួយគ្រូពេទ្យ។



## 4-4 ថ្លៃព្យាបាលកុមារ

ក្នុងករណីចូលជាសមាជិកនៃរបបថែទាំសុខភាព ចំពោះកុមារមុនចូលរៀនអាយុក្រោម 6ឆ្នាំ ភាគរយនៃបន្ទុកផ្ទាល់ខ្លួនគឺ20%។

ចំពោះភូមិឃុំស្រុកខ្លះ ថ្លៃព្យាបាលកុមាររហូតដល់បញ្ចប់វិទ្យាល័យគឺមិនគិតថ្លៃ ហើយក៏មានកន្លែងផ្តល់ការឧបត្ថម្ភបន្ថែមពីលើគ្នាផងដែរ។

## 4-5 កន្លែងទទួលកុមារមុនចូលរៀន

- កន្លែងមានគោលដៅទទួលកុមារអាយុក្រោម 6ឆ្នាំមុនពេលចូលរៀនបឋមសិក្សាមានដូចជា ទារកដ្ឋាន មត្តេយ្យសាលា មជ្ឈមណ្ឌលអប់រំកុមារតូចមានការទទួលស្គាល់។ល។
- ថ្លៃប្រើប្រាស់ទារកដ្ឋាន មត្តេយ្យសាលា មជ្ឈមណ្ឌលអប់រំកុមារតូចជាដើមសម្រាប់កុមារអាយុ 3ឆ្នាំដល់ 5ឆ្នាំគឺមិនគិតថ្លៃឡើយ។

### (1) ទារកដ្ឋាន

- ជាកន្លែងមើលថែទាំជំនួសអាណាព្យាបាលដែលមិនអាចមើលថែទាំនៅផ្ទះបាន ដោយសារមូលហេតុដូចជាអាណាព្យាបាលជាប់ធ្វើការជាដើម។
- ជាទូទៅម៉ោងមើលថែទាំគឺ 8ម៉ោងក្នុង1ថ្ងៃ ប៉ុន្តែក៏មានទារកដ្ឋានដែលធ្វើការមើលថែទាំនៅពេលយប់ និងថ្ងៃឈប់សម្រាកជាដើមផងដែរ។
- មានទារកដ្ឋានខ្លះធ្វើការទទួលមើលថែបណ្តោះអាសន្នរយៈពេលខ្លី ដោយទទួលមើលថែទាំកុមារបណ្តោះអាសន្នរយៈពេលខ្លី ក្នុងករណីមានធុរៈបន្ទាន់ឬនៅពេលធ្វើការក្រៅម៉ោងរយៈពេលខ្លីជាដើម។

ចំណុចគួរដឹង៖

**កន្លែងមើលថែទាំដែលគ្មានការទទួលស្គាល់**

ជាឈ្មោះហៅរួមនៃកន្លែងមើលថែទាំកុមារដែលគ្មានការទទួលស្គាល់តាមច្បាប់ស្តីអំពីសុខុមាលភាពកុមារ។

- កន្លែងមើលថែទាំគ្មានការទទួលស្គាល់
- កន្លែងសម្រាប់ទទួលមើលកូនរបស់ភ្ញៀវចូលផ្សារទំនើប
- កន្លែងមើលថែកុមារ
- កន្លែងមើលថែកុមារហៅថា (baby hotel)
- អ្នកថែទាំកុមារ (babysitter) ។ល។



### (2) មត្តេយ្យសាលា

- ជាសាលាបង្រៀនសម្រាប់កុមារមានអាយុពេញ 3ឆ្នាំរហូតដល់ពេលចូលរៀននៅសាលាបឋមសិក្សា។
- ជាទូទៅរយៈពេលបង្រៀនគឺ 4ម៉ោងក្នុង1ថ្ងៃ។ ប៉ុន្តែក៏មានសាលាខ្លះទទួលមើលកុមារបន្ថែមម៉ោងទៀតនៅពេលព្រឹកព្រលឹម ឬពេលល្ងាច ឬរហូតដល់ពេលយប់ក៏មានដែរ ទៅតាមស្ថានភាពការងាររបស់អាណាព្យាបាលដែលធ្វើការជាដើម។

- ខុសពីការអប់រំចាប់ពីបឋមសិក្សាតទៅ គឺសង្កត់ធ្ងន់លើការរៀនតាមរយៈការលេងដោយឯករាជ្យរបស់កុមារ
- ហើយក៏មានការទទួលពិគ្រោះទាក់ទងនឹងការចិញ្ចឹមកូនសម្រាប់អាណាព្យាបាលនៅក្នុងសហគមន៍ ហើយក៏មានសាលាខ្លះធ្វើការបើកចំហរជាសាធារណៈនូវទីធ្លារបស់សាលាផងដែរ។

### (3) មជ្ឈមណ្ឌលអប់រំកុមារតូចមានការទទួលស្គាល់

- មជ្ឈមណ្ឌលអប់រំកុមារតូចមានការទទួលស្គាល់មានទាំងមុខងារទារកដ្ឋាននិងមត្តេយ្យសាលា។
- គេអាចប្រើប្រាស់មជ្ឈមណ្ឌលអប់រំកុមារតូចមានការទទួលស្គាល់ ទោះបីជាអាណាព្យាបាលធ្វើការឬមិនធ្វើក៏ដោយ។
- មានធ្វើសកម្មភាពឆ្លើយតបនឹងកង្វល់អំពីការចិញ្ចឹមកូន និងផ្តល់កន្លែងជួបជុំសម្រាប់ឪពុកម្តាយនិងកូនជាដើម ដែលគ្រប់គ្រួសារចិញ្ចឹមកូនជាគោលដៅ។

## 4-6 ក្លឹបកុមារក្រោយម៉ោងសិក្សា (សកម្មភាពក្រោយម៉ោងសិក្សា)

- ក្នុងករណីដែលអាណាព្យាបាលធ្វើការ មិននៅផ្ទះពេលថ្ងៃ គេអាចប្រើក្លឹបកុមារក្រោយម៉ោងសិក្សាបាន។
- ក្លឹបកុមារក្រោយម៉ោងសិក្សាមានដាក់អ្នកមើលការខុសត្រូវជាដើមក្រោយម៉ោងសិក្សា ហើយផ្តល់កន្លែងលេង និងកន្លែងនៅសមស្របក្រោយពេលបញ្ចប់ម៉ោងសិក្សា។
- ក្រៅពីនេះក៏មានសហគមន៍ខ្លះដំណើរការ "ថ្នាក់បង្រៀនកុមារក្រោយម៉ោងសិក្សា" ដែលមានការហាត់រៀន និងសកម្មភាពអនុវត្តន៍ផ្ទាល់ផ្សេងៗ។

## 4-7 មជ្ឈមណ្ឌលគាំពារគ្រួសារ (Family support center)

- មនុស្សដូចខាងក្រោមគឺជាសមាជិក ដែលមានមជ្ឈមណ្ឌលគាំពារគ្រួសារជាអ្នកណែនាំ ហើយសមាជិកដូចគ្នាជាអ្នកជួយគ្នាទៅវិញទៅមក។

① ជាឪពុកម្តាយដែលកំពុងចិញ្ចឹមកុមារឬសិស្សបឋមសិក្សាជាដើម ហើយចង់បានជំនួយដូចជាការជួយមើលកូនជាដើម
② អ្នកចង់ផ្តល់ជំនួយនោះ

- ឧទាហរណ៍នៃជំនួយគឺដូចខាងក្រោម៖

① ការជូនទៅនិងទៅទទួលពីកន្លែងមើលថែទាំជាដើម
② ផ្ញើកូននៅក្រៅម៉ោងចូលកន្លែងមើលថែទាំនិងក្រោយម៉ោងសិក្សា
③ ផ្ញើកូននៅពេលអាណាព្យាបាលមិននៅដូចជាទៅទិញអីវ៉ាន់ជាដើម

- លំដាប់លំដោយនៃការប្រើគឺដូចខាងក្រោម៖

① ចុះឈ្មោះជាសមាជិកនៃមជ្ឈមណ្ឌលគាំពារគ្រួសារ។
② ដាក់ពាក្យស្នើសុំប្រើសេវាកម្ម។
③ អ្នកប្រឹក្សានៃមជ្ឈមណ្ឌលគាំពារគ្រួសារធ្វើការណែនាំអ្នកចង់ផ្តល់ជំនួយ។
④ ក្រោយពេលប្រើរួចបង់ថ្លៃទៅអោយអ្នកបានផ្តល់ជំនួយ។

# 5 សេវាពិគ្រោះយោបល់សម្រាប់ការមានផ្ទៃពោះ ការសម្រាលកូន និងការចិញ្ចឹមកូន

## 5-1 មជ្ឈមណ្ឌលកុមារ និងគ្រួសារ។ល។

សាលាក្រុងមានសេវាប្រឹក្សាយោបល់ (ដូចជាមជ្ឈមណ្ឌលកុមារ និងគ្រួសារ) ដែលស្ត្រីមានផ្ទៃពោះ ឪពុកម្ដាយចិញ្ចឹមកូន និងកុមារអាចពិគ្រោះអំពីកង្វល់ទាក់ទងនឹងការមានផ្ទៃពោះ ការសម្រាលកូន និងការចិញ្ចឹមកូន ព្រមទាំងបញ្ហាទាក់ទងនឹងជីវិតគ្រួសារ និងសាលារៀន និងទទួលបានការគាំទ្រ។.

គិលានុបដ្ឋាយិកាសុខភាពសាធារណៈអាចផ្តល់ការពិគ្រោះយោបល់លើបញ្ហាមុន និងក្រោយពេលសម្រាលកូន និងអំពីការលូតលាស់ និងការអភិវឌ្ឍន៍របស់ទារក និងកុមារទើបចេះដើរតេះតះ ហើយអ្នកប្រឹក្សាអាចផ្តល់ការប្រឹក្សាលើការចិញ្ចឹមកូន ក៏ដូចជាផ្តល់ការគាំទ្រសម្រាប់កង្វល់ផ្សេងៗ។

សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យមើលគេហទំព័ររបស់សាលាក្រុងរបស់អ្នក។

## 5-2 មជ្ឈមណ្ឌលគាំពារកុមារតាមតំបន់

សាលាក្រុងបានបង្កើតកន្លែងដែលឪពុកម្ដាយ និងកូនអាចធ្វើអន្តរកម្មនៅទីកន្លែងក្នុងតំបន់ ដូចជា កន្លែងសាធារណៈ មជ្ឈមណ្ឌលថែទាំកុមារ និងមជ្ឈមណ្ឌលកុមារ (មជ្ឈមណ្ឌលគាំពារកុមារប្រចាំតំបន់) និងផ្តល់ការប្រឹក្សា និងព័ត៌មានអំពីការថែទាំកុមារ។

សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យមើលគេហទំព័ររបស់សាលាក្រុងរបស់អ្នក។

ជំពូកទី5

# ការអប់រំ



## 1 ប្រព័ន្ធអប់រំរបស់ជប៉ុន

ប្រព័ន្ធអប់រំបច្ចុប្បន្នគឺគេនិយមហៅជាទូទៅថាជាប្រព័ន្ធ 6-3-3-4 ដែលជាប្រព័ន្ធមានសាលាបឋមសិក្សា 6ឆ្នាំ អនុវិទ្យាល័យ 3ឆ្នាំ វិទ្យាល័យ 3ឆ្នាំ សកលវិទ្យាល័យ 4ឆ្នាំ ដែលសាលាបឋម និងអនុវិទ្យាល័យគឺជាការអប់រំជាកាតព្វកិច្ច។ ហើយនៅមត្តេយ្យសាលាជាដើមគេមានកម្មវិធីអប់រំសម្រាប់មុនចូលរៀន។

### ការរៀបចំប្រព័ន្ធសាលារៀននៅប្រទេសជប៉ុន



(ចំណាំ)
(1) ផ្នែកពណ៌ប្រផេះគឺជាការអប់រំជាកាតព្វកិច្ច។
(2) * បង្ហាញពីវគ្គសិក្សាកម្រិតខ្ពស់
(3) សាលាមធ្យមសិក្សាទុតិយភូមិ ផ្នែកខាងលើនៃសាលាមធ្យមសិក្សា សាកលវិទ្យាល័យ អនុវិទ្យាល័យ និងនាយកដ្ឋានមធ្យមសិក្សាទុតិយភូមិនៃសាលាសម្រាប់ការអប់រំតម្រូវការពិសេស អាចមានវគ្គសិក្សាដាច់ដោយឡែកជាមួយនឹងវគ្គសិក្សានៃឆ្នាំ ឬច្រើនជាងនេះ។
(4) កុមារដែលមានអាយុពី 0 ទៅ 2 ឆ្នាំអាចចូលរៀននៅមជ្ឈមណ្ឌលសម្រាប់ការអប់រំ និងការថែទាំកុមារតូច ព្រោះវាមានមុខងារដូចជាសាលារៀន ក៏ដូចជាស្ថាប័នសុខុមាលភាពកុមារផងដែរ។
(5) អាយុ និងតម្រូវការចូលរៀនសម្រាប់វគ្គសិក្សាទូទៅមហាវិទ្យាល័យបណ្តុះបណ្តាលឯកទេស និងសាលាផ្សេងៗមិនត្រូវបានកំណត់ដូចគ្នាទេ។

## 1-1 សាលាបឋមសិក្សា និងអនុវិទ្យាល័យ

### ការចូលរៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យសាធារណៈ

- អាណាព្យាបាលជប៉ុនដែលមានកូនអាយុពី 6ឆ្នាំដល់ 15ឆ្នាំមានកាតព្វកិច្ចបញ្ជូនកូនអោយទៅរៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យឬសាលាអប់រំជាកាតព្វកិច្ចជាដើម។
- ចំពោះពលរដ្ឋបរទេសក៏ដោយបើមានបំណងចង់ចូលរៀននៅសាលាបឋមសិក្សា និងអនុវិទ្យាល័យសាធារណៈជាដើមគឺអាចចូលរៀនដោយមិនបាច់បង់ប្រាក់ (ថ្លៃបង្រៀន សៀវភៅពុម្ព) ឡើយ។
- សូមប្រាប់ទៅភូមិឃុំស្រុកដែលអ្នករស់នៅអំពីគោលបំណងចង់អោយកូនចូលរៀននៅសាលាសាធារណៈរបស់ជប៉ុន។
- សូមយក "លិខិតអនុញ្ញាតអោយកុមារបរទេសចូលរៀន" ដែលបានទទួលពីភូមិឃុំស្រុក ហើយទៅសាលាដែលត្រូវបានកំណត់។
- នៅប្រទេសជប៉ុន ក្រៅពីសាលាបឋមសិក្សា និងអនុវិទ្យាល័យ នៅមានសាលាអប់រំជាកាតព្វកិច្ចដែលផ្តល់ការអប់រំជាកាតព្វកិច្ចរយៈពេល 9ឆ្នាំភ្ជាប់គ្នា និងមានសាលាជំនួយពិសេសសម្រាប់កុមារពិការនិងមានបញ្ហាផ្លូវចិត្តផងដែរ។

(សម្រាប់"អនុវិទ្យាល័យរៀនវេនយប់" សូមមើលត្រង់ 1-4)

ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
"សៀវភៅណែនាំសម្រាប់ការចុះឈ្មោះចូលរៀនសម្រាប់កុមារបរទេស"
https://www.mext.go.jp/a_menu/shotou/clarinet/003/1320860.htm

ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
"វីដេអូសម្រាប់កុមារបរទេស និងឪពុកម្តាយរបស់ពួកគេ"
https://casta-net.mext.go.jp/multilingual-contents/videos-for-learners

ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
គេហទំព័រស្វែងរកព័ត៌មាន "CASTA-NET"
ដើម្បីគាំទ្រដល់ការសិក្សារបស់កុមារ និងសិស្សានុសិស្សដែលមានទំនាក់ទំនងជាមួយបរទេស
https://casta-net.mext.go.jp/

## 1-2 វិទ្យាល័យ

- វិទ្យាល័យជាសាលាដែលសិស្សដែលបានបញ្ចប់សាលាអនុវិទ្យាល័យជាដើមចូលរៀន ហើយចំពោះការចូលរៀនជាទូទៅគឺត្រូវប្រឡងចូល។
- វិទ្យាល័យមានវគ្គសិក្សាពេញម៉ោង វគ្គសិក្សាមិនពេញម៉ោង វគ្គសិក្សាដោយឆ្លើយឆ្លង ខុសៗគ្នាតាមទម្រង់នៃការអប់រំ។
- អ្នកដែលបញ្ចប់ការសិក្សានៅវិទ្យាល័យ មានសិទ្ធិចូលរៀននៅសកលវិទ្យាល័យជាដើម។

## 1-3 សាលាសម្រាប់ពលរដ្ឋបរទេស

- ក្រៅពីសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ មានគ្រឹះស្ថានអប់រំក្នុងទម្រង់ផ្សេងៗសំរាប់កុមារបរទេស ដែលគេហៅថា សាលាដែលមានគោលបំណងអប់រំកូនពលរដ្ឋបរទេស។
- ដោយសារសាលានីមួយៗខុសគ្នាទៅតាមលក្ខណៈនៃវប្បធម៌ ជាតិសាសន៍ ភាសា ខ្លឹមសារអប់រំ លទ្ធផលនៃការបន្តការសិក្សា ឬចូលធ្វើការជាដើម ដូច្នេះនៅពេលចូលរៀនគេអាចជ្រើសរើសយកសាលាណាមួយដែលសមស្រប (ចំពោះសិទ្ធិចូលរៀនសកលវិទ្យាល័យជាដើមនៅពេលបញ្ចប់សាលាសម្រាប់ពលរដ្ឋបរទេសនៅជប៉ុន សូមមើលត្រង់ “1-7 ស្ថាប័នឧត្តមសិក្សា (សកលវិទ្យាល័យជាដើម)”)។

ខាងក្រោមនេះគឺជាគេហទំព័រសម្រាប់អ្នកពាក់ព័ន្ធនឹងសាលាសម្រាប់ពលរដ្ឋបរទេស។

https://www.mext.go.jp/a_menu/kokusai/gaikoku/index.htm

## 1-4 អនុវិទ្យាល័យរៀនវេនយប់

- នៅប្រទេសជប៉ុនមាន "អនុវិទ្យាល័យរៀនវេនយប់" សម្រាប់អ្នកដែលមិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ចនៅប្រទេសរបស់ខ្លួនឬនៅប្រទេសជប៉ុន។ ដូចជាសម្រាប់អ្នកដែលមានអាយុលើសពីការចូលសាលាដែលមិនអាចទទួលបានការអប់រំជាកំហិតពេញលេញ ដោយសារកាលៈទេសៈផ្សេងៗ។
- អនុវិទ្យាល័យរៀនវេនយប់មាននៅ 32 ឃុំស្រុកក្នុងខេត្ត ទីក្រុងដែលបានកំណត់ សរុប 53សាលា (តួលេខខែមេសា ឆ្នាំ2024) ហើយទទួលយកសិស្សដែលមិនបានបញ្ចប់ការអប់រំជាកាតព្វកិច្ចដោយសារមូលហេតុផ្សេងៗ។
- ក្នុងករណីមានបំណងចង់ចូលរៀននៅក្នុងអនុវិទ្យាល័យរៀនវេនយប់ ជាដំបូង សូមពិគ្រោះជាមួយក្រុមប្រឹក្សាអប់រំនៅក្នុងភូមិឃុំសង្កាត់ដែលអ្នករស់នៅ។

ក្រសួងអប់រំយុវជននិងកីឡា(សម្រាប់អ្នកដែលចង់រៀននៅអនុវិទ្យាល័យរៀនវេនយប់)

https://www.mext.go.jp/a_menu/shotou/yakan/index_00005.htm

សូមមើល "ថ្នាក់រៀនពេលល្ងាចតាមសម្ភារៈឯកសារទំនាក់ទំនងសាធារណៈសម្រាប់សាលាអនុវិទ្យាល័យ" របស់ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីមើលវីដេអូដែលបង្ហាញពីអ្វីដែលថ្នាក់រៀនទាំងនេះរៀន។

https://www.mext.go.jp/a_menu/shotou/yakan/index_00004.htm

## 1-5 ការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាកម្រិត 1

- អ្នកដែលមិនបានបញ្ចប់អនុវិទ្យាល័យរបស់ជប៉ុនអាចប្រឡងបាន។
- ការប្រឡងមាន 1ដងក្នុង1ឆ្នាំ
- អ្នកដែលប្រឡងជាប់មានសិទ្ធិប្រឡងចូលរៀននៅវិទ្យាល័យជប៉ុន។

## 1-6 ការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាកម្រិត 2

- អ្នកដែលមិនបានបញ្ចប់វិទ្យាល័យរបស់ជប៉ុនអាចប្រឡងបាន។
- ការប្រឡងមាន 2ដងក្នុង1ឆ្នាំ
- បើប្រឡងជាប់អាចធ្វើដូចខាងក្រោមបាន៖

① អាចប្រឡងចូលរៀនថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្ររង សាលាបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។
② អាចប្រឡងចូលធ្វើការ ឬប្រឡងយកសញ្ញាបត្រជំនាញដែលតម្រូវអោយបញ្ចប់វិទ្យាល័យ។

សេចក្តីពន្យល់ត្រួសៗ (ភាសាអង់គ្លេស)
https://www.mext.go.jp/a_menu/koutou/shiken/mext_01319.html

## 1-7 ស្ថាប័នឧត្តមសិក្សា (សកលវិទ្យាល័យជាដើម)

### សិទ្ធិប្រឡងចូលសកលវិទ្យាល័យជាដើម

- អ្នកដែលបានបញ្ចប់ “វិទ្យាល័យ” “សាលាមធ្យមសិក្សា” ឬសាលាសម្រាប់ពលរដ្ឋបរទេសកំណត់ (http://www.mext.go.jp/a_menu/koutou/shikaku/07111314/003.htm): នៅប្រទេសជប៉ុនមានលក្ខណៈសម្បត្តិចូលរៀននៅសាលាដូចខាងក្រោម៖

① ថ្នាក់បរិញ្ញាបត្រ
② ថ្នាក់បរិញ្ញាបត្រផ្នែកជំនាញ
③ ថ្នាក់បរិញ្ញាបត្ររង
④ ថ្នាក់បរិញ្ញាបត្ររងផ្នែកជំនាញ
⑤ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ
(កម្មវិធីសិក្សាជំនាញនៃសាលាបណ្តុះបណ្តាល) ។ល។



- អ្នកដែលមានសញ្ញាបត្រដូចខាងក្រោម មានលក្ខណៈសម្បត្តិចូលរៀននៅសាលាខាងលើបាន។

① សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិអន្តរជាតិInternational Baccalaureate
② សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិAbitur
③ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិBaccalaureate
④ កម្រិត GCEAGeneral Certificate of Education, Advanced-Level
⑤ កម្រិត A អន្តរជាតិ
⑥ បរិញ្ញាបត្រអឺរ៉ុប
(តារាងនៃសាលាមានការទទួលស្គាល់ជាសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិអន្តរជាតិក្នុងប្រទេសជប៉ុន៖
https://ibconsortium.mext.go.jp/about-ib/school/)

- អ្នកដែលបានបញ្ចប់ការសិក្សានៅស្ថាប័នអប់រំ (កម្មវិធី12ឆ្នាំ) ដែលមានការទទួលស្គាល់ពីអង្គការខាងក្រោម មានសិទ្ធិចូលរៀននៅសាលាខាងលើបាន។

① WASC (The Western Association of Schools and Colleges)
② CIS (Council of International Schools)
③ ACSI (Association of Christian Schools International)
④ NEASC (New England Association of Schools and Colleges)
⑤ Cognia
⑥ COBIS (ក្រុមប្រឹក្សាសាលាអន្តរជាតិអង់គ្លេស)

### ស្ថាប័នឧត្តមសិក្សាផ្សេងទៀត

- ក្រៅពីនេះប្រទេសជប៉ុនមានស្ថាប័នឧត្តមសិក្សាផ្សេងទៀតដូចខាងក្រោម ដែលសាលានីមួយៗមានកំណត់លក្ខខណ្ឌចូលរៀន៖

① ថ្នាក់ក្រោយឧត្តម ជាទូទៅសម្រាប់អ្នកបញ្ចប់ថ្នាក់បរិញ្ញាបត្ររៀនបន្ត
② ថ្នាក់ក្រោយឧត្តមផ្នែកជំនាញ ជាទូទៅសម្រាប់អ្នកបញ្ចប់ថ្នាក់បរិញ្ញាបត្ររៀនបន្ត
③ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ជាទូទៅសម្រាប់អ្នកបញ្ចប់ថ្នាក់អនុវិទ្យាល័យរៀនបន្ត

## 1-8 ការប្រឡងចូលស្ថាប័នឧត្តមសិក្សា

- ដើម្បីចូលរៀននៅស្ថាប័នឧត្តមសិក្សា គេត្រូវចូលរួមការប្រឡងដែលធ្វើឡើងដោយស្ថាប័នឧត្តមសិក្សានីមួយៗ ឬឆ្លងកាត់ការត្រួតពិនិត្យឯកសារ។
- មានករណីខ្លះស្ថាប័នឧត្តមសិក្សាធ្វើការប្រឡងជ្រើសរើសពិសេសសម្រាប់ពលរដ្ឋបរទេសទៅតាមការវិនិច្ឆ័យរបស់ខ្លួន។
- ចំពោះនិស្សិតបរទេស ការប្រឡងចូលរៀនឧត្តមសិក្សានៅជប៉ុន (EJU) ដែលធ្វើឡើងដោយអង្គការគាំពារនិស្សិតជប៉ុន ត្រូវបានសកលវិទ្យាល័យជាច្រើនប្រើប្រាស់សម្រាប់ជាការប្រឡងជ្រើសរើសពិសេស។

ខាងក្រោមនេះ គឺជាគេហទំព័រសម្រាប់ជនបរទេស។
https://www.jasso.go.jp/en/ryugaku/eju/index.html

# 2 ជំនួយហិរញ្ញវត្ថុលើថ្លៃសិក្សា

## 2-1 ឧបត្ថម្ភធនលើចំណាយសិក្សា

- មានប្រព័ន្ធផ្តល់ការឧបត្ថម្ភដូចជាសម្ភារៈចាំបាច់សម្រាប់កូនសិក្សា (ឯកសណ្ឋាន កាបូបដាក់សៀវភៅ ប៊ិច សៀវភៅ) ប្រាក់សម្រាប់បង់ថ្លៃអាហារមួយផ្នែកជាដើម។
- ជាគោលដៅផ្តល់អោយអាណាព្យាបាលសិស្សថ្នាក់បឋមសិក្សា ឬអនុវិទ្យាល័យដែលជាគ្រួសារមានចំណូលទាប។
- លក្ខខណ្ឌអាចទទួលបាន និងទឹកប្រាក់ទទួលបានគឺខុសៗគ្នាទៅតាមភូមិឃុំស្រុករស់នៅ។

អ្នកណាដែលចង់ដឹងលំអិតអំពីប្រព័ន្ធនេះ សូមមើលគេហទំព័រខាងក្រោម។

https://www.mext.go.jp/a_menu/shotou/career/05010502/017.htm

## 2-2 ប្រាក់ឧបត្ថម្ភចំណាយសិក្សានៅវិទ្យាល័យជាដើម



- ក្នុងករណីដែលប្រាក់ចំណូលប្រចាំឆ្នាំនៃគ្រួសារអាណាព្យាបាល មានទឹកប្រាក់តិចជាង 910ម៉ឺនយ៉េន អាចទទួលបានប្រាក់សម្រាប់បង់ថ្លៃសាលាវិទ្យាល័យ។
- សិស្សដែលរៀននៅវិទ្យាល័យរដ្ឋ ឬវិទ្យាល័យសាធារណៈ អាចទទួលបានទឹកប្រាក់ស្មើនឹងថ្លៃបង់សាលា។
- ចំពោះសិស្សដែលរៀននៅវិទ្យាល័យឯកជនជាដើម ទទួលបានទៅតាមចំណូលរបស់អាណាព្យាបាល។
- ដើម្បីទទួលបានប្រាក់ គេត្រូវដាក់ពាក្យស្នើសុំ។
- សេចក្តីលំអិត មាននៅក្នុងការណែនាំរបស់សាលាដែលទៅរៀន។

អ្នកណាដែលចង់ដឹងលំអិតអំពីប្រព័ន្ធនេះ សូមមើលគេហទំព័រខាងក្រោម។

https://www.mext.go.jp/a_menu/shotou/mushouka/1342674.htm

អ្នកណាចង់អានជាភាសាអង់គ្លេស សូមមើលគេហទំព័រខាងក្រោមនេះ។

https://www.mext.go.jp/a_menu/shotou/mushouka/20220329-mxt_kouhou02-2.pdf

## 2-3 ប្រាក់ឧបត្ថម្ភសម្រាប់សិស្សវិទ្យាល័យជាដើម

- អាណាព្យាបាលរបស់សិស្សវិទ្យាល័យ ដែលជាគ្រួសារមានចំណូលទាប អាចទទួលបានប្រាក់សម្រាប់ចំណាយលើថ្លៃសៀវភៅ ថ្លៃសម្ភារៈសិក្សាជាដើម ក្រៅពីថ្លៃសាលា។
- ទឹកប្រាក់ដែលអាចទទួលបានមានចំនួនខុសគ្នាទៅតាមប្រភេទសាលារៀនជាដើម។
- ដើម្បីទទួលបានប្រាក់គេត្រូវដាក់ពាក្យស្នើសុំ។
- សម្រាប់សេចក្តីលំអិត សូមទាក់ទងទៅសាលាឬខេត្តក្រុងដែលអ្នករស់នៅ។

អ្នកណាដែលចង់ដឹងលំអិតអំពីប្រព័ន្ធនេះ សូមមើលគេហទំព័រខាងក្រោម។

https://www.mext.go.jp/a_menu/shotou/mushouka/1344089.htm

អ្នកណាដែលចង់អានជាភាសាអង់គ្លេស សូមមើលគេហទំព័រខាងក្រោម។ :

https://www.mext.go.jp/a_menu/shotou/mushouka/20240326-mxt_kouhou02-2.pdf

## 2-4 អាហារូបករណ៍សម្រាប់កម្រិតឧត្តមសិក្សា

- អាហារូបករណ៍ត្រូវបានបង្កើតឡើងដោយរដ្ឋ រដ្ឋបាលតាមតំបន់ និងសមាគមឯកជន។
- ប្រព័ន្ធអាហារូបករណ៍របស់រដ្ឋមាន 2ប្រភេទ។



① ប្រភេទអោយដាច់៖ ប្រព័ន្ធមិនបាច់សងមកវិញ

② ប្រភេទអោយខ្ចី៖ ជាប្រព័ន្ធអោយខ្ចីដែលត្រូវការសងវិញ

* ចំពោះប្រភេទអោយខ្ចី មាន 2ប្រភេទ គឺប្រភេទមិនគិតការប្រាក់ (គ្មានការប្រាក់) និងប្រភេទគិតការប្រាក់ (មានការប្រាក់)។

- ពលរដ្ឋបរទេសដែលបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ហើយមានលក្ខណៈសម្បត្តិស្នាក់នៅដូចខាងក្រោម ជាកម្មវត្ថុនៃប្រព័ន្ធអាហារូបករណ៍របស់រដ្ឋ៖



① អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស

② អ្នកស្នាក់នៅអចិន្ត្រៃយ៍

③ សហព័ទ្ធរបស់ជនជាតិជប៉ុនជាដើម

④ ប្តីប្រពន្ធរបស់អ្នករស់នៅអចិន្ត្រៃយ៍

⑤ អ្នកតាំងលំនៅអចិន្ត្រៃយ៍ (អ្នកមានបំណងចង់ស្នាក់នៅអចិន្ត្រៃយ៍)

⑥ ការស្នាក់នៅជាលក្ខណៈគ្រួសារដែលបំពេញតាមតម្រូវការជាក់លាក់ (អ្នកដែលបានបញ្ចប់ថ្នាក់បឋមសិក្សា អនុវិទ្យាល័យ ឬវិទ្យាល័យនៅប្រទេសជប៉ុន ហើយមានបំណងទៅធ្វើការ និងតាំងទីលំនៅក្នុងប្រទេសជប៉ុន

- ក្រៅពីនេះ មានអាហារូបករណ៍ប្រភេទអោយដាច់សម្រាប់អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅ “និស្សិតបរទេស និងបំពេញលក្ខខណ្ឌដូចជាលក្ខខណ្ឌលទ្ធផលសិក្សាជាដើម។

អ្នកណាដែលចង់អានជាភាសាអង់គ្លេស សូមមើលគេហទំព័រខាងក្រោម។

https://www.jasso.go.jp/en/ryugaku/scholarship_j/shoreihi/index.html

# 3 ការសិក្សាភាសាជប៉ុន

នៅពេលចេះភាសាជប៉ុន ជីវភាពរស់នៅប្រទេសជប៉ុនរបស់អ្នកនឹងមានភាពរលូន និងប្រសើរឡើង។ ចំនួនអ្នកស្គាល់និងមិត្តភក្តិកើនឡើង ដែលអាចជួយដល់ការរស់នៅជប៉ុនរបស់អ្នក។ ហើយក៏ប្រហែលជាអាចជួយអោយក្តីសុបិនរបស់អ្នកក្លាយជាការពិត។ សូមបន្តរៀនភាសាជប៉ុនដើម្បីអោយអាចរស់នៅដោយខ្លួនឯងបាន។




## 3-1 ស្តីពីការសិក្សាភាសាជប៉ុន

- អក្សរប្រើក្នុងភាសាជប៉ុនមាន 5ប្រភេទ។ ហ៊ីរ៉ាហ្កាណា កាតាកាណា កាន់ជិ អក្សរឡាតាំង លេខអារ៉ាប់។ ហើយហ៊ីរ៉ាហ្កាណា និងកាតាកាណា មាន46អក្សរក្នុងមួយប្រភេទ ថែមទាំងមានអក្សរសរសេរតូចៗ (ហ៊ីរ៉ាហ្កាណា ចំនួន 4 អក្សរ  កាតាកាណា ចំនួន 9 អក្សរ) និងសញ្ញា “゛” “゜” “—” ផងដែរ។
- ក្រៅពីនេះ អក្សរកាន់ជិ មានអក្សរខ្លះលំបាកប៉ុន្តែមានប្រយោជន៍ពេលចងចាំបាន។ សូមចាប់ផ្តើមសិក្សាអក្សរកាន់ជិដែលនៅក្បែរអ្នកបន្តិចម្តងៗដោយសប្បាយរីករាយ។
- គេប្រើអក្សរឡាតាំងសម្រាប់សរសេរអ៊ីម៉ែល ឬ SNS ជាដើម ច្រើនដែរ។
- នៅពេលរស់នៅប្រទេសជប៉ុន វាជាការចាំបាច់ដែលត្រូវស្គាល់ឈ្មោះកន្លែងឬផ្លូវនៅក្នុងតំបន់ជាដើម (ការបញ្ចេញសំលេងនិងអក្សរកាន់ជិ)។ ហើយនៅប្រទេសជប៉ុនក៏មាន “ពាក្យតាមតំបន់”ច្រើន ដែលចាំបាច់សម្រាប់ការរស់នៅតាមតំបន់។ គេអាចរៀនពាក្យទាំងនោះនៅថ្នាក់រៀនភាសាជប៉ុនតាមតំបន់ឬតាមរយៈការប្រាស្រ័យទាក់ទងជាមួយមនុស្សក្នុងតំបន់។
- ក្រៅពីនេះ ភាសាជប៉ុនមានភាសាគួរសម។ បើសិនជាអាចប្រើភាសាគួរសម ទៅតាមអ្នកម្ខាងទៀតជាការល្អ។

## 3-2 ក្របខ័ណ្ឌយោងក្នុងការសិក្សាភាសាជប៉ុន

- ដើម្បីឱ្យអ្នកទាំងអស់គ្នាអាចសិក្សាភាសាជប៉ុនបានងាយស្រួល នៅឆ្នាំ 2021 គេមានបង្កើត “ក្របខ័ណ្ឌយោងក្នុងការសិក្សាភាសាជប៉ុន” ដោយយោងទៅតាម CEFR (Common European Framework of Reference for Languages: Learning, teaching, assessment: ក្របខ័ណ្ឌយោងសម្រាប់ភាសារួមនៃអឺរ៉ុប)។
- នេះគឺជាខ្លឹមសារនៃការសិក្សា ឬគោលដៅនៃសកម្មភាពទៅតាមសមត្ថភាពភាសាជប៉ុន (“ការស្តាប់” “ការអាន” “ការនិយាយ” “ការធ្វើបទបង្ហាញ” “ការសរសេរ”) និងកម្រិតទាំង 6 នៃភាសាជប៉ុន (A1C2)។

  * ធ្វើការពិនិត្យមើលអំពីកម្រិតភាសាជប៉ុនសាមីខ្លួន ហើយសូមយោងដើម្បីបង្កើតគោលដៅបន្ទាប់ ក្នុងការសិក្សា។
- ធនធានដែលយើងបានបង្កើត និងធ្វើឱ្យមានរូមមាន “Seikatsu Can Do” ដែលជាការណែនាំសម្រាប់ការប្រើប្រាស់ក្របខ័ណ្ឌឯកសារយោង និង “Nihongo Check!” ដែលជាឧបករណ៍វាយតម្លៃដោយខ្លួនឯងជាភាសាជប៉ុន។

ក្របខ័ណ្ឌឯកសារយោងសម្រាប់ការអប់រំជាភាសាជប៉ុន, ការណែនាំ,
Seikatsu Can Do និងច្រើនទៀត
https://www.nihongo-ews.mext.go.jp/information/framework_of_reference

| | |
|---|---|
| C2 | អាចយល់បានងាយស្រួលនូវអ្វីៗដែលបានស្តាប់ ឬអាន។ អាចនិយាយបានតាមធម្មតា យ៉ាងរលូន ហើយត្រឹមត្រូវ ព្រមទាំងយល់ន័យលំអិត និងអាចបែងចែកច្បាស់លាស់នូវឃ្លាទាំងនោះ។ |
| C1 | អាចយល់បាននូវឃ្លានានាដែលវែង ហើយមានខ្លឹមសារខ្ពស់។ ពេលនិយាយ មិនធ្វើឱ្យគេមានអារម្មណ៍ថា កំពុងរកពាក្យ ហើយអាចនិយាយយ៉ាងរលូនបាន។ អាចប្រើពាក្យប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចសម្រួលទៅតាមគោលដៅនៃសង្គម ឯកទេស ឬការងារជាដើម។ |
| B2 | អាចយល់បាននូវខ្លឹមសារសំខាន់ៗនៃអត្ថបទស្មុគស្មាញដែលនិយាយអំពីប្រធានបទអរូបីនិងជាក់លាក់ណាមួយ រួមទាំងបច្ចេកទេសនៃវិស័យជំនាញរបស់ខ្លួន។ អាចនិយាយគ្នាជាមួយនឹងអ្នកចេះជប៉ុនច្បាស់លាស់តាមធម្មជាតិដោយមិនតានតឹង ។ |
| B1 | ស្តីពីរឿងអ្វីៗដែលកើតមានឡើងជុំវិញខ្លួនដែលបានជួបតាមការងារ តាមសាលា តាមកន្លែងកំសាន្ត បើសិនជារឿងកើតឡើងរួម អាចយល់នូវចំណុចសំខាន់ៗបាន។ ស្តីពីរឿងនៅជុំវិញខ្លួន ហើយសាមីខ្លួនមានការចាប់អារម្មណ៍ អាចតភ្ជាប់នូវរឿងខ្លីៗនោះតាមវិធីងាយស្រួល ឬអាចបង្កើតជាអត្ថបទដែលមានបរិបទត្រឹមត្រូវបាន។ |
| A2 | ស្តីពីព័ត៌មានមូលដ្ឋានរបស់បុគ្គល ឬរបស់គ្រួសារ ឬអ្វីៗដែលពាក់ព័ន្ធផ្ទាល់ ទៅនឹងការទិញឥវ៉ាន់ រឿងនៅជុំវិញផ្ទះ ការងារ ជាដើម អាចយល់ឃ្លាឬប្រយោគដែលគេប្រើច្រើនបាន។ អាចប្តូរព័ត៌មានប្រចាំថ្ងៃគ្នាទៅវិញទៅមកបាន ឬអ្វីៗដែលកើតឡើងជុំវិញខ្លួនបាន។ |
| A1 | អាចយល់ ឬប្រើបាននូវប្រយោគ ឬឃ្លាមូលដ្ឋានដែលគេប្រើប្រចាំថ្ងៃ ដើម្បីឱ្យស្របចិត្តតាមចិត្តចង់ជាក់លាក់។ បើសិនជាភាគីម្ខាងទៀត និយាយយឺតៗ ច្បាស់លាស់ ហើយជួយខ្លះផង អាចឆ្លើយឆ្លងគ្នាអំពីអ្វីៗដែលងាយស្រួលបាន។ |

## 3-3 កន្លែងសិក្សាភាសាជប៉ុន

នៅថ្នាក់រៀនជាដើម គេអាចរៀនភាសាជប៉ុនផងហើយទទួលព័ត៌មានអំពីជីវភាពរស់នៅផង និងបង្កើតមិត្តភក្តិផង។ សូមស្វែងរកសាលាភាសាជប៉ុនឬថ្នាក់បង្រៀនភាសាជប៉ុននៅក្បែរកន្លែងរបស់អ្នក។

ថ្មីៗនេះមានមនុស្សកាន់តែច្រើនប្រើប្រាស់បណ្តាញសង្គមដូចជា skype ជាដើមដើម្បីរៀនភាសាជប៉ុនពីចំងាយ ឬរៀនតាមបណ្តាញអេឡិចត្រូនិច (e learning) ជាដើម។ សូមរកអោយឃើញនូវវិធីសិក្សាដែលត្រូវនឹងអ្នក។

### (1) សាលាភាសាជប៉ុន

- មានវគ្គសិក្សាទៅតាមគោលបំណងដូចជាបន្តការសិក្សាឬចូលធ្វើការ ត្រៀមប្រឡងជាដើម។
- អាចរៀនភាសាជប៉ុនបានគ្រប់កម្រិតចាប់ពីថ្នាក់ដំបូងរហូតដល់ថ្នាក់កម្រិតខ្ពស់។
- អាចជ្រើសរើសប្រភេទបង្រៀនមានដូចជាការបង្រៀនក្នុងថ្នាក់ ឬបង្រៀនជាក្រុម បង្រៀនជាលក្ខណៈឯកជនជាដើម។
- ត្រូវបង់ថ្លៃសាលា។

## (2) ថ្នាក់រៀនភាសាជប៉ុននៅក្នុងសហគមន៍

- បើកថ្នាក់បង្រៀនភាសាជប៉ុនដោយរដ្ឋបាលមូលដ្ឋាន ឬនីតិបុគ្គលធ្វើសកម្មភាពមិនរកប្រាក់ចំណេញ។
- ធ្វើឡើងនៅមជ្ឈមណ្ឌលសហគមន៍ បន្ទប់ទំនេររបស់សាលា វិហារកាតូលិក មជ្ឈមណ្ឌលស្ម័គ្រចិត្តជាដើម។
- ភាគច្រើនបង្រៀនដោយអ្នកស្ម័គ្រចិត្ត។
- មានកន្លែងខ្លះបង្រៀនដោយមិនគិតថ្លៃ។ គឺអស់ថ្លៃថោកជាងសាលាភាសាជប៉ុន។
- ថ្នាក់រៀនមាន1ឬ2ដងក្នុង១សប្តាហ៍ ហើយក្នុង1ដងមាន1ទៅ2ម៉ោង។

ស្តីពីតារាងថ្នាក់សិក្សាភាសាជប៉ុននៃផ្នែកទទួលបន្ទុកការអប់រំនៃតំបន់នីមួយៗ ឬក្នុងតំបន់ សូមមើលគេហទំព័រខាងក្រោមនេះ។

https://www.bunka.go.jp/seisaku/kokugo_nihongo/kyoiku/nihongokyoiku_tanto/pdf/93036701_01.pdf

* នៅពេលស្វែងរកថ្នាក់បង្រៀនភាសាជប៉ុនសូមពិនិត្យមើលលើចំណុចខាងក្រោម។

① ឈ្មោះថ្នាក់រៀន ② អ្នករៀបចំ ③ ទីកន្លែង ④ លេខទំនាក់ទំនង ⑤ វិធីទាក់ទង ⑥ ភាសាប្រើប្រាស់ ⑦ រយៈពេល ⑧ ចំនួនដង ⑨ ថ្ងៃនិងម៉ោង ⑩ សិទ្ធិចូលរៀន ⑪ ថ្លៃចំណាយ ⑫ ទម្រង់នៃថ្នាក់ (ក្រុមឬម្នាក់ទល់ម្នាក់) ⑬ ចំនួនមនុស្ស ⑭ កម្រិត ⑮ អ្នកបង្រៀន ⑯ ខ្លឹមសារ ⑰ មានចំណតរថយន្តឬកន្លែងផ្ញើក្មេងឬអត់។ល។

## (3) ការអប់រំដោយឆ្លើយឆ្លង ឬពីចំងាយ

ក្នុងករណីមិនអាចទៅរៀននៅថ្នាក់បង្រៀនភាសាជប៉ុនបានដោយសាររវល់ការងារ ឬចិញ្ចឹមកូនជាដើម គេអាចរៀនភាសាជប៉ុនពីចំងាយ ឬរៀនតាមបណ្តាញអេឡិចត្រូនិច (e learning) ជាដើមដោយប្រើប្រាស់បណ្តាញសង្គម។ ថ្លៃចំណាយនិងប្រភេទសេវាកម្មក៏មានច្រើនប្រភេទ សូមរកវិធីណាមួយដែលត្រូវនឹងអ្នកសាកមើល។

# 3-4 គេហទំព័រសម្រាប់សិក្សាភាសាជប៉ុន“ផ្សារភ្ជាប់ ពង្រីក ការរស់នៅដោយប្រើភាសាជប៉ុន” (ឈ្មោះហៅធម្មតា Tsunahiro)

គឺជាគេហទំព័រសម្រាប់ជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន ហើយចង់ធ្វើការប្រាស្រ័យទាក់ទងជាភាសាជប៉ុន ឬចង់រស់នៅឱ្យងាយស្រួល សិក្សាភាសាជប៉ុន។

អាចជ្រើសរើសមេរៀនសិក្សាជាវីដេអូ ឬស្គ្រីប ទៅតាមកម្រិតភាសាជប៉ុនរបស់ខ្លួន ទៅតាមឆាកដែលចង់សិក្សា ឬទៅតាមពាក្យគន្លឹះ។ សូមលោកអ្នកតភ្ជាប់នឹងសង្គម ព្រមទាំងពង្រីកការរស់នៅ តាមរយៈការសិក្សា និងការប្រើភាសាជប៉ុនជាក់ស្តែង។

| | |
|---|---|
| ○ ភាសា | : ជប៉ុន, អង់គ្លេស, ចិន (ពុម្ពអក្សរងាយស្រួល), ចិន (ប្រពៃណី), ព័រទុយហ្គេ, អេស្ប៉ាញ, វៀតណាម, ឥណ្ឌូណេស៊ី, ហ្វីលីពីន, នេប៉ាល់, ខ្មែរ, ភាសាកូរេ, ថៃ, មីយ៉ាន់ម៉ា, ម៉ុងហ្គោលី,អ៊ុយក្រែន,រុស្ស៊ី បារាំង(18ភាសា) |
| ○ ខ្លឹមសារនៃការសិក្សា | : គារវកិច្ច, ការទិញទំនិញ, ធនាគារ, រថភ្លើង, សាលាស្រុកជាដើម, ការបង្ការគ្រោះមហន្តរាយ ជាដើម ដែលពាក់ព័ន្ធនឹងជីវភាពរស់នៅការចិញ្ចឹមកូន |

“ផ្សារភ្ជាប់ ពង្រីក ការរស់ដោយប្រើភាសាជប៉ុន”

https://tsunagarujp.mext.go.jp

## 3-5 "Nihongo Check!" ដែលជាឧបករណ៍វាយតម្លៃដោយខ្លួនឯងជាភាសាជប៉ុនដោយផ្អែកលើក្របខ័ណ្ឌឯកសារយោងសម្រាប់ការអប់រំជាភាសាជប៉ុន

ប្រព័ន្ធអនឡាញនេះមានឧបករណ៍វាយតម្លៃដោយខ្លួនឯងដែលផ្តោតគោលដៅលើអ្នករៀនភាសាជប៉ុនទាំងនៅក្នុងប្រទេសជប៉ុន និងអន្តរជាតិ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ឆ្លើយសំណួរពីផ្នែក "អាចធ្វើបាន" ដោយផ្តល់នូវការវាយតម្លៃត្រង់ៗអំពីជំនាញភាសាជប៉ុនរបស់ពួកគេ។ វាត្រូវបានបង្កើតឡើងដើម្បីលើកទឹកចិត្តដល់ការសិក្សាលក្ខណៈបុគ្គលដោយផ្អែកលើលទ្ធផល និងជួយកំណត់គោលដៅសម្រាប់ការសិក្សាភាសាជប៉ុន។

ក្របខ័ណ្ឌឯកសារយោងសម្រាប់ការអប់រំភាសាជប៉ុនមានប្រាំមួយកម្រិត (A1 ដល់ C2) និងគ្របដណ្តប់លើសកម្មភាពភាសាចំនួនប្រាំ រួមមានការស្តាប់, ការអាន, ការនិយាយ (អន្តរកម្ម និងការបញ្ចេញមតិ) និងការសរសេរ។ អ្នករៀនភាសាជប៉ុនវាយតម្លៃជំនាញផ្ទាល់ខ្លួនរបស់ពួកគេតាមរយៈការឆ្លើយសំណួរទាក់ទងនឹងលទ្ធភាពប្រើប្រាស់ភាសារបស់ពួកគេតាមមាត្រដ្ឋានបួនចំណុចដូចខាងក្រោម៖ "1. ខ្ញុំមិនអាច" "2. ខ្ញុំអាចធ្វើវាបានដោយលំបាក" "3. វាពិបាក ប៉ុន្តែខ្ញុំគ្រាន់តែអាចធ្វើវាបាន" និង "4. ខ្ញុំអាច។"

| | |
|---|---|
| ភាសាដែលគាំទ្រ៖ | ភាសាចំនួន 14 រួមទាំងភាសាជប៉ុន។<br>ចិន អង់គ្លេស ហ្វីលីពីន ឥណ្ឌូណេស៊ី ខ្មែរ កូរ៉េ ម៉ុងហ្គោលី ភូមា នេប៉ាល់ ព័រទុយហ្កាល់ អេស្ប៉ាញ ថៃ វៀតណាម និងជប៉ុន (ជាមួយនឹងការអានហ្វីរីហ្គាណា)។ |

ពិនិត្យមើលកម្រិតរបស់អ្នកនៅទំព័រខាងក្រោម។
https://www.nihongo-check.bunka.go.jp/



ជំពូកទី6

# ការថែទាំនិងព្យាបាលផ្នែកវេជ្ជសាស្ត្រ



## 1 ស្ថាប័នវេជ្ជសាស្ត្រ

### 1-1 ប្រភេទនៃស្ថាប័នវេជ្ជសាស្ត្រ

- នៅប្រទេសជប៉ុនមានស្ថាប័នវេជ្ជសាស្ត្រច្រើន ដែលនីមួយៗមានមុខងាររៀងៗខ្លួន។ ក្នុងករណីដែលមានរបួសឬជំងឺស្រាល សូមទៅមើលនៅកន្លែងព្យាបាលក្បែរកន្លែងរបស់អ្នក។

① កន្លែងព្យាបាល គ្លីនិក សម្រាប់ព្យាបាលជំងឺ ឬរបួសធម្មតា
② មន្ទីរពេទ្យតូចនិងមធ្យម សម្រាប់ករណីត្រូវការវះកាត់ ឬត្រូវការសង្គ្រោះបន្ទាន់
③ មន្ទីរពេទ្យធំ សម្រាប់ជំងឺកម្រិតធ្ងន់ត្រូវការសង្គ្រោះបន្ទាន់ឬត្រូវការការព្យាបាលកម្រិតខ្ពស់

- នៅមន្ទីរពេទ្យនិងកន្លែងព្យាបាល សូមបង្ហាញកាតសមាជិកនៃរបបថែទាំសុខភាព។ ក្នុងករណីមិនបានបង្ហាញកាតសមាជិកនៃរបបថែទាំសុខភាព នឹងត្រូវរ៉ាប់រងបន្ទុកថ្លៃព្យាបាលដោយខ្លួនឯងទាំងស្រុង។
- ផ្នែកពិគ្រោះនៃជំងឺគឺកំណត់ទៅតាមស្ថានភាពនៃជំងឺ ឬរបួស។ ខាងក្រោយជាឧទាហរណ៍បង្ហាញពីប្រភេទជំងឺ ឬរបួសដែលផ្នែកនីមួយៗទទួលពិគ្រោះជាក់ស្តែង។

| | |
|---|---|
| ផ្នែកជំងឺទូទៅ | ពិនិត្យជំងឺនៃសរីរាង្គខាងក្នុងដូចជា ប្រព័ន្ធរំលាយអាហារ ប្រព័ន្ធដង្ហើម បេះដូងនិងសរសៃឈាម ប្រព័ន្ធតម្រងនោម ឈាម លំពែង សរសៃប្រសាទជាដើម ហើយព្យាបាលដោយប្រើថ្នាំមិនធ្វើការវះកាត់។ ហើយក៏ធ្វើការពិនិត្យនិងព្យាបាលជំងឺទូទៅដូចជាផ្តាសាយនិងបញ្ហាសុខភាពទូទៅជាដើមផងដែរ។ |
| ផ្នែកវះកាត់ | ព្យាបាលជំងឺសរីរាង្គខាងក្នុងបង្កឡើងដោយមហារីក ឬរបួសខាងក្រៅ ដោយសង្កត់ធ្ងន់លើការវះកាត់។ |
| ផ្នែកជំងឺកុមារ | ធ្វើការព្យាបាលជំងឺកុមារ។ |
| ផ្នែកវះកាត់ឆ្អឹង | ធ្វើការព្យាបាលសរីរាង្គពាក់ព័ន្ធការធ្វើចលនាដូចជាឆ្អឹង សន្លាក់ សាច់ដុំ សរសៃពួរនិងសរសៃប្រសាទទាក់ទងនឹងសរីរាង្គទាំងនេះ។ |
| ផ្នែកភ្នែក | ធ្វើការព្យាបាលជំងឺពាក់ព័ន្ធនឹងភ្នែក។ |
| ផ្នែកទន្តសាស្ត្រ | ធ្វើការព្យាបាលជំងឺពាក់ព័ន្ធនឹងធ្មេញ ពត់តម្រង់ធ្មេញ ធ្មេញធ្មេញជាដើម។ |
| ផ្នែកសម្ភព | ធ្វើការព្យាបាលជំងឺពាក់ព័ន្ធនឹងការសម្រាលកូនដូចជា ការពរពោះ សម្រាល ទារកទើបនឹងកើតជាដើម។ |

## 1-2 ការស្វែងរកស្ថាប័នវេជ្ជសាស្ត្រ

- គេអាចស្វែងរកស្ថាប័នវេជ្ជសាស្ត្រតាមវិធីខាងក្រោម៖

① ព្រឹត្តិប័ត្រចេញផ្សាយដោយភូមិឃុំស្រុកដែលអ្នករស់នៅ
② បណ្ដាញអ៊ីនធើណែត
③ បណ្ដាញផ្ដល់ព័ត៌មានវេជ្ជសាស្ត្រ nationwide (Navi) ដែលជាកន្លែងដែលអ្នកអាចស្វែងរកស្ថាប័នវេជ្ជសាស្ត្រទូទាំងប្រទេស

* ព័ត៌មានវេជ្ជសាស្ត្រ Net (Navi)
https://www.iryou.teikyouseido.mhlw.go.jp/znk-web/juminkanja/S2300/initialize

* ក្រៅពីនេះ ក៏អាចស្វែងរកស្ថាប័នពេទ្យជាភាសាបរទេស
(ស្ថាប័នពេទ្យជាអាទិ៍ដែលជាកន្លែងទទួលជនបរទេស ដែលមានការកំណត់ដោយខេត្តក្រុង)
តាមគេហទំព័ររបស់មន្ទីរទេសចរណ៍ជប៉ុន(JNTO)សម្រាប់អ្នកទេសចរណ៍បរទេសមកជប៉ុនផងដែរ។
https://www.jnto.go.jp/emergency/jpn/mi_guide.html

- ហើយក៏អាចពិគ្រោះទៅស្ថាប័នខាងក្រោមបានដែរ៖

① ភូមិឃុំស្រុកដែលអ្នករស់នៅ
② មជ្ឈមណ្ឌលគាំទ្រសុវត្ថិភាពវេជ្ជសាស្ត្រ (*)

* មានសរុបប្រហែល 400 កន្លែងនៅខេត្តក្រុង ស្រុក និងតំបន់ពិសេសដែលមានមជ្ឈមណ្ឌលថែទាំសុខភាព។

ចំពោះសេចក្ដីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.anzen-shien.jp/center/

- ម្យ៉ាងទៀតអ្នកដែលមិនចេះនិយាយភាសាជប៉ុន អាចទៅពិគ្រោះកន្លែងដូចខាងក្រោម៖

① ភូមិឃុំស្រុកដែលអ្នករស់នៅ
② សមាគមផ្លាស់ប្ដូរវប្បធម៌អន្តរជាតិនៃសហគមន៍ដែលអ្នករស់នៅ
③ អង្គការធ្វើសកម្មភាពមិនរកប្រាក់ចំណេញ (អង្គការ NPO) (មានករណីឆ្លើយតបការពិគ្រោះជាភាសាបរទេស)



# 2 របបធានារ៉ាប់រងសុខភាព

អ្នកដែលរស់នៅប្រទេសជប៉ុនទោះជាសញ្ជាតិអ្វីក៏ដោយ អាចចូលធានារ៉ាប់រងសុខភាពសាធារណៈបាន។ នេះគឺជាយន្តការធានាអោយមានឱកាសស្មើភាពគ្នាក្នុងការទទួលបាននូវការថែទាំសុខភាពដែលមានគុណភាពនិងមានកម្រិតខ្ពស់ ដោយបន្ថយបន្ទុកផ្ទាល់ខ្លួននៃចំណាយលើថ្លៃព្យាបាល តាមរយៈការចែករំលែកបន្ទុកក្នុងសង្គមទាំងមូល។

## 2-1 របបថែទាំសុខភាព

### (1) លក្ខខណ្ឌចូលជាសមាជិក

អ្នកដែលធ្វើការនៅសហគ្រាស (ទីតាំងអាជីវកម្ម) ដែលតម្រូវអោយចូលជាសមាជិករបបថែទាំសុខភាព ហើយជាអ្នកមានតម្រូវការចូលជាសមាជិករបបថែទាំសុខភាព

① បុគ្គលិកពេញសិទ្ធិ អ្នកតំណាងនីតិបុគ្គល សមាជិកក្រុមប្រឹក្សាភិបាល

② អ្នកធ្វើការក្រៅម៉ោង អ្នកធ្វើការបណ្តោះអាសន្ន។ល។ ដែលធ្វើការយ៉ាងហោចណាស់បីភាគបួននៃម៉ោងធ្វើការប្រចាំសប្តាហ៍ថេររបស់និយោជិតពេញម៉ោងនៅក្នុងក្រុមហ៊ុនតែមួយ (គ្រឹះស្ថានអាជីវកម្ម)

③ អ្នកធ្វើការក្រៅម៉ោង អ្នកធ្វើការបណ្តោះអាសន្ន។ ល។ អ្នកដែលបំពេញលក្ខខណ្ឌខាងក្រោម៖

- ថេរវេលាធ្វើការធ្វើការកំណត់ចាប់ពី 20 ម៉ោងក្នុង1សប្តាហ៍
- ដែលត្រូវបានគេរំពឹងថានឹងធ្វើការលើសពីពីរខែ
- ប្រាក់កំរៃប្រចាំខែមានចំនួនលើសពី 88,000យ៉េន
- មិនមែនជាសិស្សឬនិស្សិត
- ធ្វើការនៅសហគ្រាសដែលមានបុគ្គលិកចាប់ពី51នាក់





### (2) ភាគទាន

ភាគទាននៃរបបថែទាំសុខភាព ជាទូទៅសហគ្រាសនិងបុគ្គលជាសមាជិកទទួលបន្ទុកម្នាងពាក់កណ្តាល។ ចំពោះអ្នកអាស្រ័យលើការចិញ្ចឹមមិនមានបន្ទុកបង់ភាគទានឡើយ។

### (3) ខ្លឹមសារនៃតាវកាលិក

#### បន្ទុកផ្ទាល់ខ្លួនលើថ្លៃព្យាបាល

ភាគរយនៃបន្ទុកមួយផ្នែក(បន្ទុកផ្ទាល់ខ្លួន)លើថ្លៃព្យាបាលដោយប្រើប្រាស់របបថែទាំសុខភាពគឺ

- ក្រោម 6ឆ្នាំ (កុមារមុនចូលរៀនថ្នាក់បឋមសិក្សា)៖.............20%
- ក្រោម 70ឆ្នាំ៖...........................................................30%
- 70ឆ្នាំដល់ 74ឆ្នាំ៖ ..................................................20% (ចំពោះអ្នកដែលមានចំណូលប្រហែលពេលនៅធ្វើការគឺ 30%)

## ថ្លៃព្យាបាលបង់មុន



- ទើបចូលធ្វើការមិនទាន់បានទទួលកាតសមាជិក
- នៅពេលទិញសម្ភារៈព្យាបាលដូចជារណបរុំទប់ឆ្អឹងបាក់
- នៅពេលធ្វើ Anma ចាក់ម្ជុល អុជ ម៉ាស្សាដែលគ្រូពេទ្យទទួលស្គាល់ថាចាំបាច់
- ទទួលការព្យាបាលនៅក្រៅប្រទេស ។ល។

ចេញថ្លៃព្យាបាលបង់មុនទាំងនោះទាំងអស់សិន ក្រោយមកទៀត នឹងអាចទទួលបាននូវចំណាយលើការព្យាបាលក្រៅពីបន្ទុកមួយភាគ (បន្ទុកផ្ទាល់ខ្លួន)វិញ។

## ថ្លៃព្យាបាលបង់មុនដែលមានតំលៃខ្ពស់

គឺជាប្រព័ន្ធសងប្រាក់ដែលលើសត្រឡប់វិញ ក្នុងករណីដែលចំនួនទឹកប្រាក់បង់នៅកន្លែងបង់លុយនៃស្ថាប័នវេជ្ជសាស្ត្រ ឬឱសថស្ថាន (មិនរាប់ចូលនូវបន្ទុកថ្លៃហូបចុកនៅពេលដេកពេទ្យ និងថ្លៃប្តូរគ្រែដេកជាដើមទេ) មានចំនួនលើសពីកម្រិតកំណត់មួយក្នុងអំឡុងពេល1ខែ។ “បន្ទុកខ្ពស់បំផុត” ដែលជាបន្ទុកផ្ទាល់ខ្លួនចុងក្រោយគឺខុសគ្នាទៅតាមស្ថានភាពថាសមាជិកមានអាយុលើសពី 70ឆ្នាំឬអត់ និងទៅតាមកម្រិតចំណូលរបស់សមាជិក។

## ថ្លៃបញ្ជូន

ចំពោះអ្នកជំងឺដែលមានជំងឺឬរបួសដែលមានការលំបាកក្នុងការធ្វើដំណើរ ហើយត្រូវបានបញ្ជូនដោយសារភាពបន្ទាន់ក្រោមការបញ្ជារបស់គ្រូពេទ្យ គេនឹងអាចទទួលបាននូវថ្លៃបញ្ជូនជាសាច់ប្រាក់ក្នុងករណីដែលស្របនឹងលក្ខខណ្ឌខាងក្រោម៖

- បានទទួលការព្យាបាលសមស្របក្រោយត្រូវបានបញ្ជូន
- ការដែលជំងឺ ឬរបួសដែលជាដើមហេតុនៃការបញ្ជូន ធ្វើអោយមានការលំបាកក្នុងការធ្វើដំណើរ
- មានភាពបន្ទាន់ ឬមិនអាចជៀសវាងបាន

## តាវកាលិករបួស ឬជំងឺ

សមាជិក (អ្នកចូលក្នុងរបប) មានជំងឺ ឬរបួសជាដើមហើយមិនអាចធ្វើការបាន ត្រូវឈប់សម្រាកការងារ 3ថ្ងៃជាប់គ្នា នឹងត្រូវបានផ្តល់សម្រាប់ការឈប់សម្រាកចាប់ពីថ្ងៃទី 4តទៅ។

រយៈពេលផ្តល់វែងបំផុតបានត្រឹម 1ឆ្នាំ6ខែ រាប់ចាប់ពីថ្ងៃចាប់ផ្តើមផ្តល់។

## ប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូន

ជាប្រព័ន្ធផ្តល់អោយនៅពេលសមាជិក (អ្នកចូលក្នុងរបប) ឬអ្នកដែលនៅក្នុងបន្ទុករបស់គាត់សម្រាលកូន ដើម្បីបន្ថយបន្ទុកផ្នែកសេដ្ឋកិច្ចដោយសារការសម្រាលកូន។ ទឹកប្រាក់ផ្តល់ជាទូទៅគឺ 50 ម៉ឺនយ៉េនក្នុងកូន 1នាក់។

## ប្រាក់ឧបត្ថម្ភសម្រាលកូន

នៅពេលដែលសមីខ្លួនដែលជាសមាជិកនៃរបបថែទាំសុខភាពឈប់សម្រាកពីការងារដើម្បីសម្រាលកូន អាចទទួលបាននូវប្រាក់ឧបត្ថម្ភសម្រាលកូនសម្រាប់រយៈពេលឈប់សម្រាកពីសហគ្រាសក្នុងចន្លោះត្រឹម 42ថ្ងៃ (98 ថ្ងៃក្នុងករណីពរពោះកូនភ្លោះ)មុនថ្ងៃ (គ្រោង)សម្រាលកូនរហូតដល់ 56ថ្ងៃក្រោយថ្ងៃសម្រាលកូន។

### ថ្លៃព្យាបាលគ្រួសារបង់មុន

អាចទទួលបាននូវថ្លៃព្យាបាលជម្ងឺ ឬរបួសរបស់គ្រួសារដែលទទួលអាហារកិច្ច។ ចំពោះវិសាលភាព វិធីទទួល រយៈពេលទទួលជាដើមគឺដូចជាមួយការផ្តល់ដល់សមាជិក (អ្នកចូលក្នុងរបប) ដែរ។

## 2-2 របបថែទាំសុខភាពពលរដ្ឋ

### (1) លក្ខខណ្ឌចូលជាសមាជិក

- អ្នកដែលបានចុះបញ្ជីស្នាក់នៅ មានអាយុក្រោម 75ឆ្នាំ ហើយមិនមែនជាគោលដៅនៃរបបថែទាំសុខភាពនៅកន្លែងធ្វើការ អាចចូលក្នុងរបបថែទាំសុខភាពពលរដ្ឋបាន។
- ចំពោះពលរដ្ឋបរទេស ក្រៅពីបុគ្គលប្រភេទណាមួយក្នុងចំណោមខាងក្រោម ចាំបាច់ត្រូវចូលក្នុងរបបថែទាំសុខភាពពលរដ្ឋ៖

① រយៈពេលស្នាក់នៅក្រោម 3ខែ (*)
② លក្ខណៈសម្បត្តិស្នាក់នៅ "ការស្នាក់នៅរយៈពេលខ្លី"
③ "សកម្មភាពទទួលការព្យាបាលជំងឺ" ឬអ្នក "ធ្វើសកម្មភាពមើលថែអ្នកនោះ" នៃលក្ខណៈសម្បត្តិស្នាក់នៅ "សកម្មភាពកំណត់"
④ អ្នកធ្វើ"សកម្មភាពទេសចរណ៍ ដំណើរកំសាន្ត ឬសកម្មភាពស្រដៀងនេះ" នៃលក្ខណៈសម្បត្តិស្នាក់នៅ "សកម្មភាពកំណត់"
⑤ លក្ខណៈសម្បត្តិស្នាក់នៅ "ការទូត"
⑥ បុគ្គលគ្មានលក្ខណៈសម្បត្តិស្នាក់នៅ ហើយស្នាក់នៅដោយខុសច្បាប់ជាដើម
⑦ ជាបុគ្គលមកពីប្រទេសដែលមានការចុះកិច្ចព្រមព្រៀងសន្តិសុខសង្គមដែលមានរួមទាំងរបបធានារ៉ាប់រងសុខភាពជាមួយប្រទេសជប៉ុន ហើយបានទទួលលិខិតបញ្ជាក់ការចូលរបបសន្តិសុខសង្គម (លិខិតបញ្ជាក់ការចូលជាសមាជិក) ពីរដ្ឋាភិបាលប្រទេសរបស់ខ្លួន។



* ទោះបីរយៈពេលស្នាក់ក្រោម 3ខែក៏ដោយ ក្នុងករណីលក្ខណៈសម្បត្តិស្នាក់នៅណាមួយក្នុងចំណោមខាងក្រោម អ្នកដែលត្រូវបានទទួលស្គាល់ការស្នាក់នៅលើសពី 3ខែតាមរយៈឯកសារ អាចចូលជាសមាជិកបាន៖

- លក្ខណៈសម្បត្តិស្នាក់នៅ "កំសាន្ត"
- លក្ខណៈសម្បត្តិស្នាក់នៅ "កម្មសិក្សាជំនាញ"
- លក្ខណៈសម្បត្តិស្នាក់នៅ "ស្នាក់នៅជាមួយគ្រួសារ"
- លក្ខណៈសម្បត្តិស្នាក់នៅ "សកម្មភាពកំណត់ (លើកលែងករណី③ និង ④ ខាងលើ)"

### (2) បែបបទក្នុងការចូលនិងចាកចេញ

បែបបទក្នុងការចូលនិងចាកចេញពីរបបថែទាំសុខភាពពលរដ្ឋ (*) ត្រូវធ្វើនៅភូមិឃុំស្រុកដែលអ្នករស់នៅ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

(*) បុគ្គលដូចខាងក្រោមត្រូវធ្វើបែបបទចាកចេញពីរបបថែទាំសុខភាពពលរដ្ឋ៖

① ក្នុងករណីផ្លាស់លំនៅពីភូមិឃុំស្រុកកំពុងរស់នៅទៅភូមិឃុំស្រុកផ្សេង
② បានប្តូរចូលក្នុងរបបថែទាំសុខភាពរបស់សហគ្រាស ។ល។

## (3) ភាគទាន

ភាគទានត្រូវបានគណនាតាមគ្រួសារ ទៅតាមចំណូលរបស់សមាជិកនិងចំនួនមនុស្សក្នុងគ្រួសារជាដើម។ មេគ្រួសារជាអ្នកមានកាតព្វកិច្ចត្រូវបង់ភាគទាន។

* ដោយសារមានករណីដែលភាគទានអាចត្រូវបានបន្ធូរបន្ថយទៅតាមស្ថានភាពនៃចំណូលឬជីវភាព សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

## (4) ខ្លឹមសារនៃតារាវកាលិក

### បន្ទុកផ្ទាល់ខ្លួនលើថ្លៃព្យាបាល

ភាគរយនៃបន្ទុកមួយផ្នែក (បន្ទុកផ្ទាល់ខ្លួន) លើថ្លៃព្យាបាលដោយប្រើប្រាស់របបថែទាំសុខភាពពលរដ្ឋគឺ

- ក្រោម 6ឆ្នាំ (កុមារមុនចូលរៀនថ្នាក់បឋមសិក្សា)៖.............20%
- ក្រោម 70ឆ្នាំ៖..............................................................30%
- 70ឆ្នាំដល់ 74ឆ្នាំ៖ ........................................................20% (ចំពោះអ្នកដែលមានចំណូលប្រហែលពេលនៅធ្វើការគឺ 30%)

### ថ្លៃព្យាបាលបង់មុន



- នៅពេលដែលអ្នកទើបតែបានចូលរួមជាមួយធានារ៉ាប់រងសុខភាពជាតិ ហើយមិនទាន់ទទួលបានប័ណ្ណធានារ៉ាប់រងនៅឡើយទេ។
- នៅពេលទិញសម្ភារៈព្យាបាលដូចជារណបរុំទប់ឆ្អឹងបាក់
- នៅពេលធ្វើ Anma ចាក់ម្ជុល អុជ ម៉ាស្សាដែលគ្រូពេទ្យទទួលស្គាល់ថាចាំបាច់
- ទទួលការព្យាបាលនៅក្រៅប្រទេស ។ល។

ចេញថ្លៃព្យាបាលបង់មុនទាំងនោះទាំងអស់សិន ក្រោយមកទៀត នៅពេលដាក់ពាក្យសុំ ហើយគេទទួលស្គាល់ នឹងអាចទទួលបាននូវចំណាយលើការព្យាបាលដែលលើសបន្ទុកមួយផ្នែក (បន្ទុកផ្ទាល់ខ្លួន) មកវិញ។

### ថ្លៃព្យាបាលបង់មុនដែលមានតំលៃខ្ពស់

គឺជាប្រព័ន្ធសងប្រាក់ដែលលើសត្រឡប់មកវិញ ក្នុងករណីដែលចំនួនទឹកប្រាក់បង់នៅកន្លែងបង់លុយនៃស្ថាប័នវេជ្ជសាស្ត្រ ឬឱសថស្ថាន (មិនរាប់ចូលនូវបន្ទុកថ្លៃហូបចុកនៅពេលដេកពេទ្យ និងថ្លៃប្ដូរគ្រែដេកជាដើមទេ) មានចំនួនលើសពីកម្រិតកំណត់មួយក្នុងអំឡុងពេល1ខែ។ "បន្ទុកខ្ពស់បំផុត" ដែលជាបន្ទុកផ្ទាល់ខ្លួនចុងក្រោយគឺខុសគ្នាទៅតាមស្ថានភាពថាសមាជិកមានអាយុលើសពី 70ឆ្នាំឬអត់ និងទៅតាមកម្រិតចំណូលរបស់សមាជិក។

### ថ្លៃបញ្ជូន

ចំពោះអ្នកជំងឺដែលមានជំងឺឬរបួសដែលមានការលំបាកក្នុងការធ្វើដំណើរ ហើយត្រូវបានបញ្ជូនដោយសារភាពបន្ទាន់ក្រោមការបញ្ជារបស់គ្រូពេទ្យ ក្នុងករណីបំពេញលក្ខខណ្ឌខាងក្រោម នឹងអាចទទួលបាននូវថ្លៃបញ្ជូនជាសាច់ប្រាក់ ៖

- បានទទួលការព្យាបាលសមស្របក្រោយត្រូវបានបញ្ជូន
- ការដែលជំងឺ ឬរបួសដែលជាដើមហេតុនៃការបញ្ជូន ធ្វើអោយមានការលំបាកក្នុងការធ្វើដំណើរ

- មានភាពបន្ទាន់ ឬមិនអាចជៀសវាងបាន

### ប្រាក់បំណាច់សម្រាលនិងចិញ្ចឹមកូន

ជាប្រព័ន្ធផ្តល់អោយនៅពេលសមាជិកសម្រាលកូន ដើម្បីបន្ថយបន្ទុកផ្នែកសេដ្ឋកិច្ចដោយសារការសម្រាលកូន។ ទឹកប្រាក់ផ្តល់ជាទូទៅគឺ 50 ម៉ឺនយ៉េនក្នុងកូន 1នាក់។

## 2-3 របបថែទាំសុខភាពមនុស្សចាស់

### (1) លក្ខខណ្ឌចូលជាសមាជិក

#### នៅពេលដល់អាយុ 75 ឆ្នាំ



- អ្នកដែលបានចុះបញ្ជីស្នាក់នៅ ហើយមានអាយុចាប់ពី 75ឆ្នាំ អាចចូលក្នុងរបបថែទាំសុខភាពមនុស្សចាស់។
- អ្នកមានអាយុចាប់ពី 65ឆ្នាំរហូតដល់ 74ឆ្នាំ ហើយមានការទទួលស្គាល់ថាមានពិការភាពក្នុងកម្រិតមួយក៏អាចចូលបានដែរ។
- ពេលចូលរបបថែទាំសុខភាពមនុស្សចាស់ ត្រូវចាកចេញពីរបបធានារ៉ាប់រងសុខភាពដែលបានចូលពីមុន (ដូចជា របបថែទាំសុខភាពពលរដ្ឋ សហជីពធានារ៉ាប់រងសុខភាព សមាគមធានារ៉ាប់រងសុខភាពជប៉ុន សហជីពសង្គ្រោះគ្នាទៅវិញទៅមក)
- ចំពោះពលរដ្ឋបរទេសដែលមានអាយុចាប់ពី 75ឆ្នាំឡើងទៅ ក្រៅពីបុគ្គលប្រភេទណាមួយក្នុងចំណោមខាងក្រោម ចាំបាច់ត្រូវចូលក្នុងរបបថែទាំសុខភាពមនុស្សចាស់៖

① រយៈពេលស្នាក់នៅក្រោម 3ខែ (*)
② លក្ខណៈសម្បត្តិស្នាក់នៅ "ការស្នាក់នៅរយៈពេលខ្លី"
③ "សកម្មភាពទទួលការព្យាបាលជំងឺ" ឬអ្នក "ធ្វើសកម្មភាពមើលថែអ្នកនោះ" នៃលក្ខណៈសម្បត្តិស្នាក់នៅ "សកម្មភាពកំណត់"
④ អ្នកធ្វើ "សកម្មភាពទេសចរណ៍ ដំណើរកំសាន្ត ឬសកម្មភាពស្រដៀងនេះ" នៃលក្ខណៈសម្បត្តិស្នាក់នៅ "សកម្មភាពកំណត់"
⑤ លក្ខណៈសម្បត្តិស្នាក់នៅ "ការទូត"
⑥ បុគ្គលគ្មានលក្ខណៈសម្បត្តិស្នាក់នៅ ហើយស្នាក់នៅដោយខុសច្បាប់ជាដើម
⑦ ជាបុគ្គលមកពីប្រទេសដែលបានមានការចុះកិច្ចព្រមព្រៀងផ្នែកសន្តិសុខសង្គមដែលមានរួមទាំងរបបធានារ៉ាប់រងសុខភាពជាមួយប្រទេសជប៉ុន ហើយបានទទួលលិខិតបញ្ជាក់ការចូលរបបសន្តិសុខសង្គម (លិខិតបញ្ជាក់ការចូលជាសមាជិក) ពីរដ្ឋាភិបាលប្រទេសរបស់ខ្លួន។

* ទោះបីរយៈពេលស្នាក់នៅក្រោម 3ខែក៏ដោយ ក្នុងករណីលក្ខណៈសម្បត្តិស្នាក់នៅមួយក្នុងចំណោមខាងក្រោម អ្នកដែលត្រូវបានទទួលស្គាល់ការស្នាក់នៅលើសពី 3ខែតាមរយៈឯកសារ អាចចូលជាសមាជិកបាន៖

- លក្ខណៈសម្បត្តិស្នាក់នៅ "កំសាន្ត"
- លក្ខណៈសម្បត្តិស្នាក់នៅ "កម្មសិក្សាជំនាញ"
- លក្ខណៈសម្បត្តិស្នាក់នៅ "ស្នាក់នៅជាមួយគ្រួសារ"
- លក្ខណៈសម្បត្តិស្នាក់នៅ "សកម្មភាពកំណត់ (លើកលែងករណី③ និង ④ ខាងលើ)"

## (2) បែបបទក្នុងការចូលនិងចាកចេញ

បែបបទក្នុងការចូលនិងចាកចេញពីរបបថែទាំសុខភាពមនុស្សចាស់ ត្រូវធ្វើនៅភូមិឃុំស្រុកដែលអ្នករស់នៅ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

ក្នុងករណីផ្លាស់លំនៅពីភូមិឃុំស្រុកកំពុងរស់នៅឆ្លងទៅភូមិឃុំស្រុកនៅក្នុងខេត្តក្រុងផ្សេង ត្រូវធ្វើបែបបទចាកចេញពីរបបថែទាំសុខភាពមនុស្សចាស់។

## (3) ភាគទាន

ភាគទានគឺជាទឹកប្រាក់សរុបដោយយកទឹកប្រាក់ដែលសមាជិកទាំងអស់ត្រូវមានបន្ទុកស្មើៗគ្នា បូកជាមួយទឹកប្រាក់ដែលសមាជិកត្រូវទទួលបន្ទុកទៅតាមចំណូលរបស់ខ្លួន។

មានករណីដែលភាគទានអាចត្រូវបានបន្ធូរបន្ថយ ចំពោះអ្នកដែលធ្លាប់នៅក្នុងបន្ទុកនៃសមាជិកនៃរបបថែទាំសុខភាពរបស់សហគ្រាស ឬទៅតាមស្ថានភាពនៃចំណូលឬជីវភាពជាដើម។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។ឬនៅសមាគមដែលទទួលខុសត្រូវលើប្រតិបត្តិការនៃប្រព័ន្ធថែទាំសុខភាពសម្រាប់មនុស្សចាស់ដែលមានអាយុចាប់ពី 75 ឆ្នាំឡើងទៅ។

## (4) ខ្លឹមសារនៃតាវកាលិក

### បន្ទុកផ្ទាល់ខ្លួនលើថ្លៃព្យាបាល

ភាគរយនៃបន្ទុកមួយផ្នែក (បន្ទុកផ្ទាល់ខ្លួន) នៅពេលទទួលការព្យាបាលដែលអាចប្រើប្រាស់របបធានារ៉ាប់រងសុខភាពបាន គឺ10%នៃថ្លៃព្យាបាល។ ប៉ុន្តែចំពោះអ្នកដែលមានចំណូលប្រហែលពេលនៅធ្វើការ គឺត្រូវទទួលបន្ទុក 30%ឬប្រសិនបើអ្នកមានប្រាក់ចំណូលលើសពីកម្រិតជាក់លាក់មួយ ចំណែករបស់អ្នកគឺ 20%។

### ថ្លៃព្យាបាលបង់មុន



- នៅពេលទើបចូលជាសមាជិក មិនទាន់បានទទួលកាតសមាជិក
- នៅពេលទិញសម្ភារៈព្យាបាលដូចជារណបរុំទប់ឆ្អឹងបាក់
- នៅពេលធ្វើ Anma ចាក់ម្ជុល អុជ ម៉ាស្សាដែលគ្រូពេទ្យទទួលស្គាល់ថាចាំបាច់
- ទទួលការព្យាបាលនៅក្រៅប្រទេស ។ល។

ចេញថ្លៃព្យាបាលទាំងនោះទាំងអស់សិន ក្រោយមកទៀត នៅពេលដាក់ពាក្យសុំ ហើយប្រសិនបើមានការទទួលស្គាល់ នឹងអាចទទួលបានថ្លៃព្យាបាលវេជ្ជសាស្ត្រសម្រាប់ផ្នែកដែលលើសពីការបង់ប្រាក់រួម។

### ថ្លៃព្យាបាលបង់មុនដែលមានតំលៃខ្ពស់

គឺជាប្រព័ន្ធសងប្រាក់ដែលលើសត្រឡប់វិញ ក្នុងករណីដែលចំនួនទឹកប្រាក់បង់នៅកន្លែងបង់លុយនៃស្ថាប័នវេជ្ជសាស្ត្រ ឬឱសថស្ថាន (មិនរាប់ចូលនូវបន្ទុកថ្លៃហូបចុកនៅពេលដេកពេទ្យ និងថ្លៃប្តូរគ្រែដេកជាដើមទេ) មានចំនួនលើសពីកម្រិតកំណត់មួយក្នុងអំឡុងពេល1ខែ។ "បន្ទុកខ្ពស់បំផុត" ដែលជាបន្ទុកផ្ទាល់ខ្លួនចុងក្រោយគឺខុសគ្នាទៅតាមកម្រិតចំណូលរបស់សមាជិក។

### ថ្លៃបញ្ជូន

ចំពោះអ្នកជំងឺដែលមានជំងឺឬរបួសដែលមានការលំបាកក្នុងការធ្វើដំណើរ ហើយត្រូវបានបញ្ជូនក្រោមការបញ្ជារបស់គ្រូពេទ្យ នឹងអាចទទួលនូវថ្លៃបញ្ជូនមកវិញជាសាច់ប្រាក់ក្នុងករណីដែលស្របនឹងលក្ខខណ្ឌដូចខាងក្រោម៖

- បានទទួលការព្យាបាលសមស្របក្រោយត្រូវបានបញ្ជូន
- ការដែលជំងឺ ឬរបួសដែលជាដើមហេតុនៃការបញ្ជូន ធ្វើអោយមានការលំបាកក្នុងការធ្វើដំណើរ
- មានភាពបន្ទាន់ ឬមិនអាចជៀសវាងបាន

# 3 ថ្នាំពេទ្យ

- គេអាចទិញថ្នាំពេទ្យបាននៅឱសថស្ថាន ឬនៅ drugstore ។
- គេប្រើប្រាស់ថ្នាំពេទ្យដើម្បីព្យាបាលជំងឺឬរបួស ប៉ុន្តែថ្នាំពេទ្យមានផលប៉ះពាល់ ដូច្នេះសូមប្រុងប្រយ័ត្នអំពីរបៀបប្រើ។
- បើមានចម្ងល់អំពីថ្នាំពេទ្យ សូមពិគ្រោះជាមួយឱសថការី ឬអ្នកលក់មានចុះបញ្ជីនៅឱសថស្ថាន ឬនៅ drugstore ។

* អ្នកលក់មានចុះបញ្ជី អាចលក់ថ្នាំពេទ្យមួយចំនួនដែលមិនត្រូវការវេជ្ជបញ្ជា (ថ្នាំពេទ្យ OTC)។

## 3-1 ឱសថស្ថាន

នៅឱសថស្ថានគេផ្តល់ថ្នាំតាមវេជ្ជបញ្ជាដែលចេញដោយគ្រូពេទ្យ ឱសថការីចែកចាយថ្នាំ ហើយអ្នកអាចទទួលថ្នាំបានបន្ទាប់ពីផ្តល់ការណែនាំអំពីរបៀបប្រើវា។គឺគេអាចទិញថ្នាំតាមវេជ្ជបញ្ជាបាន។ ហើយក៏អាចទិញថ្នាំពេទ្យ OTCបានដែរ។

## 3-2 Drugstore

ចំពោះថ្នាំពេទ្យ OTC គេអាចទិញបានដូចនៅឱសថស្ថានដែរ។ ប៉ុន្តែនៅ drugstore គេមិនលក់ថ្នាំតាមវេជ្ជបញ្ជានោះទេ។



ជំពូកទី7

# របបប្រាក់សោធន និងសុខុមាលភាព



## 1 របបប្រាក់សោធន

របបប្រាក់សោធនរបស់ប្រទេសជប៉ុនគឺជាយន្តការដើម្បីសម្រេចអោយបាននូវការធានាពេញមួយជីវិត តាមរយៈការទ្រទ្រង់គ្នាទៅវិញទៅមកក្នុងសង្គមទាំងមូលមិនត្រឹមតែជំនាន់របស់ខ្លួនឡើយ។

វិធីប្រតិបត្តិការគឺប្រើប្រាស់ភាគទានដែលជំនាន់មនុស្សកំពុងធ្វើការបង់ សម្រាប់ជាតាវកាលិករបស់អ្នកមានអាយុច្រើនជាដើម។

បន្ថែមពីលើប្រាក់សោធនជរាភាព ក៏មានប្រាក់សោធនពិការភាព និងប្រាកសោធនអ្នកក្នុងបន្ទុក។

### 【ទិដ្ឋភាពបង្ហាញករណីទទួលប្រាក់សោធនជរាភាពមូលដ្ឋាន និងប្រាក់សោធនជរាភាពសុខុមាលភាព】



# 1-1 របបប្រាក់សោធនពលរដ្ឋ

ក្នុងប្រព័ន្ធសោធនសាធារណៈរបស់ប្រទេសជប៉ុន ជាទូទៅអ្នកដែលរស់នៅប្រទេសជប៉ុនហើយមានអាយុពី 20ឆ្នាំដល់ 60ឆ្នាំទាំងអស់ត្រូវចូលជាសមាជិកក្នុងរបបប្រាក់សោធនសាធារណៈ។

## (1) សមាជិក (អ្នកចូលក្នុងរបប) និងនីតិវិធីចូលជាសមាជិក

សមាជិក (អ្នកចូលក្នុង) របបប្រាក់សោធនពលរដ្ឋមាន 3ប្រភេទចាប់ពីប្រភេទទី1 ដល់ប្រភេទទី3។

① សមាជិកប្រភេទទី1

- អ្នករកស៊ីខ្លួនឯង សិស្សជាដើម អ្នកដែលមិនចូលក្នុងលក្ខណៈនៃសមាជិកប្រភេទទី2 និងសមាជិកប្រភេទទី3 គឺជាសមាជិកប្រភេទទី1 នៃរបបប្រាក់សោធនពលរដ្ឋ។
- ការធ្វើបែបបទចុះបញ្ជីសមាជិកគឺធ្វើនៅភូមិឃុំស្រុកដែលខ្លួនរស់នៅ។

② សមាជិកប្រភេទទី2

- អ្នកធ្វើការនៅក្រុមហ៊ុនជាដើម ហើយជាសមាជិកនៃរបបប្រាក់សោធនសុខុមាលភាព គឺជាសមាជិកប្រភេទទី2 នៃរបបប្រាក់សោធនពលរដ្ឋ។
- បែបបទនៃការចុះបញ្ជីសមាជិក គឺក្រុមហ៊ុន (ម្ចាស់សហគ្រាស) ជាដើមជាអ្នកធ្វើ។

③ សមាជិកប្រភេទទី3

- សហព័ទ្ធដែលក្នុងបន្ទុករបស់បុគ្គលដែលជាសមាជិកនៃរបបប្រាក់សោធនសុខុមាលភាព (សមាជិកប្រភេទទី2 នៃរបបប្រាក់សោធនពលរដ្ឋ) គឺជាសមាជិកប្រភេទទី3 នៃរបបប្រាក់សោធនពលរដ្ឋ។
- បែបបទនៃការចុះបញ្ជីសមាជិកគឺធ្វើឡើងតាមរយៈក្រុមហ៊ុនដែលសហព័ទ្ធ (សមាជិកប្រភេទទី2 នៃរបបប្រាក់សោធនពលរដ្ឋ) ធ្វើការជាដើម។

* សហព័ទ្ធដែលនៅក្នុងបន្ទុករបស់សមាជិកប្រភេទទី1 គឺមិនមែនជាសមាជិកប្រភេទទី3ឡើយ។

* សហព័ទ្ធដែលនៅក្នុងបន្ទុករបស់អ្នកមានសិទ្ធិទទួលប្រាក់សោធនដែលមានអាយុចាប់ពី 65ឆ្នាំឡើងហើយជាសមាជិកនៃរបបប្រាក់សោធនសុខុមាលភាព មិនមែនជាសមាជិកប្រភេទទី3 ឡើយ។

លើសពីនេះ អ្នកដែលមិនស្ថិតនៅក្រោម ① ដល់ ③ និងរស់នៅក្នុងប្រទេសជប៉ុនដែលមានអាយុពី60 ឆ្នាំ និងក្រោម 70 ឆ្នាំអាចដាក់ពាក្យសុំក្លាយជាសមាជិករបបប្រាក់សោធនពលរដ្ឋ (សមាជិកដែលបានចុះឈ្មោះដោយស្ម័គ្រចិត្ត) ប្រសិនបើបំពេញលក្ខខណ្ឌមួយចំនួន។ នីតិវិធីចុះឈ្មោះត្រូវបានអនុវត្តនៅសាលាក្រុងភូមិឃុំសង្កាត់ដែលបុគ្គលនោះរស់នៅ។

* អ្នកដែលមានអាយុពី 65ឆ្នាំនិងក្រោម 70 ឆ្នាំត្រូវតែបំពេញតាមលក្ខខណ្ឌមួយចំនួន ដូចជាកើតមុនថ្ងៃទី 1 ខែមេសា ឆ្នាំ 1965 ឬមិនបំពេញតាមរយៈពេលមានសិទ្ធិ 10 ឆ្នាំ។

## (2) ភាគទាន

- ភាគទានដែលសមាជិកប្រភេទទី1 និងសមាជិកដែលបានចុះឈ្មោះដោយស្ម័គ្រចិត្តត្រូវបង់គឺដូចៗគ្នា។ លើសពីនេះទៀតតាមការស្នើសុំ វាអាចបង់ភាគទាន (អតិថិជនជាជម្រើស 400 យ៉េនក្នុងមួយខែ) ពីលើភាគទានធម្មតា។ សមាជិកប្រភេទទី2 និងសមាជិកប្រភេទទី3 មិនចាំបាច់បង់ ភាគទាននៃរបបប្រាក់សោធនពលរដ្ឋឡើយ។

- គេអាចបង់ភាគទានតាមរយៈវិក្កយបត្របង់ប្រាក់ (ការទូទាត់តាមបញ្ជរស្ថាប័នហិរញ្ញវត្ថុ ផ្សារម៉ាត។ល។) ការផ្ទេរតាមគណនីធនាគារ ក្រេឌីតកាត។
- ការបង់ភាគទានសរុបជាមុន អាចទទួលបានការបញ្ចុះតំលៃ។
- សមាជិកប្រភេទទី1 ក្នុងករណីដែលប្រាក់ចំណូលធ្លាក់ចុះ ឬគ្មានការងារធ្វើជាដើម ហើយមានការលំបាកក្នុងការបង់ភាគទាន គឺមានប្រព័ន្ធលើកលែង ឬលើកពេលការបង់ភាគទាន។
- សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ ឬទៅការិយាល័យប្រាក់សោធន។

* ប្រសិនបើភាគទាននៅតែមិនបានបង់,

- "ប្រាក់សោធនជរាភាពមូលដ្ឋាន" នឹងត្រូវបានកាត់បន្ថយប្រហែល 20,000 យ៉េន ក្នុងមួយឆ្នាំសម្រាប់រាល់ឆ្នាំនៃការមិនបង់ប្រាក់។
- ប្រសិនបើអ្នកក្លាយជាជនពិការ មានករណីខ្លះអ្នកប្រហែលជាមិនអាចទទួលបាន"ប្រាក់សោធនពិការភាពមូលដ្ឋាន" បានទេ។
- នៅពេលស្លាប់ អ្នកនៅក្នុងបន្ទុកប្រហែលជាមិនអាចទទួលបាន "ប្រាក់សោធនមូលដ្ឋានចំពោះអ្នកនៅក្នុងបន្ទុក" បានទេ។

## (3) តារកាលិក

### ប្រាក់សោធនជរាភាពមូលដ្ឋាន

- អ្នកដែលថេរវេលាមានសិទ្ធិទទួល (អំឡុងពេលបង់ភាគទាននិងអំឡុងពេលដែលភាគទានត្រូវបានលើកលែងជាដើម) ចាប់ពី10 ឆ្នាំឡើងទៅ អាចទទួលបានប្រាក់សោធនជរាភាពមូលដ្ឋានចាប់ពីអាយុ 65ឆ្នាំតទៅ។
- ទឹកប្រាក់នៃសោធនជរាភាពមូលដ្ឋានគឺផ្អែកលើអំឡុងពេលដែលបានបង់ភាគទាន។
- បុគ្គលដែលបានបង់ភាគទានក្នុងអំឡុងពេល 40ឆ្នាំចាប់ពីអាយុ 20ឆ្នាំដល់អាយុ 60ឆ្នាំ អាចទទួលបានប្រាក់សោធនជរាភាពមូលដ្ឋានក្នុងចំនួនពេញ។
- អ្នកដែលបានបង់ភាគទានបន្ថែមអាចទទួលបានប្រាក់សោធនបន្ថែម (ចំនួនប្រចាំឆ្នាំ) នៃ "200 យ៉េន x ចំនួនខែដែលភាគទានបន្ថែមត្រូវបានបង់" ។

* អំឡុងពេលដែលមិនបានបង់ភាគទាន គឺមិនមែនជាថេរវេលាមានសិទ្ធិទទួលឡើយ។

* ទឹកប្រាក់នៃសោធនជរាភាពមូលដ្ឋានរបស់បុគ្គលដែលមានអំឡុងពេលលើកលែងភាគទាន មានវិធីគណនាខុសៗគ្នាទៅតាមប្រភេទនៃការលើកលែង និងភាគរយនៃបន្ទុករបស់រដ្ឋក្នុងសោធនមូលដ្ឋាន។

### ប្រាក់សោធនពិការភាពមូលដ្ឋាន

- បុគ្គលដែលបំពេញលក្ខខណ្ឌខាងក្រោមទាំងអស់អាចទទួលបានប្រាក់សោធនពិការភាពមូលដ្ឋាន។

① ស្ថិតក្នុងអំឡុងពេលដែលជាសមាជិកនៃរបបប្រាក់សោធនពលរដ្ឋ មានការពិនិត្យលើកដំបូង (កាលបរិច្ឆេទនៃការពិនិត្យលើកដំបូងដោយវេជ្ជបណ្ឌិត ឬទន្តពេទ្យទាក់ទងនឹងជំងឺ ឬរបួសដែលបណ្តាលឱ្យមានពិការភាព)

② ដោយសារជំងឺ ឬរបួសមាននៅសល់ពិការភាពក្នុងកម្រិតមួយ

③ ស្របលក្ខខណ្ឌបង់ភាគទាននៅមួយថ្ងៃមុនទទួលការពិនិត្យដំបូង

- កម្រិតពិការភាពនៃប្រាក់សោធនពិការភាពមូលដ្ឋានមានកម្រិត1 កម្រិត 2 និងកម្រិត 3។
- ប្រាក់សោធនពិការភាពមូលដ្ឋានមានទឹកប្រាក់ខុសគ្នាតាមកម្រិត។

① កម្រិតពិការភាពកម្រិត1 → 1.25 ដងនៃទឹកប្រាក់ពេញនៃប្រាក់សោធនជរាភាពមូលដ្ឋាន
② កម្រិតពិការភាពកម្រិត2 → ស្មើនឹងទឹកប្រាក់ពេញនៃប្រាក់សោធនជរាភាពមូលដ្ឋាន

- ក្នុងករណីមានកូន ទាំងក្នុងករណីកម្រិត1 និងកម្រិត2 គឺមានការបូកបន្ថែម។

## ប្រាក់សោធនមូលដ្ឋានចំពោះអ្នកនៅក្នុងបន្ទុក

- សហព័ទ្ធដែលមានកូន" ឬ "កូន" ដូចលក្ខណៈសម្បត្តិខាងក្រោមអាចទទួលបានប្រាក់សោធនមូលដ្ឋានចំពោះអ្នកនៅក្នុងបន្ទុក។

  ⇒ ត្រូវនឹងលក្ខខណ្ឌ ① ឬលក្ខខណ្ឌ ②

① នៅខណៈពេលដែលបុគ្គលជាសមាជិកអាយុ 60 ឆ្នាំ ឬចាស់ជាងនេះ ប៉ុន្តែអាយុក្រោម 65 ឆ្នាំ និងអ្នកដែលរស់នៅក្នុងប្រទេសជប៉ុនទទួលមរណភាពសាមីខ្លួនបានបំពេញលក្ខខណ្ឌបង់ភាគទាននៃរបបប្រាក់សោធនពលរដ្ឋ
② បុគ្គលដែលថេរវេលាមានសិទ្ធិទទួលប្រាក់សោធនជរាភាពមូលដ្ឋានមានអំឡុងពេលចាប់ពី25ឆ្នាំឡើងបានទទួលមរណភាព

⇒ ជីវភាពត្រូវបានទ្រទ្រង់ដោយបុគ្គលដែលបានទទួលមរណភាព

- ប្រាក់សោធនមូលដ្ឋានចំពោះអ្នកនៅក្នុងបន្ទុកមានចំនួនស្មើនឹងប្រាក់សោធនជរាភាពមូលដ្ឋាន។ ក្នុងករណីដែលមាន"កូន" គឺមានការបូកបន្ថែម។

ចំណុចគួរដឹង៖

### "កូន" មានន័យថា



"កូន" គឺជាកូនដែលមិនទាន់រៀបការដូចខាងក្រោម។

- កូនមុនថ្ងៃទី31 ខែមីនាដំបូងក្រោយថ្ងៃកំណើតអាយុ18ឆ្នាំ
- កូនក្រោមអាយុ 20ឆ្នាំដែលមានពិការភាពក្នុងកម្រិតពិការភាពទី1 ឬកម្រិតពិការភាពទី2

## វិភាជន៍មរណភាព

- បុគ្គលដែលបានបង់ភាគទានលើសពី 36ខែក្នុងនាមជាសមាជិកប្រភេទទី1 ហើយបានទទួលមរណភាពដោយមិនបានទទួលប្រាក់សោធនជរាភាពមូលដ្ឋាន និងប្រាក់សោធនពិការភាពមូលដ្ឋាន ក្នុងករណីដែលអ្នកនៅក្នុងបន្ទុកមិនអាចទទួលបានប្រាក់សោធនមូលដ្ឋានចំពោះអ្នកនៅក្នុងបន្ទុក អ្នកនៅក្នុងបន្ទុកនោះអាចទទួលបានវិភាជន៍មរណភាព។
- ទឹកប្រាក់នៃវិភាជន៍មរណភាពខុសគ្នាទៅតាមអំឡុងពេលដែលបានបង់ភាគទាន និងអំឡុងពេលដែលភាគទានត្រូវបានលើកលែង។

## ប្រាក់សោធនស្ត្រីមេម៉ាយ

- ប្រាក់សោធនស្ត្រីមេម៉ាយគឺក្នុងករណីដែលប្តីដែលបានបង់ភាគទានក្នុងនាមជាសមាជិកប្រភេទទី1លើសពី 10ឆ្នាំ មានជីវភាពត្រូវបានទ្រទ្រង់ដោយប្តីនៅពេលដែលប្តីស្លាប់ ហើយមានទំនាក់ទំនងជាប្តីប្រពន្ធលើសពី 10ឆ្នាំ ប្រពន្ធនោះអាចទទួលបានប្រាក់សោធនស្ត្រីមេម៉ាយចាប់ពីអាយុ 60ឆ្នាំ ដល់អាយុ 65ឆ្នាំ។

- ប្រាក់សោធនស្ត្រីមេម៉ាយ មានចំនួន 3ភាគ4នៃប្រាក់សោធនជរាភាពមូលដ្ឋានដែលត្រូវបានគណនាដោយផ្អែកលើអំឡុងពេលជាសមាជិកប្រភេទទី1របស់ប្តីតែមួយមុខប៉ុណ្ណោះ។

## 1-2 របបប្រាក់សោធនសុខុមាលភាព

កម្មករនិយោជិតដែលធ្វើការនៅសហគ្រាសដែលអនុវត្ត អាចចូលក្នុងរបបប្រាក់សោធនសុខុមាលភាពបាន។ (លក្ខខណ្ឌនៃសហគ្រាសដែលអនុវត្ត និងលក្ខខណ្ឌនៃការចូលសមាជិកគឺដូចគ្នានឹងរបបថែទាំសុខភាពដែរ។)

កម្មករនិយោជិតដែលមិនមែនជាកម្មវត្ថុនៃរបបប្រាក់សោធនសុខុមាលភាព គឺចូលជាសមាជិកនៃរបបប្រាក់សោធនពលរដ្ឋ។

### (1) សមាជិក (អ្នកចូល)

- បុគ្គលដែលមានអាយុតិចជាង 70ឆ្នាំធ្វើការនៅសហគ្រាសដែលអនុវត្តប្រសិនបើបំពេញលក្ខខណ្ឌណាមួយខាងក្រោម ក្លាយជាសមាជិក (អ្នកចូល) របបប្រាក់សោធនសុខុមាលភាព។
- អ្នកដែលមានអាយុចាប់ពី 70 ឆ្នាំឡើងក៏អាចដាក់ពាក្យសុំក្លាយជាសមាជិក (សមាជិកដែលបានចុះឈ្មោះដោយស្ម័គ្រចិត្តសម្រាប់មនុស្សចាស់) ប្រសិនបើពួកគេមិនបំពេញលក្ខខណ្ឌមួយចំនួន ដូចជាមិនមានសិទ្ធិទទួលបានប្រាក់សោធនជរាភាព។

#### * លក្ខខណ្ឌរបស់សហគ្រាសដែលអនុវត្ត

សហគ្រាសដូចខាងក្រោមជាសហគ្រាសដែលអនុវត្ត។

① នីតិបុគ្គលដូចជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតជាដើម
② ក្រុមហ៊ុនឯកជន (លើសពី 5នាក់) ក្រៅពីឧស្សាហកម្មផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឧស្សាហកម្មសេវាកម្ម
③ កន្លែងអាជីវកម្មដែលអនុវត្តដោយស្ម័គចិត្ត តាមការព្រមព្រៀងរវាងនិយោជកនិងនិយោជិត

#### * លក្ខខណ្ឌក្លាយជាសមាជិក

អ្នកដែលមានត្រូវចំណុចណាមួយពី (ក)ដល់ (គ) ដែលប្រើប្រាស់នៅសហគ្រាសដែលអនុវត្តគឺក្លាយជាសមាជិក។

(ក) បុគ្គលិកពេញម៉ោង តំណាងក្រុមហ៊ុន និងសមាជិកក្រុមប្រឹក្សាភិបាល
(ខ) អ្នកដែល(ធ្វើការងារក្រៅម៉ោងជាដើម។ល។)ចំនួនម៉ោងកំណត់ធ្វើការក្នុង1សប្តាហ៍ឬចំនួនថ្ងៃកំណត់ធ្វើការក្នុង1ខែមានលើសពី3/4ដូចបុគ្គលិកពេញសិទ្ធិដែលធ្វើការដូចគ្នានៅកន្លែងដូចគ្នា។
(គ) បុគ្គលដែលបំពេញលក្ខខណ្ឌទាំង 4 ទោះបីជាពួកគេតិចជាង 3/4 នៃបុគ្គលិកពេញសិទ្ធិក៏ដោយ
(1) ម៉ោងធ្វើការប្រចាំសប្តាហ៍កំណត់គឺ 20 ម៉ោងឬច្រើនជាងនេះ
(2) ប្រាក់ឈ្នួលគោលយ៉ាងហោចណាស់ 88,000 យ៉េន
(3) ពួកគេមិនមែនជាសិស្ស
(4) ពួកគេធ្វើការឱ្យក្រុមហ៊ុនដែលមានបុគ្គលិក 51 នាក់ ឬច្រើនជាងនេះ

(ចំណាំ 1) បុគ្គលដែលត្រូវបានជួលដោយសហគ្រាសដែលអាចអនុវត្តដែលជាកម្មសិទ្ធិរបស់រដ្ឋាភិបាលជាតិ ឬថ្នាក់មូលដ្ឋាន គឺជាសមាជិកដែលមានលក្ខខណ្ឌតម្រូវពី (1) ដល់ (3) ប៉ុណ្ណោះ។

(ចំណាំទី 2) បុគ្គលដែលត្រូវបានរង់ចាំថានឹងធ្វើការសម្រាប់រយៈពេលពីរខែ ឬតិចជាងនេះ ហើយមិនត្រូវបានរង់ចាំថានឹងធ្វើការលើសពីរយៈពេលនោះ មិនមានសិទ្ធិទទួលបាននោះទេ។ (ទោះបីជារយៈពេលការងារដំបូងតិចជាងពីរខែក៏ដោយ ប្រសិនបើមានការរង់ចាំទុកនៃការបន្ត និយោជិតអាចមានសិទ្ធិទទួលបានការធានារ៉ាប់រងសង្គមចាប់ពីដើមកិច្ចសន្យា។ )

## (2) ភាគទាន

- ភាគទានដែលជាបន្ទុករបស់សមីខ្លួនត្រូវបានគណនាដូចខាងក្រោម៖

ប្រាក់បៀវត្ស (ទឹកប្រាក់ថ្លៃឈ្នួលមធ្យម) និងប្រាក់បំណាច់ (ទឹកប្រាក់បំណាច់មធ្យម)
× ភាគរយនៃភាគទាន ÷ 2

* ភាគទាននៃរបបប្រាក់សោធនសុខុមាលភាពគឺម្ចាស់សហគ្រាសនិងសមាជិក (អ្នកចូល)ទទួលបន្ទុកម្នាងពាក់កណ្ដាល។

## (3) តាវកាលិក

### ប្រាក់សោធនជរាភាពសុខុមាលភាព

- អ្នកទាំងឡាយណាដែលត្រូវតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍ជាមូលដ្ឋានសម្រាប់មនុស្សចាស់ និងបានចុះឈ្មោះក្នុងធានារ៉ាប់រងសោធននិវត្តន៍របស់និយោជិតយ៉ាងហោចណាស់មួយខែ មានសិទ្ធិទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍សម្រាប់និយោជិតវ័យចាស់។
- ទឹកប្រាក់សោធនជរាភាពសុខុមាលភាពគឺយោងទៅតាមទឹកប្រាក់បៀវត្ស (ទឹកប្រាក់ថ្លៃឈ្នួលមធ្យម) នៅពេលដែលខ្លួនជាសមាជិក (អ្នកចូលក្នុង)របបប្រាក់សោធនសុខុមាលភាព និងទៅតាមប្រវែងនៃអំឡុងពេល។

* អ្នកដែលកើតក្នុងផ្នែកកំណត់មួយ ហើយបំពេញលក្ខខណ្ឌបង់ភាគទាន មានករណីខ្លះអាចទទួលបានប្រាក់សោធនជរាភាពសុខុមាលភាពនៅមុនអាយុ 65ឆ្នាំ។

### ប្រាក់សោធនពិការភាពសុខុមាលភាព

- បុគ្គលដែលបំពេញលក្ខខណ្ឌខាងក្រោមទាំងអស់ អាចទទួលបានប្រាក់សោធនពិការភាពសុខុមាលភាព

① ស្ថិតក្នុងអំឡុងពេលដែលជាសមាជិកនៃរបបប្រាក់សោធនសុខុមាលភាព មានការពិនិត្យលើកដំបូង (កាលបរិច្ឆេទនៃការពិនិត្យលើកដំបូងដោយវេជ្ជបណ្ឌិត ឬទន្តពេទ្យទាក់ទងនឹងជំងឺ ឬរបួសដែលបណ្ដាលឱ្យមានពិការភាព) អំពីជំងឺ ឬរបួសដែលបណ្ដាលឱ្យពិការភាពជាយថាហេតុត្រូវបានអនុវត្ត។
② ក្រោយពេលមានជំងឺ ឬរបួសមាននៅសល់ពិការភាពក្នុងកម្រិតមួយ
③ ស្របលក្ខខណ្ឌបង់ភាគទាននៅមួយថ្ងៃមុនថ្ងៃទៅពិនិត្យដំបូង

- ប្រាក់សោធនពិការភាពសុខុមាលភាពមានទឹកប្រាក់ខុសគ្នាតាមកម្រិត1 កម្រិត2 កម្រិត3។
- ប្រាក់សោធនពិការភាពសុខុមាលភាពប្រែប្រួលតាមកម្រិត។

① ពិការភាពកម្រិត1 → 1.25ដងនៃប្រាក់សោធនជរាភាពសុខុមាលភាព
② ពិការភាពកម្រិត2 កម្រិត3 → ស្មើគ្នានឹងប្រាក់សោធនជរាភាពសុខុមាលភាព

* ប្រាក់សោធនពិការភាពសុខុមាលភាពសំរាប់ពិការភាពកម្រិត3 មានចំនួនទឹកប្រាក់ធានាទាបបំផុត។
ទឹកប្រាក់ធានាទាបបំផុត = ប្រាក់សោធនពិការភាពមូលដ្ឋានកម្រិត2 × 3/4

ក្នុងករណីដែលពិការភាពមិនគ្រប់កម្រិតទទួលបានប្រាក់សោធនពិការភាពសុខុមាលភាព ក៏មានករណីអាចទទួលបានប្រាក់បំណាច់សម្រាប់ពិការភាពដែរ។

## ប្រាក់សោធនសុខុមាលភាពចំពោះអ្នកនៅក្នុងបន្ទុក

- មនុស្សដូចករណីណាមួយក្នុងចំណោមខាងក្រោមដែលជាអ្នកនៅក្នុងបន្ទុក មានជីវភាពទ្រទ្រង់ដោយបុគ្គលដែលបានទទួលមរណភាព អាចទទួលបានប្រាក់សោធនសុខុមាលភាពចំពោះអ្នកនៅក្នុងបន្ទុកៈ

① នៅពេលដែលសមាជិក (អ្នកចូលក្នុងរបប)បានទទួលមរណភាព ហើយបានបំពេញលក្ខខណ្ឌបង់ភាគទាន
② បានបំពេញលក្ខខណ្ឌបង់ភាគទាន ហើយបានទទួលមរណភាពក្នុងអំឡុងពេល 5ឆ្នាំរាប់ចាប់ពីថ្ងៃពិនិត្យដំបូងក្នុងអំឡុងពេលជាសមាជិក (អ្នកចូលក្នុងរបប)
③ បុគ្គលដែលទទួលមរណភាពជាសមាជិក ឬធ្លាប់ជាសមាជិក ហើយថេរវេលាមានសិទ្ធិទទួលប្រាក់សោធនជរាភាពមូលដ្ឋាន មានចាប់ពី 25ឆ្នាំឡើងទៅ
④ នៅពេលដែលបុគ្គលដែលមានសិទ្ធិទទួលប្រាក់សោធនពិការភាពសុខុមាលភាពកម្រិត1 ឬកម្រិត2 បានទទួលមរណភាព។

- ចំនួនប្រាក់ឧបត្ថម្ភឱ្យក្រុមគ្រួសារ គឺស្មើនឹង ៣/៤ នៃប្រាក់សន្សំចាស់របស់បុគ្គលដែលបានស្លាប់។

ចំណុចគួរដឹងៈ

### "អ្នកនៅក្នុងបន្ទុក" មានន័យថា



អ្នកនៅក្នុងបន្ទុកមានន័យថាមនុស្សដូចខាងក្រោម។
① សហព័ទ្ធ (ប្ដីអាយុចាប់ពី55ឆ្នាំឡើង ចាប់ផ្ដើមផ្ដល់ចាប់ពីអាយុ 60ឆ្នាំ)
② កូន (ដូចកូនក្នុងករណីនៃរបបប្រាក់សោធនពលរដ្ឋដែរ)
③ ឪពុកម្ដាយ (អាយុចាប់ពី55ឆ្នាំឡើង ចាប់ផ្ដើមផ្ដល់ចាប់ពីអាយុ 60ឆ្នាំ)
④ ចៅ (មានលក្ខខណ្ឌដូចកូន)
⑤ តាយាយ (អាយុចាប់ពី55ឆ្នាំឡើង ចាប់ផ្ដើមផ្ដល់ចាប់ពីអាយុ 60ឆ្នាំ)

* ក្នុងករណីដែលប្ដីមានសិទ្ធិទទួលប្រាក់សោធនមូលដ្ឋានចំពោះអ្នកនៅក្នុងបន្ទុក អាចទទួលបានប្រាក់សោធនសុខុមាលភាពចំពោះអ្នកនៅក្នុងបន្ទុកចាប់ពីអាយុ 55តទៅ។

* ចំពោះឪពុកម្ដាយ ចៅ តាយាយ ក្នុងករណីដែលមនុស្សមានអាទិភាពកំពុងទទួល គឺមិនអាចទទួលបានឡើយ។

# 1-3 ប្រាក់សោធនពេលចាកចេញ

## លក្ខខណ្ឌស្នើសុំ

អ្នកដែលបំពេញលក្ខខណ្ឌទាំងអស់ខាងក្រោម ប្រសិនបើចេញពីប្រទេសជប៉ុន អាចទាមទារប្រាក់សោធនពេលចាកចេញបាន។

① អ្នកដែលគ្មានសញ្ជាតិជប៉ុន
② រយៈពេលដែលបានចូលជាសមាជិក(អ្នកចូល)នៃរបបប្រាក់សោធនសុខុមាលភាព ឬរយៈពេលនៃការបង់ភាគទានរបបប្រាក់សោធនពលរដ្ឋក្នុងនាមជាសមាជិកប្រភេទទី1 ។ល។ មានរយៈពេល6ខែឬលើសនេះ។
③ មិនបានបំពេញលក្ខខណ្ឌស្តីពីរយៈមានសិទ្ធិដើម្បីទទួលប្រាក់សោធនជរាភាព (សរុបរយៈពេល 10ឆ្នាំ)
④ លែងមានអាសយដ្ឋាននៅប្រទេសជប៉ុនទៀត
⑤ លែងជាសមាជិកនៃរបបប្រាក់សោធនពលរដ្ឋនិងរបបប្រាក់សោធនសុខុមាលភាព
⑥ មិនធ្លាប់បានសិទ្ធទទួលប្រាក់សោធនពិការភាព ជាអាទិ៍
⑦ ក្នុងអំឡុងពេល 2ឆ្នាំក្រោយពីបានចាកចេញពីប្រទេសជប៉ុន

## ចំណុចត្រូវប្រុងប្រយ័ត្ននៅពេលស្នើសុំ

នៅពេលស្នើសុំប្រាក់សោធនពេលចាកចេញ សូមពិនិត្យចំណុចប្រុងប្រយ័ត្នខាងក្រោមៈ

① នៅពេលស្នើសុំប្រាក់សោធនពេលចាកចេញ កំណត់ត្រានៃព័ត៌មានដែលបានចូលជាសមាជិករបបប្រាក់សោធនជប៉ុននឹងត្រូវបាត់បង់។ ទៅថ្ងៃអនាគតមានការពិចារណាពី លទ្ធិភាពក្នុងការទទួលបានប្រាក់សោធនជរាភាព ហេតុដូច្នេះហើយ សូមគិតអោយបានច្បាស់លាស់មុននឹងសម្រេចចិត្តស្នើសុំប្រាក់សោធនពេលចាកចេញ។

* គេអាចទាញយកពាក្យស្នើសុំប្រាក់សោធនពេលចាកចេញ ពីគេហទំព័ររបស់អង្គភាពសេវាកម្មសោធនជប៉ុន។ សូមមើលលំអិត រួមទាំងចំណុចប្រុងប្រយ័ត្នស្តីពីពាក្យស្នើសុំ។

② នៅថ្ងៃដែលអង្គភាពសេវាកម្មសោធនជប៉ុនទទួលពាក្យស្នើសុំរបស់អ្នក ហើយអ្នកនៅមានអាសយដ្ឋាននៅប្រទេសជប៉ុន គឺមិនអាចទទួលបានប្រាក់សោធនពេលចាកចេញឡើយ។ ហេតុដូច្នេះហើយ ក្នុងករណីស្នើសុំយកប្រាក់សោធនពេលចាកចេញ សូមដាក់ពាក្យជូនដំណឹងអំពីការផ្លាស់លំនៅចេញទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

③ ក្នុងករណីផ្ញើពាក្យស្នើសុំតាមប្រៃសណីយ៍ពីក្នុងស្រុក មុនពេលចាកចេញពីប្រទេសជប៉ុន សូមធ្វើយ៉ាងណាអោយពាក្យស្នើសុំបានទៅដល់អង្គភាពសេវាកម្មសោធនជប៉ុនក្រោយថ្ងៃដែលអ្នកត្រឡប់ទៅប្រទេសវិញ។

④ ទឹកប្រាក់សោធនពេលចាកចេញ នឹងត្រូវបានគណនាតាមរយៈពេលដែលចូលក្នុងរបបប្រាក់សោធនជប៉ុន ដោយច្រើនបំផុតគិតត្រឹមភាគទានដែលបានបង់ចំនួនឆ្នាំដែលត្រូវបានកំណត់5ឆ្នាំ(60 ខែ)។

សម្រាប់សេចក្តីលំអិតនៃពាក្យស្នើសុំ អាសយដ្ឋានផ្ញើ និងប្រាក់សោធនពេលចាកចេញ សូមពិនិត្យមើលគេហទំព័ររបស់ អង្គភាពសេវាកម្មសោធនជប៉ុន Japan Pension Service

https://www.nenkin.go.jp/shinsei/jukyu/sonota-kyufu/20150406.html

ចំណុចគួរដឹង៖

### កិច្ចព្រមព្រៀងផ្នែកសន្តិសុខសង្គម



បច្ចុប្បន្នប្រទេសជប៉ុនបានចុះកិច្ចព្រមព្រៀងផ្នែកសន្តិសុខសង្គមជាមួយប្រទេសមួយចំនួន។ ចំពោះបុគ្គលដែលមានរយៈពេលចូលក្នុងរបបប្រាក់សោធននៃប្រទេសដែលបានចុះកិច្ចព្រមព្រៀងផ្នែកសន្តិសុខសង្គម ទោះជារយៈពេលចូលក្នុងរបបប្រាក់សោធននៃប្រទេសនិមួយៗខ្លីក៏ដោយ តាមរយៈការសរុបរយៈពេលចូលក្នុងរបបប្រាក់សោធននៃប្រទេសទាំងពីរ មានករណីដែលអាចទទួលបានប្រាក់សោធននៅប្រទេសជប៉ុន ឬនៅប្រទេសដែលមានចុះកិច្ចព្រមព្រៀងនឹងជប៉ុន។

ចំពោះព័ត៌មានថា តើប្រទេសជប៉ុនបានចុះកិច្ចព្រមព្រៀងផ្នែកសន្តិសុខសង្គមជាមួយប្រទេសណាខ្លះ សូមមើលគេហទំព័ររបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព។
https://www.mhlw.go.jp/stf/seisakunitsuite/bunya/nenkin/nenkin/shakaihoshou.html

# 2 របបធានារ៉ាប់រងលើការគាំពារ



នៅប្រទេសជប៉ុនមានប្រព័ន្ធធានារ៉ាប់រងលើការគាំពារ ដែលមានយន្តការទ្រទ្រង់ថ្លៃថែទាំដោយសង្គមទាំងមូលសម្រាប់មនុស្សចាស់ជរាជាដើម ដែលត្រូវការការថែទាំ។ អ្នកចូលជាសមាជិករបបធានារ៉ាប់រងលើការគាំពារត្រូវបង់ភាគទាន ហើយនៅពេលត្រូវការការថែទាំ អាចប្រើប្រាស់សេវាគាំពារបានដោយបង់ថ្លៃមួយផ្នែក។

## 2-1 សមាជិកគោលដៅ

អ្នកមានអាយុចាប់ពី 40ឆ្នាំឡើងទៅ ហើយរស់នៅប្រទេសជប៉ុនលើសពី 3ខែគឺជាគោលដៅចូលជាសមាជិកនៃរបបធានារ៉ាប់រងលើការគាំពារ។

## 2-2 ភាគទាន

សមាជិកដែលចូលក្នុងរបបធានារ៉ាប់រងលើការគាំពារ ត្រូវបានកំណត់ភាគទានទៅតាមចំណូលនៃឆ្នាំមុន។ ភាគទាននេះក្រៅពីខុសគ្នាទៅតាមចំណូល ក៏ខុសគ្នាទៅតាមចន្លោះអាយុ តំបន់ដែលរស់នៅជាដើមផងដែរ។

① ចាប់ពី 65ឆ្នាំឡើង (សមាជិកប្រភេទទី1)

ជាទូទៅត្រូវបានប្រមូលដោយការកាត់ពីប្រាក់សោធនដោយផ្ទាល់។ (ចំពោះមនុស្សខ្លះត្រូវបានប្រមូលតាមរយៈវិក្កយបត្របង់ប្រាក់ជាដើម)

② ចាប់ពី 40ឆ្នាំដល់ 65ឆ្នាំ (សមាជិកប្រភេទទី2)

ត្រូវបានប្រមូលដោយបន្ថែមពីលើភាគទាននៃរបបធានារ៉ាប់រងសុខភាព។

ចំពោះសេចក្ដីលំអិតនៃរបបធានារ៉ាប់រងលើការគាំពារ (សមាជិកប្រភេទទី 2)
សូមបញ្ជាក់មើលនៅគេហទំព័រខាងក្រោម។
https://www.mhlw.go.jp/stf/newpage_10548.html

## 2-3 ការប្រើប្រាស់សេវាគាំពារ

របៀបប្រើសេវាគាំពារគឺដូចខាងក្រោម។

① ស្នើសុំ “ការបញ្ជាក់ភាពត្រូវការគាំពារ (ត្រូវការជំនួយ)” ទៅភូមិឃុំស្រុក ហើយទទួលការបញ្ជាក់។
- * ដើម្បីប្រើប្រាស់សេវាគាំពារគេត្រូវការ “ការបញ្ជាក់ ភាពត្រូវការគាំពារ (ត្រូវការជំនួយ)” ពីភូមិឃុំស្រុក។
- * នៅពេលស្នើសុំ នឹងមានការស៊ើបអង្កេតអំពីស្ថានភាពនៃរាងកាយនិងសត្តិ ជាទូទៅគេនឹងផ្ដល់លទ្ធផលក្នុងអំឡុង 30ថ្ងៃ។

② ស្នើអោយអ្នកគ្រប់គ្រងការគាំពារ ឬមជ្ឈមណ្ឌលគាំពារសម្រាប់សហគន៍ធ្វើផែនការប្រើសេវាគាំពារ (ផែនការគាំពារ)។
- * ក្នុងករណីចូលទៅគ្រឹះស្ថានណាមួយ សូមធ្វើការស្នើសុំទៅគ្រឹះស្ថាននោះដោយផ្ទាល់។

③ ទទួលសេវាគាំពារតាមផែនការគាំពារ។
- * ក្រៅពីនេះមានការគាំពារថែទាំ ជំនួយជីវភាពសម្រាប់អ្នកដែលគ្មាន “ការបញ្ជាក់ ភាពត្រូវការគាំពារ (ត្រូវការជំនួយ)” ផងដែរ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

# 3 សុខុមាលភាពកុមារ



## 3-1 ប្រាក់ឧបត្ថម្ភសម្រាប់កុមារ

សូមមើលត្រង់3 3-4 ប្រាក់ឧបត្ថម្ភសម្រាប់កុមារនៃជំពូកទី 4។

## 3-2 ប្រាក់ឧបត្ថម្ភចិញ្ចឹមកុមារ

- គឺជាប្រាក់ឧបត្ថម្ភដល់កុមារដែលត្រូវបានចិញ្ចឹមនៅគ្រួសារដែលមានតែម្ដាយ ឬមានតែឪពុក(*)។
- ក្នុងករណីចិញ្ចឹមបីបាច់កុមារដែលមានលក្ខណ:ណាមួយក្នុងចំណោមខាងក្រោម អាចទទួលបាន។

① កុមារដែលឪពុកម្ដាយលែងលះគ្នា
② កុមារដែលឪពុក ឬម្ដាយបានទទួលមរណភាព
③ កុមារដែលឪពុកឬម្ដាយស្ថិតក្នុងស្ថានភាពមានពិការភាពក្នុងកម្រិតមួយ
④ កុមារដែលមានឪពុក ឬម្ដាយដែលមិនដឹងថាស្លាប់ឬនៅរស់ ។ល។

* កូនមានន័យថា កូនមុនថ្ងៃទី31 ខែមីនាដំបូងក្រោយថ្ងៃកំណើតអាយុ18ឆ្នាំ ឬកូនក្រោមអាយុ 20ឆ្នាំដែលមានពិការភាពក្នុងកម្រិតមួយ។

### ទឹកប្រាក់ផ្តល់ប្រចាំខែ

* ទឹកប្រាក់សម្រាប់ឆ្នាំសារពើពន្ធ 2024 (ប្រែប្រួលជារៀងរាល់ឆ្នាំអាស្រ័យលើតំលៃទំនិញ)

- ក្នុងករណីមានកូន 1 នាក់

  ផ្តល់ពេញ៖ 45,500 យ៉េន ផ្តល់មួយផ្នែក៖ 45,490 យ៉េន ដល់ 10,740 យ៉េន

- ទឹកប្រាក់ផ្តល់បន្ថែមសម្រាប់កូនចាប់ពី 2 នាក់ឡើង

  ផ្តល់ពេញ៖ 10,750 យ៉េន ផ្តល់មួយផ្នែក៖ 10,740 យ៉េន ដល់ 5,380 យ៉េន

* ទឹកប្រាក់ផ្តល់ប្រែប្រួលរៀងរាល់ឆ្នាំទៅតាមតំលៃទំនិញ ហើយចំពោះអ្នកដែលឆ្នាំមុនមានចំណូលលើសពីកម្រិតមួយ គឺមិនអាចទទួលបានទេ។ ហើយក្នុងករណីដែលបានទទួលប្រាក់សោធនសាធារណៈជាដើមនោះគ្មានការផ្តល់ប្រាក់ប្រាក់ឧបត្ថម្ភទាំងស្រុងឬមួយផ្នែកឡើយ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

## 3-3 ប្រាក់ឧបត្ថម្ភចិញ្ចឹមកុមារពិសេស

ឪពុកម្តាយជាដើមដែលជាគ្រួសារចិញ្ចឹមកុមារដែលមានពិការភាពផ្នែកសតិអារម្មណ៍ ឬរាងកាយ (ក្រោមអាយុ20ឆ្នាំ) អាចទទួលបាន។

* ក្នុងករណីដែលឪពុកម្តាយជាដើមមានចំណូលលើសពីកម្រិតមួយនៅឆ្នាំមុន គឺមិនអាចទទួលបានទេ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

### ទឹកប្រាក់ទទួលបាន

* ទឹកប្រាក់ឆ្នាំសារពើពន្ធ 2024 (ប្រែប្រួលរៀងរាល់ឆ្នាំទៅតាមតំលៃទំនិញ)

- ក្នុងករណីកុមារដែលមានពិការភាពកម្រិតធ្ងន់ខ្លាំង (ស្មើនឹងកម្រិត1នៃប្រាក់សោធនពិការភាពមូលដ្ឋាន)

  ក្នុង1នាក់ទទួលបាន 55,350 យ៉េន ក្នុង1ខែ

- ក្នុងករណីកុមារដែលមានពិការភាពកម្រិតធ្ងន់ (ស្មើនឹងកម្រិត2នៃប្រាក់សោធនពិការភាពមូលដ្ឋាន)

  ក្នុង1នាក់ទទួលបាន 36,860 យ៉េន ក្នុង1ខែ

## 3-4 ប្រាក់ឧបត្ថម្ភសុខុមាលភាពកុមារពិការ

អាចទទួលបានក្នុងករណីដែលកុមារមានពិការភាពផ្នែកសតិអារម្មណ៍ ឬរាងកាយកម្រិតធ្ងន់ ហើយត្រូវការគាំពារជាប្រចាំនៅក្នុងជីវភាពប្រចាំថ្ងៃ (ក្រោមអាយុ 20)។

* ក្នុងករណីដែលសមីខ្លួនជាដើមមានចំណូលលើសពីកម្រិតមួយនៅឆ្នាំមុន គឺមិនអាចទទួលបានទេ។ សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

### ទឹកប្រាក់ទទួលបាន

* ទឹកប្រាក់នៅឆ្នាំសារពើពន្ធ 2024 (ប្រែប្រួលរៀងរាល់ឆ្នាំទៅតាមតំលៃទំនិញ)

15, 690 យ៉េនក្នុង1ខែ

# 4 សុខុមាលភាពជនពិការ

## 4-1 សៀវភៅ

ក្នុងករណីដែលមានពិការភាពផ្នែកសតិអារម្មណ៍ ឬរាងកាយ អាចទទួលបានសៀវភៅសម្រាប់ជនពិការទៅតាមកម្រិតនៃពិការភាពនោះ។

នៅពេលទទួលបានសៀវភៅសម្រាប់ជនពិការ គេអាចប្រើប្រាស់ប្រព័ន្ធដូចជាកាត់បន្ថយឬលើកលែងពន្ធ ការបញ្ចុះថ្លៃធ្វើដំណើរជាដើម។

### ប្រភេទនៃសៀវភៅសម្រាប់ជនពិការ

- សៀវភៅជនពិការ៖ អ្នកមានពិការភាពលើរាងកាយជាអចិន្ត្រៃយ៍
- សៀវភៅស្តានីតិសម្បទា៖ អ្នកដែលមានភាពអន់ថយផ្នែកបញ្ញា
- សៀវភៅថែទាំសុខភាពនិងសុខុមាលភាពអ្នកជំងឺស្មារតី៖ អ្នកមានកំណត់ព្រំដែននៃជីវភាពប្រចាំថ្ងៃឬជីវភាពក្នុងសង្គមដោយសារមានបញ្ហាផ្នែកស្មារតី

ចំពោះសេចក្តីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។

https://www.mhlw.go.jp/stf/seisakunitsuite/bunya/hukushi_kaigo/shougaishahukushi/techou.html

* ក្នុងករណីដែលចង់ពិគ្រោះ សូមទាក់ទងទៅភូមិឃុំស្រុកដែលនៅជិត។

## 4-2 សេវារដ្ឋបាលចំពោះជនពិការ និងកុមារពិការ

អាចប្រើប្រាស់បាននូវសេវាផ្តល់ជំនួយផ្សេងៗដល់ការរស់នៅប្រចាំថ្ងៃ និងជីវភាពក្នុងសង្គម សម្រាប់អ្នកមានពិការភាព។ ប្រភេទនៃសេវាមានដូចជាការគាំទ្រដល់ការថែទាំ ការស្តារនីតិសម្បទាជាដើម។

ចំពោះសេវារដ្ឋបាលចំពោះកុមារពិការមានដូចជា ការគាំទ្រដល់ការលូតលាស់នៃកុមារពិការ ការថែទាំជាដើម។

សម្រាប់ព័ត៌មានលំអិតអំពីសេវារដ្ឋបាលចំពោះជនពិការ និងកុមារពិការ សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។



# 5 របបជំនួយសង្គម

ក្នុងករណីដែលបានធ្វើដូចក្នុង 5-1 រួចហើយប៉ុន្តែចំណូលនៃគ្រួសារមិនគ្រប់សម្រាប់ថ្លៃជីវភាពកម្រិតទាបបំផុត អាចទទួលបាននូវជំនួយដែលមានទឹកប្រាក់ស្មើនឹងថ្លៃជីវភាពកម្រិតទាបបំផុត ដកជាមួយប្រាក់ចំណូល។

* ថ្លៃជីវភាពកម្រិតទាបបំផុតត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព។

ចំពោះពលរដ្ឋបរទេស ក្នុងចំណោះបុគ្គលប្រភេទខាងក្រោម មានករណីដែលជាគោលដៅទទួលបានរបបជំនួយសង្គម។

- បុគ្គលដែលគ្មានការកំណត់ព្រំដែលសកម្មភាពដូចជា អ្នកស្នាក់នៅអចិន្ត្រៃយ៍ សហព័ទ្ធរបស់ជនជាតិជប៉ុនជាដើម សហព័ទ្ធរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍ជាដើម អ្នកតាំងលំនៅអចិន្ត្រៃយ៍

  សម្រាប់ព័ត៌មានលំអិត សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

## 5-1 លក្ខខណ្ឌក្នុងការទទួលបានរបបជំនួយសង្គម

### (1) ការប្រើប្រាស់ទ្រព្យសម្បត្តិ

ប្រាក់ក្នុងគណនី ប្រាក់សន្សំ ក្នុងករណីមានដីឬផ្ទះដែលមិនប្រើសម្រាប់រស់នៅ លក់ជាដើមដើម្បីបានប្រាក់សម្រាប់ជីវភាព។

### (2) ការប្រើប្រាស់សមត្ថភាព

អ្នកដែលអាចធ្វើការបាន សូមធ្វើការតាមសមត្ថភាពរបស់ខ្លួន។

### (3) តាវកាលិកផ្សេងទៀតជាដើម

ក្នុងករណីអាចទទួលបានដូចជាប្រាក់សោធន ឬប្រាក់ឧបត្ថម្ភក្នុងប្រព័ន្ធផ្សេងទៀត សូមប្រើប្រាស់ប្រាក់ឧបត្ថម្ភនោះសិន។

### (4) ការចិញ្ចឹមដោយអ្នកមានកាតព្វកិច្ចចិញ្ចឹម

ក្នុងករណីដែលអាចទទួលការគាំទ្រពីគ្រួសារជាដើម សូមទទួលការគាំទ្រនោះ។

## 5-2 ប្រភេទនិងខ្លឹមសារនៃជំនួយ

ចំនួននៃការផ្តល់អោយត្រូវបានកំណត់ទៅតាមថ្លៃចំណាយចាំបាច់សម្រាប់ជីវភាព។

| ថ្លៃចំណាយចាំបាច់សម្រាប់ជីវភាព | ប្រភេទជំនួយ | ខ្លឹមសារផ្តល់ |
|---|---|---|
| ថ្លៃចំណាយចាំបាច់សំរាប់ជីវភាពប្រចាំថ្ងៃ<br>(ថ្លៃហូបចុក សំលៀកបំពាក់ ទឹក ភ្លើង ហ្គាស។ល។) | ជំនួយជីវភាព | • ថ្លៃចំណាយបុគ្គលដូចជាថ្លៃហូបចុក<br>• គណនាថ្លៃចំណាយរួមសម្រាប់គ្រួសារដូចជាទឹក ភ្លើង ហ្គាសជាដើម |
| ថ្លៃជួលផ្ទះជាដើម | ជំនួយលើការស្នាក់នៅ | ផ្តល់តាមចំនួនជាក់ស្តែងក្នុងព្រំដែនកំណត់មួយ |
| ថ្លៃប្រដាប់សិក្សាជាដើមដែលចាំបាច់សម្រាប់ការអប់រំកាតព្វកិច្ច | ជំនួយអប់រំ | ផ្តល់ទឹកប្រាក់តាមស្តង់ដារកំណត់(ការចំណាយមួយចំនួននៅក្នុងចំណូនដែលបានបញ្ជាក់។ ) |
| ថ្លៃសេវាព្យាបាល | ជំនួយវេជ្ជសាស្ត្រ | ថ្លៃចំណាយត្រូវបានផ្តល់អោយទៅស្ថា។ប័នវេជ្ជសាស្ត្រដោយផ្ទាល់ (គ្មានបន្ទុករបស់សមីខ្លួនឡើយ) |
| ថ្លៃសេវាគាំពារ | ជំនួយគាំពារ | ថ្លៃចំណាយត្រូវបានផ្តល់អោយទៅស្ថាប័នគាំពារដោយផ្ទាល់ (គ្មានបន្ទុករបស់សាមីខ្លួនឡើយ) |
| ថ្លៃសម្រាលកូន | ជំនួយសម្រាលកូន | ផ្តល់តាមចំនួនជាក់ស្តែងក្នុងព្រំដែនកំណត់មួយ |
| ចំណាយពាក់ព័ន្ធនឹងការសិក្សាជាអាទ៍នូវជំនាញចាំបាច់ដើម្បីធ្វើការ | ជំនួយចំពោះការងារសំរាប់ការរស់នៅ | ផ្តល់តាមចំនួនជាក់ស្តែងក្នុងកម្រិតដែលបានកំណត់(ផ្នែកមួយនៃការចំណាយសម្រាប់ការចូលរៀននៅវិទ្យាល័យ។ល។ គឺផ្អែកលើចំនួនស្តង់ដារដែលបានបញ្ជាក់) |
| ចំណាយលើបុណ្យសព | ជំនួយលើបុណ្យសព | ផ្តល់តាមចំនួនជាក់ស្តែងក្នុងកម្រិតដែលបានកំណត់ |

# 6 ប្រព័ន្ធគាំទ្រអ្នកមានជីវភាពក្រីក្រអោយពឹងផ្អែកលើខ្លួនឯង

មានសេវាប្រឹក្សាយោបល់ (អង្គការគាំទ្រការពិគ្រោះយោបល់សម្រាប់ការពឹងផ្អែកលើខ្លួនឯង) ដែលផ្តល់ជំនួយដល់មនុស្សដែលត្រូវការជំនួយ។

អាស្រ័យលើលក្ខណៈនៃការពិគ្រោះយោបល់របស់អ្នក អ្នកអាចទទួលបានការគាំទ្រក្នុងផ្នែកដូចជា ការងារ ហិរញ្ញវត្ថុគ្រួសារ និងលំនៅដ្ឋាន។

សូមពិគ្រោះជាមួយស្ថាប័នគាំទ្រការប្រឹក្សាអំពីការពឹងផ្អែកលើខ្លួនឯងក្នុងតំបន់របស់អ្នកជាមុនសិន។



បញ្ជីនៃអង្គការគាំទ្រការពិគ្រោះយោបល់សម្រាប់ការពឹងផ្អែកលើខ្លួនឯង
https://minna-tunagaru.jp/ichiran/

ជំពូកទី8

# ពន្ធ



## ពលរដ្ឋបរទេស និងពន្ធ

ទោះជាពលរដ្ឋបរទេសក៏ដោយ ក្នុងករណីបំពេញលក្ខខណ្ឌកំណត់មួយ គឺចាំបាច់ត្រូវបង់ពន្ធ។ ខាងក្រោមជាឧទាហរណ៍អំពីករណីដែលត្រូវបង់ពន្ធ៖

- អ្នកដែលធ្វើការនៅក្នុងប្រទេសជប៉ុន ហើយទទួលបានប្រាក់កំរៃ
  → ជាទូទៅចាំបាច់ត្រូវបង់ពន្ធលើប្រាក់ចំណូល។
- អ្នកដែលមានអាសយដ្ឋាននៅប្រទេសជប៉ុនគិតត្រឹមថ្ងៃទី1 ខែមករា
  → គឺចាំបាច់ត្រូវបង់ពន្ធលើនិវាសនជន (ត្រូវបានគិតពន្ធទៅតាមប្រាក់ចំណូលនៃឆ្នាំមុនៗ)។

ចំពោះពលរដ្ឋបរទេសក៏ដោយ នៅពេលធ្វើដំណើរហើយស្នាក់នៅសណ្ឋាគារ ឬហូបចុកជាដើមគឺចាំបាច់ត្រូវទទួលបន្ទុកលើអាករលើតំលៃបន្ថែម។

**ចំណុចគួរដឹង៖**

**"ពន្ធរដ្ឋ" និង "ពន្ធមូលដ្ឋាន"**

ប្រព័ន្ធពន្ធនៅប្រទេសជប៉ុនគឺមាន "ពន្ធរដ្ឋ" និង "ពន្ធមូលដ្ឋាន" ទៅតាមកន្លែងដែលបង់។

- ពន្ធដែលបង់ទៅអោយរដ្ឋហៅថា "ពន្ធរដ្ឋ" ។ ឧទាហរណ៍ដូចជា "ពន្ធលើប្រាក់ចំណូល"។
- ពន្ធដែលបង់ទៅអោយខេត្តក្រុង ឬភូមិឃុំស្រុកដែលអ្នករស់នៅ ហៅថា "ពន្ធមូលដ្ឋាន" ។ ឧទាហរណ៍ដូចជា "ពន្ធលើនិវាសនជន"។

## 1 ពន្ធលើប្រាក់ចំណូល

ពន្ធលើប្រាក់ចំណូលគឺពន្ធដែលគិតទៅតាមប្រាក់ចំណូលក្នុង1ឆ្នាំ គិតចាប់ពីថ្ងៃទី1 ខែមករា រហូតដល់ថ្ងៃទី31 ខែធ្នូ។

វិធីគណនាពន្ធលើប្រាក់ចំណូលគឺគណនាតាម៖

① ចំណូល - សោហ៊ុយផ្សេងៗ = ប្រាក់ចំណូល (A)

② ប្រាក់ចំណូល (A) - ប្រាក់ដកផ្សេងៗ (សូមមើលត្រង់1-3) = ប្រាក់ចំណូលត្រូវគិតពន្ធ (B)

③ ប្រាក់ចំណូលត្រូវគិតពន្ធ (B) × ភាគរយគិតពន្ធ

ភាគរយគិតពន្ធត្រូវបានគេរៀបចំអោយកាន់តែធំឡើងជាកាំៗ នៅពេលដែលប្រាក់ចំណូលត្រូវគិតពន្ធ (B) កាន់តែច្រើនឡើង។

## 1-1 អ្នកមានកាតព្វកិច្ចបង់ពន្ធនិងប្រាក់ចំណូលដែលជាគោលដៅត្រូវបង់ពន្ធ

ប្រាក់ចំណូលដែលជាគោលដៅត្រូវបង់ពន្ធលើប្រាក់ចំណូល គឺខុសគ្នាទៅតាមប្រភេទនៃការស្នាក់នៅដូចខាងក្រោម។

### (1) និវាសនជន

អ្នកដែលមាន "លំនៅដ្ឋាន" នៅក្នុងប្រទេសជប៉ុន ឬអ្នកដែលមាន "និវាសនដ្ឋាន" លើសពីរយៈពេល 1ឆ្នាំរហូតមកដល់បច្ចុប្បន្ន (លើកលែងអ្នកមិនស្នាក់នៅអចិន្ត្រៃយ៍(2))។

អ្នកដែលត្រូវនឹងលក្ខខណ្ឌនេះគឺជា "និវាសនជន"។

→ ប្រាក់ចំណូលទាំងអស់រួមទាំងប្រាក់ចំណូលដែលមានប្រភពនៅបរទេសផងគឺជាគោលដៅនៃពន្ធលើប្រាក់ចំណូលទាំងអស់។

ចំណុចគួរដឹង៖

**"លំនៅដ្ឋាន" និង "និវាសនដ្ឋាន"**

- "លំនៅដ្ឋាន" គឺជាមូលដ្ឋានរស់នៅរបស់បុគ្គល ហើយគេធ្វើការវិនិច្ឆ័យលើការពិតតាមវត្ថុវិស័យថាជាមូលដ្ឋាននៃជីវភាពឬអត់ (តើធ្វើការនៅប្រទេសជប៉ុនឬអត់ តើមានគ្រួសារ ឬសហព័ទ្ធរស់នៅប្រទេសជប៉ុនដែលមានជីវភាពរួមគ្នាឬអត់)។
- "និវាសនដ្ឋាន" គឺជាកន្លែងដែលមនុស្សបន្តស្នាក់នៅក្នុងរយៈពេលមួយ ប៉ុន្តែមិនដល់ថ្នាក់ក្លាយជាមូលដ្ឋាននៃជីវភាពនោះទេ។

### (2) អ្នកមិនស្នាក់នៅអចិន្ត្រៃយ៍

ក្នុងចំណោម "និវាសនជន" អ្នកដែលគ្មានសញ្ជាតិជប៉ុន ហើយក្នុងអំឡុងពេល 10ឆ្នាំ រយៈពេលដែលមានលំនៅដ្ឋាន ឬនិវាសនដ្ឋាននៅក្នុងប្រទេសសរុបតិចជាង 5ឆ្នាំ

អ្នកដែលដូចលក្ខខណ្ឌនេះគឺជា "អ្នកមិនស្នាក់នៅអចិន្ត្រៃយ៍"។

→ ① ប្រាក់ចំណូលក្រៅពីប្រាក់ចំណូលនៅក្រៅប្រទេសនិង ②ប្រាក់ចំណូលនៅក្រៅប្រទេស ហើយត្រូវបានបង់នៅក្នុងប្រទេស ឬប្រាក់ដែលត្រូវបានផ្ញើមកពីបរទេសគឺជាគោលដៅនៃពន្ធលើប្រាក់ចំណូល។

### (3) អនិវាសនជន

អ្នកដែលមិនត្រូវបានចាត់ថ្នាក់ជា "អ្នករស់នៅ" ឬ "អ្នករស់នៅមិនអចិន្ត្រៃយ៍" រួមទាំងអ្នកដែលមានអាសយដ្ឋាននៅបរទេសត្រូវបានគេចាត់ទុកថាជា "អ្នកមិនរស់នៅ" ។

→ ប្រាក់បៀវត្សដែលបានមកពីការធ្វើការនៅក្នុងប្រទេសជប៉ុន និងប្រាក់រង្វាន់ដែលបានមកពីការផ្តល់សេវាកម្មក្នុងប្រទេសជប៉ុនប៉ុណ្ណោះគឺជាគោលដៅនៃពន្ធលើប្រាក់ចំណូល។

## 1-2 ការប្រកាសសម្រេច សម្រាប់ពន្ធលើប្រាក់ចំណូល និងការបង់ពន្ធ

ចំពោះពន្ធលើប្រាក់ចំណូល គឺធ្វើការគណនាដោយខ្លួនឯងនូវចំនួនប្រាក់ចំណូលដែលទទួលបាននៅឆ្នាំនោះ និងពន្ធលើប្រាក់ចំណូលសម្រាប់ចំនួននោះ ហើយដាក់ទម្រង់ប្រកាសសម្រេចជូនទៅការិយាល័យពន្ធដារមុនពេលផុតកំណត់នៃការប្រកាសពន្ធ ហើយធ្វើការទូទាត់ចំនួនលើសឬខ្វះជាមួយពន្ធលើប្រាក់ចំណូលដែលត្រូវបានកាត់ទុក(យោងតាម 1-4)ជាដើម។ នីតិវិធីនេះហៅថា “ការប្រកាសសម្រេច”។

### (1) អ្នកដែលត្រូវប្រកាសសម្រេច

ចំពោះអ្នកដែលទទួលប្រាក់បៀវត្ស ភាគច្រើនពន្ធលើប្រាក់ចំណូលជាដើមត្រូវបានកាត់ទុក (សូមមើលត្រង់ 1-4) ហើយក្រោយមកទៀតត្រូវបានទូទាត់តាមរយៈការទូទាត់ពន្ធនៅចុងឆ្នាំ (សូមមើលត្រង់ 1-4) ហេតុដូច្នេះហើយមិនត្រូវការការប្រកាសសម្រេចឡើយ។

ប៉ុន្តែបុគ្គលដូចខាងក្រោមជាគោលការណ៍ចាំបាច់ត្រូវធ្វើការប្រកាសសម្រេច៖

- បុគ្គលដែលបានទទួលប្រាក់បៀវត្សពីកន្លែង1 ហើយមានប្រាក់ចំណូលផ្សេងក្រៅពីប្រាក់បៀវត្ស ឬប្រាក់ចំណូលនៃការលាឈប់ពីការងារ ដែលមានចំនួនសរុបលើសពី 20 ម៉ឺនយ៉េន
- បុគ្គលដែលបានទទួលប្រាក់បៀវត្សចាប់ពី 2កន្លែងឡើងទៅ ហើយទឹកប្រាក់ចំណូលដែលមិនបានទូទាត់ពន្ធនៅចុងឆ្នាំ បូកជាមួយទឹកប្រាក់ក្រៅពីប្រាក់បៀវត្ស ឬប្រាក់ចំណូលនៃការលាឈប់ពីការងារ មានចំនួនលើសពី 20ម៉ឺនយ៉េន
- អ្នកដែលក្រៅពីប្រាក់បៀវត្ស មានមុខជំនួញ ឬទិញលក់មូលបត្រជាដើមដែលមានប្រាក់ចំណូល ហើយក្រោយពីគណនាពន្ធលើប្រាក់ចំណូល ឃើញថាត្រូវបង់ពន្ធ។ល។

ក្រោយការប្រកាសសម្រេចអ្នកដែលត្រូវបង់ពន្ធ ចាំបាច់ត្រូវទៅបង់ពន្ធដោយខ្លួនឯងនៅការិយាល័យពន្ធដារអោយបានមុនថ្ងៃកំណត់ (គ្មានការជូនដំណឹងពីការិយាល័យពន្ធដារជាដើមអំពីការបង់ពន្ធឡើយ។)។

វិធីបង់ប្រាក់មានដូចខាងក្រោម៖

| វិធីសាស្ត្រទូទាត់ | សេចក្តីសង្ខេប |
| --- | --- |
| ការទូទាត់ផ្ទេរតាមគណនីធនាគារ | ពន្ធត្រូវបានកាត់ដោយស្វ័យប្រវត្តិពីគណនីធនាគារដែលបានចុះឈ្មោះជាមុននៅថ្ងៃផ្ទេរប្រាក់ដែលបានបញ្ជាក់ដោយទីភ្នាក់ងារជាតិពន្ធដារ។ |
| ការទូទាត់ដោយផ្ទាល់ (e-Tax) | ពន្ធត្រូវបានកាត់ដោយស្វ័យប្រវត្តិដោយប្រើ e-Tax ពីគណនីធនាគារដែលបានចុះឈ្មោះជាមុន។ |
| ការទូទាត់ពន្ធអេឡិចត្រូនិចតាមអ៊ីនធឺណិត banking, etc. | ការទូទាត់តាមរយៈគណនីធនាគារតាមអ៊ីនធឺណិត ឬអេធីអឹម |
| ទូទាត់ដោយកាតក្រេឌីតតាមអ៊ីនធើណែត | ការទូទាត់តាមរយៈកាតក្រេឌីត តាមរយៈគេហទំព័រពិសេស "គេហទំព័រទូទាត់ដោយកាតឥណទានជាតិពន្ធដា" |
| ការទូទាត់តាមកម្មវិធីទូទាត់ប្រាក់តាមទូរសព្ទឆ្លាតវៃ | ការទូទាត់តាមរយៈកម្មវិធីទូទាត់តាមស្មាតហ្វូនដូចជា "Pay" តាមគេហទំព័រពិសេស "គេហទំព័រទូទាត់ដោយស្មាតហ្វូនជាតិពន្ធដា" |
| ការទូទាត់តាមម៉ាត (កូដ QR) | Payment in cash at a convenience store by creating a QR code for payment information on the National Tax Agency website. |
| ការទូទាត់តាមម៉ាត (បាកូដ) | ការទូទាត់ជាសាច់ប្រាក់នៅតាមម៉ាតដោយប្រើបាកូដ ដែលបង្កើតឡើងដោយការិយាល័យពន្ធដារ |
| ការទូទាត់នៅតាមបញ្ជា/កញ្ចក់បញ្ជារ | វិធីសាស្ត្រទូទាត់ដោយប្រើសាច់ប្រាក់ ឬមូលប្បទានប័ត្រនៅបញ្ជរនៃស្ថាប័នហិរញ្ញវត្ថុ |

## (2) អ្នកដែលអាចទទួលបានពន្ធលើប្រាក់ចំណូលមកវិញក្រោយធ្វើការប្រកាសសម្រេច

- ដោយសារមានប្រាក់ដកពីប្រាក់ចំណូល (សូមមើលត្រង់1-3) ក្នុងករណីដែលពន្ធលើប្រាក់ចំណូលដែលត្រូវបានកាត់ទុក (សូមមើលត្រង់ 1-4) មានចំនួនលើសចំនួនកំណត់ តាមរយៈការប្រកាសសម្រេចពន្ធលើប្រាក់ចំណូលនឹងត្រូវសងត្រឡប់មកវិញ។ គេអាចទទួលបានតាមរយៈប្រៃសណីយ៍ ឬការផ្ទេរតាមគណនីធនាគារ។
- ក្នុងករណីដែលគ្មានការកាត់ទុកពន្ធលើប្រាក់ចំណូលលើសចំនួន នោះគ្មានការសងត្រឡប់នូវពន្ធលើប្រាក់ចំណូលឡើយ។

## (3) កាលកំណត់នៃការប្រកាសសម្រេចនិងការបង់ពន្ធ

ចំពោះពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំនីមួយៗ ការពិគ្រោះលើការប្រកាសសម្រេច និងការទទួលពាក្យប្រកាសសម្រេចគឺក្នុងចន្លោះពីថ្ងៃទី16ខែកុម្ភៈ ដល់ថ្ងៃទី15 ខែមីនានៃឆ្នាំបន្ទាប់។

* ថ្ងៃបិទការិយាល័យពន្ធដារ (ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃបុណ្យជាដើម) ជាទូទៅមិនទទួលពិគ្រោះលើការប្រកាសសម្រេច និងមិនទទួលពាក្យប្រកាសសម្រេចនោះទេ។

កាលកំណត់នៃការបង់ពន្ធដែលបានប្រកាសសម្រេចអំពីពន្ធលើប្រាក់ចំណូលគឺត្រឹមថ្ងៃទី 15ខែមីនា។

* ក្នុងករណីដែលកាលកំណត់ (ថ្ងៃទី15 ខែមីនា) ប៉ះចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ថ្ងៃបុណ្យជាដើម នោះថ្ងៃចូលធ្វើការបន្ទាប់ពីថ្ងៃនោះគឺជាកាលកំណត់។

## (4) ក្នុងករណីចាកចេញពីប្រទេសជប៉ុន

- ក្នុងករណីអស់ “លំនៅដ្ឋាន” និង “និវាសនដ្ឋាន” នៅប្រទេសជប៉ុន ជាទូទៅមុនពេលចាកចេញពីប្រទេសជប៉ុន ត្រូវធ្វើការទូទាត់ពន្ធនៅចុងឆ្នាំសម្រាប់ប្រាក់បៀវត្សឆ្នាំនោះជាមុនសិន។
- ក្នុងករណីដែលមានការចាំបាច់ត្រូវធ្វើការប្រកាសសម្រេចដូចក្នុង(1) នោះមុនចាកចេញពីប្រទេសជប៉ុនត្រូវធ្វើការប្រកាសសម្រេចនិងបង់ពន្ធជាមុនសិន។
- ក្នុងករណីត្រូវធ្វើនីតិវិធីដូចជាប្រកាសសម្រេចនិងបង់ពន្ធជាដើមក្រោយពេលចាកចេញពីប្រទេសជប៉ុន នោះត្រូវជ្រើសរើសអ្នកគ្រប់គ្រងពន្ធដែលមានអាសយដ្ឋាននៅប្រទេសជប៉ុន ហើយដាក់ ”ពាក្យជូនដំណឹងអំពីអ្នកគ្រប់គ្រងពន្ធ” ទៅការិយាល័យពន្ធដារដែលមានសមត្ថកិច្ច។ អ្នកគ្រប់គ្រងពន្ធនឹងធ្វើបែបបទជំនួសសមីខ្លួនក្រោយពេលចាកចេញពីប្រទេសជប៉ុន។

# 1-3 ប្រាក់ដកពីប្រាក់ចំណូលសំខាន់ៗ

ដោយការយោគយល់លើស្ថានភាពរបស់បុគ្គលម្នាក់ៗ ក្នុងករណីដូចខាងក្រោម នៅពេលគណនាពន្ធលើប្រាក់ចំណូល មានការ ដក(ផាត់ចេញនូវ)ទឹកប្រាក់ក្នុងចំនួនកំណត់មួយ។ (សូមមើលត្រង់រូបមន្តគណនានៅក្នុង 1)

ប៉ុន្តែចំពោះអនិវាសនជន (មើលត្រង់ 1-1 (3)) ប្រភេទនៃប្រាក់ដកដែលអាចអនុវត្តបានគឺមានកំណត់។

## (1) ក្នុងករណីចិញ្ចឹមគ្រួសារ

- ក្នុងករណីដែលអ្នកផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុដល់សមាជិកគ្រួសារ ហើយប្រាក់ចំណូលសរុបនៃអ្នកនៅក្នុងបន្ទុកគឺ 480,000 យ៉េន ឬតិចជាងនេះ (380,000 យ៉េន ឬតិចជាងនេះនៅក្នុង ឬមុនឆ្នាំ 2019) អ្នកអាចទទួលបានចំនួនជាក់លាក់នៃការកាត់បន្ថយប្រាក់ចំណូលលើការគណនាពន្ធលើប្រាក់ចំណូលរបស់អ្នក។
- ក្នុងករណីដែលគ្រួសារចិញ្ចឹមគឺជាអនិវាសនជន (មើលត្រង់ 1-1 (3)) ត្រូវភ្ជាប់ជាមួយពាក្យប្រកាសសម្រេចនូវ
  1. “ឯកសារបញ្ជាក់ទំនាក់ទំនងជាគ្រួសារ (ឯកសារចំលងនៃសៀវភៅគ្រួសារជាដើម)”
  2. “ឯកសារបញ្ជាក់ការចិញ្ចឹម (ឯកសារទទួលនៅពេលផ្ញើប្រាក់ពីស្ថាប័នហិរញ្ញវត្ថុជាដើម)” ឬបង្ហាញនៅពេលដាក់ពាក្យប្រកាសសម្រេច។
- បន្ទាប់ពីឆ្នាំ 2023 តទៅ គ្រួសារចិញ្ចឹមដែលមិនមែនជាអនិវាសនជនដែលមានអាយុចន្លោះពី 30 ទៅ 70 ឆ្នាំ ហើយដែលមិនស្ថិតនៅក្រោមចំណុចណាមួយខាងក្រោម នឹងមិនអាចទទួលបានការកាត់បន្ថយពន្ធប្រាក់ចំណូលបានទេ។

① គ្រួសារទាំងនោះគឺជាគ្រួសារដែលបាត់បង់អាស័យដ្ឋាន និងលំនៅឋានក្នុងប្រទេសជប៉ុន ដោយសារតែទៅសិក្សានៅបរទេស។
② សមាជិកគ្រួសារនោះមានពិការភាព។
③ ក្នុងឆ្នាំនោះ អ្នកបានបង់ប្រាក់ 380,000 យ៉េន ឬច្រើនជាងនេះទៅឱ្យគ្រួសាររបស់អ្នកសម្រាប់ការចំណាយលើការរស់នៅ ឬថ្លៃសិក្សា។

## (2) ក្នុងករណីមានសហព័ទ្ធ

- ក្នុងករណីមានសហព័ទ្ធ ហើយបំពេញលក្ខខណ្ឌមួយចំនួន គេអាចទទួលបានប្រាក់ដកពីប្រាក់ចំណូលក្នុងចំនួនកំណត់មួយ។
- ក្នុងករណីដែលសហព័ទ្ធគឺជាអនិវាសនជន (មើលត្រង់ 1-1 (3)) ត្រូវភ្ជាប់ជាមួយពាក្យប្រកាសសម្រេចនូវ
  1. “ឯកសារបញ្ជាក់ទំនាក់ទំនងជាសហព័ទ្ធ (ឯកសារចំលងនៃសៀវភៅគ្រួសារជាដើម)” និង
  2. “ឯកសារបញ្ជាក់ថាមានអាហារកិច្ច (ឯកសារទទួលនៅពេលផ្ញើប្រាក់ពីស្ថាប័នហិរញ្ញវត្ថុជាដើម)” ឬបង្ហាញនៅពេលដាក់ពាក្យប្រកាសសម្រេច។

## (3) ក្នុងករណីបង់ភាគទានរបបសន្តិសុខសង្គម

ក្នុងករណីដែលបង់ភាគទានរបបសន្តិសុខសង្គម ដោយសមីខ្លួនឬសហព័ទ្ធដែលមានជីវភាពរស់នៅរួមគ្នា ឬគ្រួសារផ្សេងទៀត (របបថែទាំសុខភាព របបប្រាក់សោធនសង្គម របបប្រាក់សោធនសុខុមាលភាព។ល។) អាចទទួលបានប្រាក់ដកពីប្រាក់ចំណូលនូវទំហំទឹកប្រាក់ដែលបានបង់។

## (4) ក្នុងករណីបង់ប្រាក់ធានារ៉ាប់រងជីវិតជាដើម

ក្នុងករណីដែលសមីខ្លួនបង់ប្រាក់ធានារ៉ាប់រងជីវិត ប្រាក់ធានារ៉ាប់រងថែទាំសុខភាព និងភាគទានប្រាក់

សោធនបុគ្គល គេអាចទទួលបានប្រាក់ដកពីប្រាក់ចំណូលក្នុងចំនួនកំណត់មួយ។

### (5) ក្នុងករណីបានបង់ថ្លៃព្យាបាល

ក្នុងករណីដែលថ្លៃព្យាបាលរបស់សមីខ្លួនឬសហព័ទ្ធដែលមានជីវភាពរស់នៅរួមគ្នា ឬគ្រួសារផ្សេងទៀត មានចំនួនលើសពីចំនួនកំណត់មួយ គេអាចទទួលបានប្រាក់ដកពីប្រាក់ចំណូលទៅតាមថ្លៃព្យាបាលនោះ។

## 1-4 ពន្ធកាត់ទុក និងការទូទាត់ពន្ធនៅចុងឆ្នាំ

- ពលរដ្ឋបរទេសដែលបានទទួលបៀវត្ស នៅពេលទទួលបៀវត្សពីនិយោជក ពន្ធលើប្រាក់ចំណូលត្រូវបាន កាត់ (ត្រូវបានកាត់ពន្ធទុក)។
- នៅពេលទទួលបៀវត្សចុងក្រោយនៅឆ្នាំនោះ ការទូទាត់ពន្ធលើប្រាក់ចំណូល (ការទូទាត់ពន្ធនៅចុងឆ្នាំ) ត្រូវបានធ្វើ។
- អ្នកផ្ដល់បៀវត្សត្រូវប្រគល់ "បង្កាន់ដៃពន្ធកាត់ទុក" ដែលមានរៀបរាប់អំពីទឹកប្រាក់ផ្ដល់ជាដើម អោយទៅ អ្នកទទួលបៀវត្ស។

## 1-5 បញ្ញត្តិពិសេសក្រោមសន្ធិសញ្ញាពន្ធ

ក្នុងករណីដែលប្រទេសកំណើតរបស់ខ្លួននិងប្រទេសជប៉ុនបានចុះសន្ធិសញ្ញាពន្ធ នៅពេលបំពេញ លក្ខខណ្ឌកំណត់មួយ មានករណីដែលពន្ធលើប្រាក់ចំណូលនឹងត្រូវបន្ធូរបន្ថយឬលើកលែង។

# 2 ពន្ធលើនិវាសនជន



## 2-1 តើអ្វីជាពន្ធលើនិវាសនជន

- គឺជាពន្ធដែលត្រូវបង់ទៅអោយខេត្តក្រុង និងភូមិឃុំស្រុកដែលមាន (ធ្លាប់មាន)អាសយដ្ឋានគិតត្រឹមថ្ងៃទី1 ខែមករា។
- ផ្សំឡើងដោយ “ផ្នែកតាមចំណូល” ដែលចំនួនទឹកប្រាក់ត្រូវបានគណនាតាមចំណូលពីថ្ងៃទី1 ខែមករា រហូតដល់ថ្ងៃទី 31ខែធ្នូនៃឆ្នាំមុនជាដើម និង“ផ្នែកថេរ” ដែលមិនទាក់ទងនឹងប្រាក់បៀវត្សទទួលជាដើម។
- ពន្ធលើនិវាសនជនដែលត្រូវបង់ទៅខេត្តក្រុង ត្រូវបង់ទៅអោយភូមិឃុំស្រុករួមជាមួយនឹងពន្ធលើនិវាសនជនដែលត្រូវបង់ទៅភូមិឃុំស្រុក។

## 2-2 ការបង់ពន្ធលើនិវាសនជន

- វិធីបង់ពន្ធលើនិវាសនជនមាន 2បែប។

① ការប្រមូលពិសេស ក្រុមហ៊ុនធ្វើការកាត់ពីប្រាក់បៀវត្សនូវពន្ធលើនិវាសនជនជាមុន ហើយបង់ទៅភូមិឃុំស្រុក។ អ្នកធ្វើការនៅក្រុមហ៊ុនឬនៅរោងចក្រជាទូទៅគឺធ្វើដូច្នេះ ហើយមិនបាច់ទៅបង់ពន្ធលើនិវាសនជនដោយខ្លួនឯងឡើយ។

② ការប្រមូលធម្មតា អ្នកនឹងបានទទួលលិខិតពីភូមិឃុំស្រុកមានខ្លឹមសារថា “សូមបង់ពន្ធលើនិវាសនជន” សូមយកលិខិតនោះនិងសាច់ប្រាក់ដែលជាប្រាក់ពន្ធដែលមានសរសេរនៅក្នុងលិខិតនោះ ទៅបង់នៅភូមិឃុំស្រុក (*) ដោយខ្លួនឯង។

* ឯកសារដែលអ្នកទទួលបានពីរដ្ឋាភិបាលក្នុងតំបន់របស់អ្នកនឹងពិពណ៌នាអំពីវិធីបង់ប្រាក់។

## 2-3 ផ្សេងៗ

- ចំពោះពន្ធលើនិវាសនជន សូមប្រុងប្រយ័ត្ននូវចំណុចខាងក្រោម៖

① ត្រូវបង់ពន្ធទៅអោយភូមិឃុំស្រុកដែលខ្លួនមាន (ធ្លាប់មាន)អាសយដ្ឋានគិតត្រឹមថ្ងៃទី1 ខែមករា ទោះបីជាចាកចេញពីប្រទេសជប៉ុនចាប់ពីថ្ងៃទី2ខែមករាតទៅក៏ដោយ ក៏ត្រូវបង់ពន្ធលើនិវាសនជនដែរ។

② ក្នុងករណីដែលអ្នកដែលបង់ពន្ធលើនិវាសនជនដោយការប្រមូលពិសេស (មើលត្រង់(1) នៃ2-2) លាឈប់ពីក្រុមហ៊ុន គឺត្រូវបង់ពន្ធលើនិវាសនជនដែលមិនទាន់បានបង់ដោយវិធីប្រមូលធម្មតា (មើលត្រង់(2) នៃ2-2) ប៉ុន្តែគេក៏អាចពឹងអោយក្រុមហ៊ុនជួយបង់ពន្ធលើនិវាសនជនដែលមិនទាន់បានបង់ទាំងអស់ទៅភូមិឃុំស្រុក ដោយដកពីប្រាក់បៀវត្សឬប្រាក់ឈប់ពីការងារបានដែរ។

③ ក្នុងករណីដែលមិនអាចបង់ពន្ធលើនិវាសនជនបានមុនចាកចេញពីប្រទេសជប៉ុន មុននឹងចាកចេញពីប្រទេសជប៉ុន ត្រូវជ្រើសរើសយកអ្នកធ្វើបែបបទបង់ពន្ធជំនួសខ្លួន (អ្នកគ្រប់គ្រងពន្ធ) ក្នុងចំណោមបុគ្គលដែលស្នាក់នៅប្រទេសជប៉ុន ហើយត្រូវជូនដំណឹងទៅភូមិឃុំស្រុកដែលខ្លួនរស់នៅ។

# 3 អាករលើតំលៃបន្ថែម

នៅពេលទិញទំនិញឬទទួលសេវាកម្ម អាករលើតំលៃបន្ថែមគឺ10% ប៉ុន្តែភាគរយនៃអាករលើតំលៃបន្ថែមគឺភាគរយបន្ធូរបន្ថយ 8% ចំពោះការទិញម្ហូបអាហារក្រៅពីគ្រឿងស្រវឹងនឹងការហូបនៅខាងក្រៅ។



# 4 ពន្ធដែលម្ចាស់រថយន្តត្រូវបង់

## 4-1 ពន្ធលើរថយន្ត និងពន្ធលើរថយន្តធុនស្រាល



### (1) ពន្ធលើរថយន្ត ឬពន្ធលើរថយន្តធុនស្រាលតាមសមត្ថភាពបរិស្ថាន

#### នៅពេលទិញរថយន្ត

ម្ចាស់រថយន្តដែលទិញរថយន្ត ឬរថយន្តធុនស្រាល ត្រូវបង់ពន្ធលើរថយន្ត ឬពន្ធលើរថយន្តធុនស្រាលតាមសមត្ថភាពបរិស្ថាន។

(ភាគរយពន្ធតាមសមត្ថភាពបរិស្ថាន គឺកំណត់ទៅតាមសមត្ថភាពចំហេះជាដើម នៃរថយន្ត-រថយន្តធុនតូច។)

### (2) ពន្ធលើរថយន្ត និងពន្ធលើរថយន្តធុនស្រាលតាមប្រភេទ

#### ក្នុងករណីមានរថយន្ត

គិតត្រឹមថ្ងៃទី1 ខែមេសា ម្ចាស់រថយន្តដែលមានរថយន្ត (ទំហំពីស្តុងចាប់ពី 660 cc) ត្រូវបង់ពន្ធលើរថយន្តតាមប្រភេទរថយន្ត(*)។

(ប្រាក់ពន្ធត្រូវបានកំណត់ទៅតាមទំហំពីស្តុងជាដើម។)

* ចំពោះទឹកប្រាក់ត្រូវបង់និងវិធីបង់ ក្នុងលិខិតដែលទទួលបានពីខេត្តក្រុង មានសរសេរអំពីខ្លឹមសារនោះ។

#### ក្នុងករណីមានរថយន្តធុនស្រាល

គិតត្រឹមថ្ងៃទី1 ខែមេសា ម្ចាស់រថយន្តដែលមានរថយន្តធុនស្រាល (ទំហំពីស្តុង 660 cc) ត្រូវបង់ពន្ធលើរថយន្តតាមប្រភេទរថយន្ត(*)។

(ប្រាក់ពន្ធត្រូវបានកំណត់ទៅតាមទំហំពីស្តុងជាដើម។)

* ចំពោះទឹកប្រាក់ត្រូវបង់និងវិធីបង់ ក្នុងលិខិតដែលទទួលបានពីខេត្តក្រុង មានសរសេរអំពីខ្លឹមសារនោះ។

## 4-2 ពន្ធលើរថយន្តតាមទម្ងន់

### នៅពេលទទួលការឈៀករថយន្ត ឬរថយន្តធុនស្រាលជាដើម

នៅពេលទទួលការឈៀករថយន្ត ត្រូវបង់ពន្ធលើរថយន្តតាមទម្ងន់របស់រថយន្ត ដោយយោងលើទម្ងន់នៃរថយន្ត ឬរថយន្តធុនស្រាលជាដើម។

# 5 ពន្ធលើអចលនទ្រព្យ

- គិតត្រឹមថ្ងៃទី1 ខែមករា ក្នុងករណីដែលមានរបស់ខាងក្រោម គឺត្រូវបង់ពន្ធ៖

① ដី ② ផ្ទះ ③ ទ្រព្យដែលអាចរំលស់បាន

- ក្នុងករណីមានទ្រព្យដែលអាចរំលស់បាន ត្រូវធ្វើការប្រកាស។
- ប្រាក់ពន្ធគឺភូមិឃុំស្រុកជាអ្នកគណនាផ្អែកលើតំលៃនៃទ្រព្យ។
- ប្រាក់ពន្ធត្រូវបង់ទៅអោយភូមិឃុំស្រុកដែលទ្រព្យនៅស្ថិតនៅ។

# 6 អាសយដ្ឋានទំនាក់ទំនងសួរអំពីពន្ធ

## 6-1 សំណួរអំពីពន្ធរដ្ឋ



### (1) មជ្ឈមណ្ឌលពិគ្រោះតាមទូរស័ព្ទ

ចំពោះការពិគ្រោះទូទៅទាក់ទងនឹងពន្ធរដ្ឋ មានទទួលការពិគ្រោះសំខាន់ជាភាសាអង់គ្លេសតាម “មជ្ឈមណ្ឌលពិគ្រោះតាមទូរស័ព្ទ” ដូចតទៅ។

- មជ្ឈមណ្ឌលពិគ្រោះតាមទូរស័ព្ទ ការិយាល័យពន្ធដាររដ្ឋប្រចាំតូក្យូ
  03-3821-9070
- មជ្ឈមណ្ឌលពិគ្រោះតាមទូរស័ព្ទ ការិយាល័យពន្ធដាររដ្ឋប្រចាំអូសាកា(បញ្ជូនតពីលេខតំណាង)
  06-4965-8298
- មជ្ឈមណ្ឌលពិគ្រោះតាមទូរស័ព្ទ ការិយាល័យពន្ធដាររដ្ឋប្រចាំណាហ្គោយ៉ា
  052-971-2059

### (2) Tax answer (សំណួរញឹកញាប់អំពីពន្ធ)

គេអាចស្រាវជ្រាវរកចំលើយទូទៅចំពោះសំណួរញឹកញាប់អំពីប្រភេទពន្ធនីមួយៗ។

https://www.nta.go.jp/english/taxes/index.htm

### (3) ការណែនាំអំពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ

ផ្ដល់ព័ត៌មានមានអត្ថប្រយោជន៍សម្រាប់ការប្រកាសពន្ធ និងការបង់ពន្ធជាដើម។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://www.nta.go.jp/english/index.htm

| National Tax Agency JAPAN | ស្វែងរក |
|---|---|

## 6-2 សំណួរអំពីពន្ធមូលដ្ឋាន

ពេលចង់សួរពាក់ព័ន្ធនឹងពន្ធមូលដ្ឋាន សូមប្រើគេហទំព័រខាងក្រោមនេះ។

(1) សូមណែនាំឱ្យស្គាល់គេហទំព័ររបស់ក្រសួងមហាផ្ទៃ

មានណែនាំអំពីពន្ធលើនិវាសនជនជាបុគ្គល សម្រាប់ជនបរទេស

https://www.soumu.go.jp/main_sosiki/jichi_zeisei/czaisei/czaisei_seido/individual-inhabitant-tax.html

(2) ស្ដីពីព័ត៌មានលំអិត សូមទាក់ទងសួរទៅភូមិឃុំស្រុកនីមួយៗ ឬខេត្តក្រុងនីមួយៗដែលលោកអ្នករស់នៅ។

ជំពូកទី9 ចរាចរណ៍



## 1 ច្បាប់ចរាចរណ៍

នៅតាមផ្លូវមានមនុស្សជាច្រើនធ្វើដំណើរ។ ហេតុដូច្នេះហើយ ការគោរពច្បាប់ចរាចរណ៍ និងអនុវត្តន៍សុជីវធម៌ចរាចរណ៍ ដើម្បីអោយការធ្វើដំណើរមានសុវត្ថិភាពនិងមានភាពរលូន គឺជាកាតព្វកិច្ចរបស់សមាជិកនៃសង្គម។

### 1-1 ប្រការត្រូវប្រុងប្រយ័ត្ននៅពេលធ្វើដំណើរដោយថ្មើរជើង

#### (1) នៅពេលធ្វើដំណើរទៅមុខ

**ជាទូទៅអ្នកថ្មើរជើងប្រកាន់ស្តាំ យានយន្តប្រកាន់ឆ្វេង**

- ធ្វើដំណើរនៅកៀនខាងស្តាំ។
- នៅពេលមានផ្លូវសម្រាប់អ្នកថ្មើរជើង ឬចិញ្ចើមផ្លូវសូមធ្វើដំណើរនៅលើនោះ។



#### (2) វិធីឆ្លងផ្លូវ

**ឆ្លងផ្លូវនៅកន្លែងមានសុវត្ថិភាព**

- សូមឆ្លងផ្លូវនៅកន្លែងមានភ្លើងសញ្ញាចរាចរណ៍ ផ្លូវដើរឆ្លងកាត់ ឬស្ពានអាកាសថ្មើរជើង ឬក្នុងករណីដែលមានផ្លូវថ្មើរជើងក្រោមដីនៅក្បែរ សូមឆ្លងតាមនោះ។
- នៅកន្លែងដែលមានផ្លាកសញ្ញា “ហាមអ្នកថ្មើរជើងឆ្លងផ្លូវ” គឺមិនត្រូវឆ្លងជាដាច់ខាត។
- នៅកន្លែងសម្រាប់ដើរឆ្លង ត្រូវលើកដៃ ហើយបែរមុខទៅអ្នកបើកបរ ដើម្បីបញ្ជាក់ប្រាប់គេថា យើងឆ្លង ហើយមើលឆ្វេងស្តាំ ដើម្បីបញ្ជាក់សុវត្ថិភាព។
- ពេលកំពុងឆ្លង ត្រូវពិនិត្យមើលថា តើមានរថយន្តមកឬទេ។

**អត្ថន័យនៃភ្លើងសញ្ញាចរាចរណ៍**



- ភ្លើងភ្លឺពណ៌ខៀវ៖ ទៅមុខ។
- ភ្លើងភ្លឺពណ៌លឿង ឬភ្លើងភ្លឹបភ្លែតពណ៌ខៀវ៖ មិនអាចចាប់ផ្តើមឆ្លងបានទេ។ ក្នុងករណីដែលកំពុងឆ្លង ត្រូវប្រញាប់ឆ្លងអោយផុត ឬបោះបង់ការឆ្លងត្រឡប់ក្រោយវិញ។

- ភ្លើងភ្លឺពណ៌ក្រហម៖ មិនអាចឆ្លងបានទេ។
- ក្នុងករណីភ្លើងសញ្ញាចរាចរណ៍ដែលមានប៊ូតុងចុច៖ ចុចប៊ូតុង ហើយរង់ចាំរហូតដល់ភ្លើងប្តូរទៅជាពណ៌ខៀវទើបឆ្លង។

### នៅពេលឆ្លងនៅកន្លែងដែលគ្មានភ្លើងសញ្ញាចរាចរណ៍

- នៅពេលយប់អ្នកថ្មើរជើងគួរពាក់អាវពណ៌ភ្លឺនិងវត្ថុចាំងពន្លឺ
- មុននឹងឆ្លងត្រូវឈប់បន្តិចសិន មើលបញ្ជាក់ឆ្វេងស្តាំថាគ្មានយានយន្តមកទេ។ បើមានយានយន្តមកជិត រង់ចាំរហូតយានយន្តទៅផុត។
- នៅពេលឆ្លងក៏ត្រូវមើលថាគ្មានយានយន្តណាមក ហើយទៅមុខអោយត្រង់។ មិនត្រូវឆ្លងបញ្ឆិតឡើយ។

### ការឆ្លងកាត់ផ្លូវរថភ្លើង

- ដាច់ខាតត្រូវឈប់បន្តិចនៅពីមុខផ្លូវរថភ្លើង ហើយមើលសុវត្ថិភាពឆ្វេងស្តាំ។
- ប្រសិនបើម៉ាស៊ីនបន្លឺសំលេង ឬរបាំងចាប់ផ្តើមធ្លាក់ចុះ មិនត្រូវឆ្លងផ្លូវរថភ្លើងជាដាច់ខាត។

## (3) នៅពេលធ្វើដំណើរដោយថ្មើរជើងនៅពេលយប់

### នៅពេលយប់អ្នកថ្មើរជើងគួរពាក់អាវពណ៌ភ្លឺនិងវត្ថុចាំងពន្លឺ

នៅពេលដើរលើផ្លូវពេលយប់ សូមពាក់សំលៀកបំពាក់ភ្លឺដូចជាពណ៌សឬពណ៌លឿង ភ្ជាប់វត្ថុចាំងពន្លឺ ឬភ្លើង LED នៅលើខ្លួន ឬនៅលើអីវ៉ាន់ ដើម្បីអោយយានយន្តងាយស្រួលមើលឃើញ។

# 1-2 ប្រការត្រូវប្រុងប្រយ័ត្ននៅពេលជិះកង់

## (1) ការគោរពច្បាប់ធ្វើដំណើរដោយកង់ "ច្បាប់ប្រើប្រាស់កង់ដោយសុវត្ថិភាពទាំង 5"



### ច្បាប់ទី1 ជាទូទៅកង់ត្រូវជិះលើផ្លូវយានយន្ត ប្រកាន់ឆ្វេង ផ្លូវថ្មើរជើងគឺជាករណីលើកលែង ដោយផ្តល់អាទិភាពដល់អ្នកថ្មើរជើង

- កង់គឺជាយានយន្ត ជាទូទៅត្រូវធ្វើដំណើរលើផ្លូវយានយន្តដោយប្រកាន់ឆ្វេង។
- នៅកន្លែងដែលមានផ្លូវសម្រាប់កង់ គេធ្វើដំណើរលើផ្លូវសម្រាប់កង់។
- អ្នកអាចជិះនៅចិញ្ចើមផ្លូវនៅខាងឆ្វេងនៃផ្លូវ ប៉ុន្តែមិនត្រូវរំខានដល់ការធ្វើដំណើររបស់អ្នកថ្មើរជើងឡើយ។
- ផ្លូវសម្រាប់អ្នកថ្មើរជើងដែលមានផ្លាកសញ្ញាអនុញ្ញាតអោយកង់ជិះបានជាដើម នោះគេអាចជិះកង់បាន។
- កុមារអាយុក្រោម 13ឆ្នាំ មនុស្សចាស់អាយុចាប់ពី 70ឆ្នាំ អ្នកមានពិការភាពលើរាងកាយ អាចជិះកង់លើផ្លូវសម្រាប់អ្នកថ្មើរជើងបាន។
- ប្រសិនបើអ្នកអាចជិះលើផ្លូវថ្មើរជើងបាន អ្នកត្រូវតែបន្ថយល្បឿនក្នុងល្បឿនដែលអនុញ្ញាតឱ្យអ្នកឈប់បានភ្លាមៗជាងនៅលើផ្លូវយានយន្ត។
- ប្រសិនបើមានហានិភ័យនៃការស្ទះចរាចរណ៍នៃអ្នកថ្មើរជើង អ្នកត្រូវតែឈប់។

### ច្បាប់ទី2 នៅផ្លូវប្រសព្វ ត្រូវគោរពភ្លើងសញ្ញាចរាចរណ៍ ហើយឈប់និចសិន ហើយបញ្ជាក់ពីសុវត្ថិភាព

- នៅផ្លូវប្រសព្វដែលលមានភ្លើងសញ្ញាចរាចរណ៍ សូមរង់ចាំរហូតដល់ភ្លើងសញ្ញាប្រែទៅជាពណ៌ខៀវហើយ បញ្ជាក់ពីសុវត្ថិភាពហើយឆ្លងកាត់។
- នៅផ្លូវប្រសព្វដែលអ្នកតម្រូវឱ្យឈប់ ត្រូវប្រាកដថាឈប់ ហើយបញ្ជាក់ពីសុវត្ថិភាពរបស់អ្នក។

### ច្បាប់ទី3 បើកភ្លើងនៅពេលយប់

- នៅពេលយប់ចាំបាច់ត្រូវតែបើកភ្លើង
- ត្រូវប្រាកដថាភ្លើងបានបើក មុនពេលអ្នកជិះកង់របស់អ្នក។

### ច្បាប់ទី4 ការបើកបរក្នុងស្ថានភាពស្រវឹងត្រូវបានហាមឃាត់



- ដាច់ខាតមិនអាចជិះកង់បានបន្ទាប់ពីផឹកស្រាហើយ។

### ច្បាប់ទី5 ការពាក់មួកសុវត្ថិភាព

- ពាក់មួកសុវត្ថិភាពសម្រាប់ជិះកង់នៅពេលជិះកង់។
- ពេលអោយអ្នកដទៃជិះកង់របស់អ្នក សូមអោយពួកគេពាក់មួកសុវត្ថិភាពសម្រាប់ជិះកង់។ អាណាព្យាបាលរបស់កុមារ នៅពេលអោយកូនជិះកង់ និងនៅពេលអោយកុមារជិះលើកៅអីសម្រាប់កុមារ ត្រូវអោយពាក់មួកសុវត្ថិភាពសម្រាប់ជិះកង់។

### ច្បាប់ផ្សេងទៀត

- បញ្ឈប់ការជិះឌុបគ្នា ឬជិះទន្ទឹមគ្នា
- ពេលកំពុងជិះកង់មិនអាចប្រើឆ័ត្រ ឬប្រើទូរស័ព្ទដៃ។
- លោកអ្នកអាចចូលធានារ៉ាប់រងចំពោះការទទួលខុសត្រូវនូវសំណងនៃការខូចខាតដោយសារកង់ ឬចំពោះរបួសខ្លួនឯងបាន។ក្នុងនោះ ជាពិសេសស្តីពី "ការធានារ៉ាប់រងចំពោះការទទួលខុសត្រូវនូវសំណងនៃការខូចខាតដោយសារកង់ ជាអាទិ៍" មានតំបន់ជាច្រើន ដូចជា តូក្យូ អូសាកា ជាដើម គេតម្រូវឱ្យចូលធានារ៉ាប់រងនេះ។

ចំពោះសេចក្តីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.mlit.go.jp/road/bicycleuse/promotion/index.html

## (2) វិធីឆ្លងផ្លូវប្រសព្វ

### ក្នុងករណីបត់ស្តាំ

- ក្នុងករណីមានភ្លើងសញ្ញាចរាចរណ៍
  នៅពេលភ្លើងសញ្ញាពណ៌ខៀវ ទៅមុខត្រង់តាមចំហៀងខាងឆ្វេងនៃផ្លូវប្រសព្វរហូតដល់ជ្រុងម្ខាងទៀតនៃផ្លូវ ពេលនោះឈប់ហើយប្តូរទិសដៅ។ នៅពេលភ្លើងសញ្ញាក្នុងទិសដៅនោះមានពណ៌ខៀវ ពិនិត្យសុវត្ថិភាពមុខក្រោយឆ្វេងស្តាំហើយទៅមុខត្រង់។

- ក្នុងករណីគ្មានភ្លើងសញ្ញាចរាចរណ៍
  ត្រួតពិនិត្យសុវត្ថិភាពខាងក្រោយ ទៅមុខត្រង់តាមចំហៀងខាងឆ្វេងនៃផ្លូវរហូតដល់ម្ខាងទៀតនៃផ្លូវ ពិនិត្យសុវត្ថិភាពរួចបត់ស្តាំហើយទៅមុខត្រង់។

### ក្នុងករណីបត់ឆ្វេង

ក្រោយពេលបត់ឆ្វេងចូលផ្លូវនោះហើយ ធ្វើយ៉ាងណាកុំអោយរំខានដល់អ្នកដំណើរថ្មើរជើងដែលកំពុងឆ្លងផ្លូវនោះ។

### កន្លែងដែលមានតំបន់សម្រាប់កង់ឆ្លង

ក្នុងករណីដែលនៅផ្លូវប្រសព្វឬនៅក្បែរនោះមានតំបន់សម្រាប់កង់ឆ្លង សូមឆ្លងតាមនោះ។



## 1-3 គោលការណ៍ណែនាំស្ដីពីសុវត្ថិភាពសម្រាប់អ្នកជិះ "កង់អគ្គិសនីខ្នាតតូចជាក់លាក់" (កង់អគ្គិសនី/កង់ស្ដី។ល។)

- ទោះមិនតម្រូវឱ្យមានបណ្ណបើកបរក្នុងការប្រតិបត្តិការកង់អគ្គិសនីក៏ដោយ ក៏អ្នកដែលមានអាយុក្រោម 16 ឆ្នាំត្រូវបានហាមឃាត់មិនឱ្យជិះផងដែរ។
- ប្រសិនបើយានជំនិះមិនត្រូវនឹងទំហំជាក់លាក់ និងស្តង់ដាររចនាសម្ព័ន្ធនៃ "កង់អគ្គិសនីខ្នាតតូចជាក់លាក់" នោះនឹងតម្រូវឱ្យមានបណ្ណបើកបរសម្រាប់ការប្រើប្រាស់។
- វាក៏ចាំបាច់ផងដែរក្នុងការភ្ជាប់ផ្លាកលេខ និងចុះឈ្មោះក្នុងការធានារ៉ាប់រងបំណុល។
- កង់អគ្គិសនីត្រូវជិះនៅលើគន្លងខាងឆ្វេងនៃផ្លូវ។ ហាមជិះខាងស្តាំ។
- ត្រូវប្រាកដថាគោរពភ្លើងសញ្ញាចរាចរណ៍ និងផ្លាកសញ្ញាទាំងអស់។
- ហាមជិះកង់អគ្គិសនីបន្ទាប់ពីពិសារគ្រឿងស្រវឹង។
- មិនត្រូវឱ្យទៅអ្នកដែលទើបពិសារគ្រឿងស្រវឹងខ្ចី ឬលើកទឹកចិត្តអ្នកដែលអាចនឹងជិះឱ្យពិសារគ្រឿងស្រវឹងឡើយ។
- មិនត្រូវជិះស្មើគ្នា ឬជិះចំហៀងគ្នា។
- ហាមប្រើឆត្រ ឬទូរសព្ទដៃនៅពេលជិះកង់។
- ប្រសិនបើមានគ្រោះថ្នាក់កើតឡើង សូមឈប់កង់ និងទៅជួយអ្នកដែលរងរបួស និងរាយការណ៍អំពីគ្រោះថ្នាក់ទៅប៉ូលិស។
- ត្រូវប្រាកដថាត្រូវពាក់មួកសុវត្ថិភាពនៅពេលជិះកង់អគ្គិសនី។



សូមមើលគេហទំព័រខាងក្រោមសម្រាប់ព័ត៌មានលម្អិត៖

https://www.npa.go.jp/english/bureau/traffic/index.html

## 1-4 នៅពេលបើកបរយានយន្ត (រួមទាំងម៉ូតូ)

- ដើម្បីបើកបរយានយន្តគឺតម្រូវអោយមានប័ណ្ណបើកបរ។
- នៅពេលមានការល្មើសច្បាប់ចរាចរណ៍ ឬនៅពេលមានគ្រោះថ្នាក់ចរាចរណ៍ ហើយប៉ូលីសទាមទារមើលប័ណ្ណបើកបរ ត្រូវតែបង្ហាញ។
- ត្រូវបើកបរនៅចំហៀងខាងឆ្វេងនៃផ្លូវ។
- នៅពេលទៅជិតអ្នកថ្មើរជើងឬកង់ ត្រូវទុកចន្លោះសុវត្ថិភាពឬបើកយឺតៗ។
- នៅពេលពិសាគ្រឿងស្រវឹង មិនត្រូវបើកបរជាដាច់ខាត។
- គេក៏មិនអាចអោយអ្នកពិសាគ្រឿងស្រវឹងខ្ចីយានយន្ត ឬណែនាំអោយអ្នកបើកបរយានយន្តពិសាគ្រឿងស្រវឹង ឬពឹងអោយអ្នកពិសាគ្រឿងស្រវឹងបើកបរបានឡើយ។



- នៅពេលបើកបរយានយន្តគឺត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព។ ហើយអ្នកជិះជាមួយក៏ត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាពដែរ។
- ចំពោះកុមារអាយុក្រោម 6ឆ្នាំគឺត្រូវប្រើកៅអីសម្រាប់កុមារ។
- នៅពេលបើកបរមិនត្រូវប្រើប្រាស់ទូរស័ព្ទដៃឡើយ។
- ត្រូវតែពាក់មួកសុវត្ថិភាពនៅពេលជិះម៉ូតូ។



ចំពោះសេចក្ដីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.npa.go.jp/english/bureau/traffic/index.html

# 2 ប័ណ្ណបើកបរ

ដើម្បីបើកបរយានយន្ត (រួមទាំងម៉ូតូ) ឬកង់មានមាស៊ីនរុញមានវិធី 3យ៉ាងដូចតទៅ។

① យកប័ណ្ណបើកបររបស់ប្រទេសជប៉ុន
② បើកបរដោយប្រើប័ណ្ណបើកបរអន្តរជាតិ
(ចេញដោយប្រទេសសមាជិកសន្ធិសញ្ញាទីក្រុងហ្សឺណែវ ហើយត្រូវនឹងទម្រង់កំណត់)
③ បើកបរដោយប្រើប្រាស់ប័ណ្ណបើកបររបស់បរទេស ដោយភ្ជាប់ឃ្លាបកប្រែជាភាសាជប៉ុនដោយស្ថានទូតជាដើម
(ស្វីស អាឡឺម៉ង់ បារាំង បែលហ្សិក ម៉ូណាកូ តៃវ៉ាន់ សរុប 6ប្រទេស-តំបន់)

* Moped គឺជាប្រភេទកង់មានមាស៊ីនរុញទូទៅ ហេតុដូច្នេះហើយគេត្រូវបើកបរដោយវិធីណាមួយក្នុងចំណោម ① ដល់ ③។
* គេអាចបើកបរដោយប័ណ្ណបើកបរ ② ឬ ③ បានយ៉ាងយូរបំផុតត្រឹម1ឆ្នាំ។

ចំពោះសេចក្ដីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.npa.go.jp/english/bureau/traffic/index.html

## 2-1 ការយកប័ណ្ណបើកបររបស់ប្រទេសជប៉ុន

- ដើម្បីយកប័ណ្ណបើកបររបស់ជប៉ុន មានវិធីដូចខាងក្រោម៖

① វិធីយកប័ណ្ណបើកបរដោយចូលប្រឡងក្នុងការប្រឡងយកប័ណ្ណបើកបររបស់ជប៉ុន។
- ប្រឡងអនុវត្តន៍ ប្រឡងទ្រឹស្ដី ប្រឡងអំពីភាពសមស្រប (សមត្ថភាពមើលឃើញ។ល។) នៅមជ្ឈមណ្ឌលប័ណ្ណបើកបរជាដើម ដោយចាំបាច់ត្រូវប្រឡងអោយជាប់។
- ប្រសិនបើបញ្ចប់វគ្គបង្រៀនបើកបរ (សាលាបង្រៀនបើកបរកំណត់) នោះការប្រឡងអនុវត្តន៍ត្រូវបានលើកលែង។

② វិធីប្ដូរប័ណ្ណបើកបរបរទេសមកជាប័ណ្ណបើកបរជប៉ុន
- ចំពោះអ្នកដែលមានប័ណ្ណបើកបរមកពីបរទេស ក្នុងករណីដែលគេបញ្ជាក់អំពីចំណេះដឹងនិងសមត្ថភាពក្នុងការបើកបរ ហើយត្រូវបានទទួលស្គាល់ថាមានភាពសមស្របអាចបើកបរបាន នោះការប្រឡងទ្រឹស្ដីនិងការប្រឡងអនុវត្តន៍នឹងត្រូវបានលើកលែង។
- ក្នុងលក្ខខណ្ឌដែលបានស្នាក់នៅចាប់ពី 3ខែឡើងទៅ ក្រោយពីបានទទួលប័ណ្ណបើកបរក្នុងប្រទេសខ្លួន។
- ការស្នើសុំធ្វើនៅមជ្ឈមណ្ឌលប័ណ្ណបើកបររបស់ប៉ូលីសនៃខេត្តក្រុងដែលអ្នករស់នៅ ជាដើម។
- ចំពោះឯកសារចាំបាច់សម្រាប់ការស្នើសុំជាដើម សូមធ្វើការទាក់ទងសួរទៅមជ្ឈមណ្ឌលប័ណ្ណបើកបររបស់ប៉ូលីសជាដើម។

## 2-2 ការបន្តសុពលភាពប័ណ្ណបើកបររបស់ប្រទេសជប៉ុនជាដើម



### ការបន្តសុពលភាពប័ណ្ណបើកបរ

- ប័ណ្ណបើកបររបស់ជប៉ុនមានកាលកំណត់នៃសុពលភាព។
- កាតប៉ុស្តាល់ដែលមានរៀបរាប់អំពីបែបបទចាំបាច់ក្នុងការបន្តសុពលភាពនឹងត្រូវបានផ្ញើទៅអាសយដ្ឋានដែលមានសរសេរលើប័ណ្ណបើកបរ។ សូមធ្វើបែបបទបន្តសុពលភាពក្នុងអំឡុងកាលកំណត់។
- បើមិនបន្តសុពលភាពទេ គឺលែងអាចបើកបរបានហើយ។

### ការប្តូរអាសយដ្ឋាននៃប័ណ្ណបើកបរជាដើម

- នៅពេលមានការប្តូរឈ្មោះ អាសយដ្ឋានជាដើមដែលមានសរសេរនៅលើប័ណ្ណបើកបរ សូមធ្វើបែបបទប្តូរនៅការិយាល័យប៉ូលីសដែលនៅក្បែរបំផុតជាដើម។
- ចំពោះខ្លឹមសារលំអិតដូចជាឯកសារចាំបាច់ជាដើម សូមទាក់ទងសួរទៅការិយាល័យប៉ូលីសនៅក្បែរកន្លែងអ្នក។

## 2-3 ប្រព័ន្ធដាក់ពិន្ទុលើប័ណ្ណបើកបរ

- ក្នុងករណីដែលមានការប្រព្រឹត្តល្មើសច្បាប់ចរាចរណ៍ ឬមានគ្រោះថ្នាក់ចរាចរណ៍ គឺមានការដាក់ពិន្ទុកំណត់មួយ។
- មានការពិន័យដូចជាបញ្ឈប់ ឬលុបចោលប័ណ្ណបើកបរ ទៅតាមពិន្ទុសរុបក្នុងអំឡុងពេល 3ឆ្នាំចុងក្រោយ។

# 3 ការធ្វើជាម្ចាស់យានយន្ត (រួមទាំងម៉ូតូ)

## 3-1 ការចុះបញ្ជីយានយន្ត

ក្នុងករណីមិនចុះបញ្ជីយានយន្តទេគឺមិនអាចបើកបរលើផ្លូវសាធារណៈ បានទេ។

លើសពីនេះទៀតនីតិវិធីចុះឈ្មោះត្រូវបានទាមទារនៅពេល ហើយក្នុងករណីដែលម្ចាស់យានយន្តដែលបានធ្វើការចុះបញ្ជីមានការប្តូរឈ្មោះ ឬអាសយដ្ឋានអ្នកប្រើប្រាស់យានយន្តដែលបានចុះបញ្ជី,ជាដើម ឬលែងប្រើប្រាស់នៅប្រទេសជប៉ុនតទៅទៀតក៏ត្រូវធ្វើបែបបទចុះបញ្ជីដែរ។

### (1) កាលៈទេសៈដែលត្រូវធ្វើបែបបទចុះបញ្ជីនិងឈ្មោះនៃបែបបទចុះបញ្ជី

#### ការចុះបញ្ជីយានយន្តដែលមិនត្រូវបានប្រើ

- នៅពេលចាប់ផ្តើមប្រើយានយន្តដែលមិនត្រូវបានប្រើ
  → ការចុះបញ្ជីថ្មី

## ការចុះបញ្ជីយានយន្តដែលកំពុងប្រើ

- នៅពេលមានការប្តូរឈ្មោះឬអាសយដ្ឋានរបស់ម្ចាស់ជាដើម និងអ្នកប្រើប្រាស់
  → ការចុះបញ្ជីប្តូរ
- នៅពេលមានការប្តូរម្ចាស់យានយន្ត
  → ការចុះបញ្ជីផ្ទេរសិទ្ធិ
- នៅពេលកម្ទេចយានយន្ត ឬនៅពេលនាំយានយន្តយកទៅក្រៅប្រទេស
  → ការចុះបញ្ជីលុបចោល

### (2) ទីកន្លែងដែលអាចធ្វើបែបបទចុះបញ្ជីនិងអាសយដ្ឋានទំនាក់ទំនង

- បែបបទចុះបញ្ជីអាចធ្វើទៅបាននៅការិយាល័យដឹកជញ្ជូនចំនួន 91កន្លែងទូទាំងប្រទេស និងនៅការិយាល័យត្រួតពិនិត្យចុះបញ្ជីយានយន្ត។
- ចំពោះចំណុចដែលដែលមិនយល់អំពីនីតិវិធីចុះបញ្ជី សូមទាក់ទងសួរទៅការិយាល័យដឹកជញ្ជូន ឬការិយាល័យត្រួតពិនិត្យចុះបញ្ជីយានយន្តនៅក្បែរកន្លែងអ្នករស់នៅ។

សេចក្តីណែនាំឱ្យដឹងអំពីការិយាល័យដឹកជញ្ជូនទូទាំងប្រទេស
https://www.jidoushatouroku-portal.mlit.go.jp/jidousha/kensatoroku/list/index.html

## 3-2 លិខិតបញ្ជាក់កន្លែងទុកយានយន្ត



ដើម្បីក្លាយជាម្ចាស់យានយន្ត ម្ចាស់យានយន្តត្រូវរកកន្លែងរក្សាទុកយានយន្តអោយបាន។

ហេតុដូច្នេះហើយ នៅពេលទិញយានយន្ត ឬនៅពេលផ្លាស់ប្តូរអាសយដ្ឋានជាដើម ត្រូវទទួលលិខិតបញ្ជាក់កន្លែងរក្សាទុកយានយន្ត (លិខិតបញ្ជាក់កន្លែងទុកយានយន្ត) ពីប្រធានការិយាល័យប៉ូលីសមានសមត្ថកិច្ច ដើម្បីបញ្ជាក់ទីកន្លែងរក្សាទុក ដែលត្រូវការនៅពេលចុះបញ្ជីយានយន្ត។

លើសពីនេះទៀត ចំពោះយានយន្តធុនស្រាល ចាំបាច់ត្រូវជូនដំណឹងអំពីកន្លែងរក្សាទុកទៅប្រធានការិយាល័យប៉ូលីសមានសមត្ថកិច្ច។

វិញ្ញាបនប័ត្រនេះត្រូវបានទាមទារសម្រាប់រថយន្តនៅក្នុងទីក្រុង ទីប្រជុំជន ភូមិមួយចំនួន និងវួដទាំង 23 នៃទីក្រុងតូក្យូ។ លើសពីនេះទៀត សម្រាប់យានជំនិះធុនស្រាល វិញ្ញាបនប័ត្រនេះត្រូវបានទាមទារនៅក្នុងទីក្រុងមួយចំនួន និងសង្កាត់ទាំង 23 នៃទីក្រុងតូក្យូ។

កន្លែងដែលត្រូវធ្វើបែបបទដូច្នេះ ចំពោះរថយន្តធុនស្រាលគឺនៅខណ្ឌទាំង 23 និងស្រុកខ្លះ។ ចំពោះរថយន្តផ្សេងក្រៅពីនេះ មាននៅភូមិខ្លះនៃខណ្ឌទាំង23 ស្រុក ក្រុង។

ចំពោះខ្លឹមសារលំអិតអំពីនីតិវិធីផ្តល់លិខិតបញ្ជាក់កន្លែងទុកយានយន្ត សូមទាក់ទងសួរទៅការិយាល័យប៉ូលីសមានសមត្ថកិច្ចនៃកន្លែងទុក (ចំណតយានយន្ត)។

## 3-3 ការត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្ត (រួមទាំងម៉ូតូប្រភេទខ្លះផង)

- ម្ចាស់យានយន្តត្រូវទទួលការត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្ត (ឈៀក) ទៅតាមរយៈពេលទៀងទាត់ដែលកំណត់ដោយច្បាប់។
- វិធីទទួលការឈៀករថយន្តមាន 2ប្រភេទ។

① ករណីប្រើសេវារោងចក្រថែទាំយានយន្ត

បច្ចុប្បន្ននៅប្រទេសជប៉ុនមនុស្សប្រហែល 90% ប្រើសេវារបស់រោងចក្រថែទាំយានយន្តសម្រាប់ការឈៀក ហើយការមិនធ្វើការថែទាំ ឬត្រួតពិនិត្យដោយខ្លួនឯងគឺទូទៅ។ ចំពោះការប្រើសេវាកម្មឈៀក សូមពិគ្រោះជាមួយយានដ្ឋានជួសជុលយានយន្តដែលមានឃីហោពណ៌ខៀវ (យានដ្ឋានដែលត្រូវបានកំណត់) ឬយានដ្ឋានដែលមានឃីហោពណ៌លឿង ឬពណ៌បៃតង (យានដ្ឋានដែលមានការទទួលស្គាល់) ដែលនៅក្បែរកន្លែងអ្នក។

② ក្នុងករណីធ្វើការឈៀកដោយខ្លួនឯង

បច្ចុប្បន្ននៅប្រទេសជប៉ុន មនុស្សប្រហែល 10% ទទួលការឈៀកយានយន្តដោយខ្លួនឯង។ ក្នុងករណីនេះត្រូវយកយានយន្តទៅបង្ហាញនៅស្ថាប័នរបស់រដ្ឋ ដូចជាការិយាល័យដឹកជញ្ជូនជាដើម ដើម្បីទទួលការត្រួតពិនិត្យ។ កន្លែងដែលអាចទទួលការឈៀកយានយន្តដូចជាការិយាល័យដឹកជញ្ជូនជាដើម មានចំនួន93 កន្លែង (ចំពោះរថយន្តធុនស្រាលមាន 89កន្លែង) ទូទាំងប្រទេស។ ក្នុងករណីនេះ ការថែទាំចាំបាច់ជាដើមគឺសមីខ្លួនជាអ្នកធ្វើ។ ចំពោះនីតិវិធីទទួលការឈៀកយានយន្តដោយខ្លួន សូមទាក់ទងទៅការិយាល័យដឹកជញ្ជូនជាដើមដែលនៅក្បែរកន្លែងអ្នក។

ការណែនាំអំពីការិយាល័យដឹកជញ្ជូនទូទាំងប្រទេស
https://www.jidoushatouroku-portal.mlit.go.jp/jidousha/kensatoroku/list/index.html

ការណែនាំអំពីរថយន្តធុនស្រាល
https://www.keikenkyo.or.jp/procedures/procedures_000134.html

- នៅពេលដែលការត្រួតពិនិត្យបានជាប់ នឹងទទួលបានប័ណ្ណសំគាល់ការឈៀកនិងបដិរូបសំគាល់ការត្រួតពិនិត្យ (តែម) សូមបិទតែមនៅលើកញ្ចក់ខាងមុខ (ករណីទោចក្រយានយន្ត សូមបិទនៅលើផ្លាកលេខ ផ្នែកខាងឆ្វេងនៅខាងលើ) ហើយយកប័ណ្ណសំគាល់ការឈៀកយានយន្តតាមខ្លួននៅពេលបើកបរយានយន្ត។

ជំពូកទី1 ជំពូកទី2 ជំពូកទី3 ជំពូកទី4 ជំពូកទី5 ជំពូកទី6 ជំពូកទី7 ជំពូកទី8 ជំពូកទី9 ជំពូកទី10 ជំពូកទី11 ជំពូកទី12

# 3-4 ធានារ៉ាប់រងលើយានយន្ត

## (1) ធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត (ជួយគ្នាទៅវិញទៅមក)

### អ្វីជាធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត (ជួយគ្នាទៅវិញទៅមក)

- គឺជាធានារ៉ាប់រងដោយកាតព្វកិច្ចដែលយានយន្តទាំងអស់ដូចជា រថយន្ត និងម៉ូតូជាដើមចាំបាច់ត្រូវចូលដើម្បីសង្គ្រោះជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍។
- ក្នុងករណីធ្វើអោយអ្នកម្ខាងទៀតរងរបួស ឬស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ ប្រាក់ធានារ៉ាប់រង(ជួយគ្នាទៅវិញទៅមក) នឹងត្រូវបានបង់ពីធានារ៉ាប់រងដោយកាតព្វកិច្ច(ជួយគ្នាទៅវិញទៅមក) ។
- តាមច្បាប់ រថយន្ត ម៉ូតូមបញ្ចូល ហើយម៉ូតូអាគុយ និងmopedsអាចនឹងមិនដំណើរការដោយគ្មានការធានារ៉ាប់រងលើការទទួលខុសត្រូវឡើយ។ ការបំពានអាចនាំឱ្យមានផាកការពិន័យ។
- វិញ្ញាបនបត្រនឹងត្រូវបានចេញនៅពេលអ្នកចូលក្នុងការធានារ៉ាប់រងដោយកាតព្វកិច្ច(ជួយគ្នាទៅវិញទៅមក) ដូច្នេះត្រូវប្រាកដថាយកវិញ្ញាបនបត្រទៅជាមួយអ្នកនៅពេលបើកបរ។ស្លាកសញ្ញា(ស្ទីកឃើ)ធានារ៉ាប់រង (ជួយគ្នាទៅវិញទៅមក) ក៏ត្រូវបានចេញសម្រាប់ឡានដែលមានម៉ាស៊ីនកម្លាំង 250cc ឬតិចជាងនេះផងដែរ ដូច្នេះសូមបិតនៅជ្រុងខាងឆ្វេងខាងលើនៃផ្លាកលេខ (សម្រាប់កង់ដែលមានម៉ាស៊ីនរុញ បិតនៅផ្នែកដែលអាចមើលឃើញយ៉ាងងាយនៃស្លាកលេខ។ )
- ក្នុងករណីមិនចូលធានារ៉ាប់រងដោយកាតព្វកិច្ច (ជួយគ្នាទៅវិញទៅមក) ហើយធ្វើអោយអ្នកម្ខាងទៀតរងរបួសឬស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ គឺត្រូវបង់ថ្លៃព្យាបាលនិងថ្លៃសំណងដ៏ច្រើនដោយខ្លួនឯង។
- ក្នុងករណីខ្លះ ដូចជាពិការភាពអចិន្ត្រៃយ៍ធ្ងន់ធ្ងរដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ អ្នកអាចមានសិទ្ធិទទួលបានជំនួយថ្លៃថែទាំពីទីភ្នាក់ងារជាតិសម្រាប់សុវត្ថិភាពរថយន្ត និងជំនួយសម្រាប់ជនរងគ្រោះ (NASVA)។ សូមពិគ្រោះជាមួយ NASVA សម្រាប់ព័ត៌មានលម្អិត។

ចំពោះសេចក្តីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។

អំពី CALI/ធានារ៉ាប់រងជួយគ្នាទៅវិញទៅមក

https://www.mlit.go.jp/jidosha/jibaiseki/about/overview/index.html

About NASVAអំពីNASVA

https://www.mlit.go.jp/jidosha/jibaiseki/nini_nasva/index.html

### ធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត

- គេអាចចូលធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត នៅកន្លែងដូចខាងក្រោម៖

① សាខា ឬភ្នាក់ងាររបស់ក្រុមហ៊ុនធានារ៉ាប់រង (សហករណ៍ជួយគ្នាទៅវិញទៅមក) ជាដើម

② ហាងលក់រថយន្តឬម៉ូតូ។ល។

③ ចំពោះកង់មានមាស៊ីនរុញ និងម៉ូតូ មាននៅការិយាល័យប្រៃសណីយ៍ (មានការិយាល័យខ្លះមិនទទួលធ្វើទេ) ចំពោះក្រុមហ៊ុនធានារ៉ាប់រង (សហករណ៍ជួយគ្នាទៅវិញទៅមក) ខ្លះគឺតាមអ៊ីនធើណែត ឬផ្សារម៉ាត

* ចំពោះចំណុចមិនច្បាស់អំពីនីតិវិធីនៃការចូល សូមសាកសួរទៅភ្នាក់ងារទទួលបន្ទុកធ្វើដែលនៅក្បែរកន្លែងអ្នកបំផុត។

## (2) ធានារ៉ាប់រងស្ម័គ្រចិត្តលើយានយន្ត (ជួយគ្នាទៅវិញទៅមក)

ទោះបីជាចូលធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត (ជួយគ្នាទៅវិញទៅមក) ក៏ដោយ ករណីគ្រោះថ្នាក់ខូចខាតរបស់ (ក្នុងករណីដែលរថយន្តខូចខាត) ជាដើមគឺមិនមែនជាគោលដៅទទួលបានប្រាក់ធានារ៉ាប់រងឡើយ។

ហេតុដូច្នេះហើយទើបមានធានារ៉ាប់រងស្ម័គ្រចិត្តលើយានយន្ត (ជួយគ្នាទៅវិញទៅមក) សម្រាប់គ្របដណ្តប់ផ្នែកដែលមិនមែនជាគោលដៅផ្តល់ប្រាក់ធានារ៉ាប់រងដោយធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត (ជួយគ្នាទៅវិញទៅមក) ។

ភាពខុសគ្នារវាងធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត (ជួយគ្នាទៅវិញទៅមក) និងធានារ៉ាប់រងស្ម័គ្រចិត្តលើយានយន្ត (ជួយគ្នាទៅវិញទៅមក)

| | ធានារ៉ាប់រងដោយកាតព្វកិច្ចលើយានយន្ត (ជួយគ្នាទៅវិញទៅមក) | ធានារ៉ាប់រងស្ម័គ្រចិត្តលើយានយន្ត (ជួយគ្នាទៅវិញទៅមក) |
|---|---|---|
| វិធីចូល | ចូលដោយកាតព្វកិច្ច | ចូលដោយស្ម័គ្រចិត្ត (ក្រុមហ៊ុនធានារ៉ាប់រងឯកជន (សហករណ៍ជួយគ្នាទៅវិញទៅមក)។ល។) |
| គោលដៅសំណង | • មានតែសំណងលើមនុស្ស | • សំណងលើមនុស្ស<br>• សំណងលើរបស់<br>• របួសខ្លួនប្រាណ<br>• សំណងលើរថយន្ត ។ល។<br>ខុសៗគ្នាទៅតាមកិច្ចសន្យា |
| ទឹកប្រាក់សំណង | មានចំនួនកំណត់ | ចំនួនកំណត់ខុសៗគ្នាតាមកិច្ចសន្យា |

# 4 ដំណោះស្រាយនៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង

## 4-1 បញ្ឈប់ការបើកបរយានជំនិះ

- បញ្ឈប់ការបើកបរយានជំនិះភ្លាម។
- បំលាស់ទីយានជំនិះទៅកន្លែងមានសុវត្ថិភាពដូចជាចិញ្ចើមផ្លូវ ឬដីទំនេរជាដើម កុំអោយរំខានដល់ចរាចរណ៍អ្នកដទៃ។

## 4-2 ការជូនដំណឹងទៅក្រុមសង្គ្រោះបន្ទាន់ និងប៉ូលីសចរាចរណ៍



- ក្នុងករណីដែលមានអ្នករបួស ហៅរថយន្តសង្គ្រោះបន្ទាន់ (លេខទូរស័ព្ទ៖ 119)។
- មុនពេលដែលរថយន្តសង្គ្រោះបន្ទាន់មកដល់ កុំធ្វើចលនាអ្នកមានរបួសលើសពីការចាំបាច់ គឺធ្វើតាមការណែនាំរបស់អ្នកទទួលទូរស័ព្ទ ហើយធ្វើវិធានការសង្គ្រោះតាមដែលអាចធ្វើទៅបានដូចជាឃាត់ឈាមជាដើម។
- ទោះជាមានអ្នករងរបួសឬគ្មានក៏ដោយ ត្រូវជូនដំណឹងទៅប៉ូលីស (លេខទូរស័ព្ទ៖ 110)។
- មុនពេលមន្ត្រីប៉ូលីសមកដល់កន្លែងកើតហេតុ មិនត្រូវចាកចេញពីកន្លែងកើតហេតុឡើយ។
- នៅពេលដែលមន្ត្រីប៉ូលីសមកដល់ រាយការណ៍អំពីស្ថានភាពនៃគ្រោះថ្នាក់ដើម្បីអោយធ្វើការត្រួតពិនិត្យកន្លែងកើតហេតុ។



## 4-3 ការពិនិត្យវិនិច្ឆ័យដោយគ្រូពេទ្យ

- នៅពេលមានគ្រោះថ្នាក់កើតឡើង ទោះជាគិតថាគ្មានរបួស ឬរបួសស្រាលក៏ដោយ អាចនឹងមានករណីដែលថ្ងៃក្រោយទើបដឹងថាមានរបួសធ្ងន់។
- វាជាការល្អដែលត្រូវរួសរាន់អោយគ្រូពេទ្យពិនិត្យ។

ចំពោះសេចក្តីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.npa.go.jp/english/bureau/traffic/index.html

## 4-4 ការស្នើសុំលិខិតបញ្ជាក់គ្រោះថ្នាក់ចរាចរណ៍

- ក្រោយពេលមានគ្រោះថ្នាក់ចរាចរណ៍ គេត្រូវការ "លិខិតបញ្ជាក់គ្រោះថ្នាក់ចរាចរណ៍" ដើម្បីប្រើប្រាស់សម្រាប់ទទួលការគាំទ្រផ្សេងៗ។
- គេអាចទទួលបាន "លិខិតបញ្ជាក់គ្រោះថ្នាក់ចរាចរណ៍" ដោយស្នើសុំទៅមជ្ឈមណ្ឌលសុវត្ថិភាពបើកបរនៃយានយន្ត។ ចំពោះបែបបទនៃការស្នើសុំ សូមធ្វើការសាកសួរទៅការិយាល័យប៉ូលីសដែលបានជូនដំណឹងអំពីគ្រោះថ្នាក់។
- ប៉ុន្តែចំពោះគ្រោះថ្នាក់ដែលមិនបានជូនដំណឹងទៅប៉ូលីសគឺមិនអាចស្នើសុំ "លិខិតបញ្ជាក់គ្រោះថ្នាក់ចរាចរណ៍" បានឡើយ។ ហេតុដូច្នេះនៅពេលមានគ្រោះថ្នាក់ចរាចរណ៍ត្រូវតែជូនដំណឹងទៅប៉ូលីសកុំខាន។

មជ្ឈមណ្ឌលសុវត្ថិភាពបើកបរនៃយានយន្ត
https://www.jsdc.or.jp/center/tabid/106/Default.aspx

ជំពូកទី1 ជំពូកទី2 ជំពូកទី3 ជំពូកទី4 ជំពូកទី5 ជំពូកទី6 ជំពូកទី7 ជំពូកទី8 ជំពូកទី9 ជំពូកទី10 ជំពូកទី11 ជំពូកទី12

ជំពូកទី10

# អាសន្ន និងគ្រោះមហន្តរាយ



## 1 លេខទូរស័ព្ទទំនាក់ទំនងពេលមានអាសន្ន

### 1-1 ជំងឺឬរបួសបន្ទាន់ ឬអគ្គីភ័យ (លេខ 119)

នៅពេលមានជំងឺឬរបួសបន្ទាន់ ឬមានអគ្គីភ័យ សូមទូរស័ព្ទទៅកាន់លេខ 119។

#### នៅពេលមានជំងឺបន្ទាន់ ឬមានរបួស

① នៅពេលទូរស័ព្ទទៅលេខ 119 អ្នកទទួលទូរស័ព្ទនឹងសួរមកថា “អគ្គីភ័យ ឬសង្គ្រោះបន្ទាន់” សូមឆ្លើយថា “សង្គ្រោះបន្ទាន់”។
② សូមប្រាប់កន្លែង ឬតម្រុយដែលចង់អោយរថយន្តសង្គ្រោះបន្ទាន់មក។
③ សូមប្រាប់អំពីអាការៈ និងអាយុរបស់អ្នកជំងឺ។
④ សូមប្រាប់ឈ្មោះនិងអាសយដ្ឋានទំនាក់ទំនងរបស់អ្នក។

នៅគេហទំព័រខាងក្រោមនេះ គេអាចមើលអំពីវិធីហៅរថយន្តសង្គ្រោះបន្ទាន់បាន (ជាពហុភាសា)៖
https://www.fdma.go.jp/publication/portal/post1.html

#### នៅពេលមានអគ្គីភ័យ

① នៅពេលទូរស័ព្ទទៅលេខ 119 អ្នកទទួលទូរស័ព្ទនឹងសួរមកថា “អគ្គីភ័យ ឬសង្គ្រោះបន្ទាន់” សូមឆ្លើយថា “អគ្គីភ័យ”។
② សូមប្រាប់ទីកន្លែងនៃអគ្គីភ័យ។
③ សូមប្រាប់ឈ្មោះនិងអាសយដ្ឋានទំនាក់ទំនងរបស់អ្នក។

# 1-2 គ្រោះថ្នាក់ចរាចរណ៍ ឬការរងគ្រោះពីបទល្មើសផ្សេងៗ (លេខ 110)

- នៅពេលជួបគ្រោះថ្នាក់ចរាចរណ៍ ឬការរងគ្រោះពីបទល្មើស ហើយចង់អោយប៉ូលីសមកភ្លាមៗ សូមទូរស័ព្ទទៅកាន់លេខ110 ដើម្បីរាយការណ៍ទៅប៉ូលីស។
- នៅពេលទូរស័ព្ទទៅលេខ 110 អ្នកទទួលទូរស័ព្ទនឹងសួរសំណួរភាគច្រើនអំពីប្រការខាងក្រោម ដូច្នេះ សូមកុំភ័យ ហើយព្យាយាមឆ្លើយអោយបានសុក្រឹតបំផុត៖

① ពេលណា នៅទីណា មានអ្វីកើតឡើង
② ឈ្មោះនិងអាសយដ្ឋានទំនាក់ទំនងរបស់អ្នកជាដើម
③ ភេទ ចំនួនមនុស្ស អាយុ សំលៀកបំពាក់នៃគូភាគីគ្រោះថ្នាក់ ឬជនល្មើសជាដើម
④ តើមានអ្នករងរបួសឬទេ

- ក្នុងករណីដែលមិនអាចទូរស័ព្ទដោយខ្លួនឯងបានទេ សូមរកជំនួយពីអ្នកនៅក្បែរ។





## ចំណុចគួរដឹង៖ ហៅបន្ទាន់ពីទូរស័ព្ទសាធារណៈ

អាចប្រើទូរស័ព្ទសាធារណៈដើម្បីធ្វើការហៅបន្ទាន់ទៅកាន់លេខ 110 (ប៉ូលីស), 118 (ឆ្មាំឆ្នេរសមុទ្រ) និង 119 (នាយកដ្ឋានពន្លត់អគ្គីភ័យ)។ មិនចាំបាច់មានកាក់ ឬកាតទូរស័ព្ទទេ។

- សព្ទសាធារណៈដែលមានប៊ូតុងហៅបន្ទាន់ (ប៊ូតុងក្រហម)
  លើកទូរស័ព្ទហើយចុចប៊ូតុងហៅបន្ទាន់ ហើយចុច110
- Pទូរស័ព្ទសាធារណៈដែរគ្មានប៊ូតុងហៅអាសន្ន
  លើកទូរស័ព្ទហើយចុចតេទៅ110 ដោយផ្ទាល់

◆ទូរសព្ទសាធារណៈដែលមានប៊ូតុងហៅទូរសព្ទបន្ទាន់




◆ទូរស័ព្ទសាធារណៈដោយគ្មានប៊ូតុងហៅទូរសព្ទបន្ទាន់



# 2 គ្រោះមហន្តរាយ



## 2-1 ព្យុះ ឬភ្លៀងធ្លាក់ខ្លាំង

- នៅពេលផ្លាស់ប្តូររដូវ ខ្សែព្រំដែននៃខ្យល់ក្តៅមកពីទិសខាងត្បូង និងខ្យល់ត្រជាក់មកពីទិសខាងជើង (ខ្សែមុខ) ស្ថិតនៅទ្រឹងរយៈពេលយូរក្នុងអាកាសពីលើប្រទេសជប៉ុន ដែលធ្វើអោយមានភ្លៀងធ្លាក់ខ្លាំងជាញឹកញាប់។
- នៅពេលដែលព្យុះឬសំពាធទាបដែលមានខ្សែមុខឆ្លងកាត់ក្បែរប្រទេសជប៉ុន ធ្វើអោយមានភ្លៀងធ្លាក់ខ្លាំងនៅច្រើនកន្លែង។
- ដោយសារទ្រង់ទ្រាយដីជាដើម ធ្វើអោយមានមានចរន្តខ្យល់ឡើងលើខ្លាំង បង្កើតទៅជាពពកច្រើន (បណ្តុំពពក) កើតឡើងនៅកន្លែងតែមួយ ធ្វើអោយមានបាតុភូតភ្លៀងធ្លាក់ខ្លាំងរយៈពេលយូរ (ភ្លៀងធ្លាក់ខ្លាំង) កើតឡើង។
- នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំងបែបនេះ ធ្វើអោយមានគ្រោះបាក់ដីឬគ្រោះទឹកជំនន់ នាំអោយមានមហន្តរាយធ្ងន់ធ្ងរ ដូច្នេះគេត្រូវប្រុងប្រយ័ត្ន។

### (1) ទឹកជន់ពីទន្លេ

- នៅពេលភ្លៀងធ្លាក់ខ្លាំងជាដើម ធ្វើអោយទឹកហូរហៀរចេញពីទន្លេ ហើយនៅពេលមានទឹកជំនន់ វាអាចធ្វើអោយអោយលិចលង់ផ្ទះសំបែង ឬទឹកហូរនាំយកមនុស្សទៅជាមួយ។
- ដើម្បីការពារជីវិតពីទឹកជំនន់ សូមធ្វើសកម្មភាពខាងក្រោម។

#### ធ្វើការត្រៀមទុកជាមុន

សំខាន់គឺ ត្រូវប្រើផែនទីគ្រោះថ្នាក់ ជាអាទិ៍ ជាប្រចាំ  ដើម្បីបញ្ជាក់ជាមុននូវកន្លែងដែលអាចនឹងលេចទឹក កន្លែងភៀសខ្លួន ផ្លូវដែលមានសុវត្ថិភាពពីផ្ទះលោកអ្នកទៅកន្លែងភៀសខ្លួនជាមុន ជាការល្អ។

ចំណុចគួរដឹង៖

**ផែនទីគ្រោះថ្នាក់**




គឺជាផែនទីគូសបង្ហាញទីកន្លែងដែលមានហានិភ័យគ្រោះថ្នាក់កើតឡើង។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

https://disaportal.gsi.go.jp/

### នៅពេលមានភ្លៀងធ្លាក់ខ្លាំង

① ដោយផ្អែកលើព័ត៌មានស្តីពីគ្រោះមហន្តរាយ និងឧត្តុនិយម ជាអាទិ៍ របស់នាយកដ្ឋានឧត្តុនិយមជប៉ុនជាដើម នៅពេលដែលអ្នកគិតថាមានគ្រោះថ្នាក់សូមគិតដោយខ្លួនឯងហើយធ្វើការភៀសខ្លួន។
② ក្នុងករណីដែលមានព័ត៌មានអោយភៀសខ្លួនចេញ ដោយភូមិឃុំស្រុក សូមធ្វើការភៀសខ្លួនពីកន្លែងដែលមានគ្រោះថ្នាក់ ទៅកន្លែងមានសុវត្ថិភាព។
③ ចំពោះវិធីភៀសខ្លួន សូមពិនិត្យត្រង់ "3 ការភៀសខ្លួន"។

## (2) គ្រោះបាក់ដី

គ្រោះបាក់ដីកើតឡើងនៅពេលដែលជម្រាលភ្នំ ឬច្រាំងថ្មដួលរលំដោយសារភ្លៀងធ្លាក់ខ្លាំង ឬការរញ្ជួយដី ឬនៅពេលដែលដី ថ្ម និងដើមឈើត្រូវបានទឹកនាំទៅឆ្ងាយពីតំបន់ទន្លេក្នុងអំឡុងពេលទឹកជំនន់។ គ្រោះមហន្តរាយបែបនេះអាចបំផ្លាញ ឬកប់អគារ ឬបិទផ្លូវ។

ដើម្បីការពារជីវិតពីគ្រោះបាក់ដី សូមធ្វើសកម្មភាពខាងក្រោម។

### ធ្វើការត្រៀមទុកជាមុន

សំខាន់គឺ ត្រូវប្រើផែនទីគ្រោះថ្នាក់ ជាអាទិ៍ ជាប្រចាំ ដើម្បីបញ្ជាក់ជាមុននូវកន្លែងដែលអាចនឹងមានគ្រោះបាក់ដី ឬកន្លែងភៀសខ្លួន ផ្លូវដែលមានសុវត្ថិភាពពីផ្ទះលោកអ្នកទៅកន្លែងភៀសខ្លួនជាមុន ជាការល្អ។

### នៅពេលមានភ្លៀងធ្លាក់ខ្លាំង

① ដោយផ្អែកលើព័ត៌មានស្តីពីគ្រោះមហន្តរាយ និងឧត្តុនិយម ជាអាទិ៍ របស់នាយកដ្ឋានឧត្តុនិយមជប៉ុនជាដើម នៅពេលដែលអ្នកគិតថាមានគ្រោះថ្នាក់សូមគិតដោយខ្លួនឯងហើយធ្វើការភៀសខ្លួន។
② ក្នុងករណីដែលមានព័ត៌មានអោយភៀសខ្លួនចេញដោយភូមិឃុំស្រុក សូមធ្វើការភៀសខ្លួនពីកន្លែងដែលមានគ្រោះថ្នាក់ទៅកន្លែងមានសុវត្ថិភាព។
③ ចំពោះវិធីភៀសខ្លួន សូមពិនិត្យត្រង់ "3 ភៀសខ្លួន"។

# 2-2 គ្រោះរញ្ជួយដី

- ប្រទេសជប៉ុនស្ថិតនៅតាមបណ្តោយអ្វីដែលហៅថា Ring of Fire ឬខ្សែក្រវាត់ Circum-Pacific Belt ហើយចាន tectonic ជាច្រើនបានប៉ះទង្គិច និងបុកគ្នា លក្ខណៈពិសេសនេះធ្វើអោយក្លាយទៅជាតំបន់ដែលមានគ្រោះរញ្ជួយដីច្រើនជាងគេបំផុតមួយលើសកលលោក។
- នៅពេលដែលគ្រោះរញ្ជួយដីកើតឡើង ដំបូងត្រូវការពារជីវិតខ្លួនឯង និងសហការជាមួយមនុស្សក្នុងសហគមន៍ដើម្បីការពារជីវិត ទាំងនេះគឺមានសារៈសំខាន់ណាស់។
- ដើម្បីការពារជីវិតពីគ្រោះរញ្ជួយដី ត្រូវធ្វើសកម្មភាពខាងក្រោមជាប្រចាំ។



## ធ្វើការត្រៀមទុកជាមុន

① ពិគ្រោះជាមួយគ្រួសារអំពីកន្លែងត្រូវភៀសខ្លួនទៅក្នុងករណីដែលមានគ្រោះរញ្ជួយដីកើតឡើង។

② ចូលរួមក្នុងការហ្វឹកហាត់ការពារគ្រោះមហន្តរាយរបស់សហគមន៍ និងយល់អំពីសកម្មភាពរបស់សហគមន៍។

③ រៀបចំទុកនូវម្ហូបអាហារនិងទឹកបរិភោគសម្រាប់យ៉ាងហោច 3ថ្ងៃនិងសម្ភារៈដែលអាចប្រើប្រាស់បាននៅពេលមានរបួសជាដើម។

④ ភ្ជាប់គ្រឿងសង្ហារឹមអោយជាប់កុំអោយដួលរលំបាន។ កន្លែងដាក់ក៏ត្រូវលៃយ៉ាងណាកុំអោយប៉ះពាល់ ទោះជាដួលរលំក៏ដោយ។

ចំណុចគួរដឹង៖

### កម្រិតអានុភាព (Magnitude) និងកម្រិតរំញ័រ

- កម្រិតអានុភាព បង្ហាញជាលេខនូវទំហំនៃរញ្ជួយដី។ នៅពេលដែលតំលៃនៃកម្រិតអានុភាពកើនឡើង1 ថាមពលមានប្រហែល 32 ដង។
- កម្រិតរំញ័រ បង្ហាញពីភាពខ្លាំងនៃរំញ័រនៅកន្លែងនោះដោយសាររញ្ជួយដី។ នាយកដ្ឋានឧត្តុនិយមជប៉ុនធ្វើការចំណាត់ថ្នាក់អំពីកម្រិតរំញ័រជា 10 កម្រិត (0, 1, 2, 3, 4, 5ស្រាល, 5ខ្លាំង, 6ស្រាល, 6ខ្លាំង, 7)។
- ព័ត៌មានទាំងអស់នេះ អាចទទួលបានតាមទូរទស្សន៍ វិទ្យុ អ៊ីនធើណែត ។ល។

## នៅពេលគ្រោះរញ្ជួយដីកើតឡើង

នៅពេលគ្រោះរញ្ជួយដីកើតឡើង សូមកុំធ្វើសកម្មភាពដោយភាពស្លន់ស្លោ។ ចំពោះសកម្មភាពដែលត្រូវធ្វើគឺខុសគ្នាទៅតាមកន្លែងដែលអ្នកនៅ នៅពេលដែលរញ្ជួយដីកើតឡើង សូមប្រុងប្រយ័ត្ននូវចំណុចខាងក្រោមៈ

① មិនភ័យស្លន់ស្លោ

- ក្នុងករណីនៅក្នុងផ្ទះ ឬក្នុងអគារ
  លាក់ខ្លួននៅក្នុងតុរឹងមាំជាដើម ដើម្បីការពារកុំអោយធ្លាក់របស់លើក្បាលដោយសាររំញ័រ ហើយរង់ចាំរហូតដល់បាត់រំញ័រ។
- ក្នុងករណីនៅខាងក្រៅ
  ប្រសិនបើនៅជិតអគារ គឺមានហានិភ័យដែលធ្លាកយីហោ ជញ្ជាំងឬកញ្ចក់បង្អួចធ្លាក់មកលើ ដូច្នេះសូមការពារក្បាលរបស់អ្នកដោយកាបូបជាដើម ហើយភៀសខ្លួនទៅរកកន្លែងមានសុវត្ថិភាព។
- ក្នុងករណីកំពុងជិះនៅក្នុងយានយន្ត
  នៅពេលអ្នកចាប់អារម្មណ៍ថាមានរំញ័រ សូមកុំស្លន់ស្លោ ហើយពន្លត់ម៉ាស៊ីនបញ្ឈប់យានយន្តនៅផ្នែកខាងឆ្វេងនៃផ្លូវ។ ចុះពីយានយន្តហើយដើរទៅរកកន្លែងមានសុវត្ថិភាព ប៉ុន្តែមិនបាច់ដកសោចេញពីយានយន្តឡើយ។

② ការពន្លត់ភ្លើង

នៅពេលដែលមានគ្រោះរញ្ជួយដី ហើយធ្វើអោយមានអគ្គីភ័យ នាំអោយការខូចខាតកាន់តែធ្ងន់ធ្ងរ។

- នៅពេលដែលបាត់រំញ័រ ត្រូវពន្លត់ភ្លើងនៅចង្ក្រានបាយ និងចង្ក្រានកំដៅ។
- ក្នុងករណីដែលមានភ្លើងឆាបឆេះ ត្រូវពន្លត់ភ្លើងដោយបំពង់ពន្លត់អគ្គីភ័យជាដើមអោយអស់លទ្ធភាព។
- អាចមានករណីលេចហ្គាសចេញក្រោយពេលមានរញ្ជួយដីកើតឡើង សូមកុំបញ្ឆេះភ្លើង។

③ ភៀសខ្លួនទៅកន្លែងមានសុវត្ថិភាព

ដោយសារការរញ្ជួយដី ធ្វើអោយមានហានិភ័យរលំអគារ ឬអគ្គីភ័យជាដើម។

- នៅក្បែរភ្នំជាដើម អាចនឹងមានការបាក់ដី នៅពេលដែលបាត់រំញ័រ សូមប្រញាប់ភៀសខ្លួនទៅកន្លែងមានសុវត្ថិភាពដែលកំណត់ដោយភូមិឃុំស្រុកដែលអ្នករស់នៅ។
- បិទទម្លាក់ឌីសង់ទ័រ មុនពេលជម្លៀសចេញ ដើម្បីការពារអគ្គីភ័យដែលអាចកើតឡើងនៅពេលដែលថាមពលត្រូវបានស្តារឡើងវិញបន្ទាប់ពីការរញ្ជួយដី

④ ការសហការ និងការជួយគ្នារវាងអ្នកជិតខាង

នៅពេលមានគ្រោះអាសន្នកើតឡើង ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាងគឺមានសារៈសំខាន់ណាស់។

- ជាពិសេសត្រូវសហការសាកសួរ និងជួយដល់ចាស់ជរាដែលរស់នៅម្នាក់ឯង និងជនពិការជាដើម។

⑤ ទទួលយកព័ត៌មានច្បាស់លាស់

ក្រោយពេលមានគ្រោះរញ្ជួយដីធំ មានព័ត៌មានផ្សេងៗលេចចេញ។

- សូមប្រមូលយកព័ត៌មានថ្មីបំផុតនិងច្បាស់លាស់ តាមរយៈទូរទស្សន៍ វិទ្យុ ទូរស័ព្ទដៃ វិទ្យុរបស់រដ្ឋបាលការការពារគ្រោះមហន្តរាយជាដើម ហើយធ្វើសកម្មភាពដោយពុំមានភាពស្លន់ស្លោ។

ចំណុចគួរដឹង៖

### ព័ត៌មានបន្ទាន់អំពីគ្រោះរញ្ជួយដី (ប្រកាសព្រមាន)

- ទីភ្នាក់ងារឧតុនិយមជប៉ុន ចេញការព្រមានជាមុនអំពីការរញ្ជួយដី នៅពេលដែលមានការរញ្ជួយខ្លាំងត្រូវបានគេរំពឹងទុក។
- ព័ត៌មានបន្ទាន់អំពីគ្រោះរញ្ជួយដីមានផ្សាយតាមទូរទស្សន៍ វិទ្យុ ទូរស័ព្ទចល័ត វិទ្យុរបស់រដ្ឋបាលការពារគ្រោះមហន្តរាយជាដើម។

វីដេអូស្តីអំពីគ្រោះរញ្ជួយដី និងព័ត៌មានបន្ទាន់អំពីគ្រោះរញ្ជួយដី (ភាសាអង់គ្លេស ចិន កូរ៉េ ជប៉ុន)
https://www.jma.go.jp/jma/kishou/books/sokuho_dvd/index.html

**ពេលស្តាប់ឬមើលព័ត៌មានបន្ទាន់ស្តីពីការរញ្ជួយដី សូមកុំស្លន់ស្លោ ហើយគិតអំពីសុវត្ថិភាពជាមុន។**

## 2-3 គ្រោះរលកស៊ីណាមិ



- នៅពេលដែលមានរញ្ជួយដីធំនៅបាតសមុទ្រ ធ្វើអោយបាតសមុទ្រប៉ោងឡើងឬធ្លាក់ចុះ។ បាតុភូតនេះធ្វើអោយផ្ទៃទឹកសមុទ្រមានការប្រែប្រួល ក្លាយជារលកដ៏ធំរាលដាលគ្រប់ទិសទី នេះហើយគឺជារលកស៊ីណាមិ។
- មានពាក្យចចាមអារាមថា “ទឹកសមុទ្រដាច់ខាតត្រូវនាចនៅមុនពេលមានរលកស៊ីណាមិ” នេះមិនមែនត្រឹមត្រូវទាំងស្រុងឡើយ។

### ធ្វើការត្រៀមទុកជាមុន

ដើម្បីការពារខ្លួនពីគ្រោះរលកស៊ីណាមិ សូមប្រើប្រាស់ផែនទីគ្រោះថ្នាក់ជាដើម ដើម្បីពិនិត្យមើលកន្លែងភៀសខ្លួន និងត្រួតពិនិត្យផ្លូវសុវត្ថិភាពពីផ្ទះរបស់ខ្លួនជាដើមទៅកន្លែងភៀសខ្លួន។

### នៅពេលរលកស៊ីណាមិកើត (បានកើត)ឡើង

បើគេរង់ចាំរហូតដល់រលកស៊ីណាមិមកដល់ច្រាំងទើបចាប់ផ្តើមភៀសខ្លួននោះគឺមិនទាន់ពេលឡើយ។ សូមភៀសខ្លួនដោយប្រុងប្រយ័ត្ននូវចំណុចខាងក្រោម៖

- នៅពេលទទួលអារម្មណ៍ថាមានរំញ័រខ្លាំងនៅក្បែរមាត់សមុទ្រឬមាត់ទន្លេ ទោះជារំញ័រខ្សោយក៏ដោយ នៅពេលទទួលអារម្មណ៍ថាមានរញ្ជួយដីយឺតៗរយៈពេលយូរ សូមប្រញាប់ចាកចេញពីមាត់សមុទ្រឬមាត់ទន្លេ ហើយភៀសខ្លួនទៅកន្លែងខ្ពស់ដូចជាទីទួលខ្ពស់ ឬអគារភៀសខ្លួនជាដើម។
- ទោះបីជាមិនទទួលអារម្មណ៍ថាមានរញ្ជួយដីក៏ដោយ នៅពេលដែលមានការប្រកាសព្រមាន អំពីស៊ីណាមិដោយនាយកដ្ឋានឧតុនិយមជប៉ុន ឬពេលដែលមានការបង្គាប់ឱ្យរត់ភៀសខ្លួនពីភូមិឃុំស្រុក សូមប្រញាប់ចាកចេញពីមាត់សមុទ្រឬមាត់ទន្លេ ហើយភៀសខ្លួនទៅកន្លែងខ្ពស់ដូចជាទីទួលខ្ពស់ ឬអគារភៀសខ្លួនជាដើម។
- សូមប្រមូលយកព័ត៌មានច្បាស់លាស់ តាមរយៈទូរទស្សន៍ វិទ្យុ ទូរស័ព្ទចល័ត វិទ្យុរបស់រដ្ឋបាលការពារគ្រោះមហន្តរាយ ឬគេហទំព័រជាភាសាអង់គ្លេសរបស់នាយកដ្ឋានឧតុនិយម Safety tips ។ល។
- រលកស៊ីណាមិធ្វើការវាយលុកម្តងហើយម្តងទៀត ដូច្នេះហើយ សូមកុំទៅជិតមាត់សមុទ្រឬមាត់ទន្លេ មុនពេលដែលការប្រកាសព្រមាន ឬអោយប្រុងប្រយ័ត្នត្រូវបានដកចេញ។

ចំណុចគួរដឹង៖

## ស្ដីពីទង់រលកស៊ុណាមិ



- ពីខែមិថុនា ឆ្នាំ2020 ទៅ នៅតាមឆ្នេរសមុទ្រសម្រាប់ងូតទឹក ជាដើម គេបានចាប់ផ្ដើមប្រើ “ទង់រលកស៊ុណាមិ” ដែលមានក្រឡាពណ៌ក្រហមនិងស សម្រាប់ប្រកាសអាសន្នអំពីរលកយក្សស៊ុណាមិ ឬរលកស៊ុណាមិ ឬប្រកាសឱ្យប្រយ័ត្នរលកស៊ុណាមិ តាមរយៈការមើលនឹងភ្នែក។
- តាមរយៈការប្រើ “ទង់រលកស៊ុណាមិ” នេះ អ្នកពិការត្រចៀក ឬអ្នកកំពុងហែលទឹកហើយថ្លង់សម្លេងរលក ស្ដាប់មិនឮ ព្រមទាំងជនបរទេសក៏អាចដឹងអំពីការប្រកាសអាសន្នដែរ។

ស្ដីពី “ទង់រលកស៊ុណាមិ” (មានតែជាភាសាជប៉ុនប៉ុណ្ណោះ)
https://www.data.jma.go.jp/svd/eqev/data/tsunami_bosai/tsunami_bosai_p2.html

ស្ដីពី “ទង់រលកស៊ុណាមិ” (ភាសាអង់គ្លេស)
https://www.data.jma.go.jp/eqev/data/en/tsunami/tsunami_flag.html

## 2-4 គ្រោះផ្ទុះភ្នំភ្លើង

- នៅប្រទេសជប៉ុនមានភ្នំភ្លើងរស់ 111។
- នៅពេលដែលភ្នំភ្លើងផ្ទុះ អាចបង្កគ្រោះមហន្តរាយធ្ងន់ធ្ងររហូតដល់ជីវិត។
- ដើម្បីការពារជីវិតអ្នកពីគ្រោះផ្ទុះភ្នំភ្លើង អ្នកត្រូវធ្វើសកម្មភាពដូចខាងក្រោម។

### ធ្វើការត្រៀមទុកជាមុន



- ពិនិត្យជាមុននូវតំបន់ដែលអាចរងផលប៉ះពាល់ដោយសកម្មភាពភ្នំភ្លើង ដោយប្រើផែនទីគ្រោះថ្នាក់ និងប្រភពព័ត៌មានផ្សេងទៀត។
- នៅពេលឡើងភ្នំ ធ្វើការរៀបចំដូចខាងក្រោម៖

① បញ្ជាក់មើលព័ត៌មានប្រកាសដោយនាយកដ្ឋានឧត្តុនិយមជប៉ុន អំពីភ្នំភ្លើង ដូចជា ការប្រកាសអំពីការផ្ទុះភ្នំភ្លើង ឬកម្រិតប្រយ័ត្នទៅលើការផ្ទុះ និងផែនទីគ្រោះថ្នាក់ដែលបង្កើតឡើងដោយភូមិឃុំស្រុក ជាដើម។
② ដាក់ពាក្យជូនដំណឹងអំពីការឡើងភ្នំ។
③ រៀបចំឧបករណ៍ទំនាក់ទំនង និងម្ហូបសុវត្ថិភាព។

ចំណុចគួរដឹង៖

## កម្រិតប្រយ័ត្នទៅលើការផ្ទុះ

- គឺជាព័ត៌មានដែលគេផ្សាយឱ្យដឹងភ្លាមៗអំពី "តំបន់ចាំបាច់ត្រូវប្រយ័ត្ន" និង "សកម្មភាពដែលត្រូវធ្វើ" ទៅតាមស្ថានភាពនៃ សកម្មភាពរបស់ភ្នំភ្លើង។
- ក្នុងចំណោមភ្នំភ្លើងរស់ទាំងអស់ដែលមាននៅប្រទេសជប៉ុន គេអនុវត្តចំពោះភ្នំភ្លើង 49 ។
- កម្រិតប្រយ័ត្នទៅលើការផ្ទុះ មានទាំងអស់ 5កម្រិត។

| | |
|---|---|
| កម្រិតទី 5 .......... | ភៀសខ្លួន (ភៀសខ្លួនពីតំបន់លំនៅដ្ឋានដែលមានគ្រោះថ្នាក់ជាដើមគឺចាំបាច់) |
| កម្រិតទី 4 .......... | មនុស្សចាស់ ជាដើម ត្រូវភៀសខ្លួន (វាចាំបាច់ក្នុងការជម្លៀសប្រជាជនដែលត្រូវការការថែទាំពិសេស ដូចជាមនុស្សចាស់ នៅតាមតំបន់លំនៅដ្ឋាន ដែលតម្រូវឱ្យមានការប្រុងប្រយ័ត្ន និងរៀបចំសម្រាប់ការជម្លៀសប្រជាជនជាដើម។) |
| កម្រិតទី 3 .......... | ហាមមិនឱ្យឡើងភ្នំ (អាស្រ័យលើស្ថានភាព រៀបចំសម្រាប់ការជម្លៀសមនុស្សដែលត្រូវការការថែទាំពិសេស ដូចជាមនុស្សចាស់ជាដើម។ ការហាមឃាត់ការឡើងភ្នំ ការរឹតត្បិតការឡើងភ្នំជាដើម ហាមមិនឱ្យចូលតំបន់គ្រោះថ្នាក់ ជាដើម) |
| កម្រិតទី 2 .......... | ហាមនៅជុំវិញមាត់ភ្នំភ្លើង (ហាមមិនឱ្យចូលទៅជុំវិញមាត់ភ្នំភ្លើង ជាដើម) |
| កម្រិតទី 1 .......... | ប្រយ័ត្នភ្នំភ្លើងនៅរស់ (មិនមានវិធានការអ្វីពិសេសទេ) |

ស្តីពីការប្រកាសការផ្ទុះភ្នំភ្លើង-កម្រិតប្រយ័ត្នទៅលើការផ្ទុះ (ភាសាអង់គ្លេស)
https://www.data.jma.go.jp/vois/data/tokyo/STOCK/kaisetsu/English/level.html

## នៅពេលគ្រោះផ្ទុះភ្នំភ្លើងកើត (បានកើត)ឡើង

- យោងលើព័ត៌មានបន្ទាន់អំពីគ្រោះផ្ទុះភ្នំភ្លើងផ្សាយចេញដោយនាយកដ្ឋានឧត្តុនិយមជប៉ុន ផ្អែកលើការព្រមានអំពីការផ្ទុះភ្នំភ្លើង ឬកម្រិតនៃការប្រុងប្រយ័ត្នលើការផ្ទុះភ្នំភ្លើង ក្នុងករណីចាំបាច់ សូមគិតដោយខ្លួនឯងហើយធ្វើការភៀសខ្លួន។
- ក្នុងករណីដែលមានការបង្គាប់អោយភៀសខ្លួនចេញដោយភូមិឃុំស្រុក សូមធ្វើការភៀសខ្លួនទៅកន្លែងមានសុវត្ថិភាព។
- ក្នុងករណីដែលកំពុងឡើងភ្នំហើយទទួលបានព័ត៌មានដូចខាងលើ ឬមានភ្នំភ្លើងផ្ទុះ សូមធ្វើសកម្មភាពដូចខាងក្រោមដើម្បីការពារខ្លួនអ្នកពីថ្មភ្នំភ្លើង និងកំទេចកំទីផ្សេងៗ៖

① ប្រញាប់ចាកចេញពីមាត់ភ្នំភ្លើង។
② ជម្លៀសខ្លួនចូលក្នុង ទៅកាន់ខ្ទមលើភ្នំឬកន្លែងជ្រកឬនៅពីក្រោយដុំថ្មជាដើម។
③ ការពារក្បាលរបស់អ្នកដោយពាក់មួកសុវត្ថិភាពដើម្បីការពារក្បាលឬឧបករណ៍ការពារផ្សេងទៀត.។

# 3 ការភៀសខ្លួន

## 3-1 កន្លែងភៀសខ្លួន

កន្លែងភៀសខ្លួនគឺជាកន្លែងឬអគារសម្រាប់គេចខ្លួនមួយរយៈ ដើម្បីការពារខ្លួនពីគ្រោះថ្នាក់។

### នៅពេលគ្រោះថ្នាក់កើត (បានកើត)ឡើង

- ភៀសខ្លួនពីកន្លែងដែលមានគ្រោះថ្នាក់ ទៅកន្លែងមានសុវត្ថិភាពជាប្រញាប់ ដោយផ្អែកលើព័ត៌មានស្តីពីការភៀសខ្លួន ជាដើម។
- ពិនិត្យមើលអំពីកន្លែងភៀសខ្លួននៃសហគមន៍ដែលអ្នករស់នៅទុកជាមុន។
- គេអាចពិនិត្យមើលអំពីកន្លែងភៀសខ្លួនតាមផែនទីគ្រោះថ្នាក់ ឬតាមគេហទំព័ររបស់ភូមិឃុំស្រុកនីមួយៗ ជាដើម។
- ក្នុងករណីដែលទឹកជំនន់បានកើតឡើង ហើយគិតឃើញថា ការភៀសខ្លួនទៅ កន្លែងភៀសខ្លួន វាមានគ្រោះថ្នាក់ទៅវិញ សូមភៀសខ្លួនទៅកន្លែងដែលមានសុវត្ថិភាពផ្សេងវិញ (ភៀសខ្លួនទៅអគាររឹងមាំ (ល្អ) នៅក្បែរនោះ ក្នុងករណីបែបនេះក៏ពិបាកធ្វើការភៀសខ្លួន អ្នកត្រូវភៀសខ្លួនទៅកន្លែងសុវត្ថិភាពដូចជាជាន់ទី2ឡើងទៅនៅផ្ទះ)ជាដើម ដើម្បីការពារជីវិត។

## 3-2 ព័ត៌មានសម្រាប់ការភៀសខ្លួន

ព័ត៌មានសម្រាប់ការភៀសខ្លួនគឺជាព័ត៌មានផ្សាយចេញដើម្បីប្រាប់អោយភៀសខ្លួននៅពេលមានគ្រោះថ្នាក់នឹងកើត (បានកើត)ឡើង។

### ការប្រយ័ត្នកម្រិតទី 3 មនុស្សចាស់ត្រូវភៀសខ្លួន

- ព័ត៌មានបែបណា?
  ជាព័ត៌មានប្រាប់អោយមនុស្សចាស់ឬកុមារជាដើម ដែលត្រូវការពេលវេលាដើម្បីភៀសខ្លួន អោយធ្វើការភៀសខ្លួន ដោយសារតែអាចទទួលរងគ្រោះដោយសារគ្រោះមហន្តរាយ។
- នៅពេលព័ត៌មាននេះចេញមក
  មនុស្សខាងក្រោមចាប់ផ្តើមភៀសខ្លួនពីកន្លែងគ្រោះថ្នាក់៖

① មនុស្សចាស់
② មនុស្សពិការ
③ កុមារ
④ ក្រៅពីនេះ អ្នកដែលមានការពិបាកនឹងភៀសខ្លួនដោយខ្លួនឯង ឬអ្នកដែលត្រូវការពេលវេលាដើម្បីភៀសខ្លួនផ្សេងទៀត (ស្ត្រីមានផ្ទៃពោះជាដើម)
⑤ អ្នកអមដំណើរមនុស្ស ① ដល់ ④
⑥ អ្នកដែលទទួលអារម្មណ៍ថាមានគ្រោះថ្នាក់

អ្នកផ្សេងទៀតក៏ត្រូវបង្អាកសកម្មភាពដែលធ្វើធម្មតា ឬចាប់ផ្តើមរៀបចំដើម្បីភៀសខ្លួន ទៅតាមការចាំបាច់។

## ការប្រយ័ត្ន កម្រិតទី 4 ការបង្គាប់ឱ្យភៀសខ្លួន

- ការណែនាំបែបណា?

  ជាព័ត៌មានដែលចេញមកនៅពេលដែលហានិភ័យនៃការខូចខាតដោយសារគ្រោះមហន្តរាយកើនឡើង។
- នៅពេលព័ត៌មាននេះចេញមក

  ទាំងអស់គ្នាត្រូវភៀសខ្លួនពីកន្លែងដែលគ្រោះថ្នាក់ ទៅកន្លែងដែលមានសុវត្ថិភាពខាងក្រោមនេះ៖

① កន្លែងភៀសខ្លួន

② កន្លែងមានសុវត្ថិភាពផ្សេងទៀត (ផ្ទះញាតិមិត្ត, សណ្ឋាគារ, ផ្ទះសំណាក់ ជាដើមដែលមានសុវត្ថិភាព )

ម្យ៉ាងទៀត ពេលបញ្ជាក់មើលផែនទីគ្រោះថ្នាក់ ហើយអាចវិនិច្ឆ័យថា ខ្លួនស្របនឹងលក្ខខណ្ឌ3ខាងក្រោមនេះ អាចនៅក្នុងផ្ទះដើម្បីរក្សាសុវត្ថិភាពក៏បានដែរ។

① មិនស្ថិតនៅក្នុងតំបន់ដែលផ្ទះអាចបែកបាក់ ឬរលំដោយសារទឹកជំនន់ (តំបន់ចាត់ទុកថា ផ្ទះអាចបែកបាក់ ឬរលំ ជាអាទិ៍ ដោយសារទឹកជំនន់)

② រស់នៅក្នុងអគារខ្ពស់ៗដែលទឹកជន់មិនដល់

③ មានត្រៀមនូវទឹក និងចំណីអាហារជាដើម គ្រប់គ្រាន់ដែលអាចទ្រាំរហូតដល់ទឹកស្រកវិញ

## ការប្រយ័ត្នកម្រិតទី 5 ត្រូវរកកន្លែងមានសុវត្ថិភាពជាបន្ទាន់

- វិធានការបែបណា?

  ជាព័ត៌មានដែលចេញមកនៅពេលដែលគ្រោះមហន្តរាយបានកើតមានឡើងហើយ ឬស្ថានការណ៍កាន់តែធ្ងន់ធ្ងរ ហើយការខូចខាតអាចនឹងកើតឡើងគ្រប់ពេលវេលា។
- នៅពេលព័ត៌មាននេះចេញមក

  ពេលភៀសខ្លួន ដោយសារតែអាចមានគ្រោះថ្នាក់ដល់ជីវិត ត្រូវរក្សាសុវត្ថិភាពជាចំបង។ បើសិនជាគិតឃើញថា ពេលរត់ទៅកន្លែងភៀសខ្លួន អាចមានគ្រោះថ្នាក់ទៅវិញ សូមធ្វើសកម្មភាពដូចតទៅជាបន្ទាន់។

① ភៀសខ្លួនទៅអគារខ្ពស់ៗហើយមាំដែលនៅជិត

② ភៀសខ្លួនទៅផ្ទះដែលមាន 2ជាន់ឡើងទៅ ដែលមានសុវត្ថិភាពជាងជាដើម



ចំណុចគួរដឹង៖

### ព័ត៌មានភៀសខ្លួនដោយប្រើ “កម្រិតប្រុងប្រយ័ត្ន”

~តើអ្វីជាកម្រិតប្រុងប្រយ័ត្ន?~

- គឺជាព័ត៌មានដែលប្រកាសចេញមកអោយអាចដឹងភ្លាមៗថាត្រូវធ្វើសកម្មភាពអ្វី ក្នុងករណីគ្រោះមហន្តរាយដោយទឹកក្រៅពីរលកស៊ុណាមិ ឬនៅពេលមានគ្រោះបាក់ដីបម្រុងនឹងកើតឡើង។
- ចាប់ពីឆ្នាំ2019 តទៅ ត្រូវបានផ្សាយចេញជាមួយព័ត៌មានភៀសខ្លួន និងព័ត៌មានឧត្តុនិយមការពារមហន្តរាយ។
- កម្រិតប្រុងប្រយ័ត្នមាន 5កម្រិតដូចខាងក្រោម៖

| | |
|---|---|
| កម្រិតប្រុងប្រយ័ត្នទី1....... | បង្កើនការត្រៀមរៀបចំខ្លួនទប់ស្កាត់គ្រោះមហន្តរាយ (ស្វែងរកព័ត៌មានអំពីភ្លៀងឬទឹកទន្លេនៅក្នុងទូរទស្សន៍ឬអ៊ីនធើណែត) |
| កម្រិតប្រុងប្រយ័ត្នទី2....... | បញ្ជាក់អំពីសកម្មភាពភៀសខ្លួនដើម្បីត្រៀមភៀសខ្លួន (ស្រាវជ្រាវមើលថាតើកន្លែងដែលរស់នៅនោះមានគ្រោះថ្នាក់ឬទេ បើមានត្រូវភៀសខ្លួនទៅទីណាដោយរបៀបណា) |
| កម្រិតប្រុងប្រយ័ត្នទី3....... | មនុស្សចាស់ជាដើមភៀសខ្លួនពីកន្លែងគ្រោះថ្នាក់ (មនុស្សដែលត្រូវការពេលវេលាដើម្បីភៀសខ្លួនដូចជាមនុស្សចាស់ជរា និងកុមារជាដើមធ្វើការភៀសខ្លួន) |
| កម្រិតប្រុងប្រយ័ត្នទី4....... | ភៀសខ្លួនទាំងអស់គ្នាពីកន្លែងគ្រោះថ្នាក់ (ទាំងអស់គ្នាភៀសខ្លួនពីកន្លែងគ្រោះថ្នាក់ទៅកន្លែងមានសុវត្ថិភាព។) |
| កម្រិតប្រុងប្រយ័ត្នទី5....... | ធ្វើសកម្មភាពទៅតាមដែលអាចធ្វើបានដើម្បីការពារជីវិត (គ្រោះមហន្តរាយបានកើតឡើង ឬនឹងកើត។ សូមថែរក្សាជីវិតដ៏មានតំលៃរបស់អ្នក!) |

## 3-3 វិធីភៀសខ្លួន

នៅពេលភៀសខ្លួនមែនទែន សូមប្រុងប្រយ័ត្នលើចំណុចខាងក្រោម៖

- មុននឹងភៀសខ្លួន ដាច់ខាតត្រូវពន្លត់ភ្លើង។
- នៅពេលភៀសខ្លួន យករបស់តាមខ្លួនអោយបានតិចបំផុតហើយស្ពាយលើខ្នងជាដើម ធ្វើយ៉ាងណាអោយដៃទាំងពីរទំនេរអាចប្រើបានដោយសេរី។



ចំណុចគួរដឹង៖

## សេវាកម្មសារសំលេងទូរស័ព្ទសម្រាប់ពេលមានគ្រោះមហន្តរាយ

- ក្នុងករណីដែលមានគ្រោះរញ្ជួយដីធំកើតឡើងជាដើម គឺមានបាតុភូតដែលទូរស័ព្ទមានភាពលំបាកក្នុងការតភ្ជាប់។
- ក្នុងករណីបែបនេះ គេផ្តល់សេវាកម្មសារសំលេងទូរស័ព្ទសម្រាប់ពេលមានគ្រោះមហន្តរាយ។

នៅក្នុងគេហទំព័ររបស់ក្រសួងមហាផ្ទៃ ក៏មានចុះអំពីព័ត៌មានសង្ខេបនេះដែរ។

https://www.soumu.go.jp/menu_seisaku/ictseisaku/net_anzen/hijyo/dengon.html

លេខទូរស័ព្ទសារសំលេងសម្រាប់ពេលមានគ្រោះមហន្តរាយ (171)

តាមរយៈការទូរស័ព្ទទៅលេខ "171" ពីទូរស័ព្ទមានខ្សែ ឬទូរស័ព្ទដៃ គេអាចថតសារសំលេងនិងចាក់សារសំលេងបានយ៉ាងងាយស្រួលតាមការណែនាំក្នុងការប្រើប្រាស់។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

NTT EAST : https://www.ntt-east.co.jp/saigai/voice171/
NTT WEST : https://www.ntt-west.co.jp/dengon/

កន្លែងសារសំលេងសម្រាប់ពេលមានគ្រោះមហន្តរាយ
(ភាសាអង់គ្លេស ភាសាចិន ភាសាកូរ៉េ ភាសាជប៉ុន)

គេអាចបញ្ចូលលេខទូរស័ព្ទ និងព័ត៌មានស្តីពីសុវត្ថិភាពតាមរយៈទូរស័ព្ទមានខ្សែ ឬទូរស័ព្ទស្មាតហ្វូន ហើយក៏អាចបញ្ជាក់មើលព័ត៌មានបានដែរ។

សូមប្រើពីគេហទំព័រខាងក្រោម៖

https://www.web171.jp/web171app/topRedirect/

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

NTT EAST : http://www.ntt-east.co.jp/saigai/web171/
NTT WEST : https://www.ntt-west.co.jp/dengon/web171/

កន្លែងទទួលសារសំលេងសម្រាប់ពេលមានគ្រោះមហន្តរាយ (ទូរស័ព្ទចល័ត)

ក្រុមហ៊ុនបម្រើសេវាទូរស័ទ្ទចល័តក៏មានការផ្តល់សេវាកម្មសារផងដែរ។

សូមប្រើពីគេហទំព័រខាងក្រោម៖

NTT DOCOMO : http://dengon.docomo.ne.jp/top.cgi
KDDI (au) : http://dengon.ezweb.ne.jp/
SoftBank/
Y!mobile : http://dengon.softbank.ne.jp/
Rakuten Mobile : https://public-safety.mobile.rakuten.co.jp/?lang=ja

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

NTT DOCOMO : https://www.nttdocomo.co.jp/info/disaster/disaster_board/index.html
KDDI (au) : https://www.au.com/mobile/anti-disaster/saigai-dengon/
SoftBank : https://www.softbank.jp/mobile/service/dengon/
Y!mobile : https://www.ymobile.jp/service/dengon/
Rakuten Mobile : https://public-safety.mobile.rakuten.co.jp/info/public-safety/ja/service.html

NTT EAST / NTT WEST
NTT EAST / NTT WEST
NTT DOCOMO / KDDI (au) / SoftBank/Y!mobile / Rakuten Mobile
NTT DOCOMO / KDDI (au) / SoftBank / Y!mobile / Rakuten Mobile

# 3-4 ការទទួលព័ត៌មានអំពីអាកាសធាតុមានប្រយោជន៍នៅពេលមានគ្រោះមហន្តរាយ

នាយកដ្ឋានឧតុនិយមជប៉ុន ប្រកាសព័ត៌មានឧតុនិយមដែលមានប្រយោជន៍នៅពេលមានគ្រោះមហន្តរាយទៅខេត្តក្រុងជាដើម។

គេអាចទទួលបានព័ត៌មានឧតុនិយមទាំងនេះតាមរយៈទូរទស្សន៍ វិទ្យុ អ៊ីនធើណែត ។ល។

ព័ត៌មានអំពីភ្លៀងធំ និងការរញ្ជួយដី (មានច្រើនភាសា)

https://www.jma.go.jp/jma/kokusai/multi.html

## ព័ត៌មានអំពីការការពារគ្រោះមហន្តរាយ

សូមពិនិត្យមើលព័ត៌មានអំពីគ្រោះមហន្តរាយនៅគេហទំព័រខាងក្រោម៖

https://www.jma.go.jp/jma/en/menu.html

## Kikikuru (ការបង្ហាញទីតាំងគ្រោះថ្នាក់)

សូមពិនិត្យមើលលើផែនទីអំពីកន្លែងគ្រោះថ្នាក់ ដែលគ្រោះមហន្តរាយងាយនឹងកើតឡើង។

គ្រោះលិចទឹក (មហន្តរាយដោយសារ ទឹកលិចកន្លែងទាប)

https://www.jma.go.jp/bosai/en_risk/#elements:inund

https://www.jma.go.jp/jma/kokusai/multi.html

ទឹកជំនន់ (មហន្តរាយដោយសារទឹកហូរហៀរចេញពីទន្លេ)

https://www.jma.go.jp/bosai/en_risk/#elements:flood

https://www.jma.go.jp/jma/kokusai/multi.html

គ្រោះបាក់ដី (គ្រោះមហន្តរាយកើតឡើងដោយសារការបាក់ដីភ្នំឬចំណោត)

https://www.jma.go.jp/bosai/en_risk/#elements:land

https://www.jma.go.jp/jma/kokusai/multi.html

## កម្រិតប្រុងប្រយ័ត្នលើការផ្ទុះភ្នំភ្លើង

ព័ត៌មានអំពីភ្នំភ្លើង

https://www.jma.go.jp/bosai/map.html#5/34.5/137/&contents=volcano&lang=en

https://www.jma.go.jp/jma/kokusai/multi.html

ចំណុចគួរដឹង៖

### ការព្រមានពិសេសអំពីគ្រោះថ្នាក់ភ្លៀងខ្លាំង

- នាយកដ្ឋានឧត្តុនិយមជប៉ុន មានការផ្សាយចេញនូវការព្រមានពិសេសអំពីគ្រោះថ្នាក់ភ្លៀងខ្លាំង។
- គឺធ្វើការព្រមានពិសេសអំពីករណីភ្លៀងធំ ដែលអាចកើតមានឡើង 10ឆ្នាំម្តង ឬករណីដែលមហន្តរាយធ្ងន់ធ្ងរកើតមានឡើងហើយ។

ចំណុចគួរដឹង៖

### Kikikuru (ការបង្ហាញទីតាំងគ្រោះថ្នាក់)

- នាយកដ្ឋានឧត្តុនិយមជប៉ុន មានផ្តល់នូវព័ត៌មាន Kikikuru (ការបង្ហាញទីតាំងគ្រោះថ្នាក់) ដោយផ្អែកលើការព្យាករណ៍អំពីភ្លៀង ហើយបង្ហាញនៅលើផែនទីអំពីកន្លែងដែលនឹងលេចទឹក ឬមានគ្រោះបាក់ដី គ្រោះទឹកជំនន់ជាដើម។
- គេអាចទទួលបានពី Kikikuru(ការបង្ហាញទីតាំងគ្រោះថ្នាក់) ពីគេហទំព័ររបស់នាយកដ្ឋានឧត្តុនិយមជប៉ុនរៀងរាល់ 10នាទី។
- នៅពេលដែលទទួលបានព័ត៌តាមរយៈទូរស័ព្ទស្មាតហ្វូនជាដើមថាហានិភ័យនៃកន្លែងដែលអ្នកនៅកើនឡើង សូមប្រញាប់ភៀសខ្លួន។

ចំណុចគួរដឹង៖

## កម្មវិធី “Safety tips” ដែលផ្តល់ព័ត៌មានមានប្រយោជន៍សម្រាប់ពេលមានគ្រោះមហន្តរាយ

- នៅប្រទេសជប៉ុនមានកម្មវិធីដែលផ្តល់ព័ត៌មានមានប្រយោជន៍សម្រាប់ពេលមានគ្រោះមហន្តរាយ ដល់ភ្ញៀវទេសចរណ៍បរទេសឥតគិតថ្លៃ។
- នៅពេលគេទាញយកកម្មវិធីនោះហើយ នៅពេលដែលមានគ្រោះមហន្តរាយដូចខាងក្រោមបម្រុងនឹងកើតឡើង វានឹងផ្តល់ដំណឹងជាមុន៖

  1 ព័ត៌មានបន្ទាន់អំពីគ្រោះរញ្ជួយដី (ជាការប្រាប់អោយប្រុងប្រយ័ត្នថារំញ័រខ្លាំងនឹងមកដល់ឆាប់ៗ)

  2 ការប្រកាសព្រមានអំពីស៊ីណាមី (ជាការប្រកាសប្រាប់អោយគេចខ្លួនទៅកន្លែងខ្ពស់ដោយសាររលកស៊ីណាមីនឹងមកដល់ឆាប់ៗ)

  3 ការព្រមានពិសេសពាក់ព័ន្ធនឹងអាកាសធាតុ (ជាការព្រមានកម្រិតខ្ពង់ជាងគេ 3 អោយដឹងថា អាចនឹងមានភ្លៀងធំ ឬខ្យល់ព្យុះខ្លាំង កម្រិតម្តងក្នុងអំឡុងពេលរាប់សិបឆ្នាំអាចនឹងកើតមានគ្រប់ពេល ហេតុដូច្នេះហើយអ្នកដែលមិនទាន់បានភៀសខ្លួន សូមធ្វើសកម្មភាពការពារជីវិតរបស់ខ្លួន)

  4 អោយដឹងថា អាចនឹងមានភ្លៀងធំ ឬខ្យល់ព្យុះខ្លាំង កម្រិតម្តងក្នុងអំឡុងពេលរាប់សិបឆ្នាំអាចនឹងកើតមានគ្រប់ពេល ហេតុដូច្នេះហើយអ្នកដែលមិនទាន់បានភៀសខ្លួន សូមធ្វើសកម្មភាពការពារជីវិតរបស់ខ្លួន)

  5 ព័ត៌មានបន្ទាន់អំពីគ្រោះផ្ទុះភ្នំភ្លើង (ជាការព្រមានអោយការពារខ្លួនដោយសារភ្នំភ្លើងបានផ្ទុះ)

  6 ព័តមានស្ពកដោយកម្តៅ(ព្រមានការពារខ្លួនរបស់អ្នកព្រោះមានហានិភ័យនៃស្ពកដោយកម្តៅ អ្នកក៏អាចស្វែងរកព័ត៌មានដែលមានប្រយោជន៍ខាងក្រោមនៅពេលមានគ្រោះមហន្តរាយកើតឡើង៖)

- ម្យ៉ាងទៀតអាចប្រើប្រាស់ព័ត៌មានដែលមានប្រយោជន៍នៅពេលគ្រោះមហន្តរាយកើតឡើង។

  ① ប្លង់ប្រាប់លំដាប់លំដោយថាត្រូវធ្វើយ៉ាងណានៅពេលមានមហន្តរាយកើតឡើង

  ② កាតទំនាក់ទំនងដើម្បីនិយាយជាមួយជនជាតិជប៉ុននៅជុំវិញ

- តំណភ្ជាប់ទៅគេហទំព័រដែលអាចប្រមូលព័ត៌មានចាំបាច់នៅពេលមានគ្រោះមហន្តរាយ

Android : https://play.google.com/store/apps/details?id=jp.co.rcsc.safetyTips.android
iPhone : https://itunes.apple.com/jp/app/safety-tips/id858357174?mt=8

Safety tips | Android | iPhone

ជំពូកទី11

# លំនៅដ្ឋាន



## 1 អំពីលំនៅដ្ឋាននៅប្រទេសជប៉ុន

### 1-1 ផ្ទះឯកជន

ផ្ទះដែលមានសិទ្ធិកាន់កាប់ នៅប្រទេសជប៉ុនគេហៅថា "ផ្ទះឯកជន"។ "ផ្ទះឯកជន" មានច្រើនប្រភេទដូចផ្ទះដាច់តែឯង ឬខុនដូជាដើម ហើយដើម្បីសង់ផ្ទះ ឬទិញផ្ទះ គេត្រូវបំពេញបែបបទនិងកិច្ចសន្យាផ្សេងៗ។

### 1-2 ផ្ទះរបស់រដ្ឋ

ជាផ្ទះសម្រាប់អ្នកមានចំណូលទាបហើយខ្វះកន្លែងស្នាក់នៅ ជាផ្ទះមានតំលៃជួលថោកផ្តល់ដោយរដ្ឋបាលសាធារណៈតាមតំបន់ ដែលមានលក្ខខណ្ឌចូលនៅកំណត់ដោយប្រាក់ចំណូល ទៅតាមខេត្តក្រុងឬភូមិឃុំស្រុកនីមួយៗ។

### 1-3 ផ្ទះជួលរបស់ UR

ជាផ្ទះដែលគ្រប់គ្រងដោយអង្គការ Urban Renaissance Agency ហើយដើម្បីចូលនៅត្រូវមានប្រាក់ចំណូលប្រចាំខែច្រើនជាងតំលៃស្តង់ដារមួយកំណត់ដោយ UR ក្នុងករណីដែលមានលក្ខណៈសម្បត្តិស្នាក់នៅកំណត់មួយ (សូមមើលត្រង់ 2-2) គឺអាចចូលនៅបាន។

### 1-4 ផ្ទះជួលឯកជន

គឺជាផ្ទះជួលទូទៅ។ តាមរយៈការបង់ថ្លៃឈ្នួលផ្ទះជាដើមផ្អែកលើកិច្ចសន្យាជួលផ្ទះ អ្នកណាក៏អាចជួលផ្ទះស្នាក់នៅបានដែរ។ ចំពោះកិច្ចសន្យាជួលផ្ទះគឺមានលក្ខណៈខុសៗគ្នាទៅតាមផ្ទះនីមួយៗ ហេតុដូច្នេះសូមត្រួតពិនិត្យអោយបានល្អិតល្អន់។

# 2 អំពីការចូលរស់នៅ

## 2-1 ផ្ទះរបស់រដ្ឋ

- ដោយសារផ្ទះរបស់រដ្ឋជាផ្ទះសម្រាប់អ្នកមានចំណូលទាបហើយខ្វះកន្លែងស្នាក់នៅ ខេត្តក្រុង ឬភូមិឃុំស្រុកនីមួយៗដែលជាអ្នកគ្រប់គ្រង ធ្វើការកំណត់លក្ខខណ្ឌចូលរស់នៅកំណត់ដោយប្រាក់ចំណូលជាដើម។
- ចំពោះពលរដ្ឋបរទេសវិញ បន្ថែមពីលើលក្ខណចូលរស់នៅទូទៅ ក្នុងករណីខ្លះមានលក្ខខណ្ឌដូចជាត្រូវមានលក្ខណៈសម្បត្តិស្នាក់នៅ ឬប្រវត្តិស្នាក់នៅប្រទេសជប៉ុនលើសពី1ឆ្នាំជាដើម។
- ក្នុងករណីមានបំណងចង់ចូលរស់នៅផ្ទះរបស់រដ្ឋ សូមធ្វើការដាក់ពាក្យស្នើសុំទៅខេត្តក្រុង ឬភូមិឃុំស្រុកដែលជាអ្នកគ្រប់គ្រងផ្ទះ។
- ចំពោះខ្លឹមសារលំអិតនៃលក្ខខណ្ឌចូលរស់នៅ វិធីស្នើសុំជាដើម សូមទាក់ទងទៅខេត្តក្រុង ឬភូមិឃុំស្រុកដែលជាអ្នកគ្រប់គ្រងផ្ទះដែលអ្នកចង់ចូលរស់នៅ។

## 2-2 ផ្ទះជួលរបស់ UR

- លក្ខខណ្ឌចូលរស់នៅមានដូចជា ត្រូវមានប្រាក់ចំណូលប្រចាំខែច្រើនជាងតំលៃស្តង់ដារមួយកំណត់ដោយអង្គការ Urban Renaissance Agency ជាដើម។
- ក្នុងករណីពលរដ្ឋបរទេស អ្នកដែលមានលក្ខណៈសម្បត្តិស្នាក់នៅស្នាក់នៅជាបន្តបន្ទាប់និងជា ការទូតផ្លូវការ អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស អ្នកស្នាក់នៅរយៈពេលមធ្យមឬវែង (រួមទាំងអ្នកស្នាក់នៅអចិន្ត្រៃយ៍) អាចចូលនៅបាន។
- ចំពោះវិធីដាក់ពាក្យចូលរស់នៅ ឬស្ថានភាពនៃការប្រកាសរកអ្នកស្នាក់នៅជាដើម សូមទាក់ទងសួរទៅសេវាទទួលអតិថិជនរបស់ UR ជាដើម។

## 2-3 ផ្ទះជួលឯកជន

- សម្រាប់ពលរដ្ឋបរទេសដែលស្វែងរកផ្ទះជួលឯកជននៅប្រទេសជប៉ុន គេមាន “សៀវភៅមគ្គុទេសក៍សម្រាប់រកបន្ទប់ជួល” “សៀវភៅណែនាំអំពីការចូលរស់នៅក្នុងផ្ទះជួលសម្រាប់ជនបរទេស”។
- នៅក្នុង“សៀវភៅមគ្គុទេសក៍សម្រាប់រកបន្ទប់ជួល” មានសរសេរអំពីព័ត៌មានមានប្រយោជន៍សម្រាប់ការស្វែងរកបន្ទប់ជួលដូចខាងក្រោមជាដើម សូមពិនិត្យមើល៖

① វិធីស្វែងរកផ្ទះជួលនៅជប៉ុន និងលំដាប់លំដោយនៃកិច្ចសន្យា
② ឯកសារចាំបាច់និងថ្លៃចំណាយ
③ នីតិវិធីចូលនៅ
④ ច្បាប់អំពីរបៀបរស់នៅផ្ទះរបស់ជប៉ុន
⑤ នីតិវិធីចាកចេញ
⑥ វាក្យសព្ទអំពីអចលនទ្រព្យដែលត្រូវការនៅពេលជួលបន្ទប់ ។ល។



- ក្នុង “សៀវភៅណែនាំអំពីការស្វែងរកផ្ទះ” មានសរសេរអំពីព័ត៌មានសំខាន់ៗដែលអាចប្រើនៅពេលរកបន្ទប់ជួលនៅជប៉ុន ឬគេហទំព័រក្រុមហ៊ុនអចលនទ្រព្យដែលអាចឆ្លើយឆ្លងជាភាសាបរទេស ជាដើម។

គេហទំព័ររបស់ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍
ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖
https://www.mlit.go.jp/jutakukentiku/house/jutakukentiku_house_tk3_000017.html

## “សៀវភៅមគ្គុទេសក៍សម្រាប់រកបន្ទប់ជួល”

| | |
|---|---|
| ភាសាជប៉ុន-JAPANESE- | http://www.mlit.go.jp/common/001317843.pdf |
| ភាសាអង់គ្លេស-ENGLISH- | http://www.mlit.go.jp/common/001317844.pdf |
| ភាសាចិន-CHINESE- | http://www.mlit.go.jp/common/001317845.pdf |
| ភាសាកូរ៉េ-KOREAN- | http://www.mlit.go.jp/common/001317846.pdf |
| ភាសាអេស្ប៉ាញ-SPANISH- | http://www.mlit.go.jp/common/001317847.pdf |
| ភាសាព័រទុយហ្គាល់-PORTUGUES- | http://www.mlit.go.jp/common/001317848.pdf |
| ភាសាវៀតណាម-VIETNAMESE- | http://www.mlit.go.jp/common/001316936.pdf |
| ភាសានេប៉ាល់-NEPALI- | http://www.mlit.go.jp/common/001316937.pdf |
| ភាសាថៃ-THAI- | http://www.mlit.go.jp/common/001312581.pdf |
| ភាសាឥណ្ឌូនេស៊ី-INDNESIAN- | http://www.mlit.go.jp/common/001312584.pdf |
| ភាសាភូមា-MYANMAR- | http://www.mlit.go.jp/common/001312587.pdf |
| ភាសាខ្មែរ-KHMER- | http://www.mlit.go.jp/common/001312589.pdf |
| ភាសាតាហ្គាឡុក-TAGALOG- | http://www.mlit.go.jp/common/001312590.pdf |
| ភាសាម៉ុងហ្គោលី-MONGOLIAN- | http://www.mlit.go.jp/common/001312591.pdf |

| | | | |
|---|---|---|---|
| ភាសាជប៉ុន | ភាសាអង់គ្លេស | ភាសាចិន | ភាសាកូរ៉េ |
| ភាសាអេស្ប៉ាញ | ភាសាព័រទុយហ្កាល់ | ភាសាវៀតណាម | ភាសានេប៉ាល់ |
| ភាសាថៃ | ភាសាឥណ្ឌូនេស៊ី | ភាសាភូមា | ភាសាខ្មែរ |
| ភាសាតាហ្កាឡុក | ភាសាម៉ុងហ្គោលី | | |

“សៀវភៅណែនាំអំពីការចូលរស់នៅផ្ទះជួលសម្រាប់ជនបរទេស”
https://www.mlit.go.jp/common/001334734.pdf

ព័ត៌មានអំពីផ្ទះដែលពលរដ្ឋបរទេសអាចជួលបាន
https://safetynet-jutaku.mlit.go.jp/guest/index.php (ភាសាជប៉ុន)

ជំពូកទី12

# ច្បាប់ និងទំនៀមទំលាប់ក្នុងការរស់នៅប្រចាំថ្ងៃ



## 1 ច្បាប់នៃការរស់នៅ

### 1-1 សំរាម



#### (1) ច្បាប់មូលដ្ឋានក្នុងការចោលសំរាម

នៅពេលចោលសំរាមចាំបាច់ត្រូវគោរពច្បាប់ខាងក្រោម៖

- ត្រូវគោរពកន្លែងដាក់សំរាមនិងថ្ងៃ (ថ្ងៃក្នុងនៃសប្តាហ៍) ដាក់ប្រភេទនីមួយៗ
- ចំពោះថាត្រូវដាក់សំរាមប្រភេទណានៅទីណា គឺត្រូវធ្វើតាមច្បាប់កំណត់ដោយភូមិឃុំស្រុកដែលអ្នករស់នៅ

* ជាទូទៅត្រូវដាក់សំរាមនៅព្រឹកនៃថ្ងៃដែលគេប្រមូលសំរាម។

* ក្នុងករណីដែលដាក់សំរាមប្រភេទផ្សេងពីអ្វីដែលបានកំណត់ ឬដាក់នៅកន្លែងផ្សេងពីកន្លែងកំណត់ នោះគេមិនប្រមូលយកសំរាមនោះឡើយ។

* នៅភូមិឃុំស្រុកខ្លះគេតម្រូវអោយប្រើប្រាស់ថង់ដាក់សំរាមគិតថ្លៃ ដែលកំណត់ដោយភូមិឃុំស្រុក។



ឧទាហរណ៍នៃប្រភេទសំរាម (ត្រូវអនុវត្តតាមវិន័យនៃភូមិ ឃុំស្រុក នៃកន្លែងស្នាក់នៅ)

| | |
|---|---|
| សំរាមដុត | សំរាមនៅចេញមកពីផ្ទះបាយ ឬសំរាមក្រដាស។ល។ |
| សំរាមមិនដុត | ចានឬពែងបែក លោហៈធាតុ កែវ។ល។ |
| សំរាមធនធាន | ដប កំប៉ុង ដបទឹកសុទ្ធ កាសែត សៀវភៅ ប្រដាប់ដាក់របស់ផ្លាស្ទិច ឡាំងក្រដាស ។ល។ |
| សំរាមធំ<br>នៅពេលចោលមានករណីខ្លះត្រូវបង់ថ្លៃចោលឬថ្លៃកែច្នៃឡើងវិញ | គ្រឿងសង្ហារឹមដូចជាតុ កៅអី កង់ ពូក ។ល។ |
| សំរាមគ្រឿងអគ្គិសនី<br>នៅពេលចោលមានករណីខ្លះត្រូវបង់ថ្លៃកែច្នៃឡើងវិញ | ម៉ាស៊ីនត្រជាក់ឬកំដៅ ទូរទស្សន៍ ទូទឹកកក ទូក្លាសេ ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនសំងួតខោអាវ។ល។ |

ចំណុចគួរដឹង៖

### ប្រេងបន្ទាប់ពីប្រើធ្វើម្ហូបរួច

មិនត្រូវបង្ហូរប្រេងចូលកន្លែងលាងចានឡើយ។ សូមអនុវត្តតាមច្បាប់របស់សាលាក្រុងភូមិឃុំសង្កាត់ដែលអ្នករស់នៅ ដូចជាដាក់កន្សែងក្រដាសនៅក្នុងផ្ទាំងដើម្បីស្រូបប្រេង ឬធ្វើឲ្យប្រេងរឹងជាមួយនឹងសារធាតុ coagulant មុននឹងបោះវាចោល។

ចំណុចគួរដឹង៖

### សំរាមគ្រឿងអគ្គិសនី



នៅពេលទិញប្តូរ ឬចោលគ្រឿងអគ្គិសនីខាងក្រោម គឺត្រូវបង់ថ្លៃកែច្នៃឡើងវិញ (recycle) ឬបង់ថ្លៃមកប្រមូលនិងដឹកនៃគ្រឿងអគ្គិសនីនោះ៖

- ម៉ាស៊ីនត្រជាក់ឬកំដៅ
- ទូរទស្សន៍
- ទូទឹកកក ឬទូក្លាសេ
- ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនសំងួតខោអាវ

លើសពីនេះ ពេលបោះចោល ត្រូវពឹងក្រុមហ៊ុនណាដែលបានទទួលការអនុញ្ញាតឱ្យប្រមូលនិងដឹកជញ្ជូន។ តើត្រូវពឹងក្រុមហ៊ុនណា សូមសួរទៅភូមិឃុំស្រុកសង្កាត់ដែលរស់នៅ។

កន្លែងបង់ថ្លៃកែច្នៃឡើងវិញ (recycle) កន្លែងទទួលយកផលិតផលចាស់

① ក្នុងករណីទិញផលិតផលថ្មីប្តូរ

- ហាងទិញផលិតផលថ្មី

  ដោយសារគោលការណ៍ទិញលក់នៃហាងនីមួយៗខុសៗគ្នា ចំពោះខ្លឹមសារលំអិតសូមទាក់ទងសួរទៅហាងនោះ។

② ក្នុងករណីមិនទិញប្តូរ គ្រាន់តែចោលប៉ុណ្ណោះ

- ហាងដែលបានទិញផលិតផលដែលត្រូវចោល

  ក្នុងករណីដែលមិនដឹងថាបានទិញនៅហាងណាជាដើម សូមសាកសួរទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

## (2) ការចោលសំរាមខុសច្បាប់ជាដើម (ការចោលសំរាមដោយខុសច្បាប់)

ទោះជានៅកន្លែងណាក៏ដោយមិនត្រូវចោលសំរាមពាសវាលពាសកាលក្រៅពីកន្លែងកំណត់ឡើយ។

ក្នុងករណីដែលបោះសំរាមចោលនៅក្រៅពីកន្លែងកំណត់ មានករណីខ្លះត្រូវទទួលទោសព្រហ្មទណ្ឌ។

សូមចោលសំរាមដោយគោរពច្បាប់នៃភូមិឃុំស្រុកដែលអ្នករស់នៅ។

ម្យ៉ាងទៀតភូមិឃុំស្រុកជាច្រើនដាក់ចេញនូវប្រកាសហាមឃាត់ការបោះចោលសំបកកំប៉ុង ឬកន្ទុយបារីនៅតាមផ្លូវ "ការពង្រាយសំរាម"។ សូមកុំពង្រាយសំរាមព្រោះអាចទទួលទណ្ឌកម្មរដ្ឋបាល ឬទណ្ឌកម្មព្រហ្មទ័ណ្ឌ។

## 1-2 សំលេងរំខាន

ជនជាតិជប៉ុនគិតថាការបញ្ចេញសំលេងខ្លាំងៗឬសំលេងនិយាយលឺ គឺជាអំពើរំខានដល់អ្នកដទៃ។

- សូមធ្វើយ៉ាងណាកុំអោយមានការរំខានដល់អ្នកជិតខាងដោយសារសំលេងនិយាយគ្នាលឺៗ សំលេងជប់លៀង សំលេងទូរទស្សន៍ឬតន្ត្រីជាដើម។
- សូមប្រុងប្រយ័ត្នកុំបញ្ចេញសំលេងលឺខ្លាំងនៅពេលព្រឹកព្រលឹមដូចជាបោកខោអាវឬប្រើម៉ាស៊ីនបូមធូលី ឬងូតទឹកជាដើម។
- ជាពិសេសនៅផ្ទះស្នាក់នៅរួមដូចជាបន្ទប់ជួល ឬខុនដូជាដើម សូមប្រុងប្រយ័ត្នកុំបញ្ចេញសំលេងលឺៗ។



## 1-3 បង្គន់



### បង្គន់លាងដោយទឹករបស់ជប៉ុន

- ចំពោះក្រដាសប្រើ ត្រូវតែប្រើក្រដាសដែលមានដាក់នៅក្នុងបង្គន់។
- ក្រដាសដែលប្រើរួច ត្រូវតែបង្ហូរចូលក្នុងបង្គន់
  → មានប្រទេសខ្លះមានទំលាប់ចោលក្រដាសដែលប្រើរួចក្នុងធុងសំរាមដែលដាក់នៅក្នុងបង្គន់ ប៉ុន្តែបើគេប្រើក្រដាសដែលមានដាក់នៅក្នុងបង្គន់ នោះបង្គន់លាងដោយទឹករបស់ជប៉ុន កំរនឹងស្ទះណាស់។
- បង្គន់នៅផ្សារទំនើបឬស្ថានីយ៍រថភ្លើង មានប៊ូតុងច្រើន ប៉ុន្តែប៊ូតុងបង្ហូរទឹកភាគច្រើនមានសរសេរពាក្យបង្ហូរ (FLUSH) ។

## 1-4 ការប្រើប្រាស់ទូរស័ព្ទចល័ត



- ការប្រើទូរស័ព្ទបណ្តើរដើរបណ្តើរអាចប៉ះទង្គិចអ្នកដើរផ្សេងទៀតអោយមានរបួស ឬធ្វើអោយខ្លួនឯងត្រូវរបួស ដូច្នេះមិនត្រូវធ្វើឡើយ។
- ការបើកយានយន្ត ឬជិះកង់បណ្តើរប្រើទូរស័ព្ទបណ្តើរ ត្រូវបានហាមឃាត់ដោយច្បាប់។

## 1-5 នៅក្នុងរថភ្លើងឬរថយន្តក្រុង

នៅក្នុងរថភ្លើងឬរថយន្តក្រុងគឺជាកន្លែងសាធារណៈ សូមប្រុងប្រយ័ត្នលើចំណុចខាងក្រោមៈ

- ការនិយាយដោយសំលេងលឺៗ គឺជាការខុសច្បាប់សុជីវធម៌នៅក្នុងប្រទេសជប៉ុន។
- នៅប្រទេសជប៉ុន ការនិយាយទូរស័ព្ទនៅក្នុងរថភ្លើងឬរថយន្តក្រុងគឺជាការខុសច្បាប់សុជីវធម៌។
- ការស្តាប់តន្ត្រីដោយសំលេងលឺៗ ក៏ជាអំពើរំខានដែរ។ សូមប្រុងប្រយ័ត្នកុំអោយសំលេងធ្លាយចេញពីកាសស្តាប់ត្រចៀក។
- នៅពេលដែលក្នុងឡានក្រុងឬរថភ្លើងមានមនុស្សណែន ការស្ពាយកាបូបស្ពាយពីក្រោយ ធ្វើអោយប៉ះពាល់និងរំខានដល់អ្នកដទៃ។

## 1-6 អុនសេន និងសេនតូ

- នៅកន្លែងងូតទឹកសាធារណៈដូចជាអុនសេន និងសេនតូ គឺមានមនុស្សប្រើប្រាស់ចម្រុះ ដូច្នេះសូមគោរពច្បាប់ខាងក្រោមនៅពេលប្រើប្រាស់៖
- លាងខ្លួនអោយស្អាតសិនមុនចូលក្នុងអាងទឹក។
- មិនអាចយកកន្សែងចូលក្នុងអាងទឹកឡើយ។
- មិនអាចប្រើសាប៊ូដុសខ្លួនឬសាប៊ូកក់សក់ ដើម្បីដុសខ្លួនឬកក់សក់ក្នុងអាងទឹកបានឡើយ។
- អ្នកដែលមានសាក់(tattoo) ក្នុងករណីខ្លះមិនអាចចូលបានឡើយ។

## 1-7 សញ្ញាបង្ហាញការហាមឃាត់

មានសញ្ញាបង្ហាញថា “មិនអាចធ្វើ” អ្វីមួយបានច្រើនប្រភេទ។

គឺជាសញ្ញាមូលដ្ឋានបង្ហាញការហាមឃាត់។



នៅកន្លែងដែលមានសញ្ញាហាមឃាត់ សូមគោរពច្បាប់ទាំងអស់គ្នា។



“មិនអាចហែលទឹកបាន”



“មិនអាចជក់បារីបាន”



“មិនអាចប្រើទូរស័ព្ទចល័តបាន”

# 2 ការបង្ការជម្ងឺផ្លូង

នៅជប៉ុន ជាពិសេសពេលរដូវរងារដែលខ្យល់អាកាសស្ងួតខ្លាំង ជម្ងឺផ្លូង ដូចជា ជម្ងឺផ្ដាសសាយឬជម្ងឺផ្ដាសសាយធំ ជាដើមនឹងរាលដាល ហើយក៏អាចមានការរាលដាលនូវជម្ងឺឆ្លងដោយសារវីរុសថ្មី ដែលមិនធ្លាប់មានពីមុនៗ។ ក្នុងនេះ មានពន្យល់អំពីវិធីបង្ការមូលដ្ឋានដើម្បីកុំឱ្យជម្ងឺឆ្លងរាលដាល។ ពេលមានជម្ងឺឆ្លងរាលដាល សូមអ្នកទាំងអស់គ្នាប្រយ័ត្នរៀងៗខ្លួនដូចខាងក្រោមនេះ។

## 2-1 ការលាងដៃ

ការលាងដៃដោយទឹកស្អាតនិងសាប៊ូ គឺជាវិធីកំចាត់វីរុសពីម្រាមដៃនិងដៃជាដើម ប្រកបដោយប្រសិទ្ធភាព។ ពេលត្រឡប់មកពីក្រៅ ឬមុននិងក្រោយពេលធ្វើម្ហូប មុនពេលញ៉ាំបាយជាដើម សូមលាងដៃរាល់ដង។ របៀបលាងដៃគឺដូចតទៅ។




① លាងដៃនឹងទឹកសិន ហើយលាបសាប៊ូលើបាតដៃឱ្យស្រួលបួល។
② លាបសាប៊ូទៅខាងខ្នងដៃឱ្យស្រួមបួល។
③ លាបសាប៊ូតាមម្រាមដៃនិងក្រចកឱ្យហ្មត់ចត់។
④ លាងសំអាតម្រាមដៃនឹងទឹក។
⑤ យកម្រាមដៃទៅលាងបាតដៃ។
⑥ សូមកុំភ្លេចលាងកដៃផងដែរ។

* ពេលលាងដោយសាប៊ូរួចហើយ សូមលាងទឹកឱ្យអស់សាប៊ូ ត្រូវសម្ងួតដៃដោយក្រណាត់ឬក្រដាសឱ្យស្ងួត។

## 2-2 សុជីវធម៌ពេលក្អក

សុជីវធម៌ពេលក្អក គឺជាការប្រើម៉ាស់ ឬក្រដាស ឬកូនកន្សែង ឬដៃអាវ ជាដើម បិទមាត់ ឬច្រមុះ នៅពេលក្អក ឬកណ្តាស់ ដើម្បីកុំឱ្យចម្លងជម្ងឺឆ្លងទៅអ្នកដទៃ។

ពេលក្អក ឬកណ្តាស់ សូមធ្វើដូចតទៅៈ

- ពាក់ម៉ាស់ បិទមាត់និងច្រមុះ។
- ពេលអត់មានម៉ាស់ សូមយកក្រដាស ឬកន្សែងបិទមាត់និងច្រមុះ។
- ពេលបន្ទាន់ សូមយកដៃអាវផ្នែកខាងក្នុងទៅបិទមាត់និងច្រមុះ។

លើសពីនេះ ពេលប្រើម៉ាស់ សំខាន់គឺត្រូវប្រើឱ្យបានត្រឹមត្រូវ។ ការប្រើម៉ាស់ ត្រូវធ្វើដូចខាងក្រោមនេះ។

① បិទម៉ាស់ទាំងច្រមុះនិងមាត់។
② បំពាក់ខ្សែយឺតទៅនឹងត្រចៀក
③ ត្រូវបិទទាំងច្រមុះ កុំឱ្យមានគម្លាត

## 2-3 សំណើម

ពេលខ្យល់ស្ងួត មុខងារបង្ការនៃជាតិរំអិលក្នុងបំពង់កនឹងធ្លាក់ចុះ ហើយងាយស្រួលឆ្លងជម្ងឺឆ្លង។ ជាពិសេស នៅក្នុងបន្ទប់ដែលងាយស្រួលស្ងួត សូមប្រើម៉ាស៊ីនបញ្ចេញចំហាយទឹកធ្វើឱ្យមានសំណើមសមស្រប (50~60%) ជាដើម នឹងមានប្រសិទ្ធភាព។

## 2-4 ការសម្រាកនិងការញ៉ាំឱ្យមានជីវជាតិ

ដើម្បីធ្វើឱ្យខ្លួនប្រាណងាយស្រួលប្រឈមនឹងជម្ងឺឆ្លង ត្រូវសម្រាកឱ្យបានច្រើន ហើយញ៉ាំចំណីអាហារដែលមានជីវជាតិល្អគ្រប់គ្រាន់ជាប្រចាំ។

## 2-5 ការចេញទៅក្រៅ

នៅពេលដែលជំងឺឆ្លងដែលឆ្លងតាមដំណក់ទឹកមានច្រើន ការពាក់ម៉ាសត្រូវបានចាត់ទុកថាជាវិធានការបង្ការដ៏មានប្រសិទ្ធភាព។ វាមានសារៈសំខាន់ជាពិសេសសម្រាប់មនុស្សចាស់ អ្នកដែលមានលក្ខខណ្ឌមូលដ្ឋាន អ្នកដែលកំពុងទទួលការព្យាបាលជំងឺមហារីក ស្ត្រីមានផ្ទៃពោះ និងអ្នកដែលមានសុខភាពខ្សោយ ដើម្បីធ្វើការប្រុងប្រយ័ត្នដើម្បីការពារការឆ្លងមេរោគ។



ត្រូវប្រុងប្រយ័ត្នជាពិសេសក្នុងអំឡុងពេលដែលជំងឺឆ្លងរីករាលដាល និងពេលចូលទៅកន្លែងមានមនុស្សច្រើន។

# 3 អ្វីដែលចាំបាច់ក្នុងការរស់នៅ

## 3-1 ជីវភាពក្នុងសហគមន៍

### (1) សហគមន៍មូលដ្ឋាន (សមាគមមូលដ្ឋាន សមាគមអ្នកជិតខាង)

នៅប្រទេសជប៉ុនអ្នកដែលរស់នៅក្នុងសហគមន៍នាំគ្នាស្ម័គ្រចិត្តបង្កើតជាសមាគម ធ្វើសកម្មភាពផ្សេងៗ ដើម្បីអោយងាយស្រួលរស់នៅ និងបង្កើតជាកន្លែងដែលអាចរស់នៅដោយគ្មានការព្រួយបារម្ភ។ ចំណាយផ្សេងៗក្នុងការធ្វើសកម្មភាពគឺជាបន្ទុករបស់សមាជិក។



**ខ្លឹមសារនៃសកម្មភាពសំខាន់ៗ**

- ការហ្វឹកហាត់ការពារគ្រោះមហន្តរាយត្រៀមសម្រាប់ករណីគ្រោះរញ្ជួយដី ឬអគ្គីភ័យកើតឡើង
- សកម្មភាពការពារកុមារទៅមកពីសាលា
- សកម្មភាពទាក់ទងនឹងសុខុមាលភាពរបស់មនុស្សចាស់ និងជនពិការ
- ការចែកចាយប្រាប់ព័ត៌មានដែលទទួលបានពីសាលាក្រុងជាដើម
- បង្កើតកម្មវិធីផ្សេងៗដូចជាពិធីបុណ្យ កម្មវិធីកីឡាជាដើម ដើម្បីរឹតចំណងទាក់ទងរវាងសមាជិក ។ល។ សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

### (2) ការរាប់អានអ្នកជិតខាង

- តាមរយៈការនិយាយពាក្យស្វាគមន៍ជាមួយអ្នកជិតខាងជាប្រចាំ និងការរាប់អានដោយចូលរួមក្នុងកម្មវិធីផ្សេងៗ ធ្វើអោយបញ្ហារវាងអ្នកជិតខាងដូចគ្នាពិបាកកើតឡើង ហើយក៏អាចផ្លាស់ប្តូរព័ត៌មានផ្សេងៗដូចជាចំណុចត្រូវប្រុងប្រយ័ត្ននៅតំបន់នោះជាដើម។
- នៅពេលមានគ្រោះមហន្តរាយកើតឡើងជាដើម ក៏អាចជួយគ្នាបានដែរ។

## 3-2 ការការពារបទល្មើស

សូមប្រុងប្រយ័ត្ននូវចំណុចខាងក្រោម ដើម្បីកុំអោយជួបបទល្មើសចោរកម្ម ឬការបៀតបៀនផ្លូវភេទ៖

- នៅពេលចេញទៅក្រៅ ត្រូវចាក់សោទ្វារបង្អួចផ្ទះជានិច្ច។
- នៅពេលទុករថយន្ត ម៉ូតូ កង់ ត្រូវចាក់សោជានិច្ច។
- នៅពេលកាន់របស់សំខាន់តាមខ្លួនដូចជា កាបូបយួរ កាបូបលុយ សូមកុំដាក់ចោលនៅកន្លែងមើលមិនឃើញ។
- នៅពេលយប់សូមកុំដើរនៅផ្លូវងងឹត ឬកន្លែងដែលមិនសូវមានមនុស្សទៅមក។
- ទាក់ទងនឹងការការពារបទល្មើស បើមានចំណុចមិនយល់ឬមានការព្រួយបារម្ភ សូមពិគ្រោះជាមួយការិយាល័យប៉ូលីសដែលនៅក្បែរជាដើម។

# 3-3 សេវាកម្មចាំបាច់សម្រាប់ជីវភាព

## (1) អគ្គិសនី

### ការចាប់ផ្ដើមប្រើអគ្គិសនី

ដើម្បីចាប់ផ្ដើមប្រើប្រាស់អគ្គិសនីចាំបាច់ត្រូវធ្វើដូចខាងក្រោម៖

① កំណត់ថ្ងៃដែលអ្នកចង់ចាប់ផ្ដើមប្រើប្រាស់អគ្គិសនី។
② ចុះឈ្មោះប្រើប្រាស់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីតាមអ៊ីនធើណែតឬទូរស័ព្ទ។
③ នៅថ្ងៃចាប់ផ្ដើមប្រើប្រាស់ គេគ្រាន់តែបើកដេហ្សុងទ័រគឺអាចប្រើអគ្គិសនីបានហើយ។

ប៉ុន្តែចំពោះខ្លឹមសារនៃកិច្ចសន្យាខ្លះ ឬសម្ភារៈនៅក្នុងផ្ទះខ្លះ ចាំបាច់ត្រូវអោយបុគ្គលិករបស់ក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីមកជួប។ ក្នុងករណីនោះនឹងមានការណែនាំពីក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនី សូមប្រុងប្រយ័ត្ន។

### វិធីបង់ថ្លៃអគ្គិសនី

- មានជំរើសច្រើនទៅតាមរបៀបប្រើរបស់អ្នកប្រើអគ្គិសនី។ គេអាចជ្រើសរើសយកកិច្ចសន្យាដែលត្រូវនឹងរបៀបប្រើអគ្គិសនីរបស់ខ្លួន។
- ទូទៅតំលៃប្រើប្រាស់កំណត់ដោយបរិមាណអគ្គិនីប្រើប្រាស់ ប៉ុន្តែ ផ្នែកនៃ "ថ្លៃគោល" គឺ មិនប្រែប្រួលចំនួនទឹកប្រាក់ដែលអ្នកបង់ជារៀងរាល់ខែ ទោះជាបរិមាណតើអ្នកប្រើអគ្គិសនីប៉ុន្មានទេ
- វិធីបង់ថ្លៃអគ្គិសនីមាន វិធីដកពីគណនីធនាគារដោយស្វ័យប្រវត្តិ វិធីបង់នៅផ្សារម៉ាត ឬនៅធនាគារ បង់តាមកាតក្រេឌីតជាដើម។

* ចំពោះបរិមាណអគ្គិសនីប្រើប្រាស់ បុគ្គលិករបស់ក្រុមហ៊ុនអគ្គិសនី នឹងត្រូតពិនិត្យកុងទ័រមើលបរិមាណប្រើ តាមផ្ទះនីមួយៗ ដោយទៅផ្ទាល់ ឬពីចម្ងាយក្នុងមួយខែម្ដង។
* ក្រុមហ៊ុនអគ្គិសនីជូនដំណឹងទៅអ្នកប្រើប្រាស់រៀងរាល់ខែ តាមរយៈ "សេចក្ដីជូនដំណឹងអំពីបរិមាណអគ្គិសនីប្រើប្រាស់" (ការជូនដំណឹងអំពីការប្រើប្រាស់ពេលខ្លះផ្ដល់ជូននៅលើគេហទំព័រ)។។
* ចំពោះខ្លឹមសារនៃកិច្ចសន្យាប្រើប្រាស់អគ្គិសនី គេអាចត្រួតពិនិត្យមើលឯកសារដែលក្រុមហ៊ុនអគ្គិសនីផ្ដល់អោយនៅក្នុងអំឡុងពេលចុះកិច្ចសន្យា(ពេលខ្លះផ្ដល់ជូននៅលើគេហទំព័រ)។

### នៅពេលឈប់ប្រើអគ្គិសនី

ដើម្បីបញ្ចប់ការប្រើប្រាស់អគ្គិសនី គេត្រូវធ្វើដូចខាងក្រោម៖

① កំណត់ថ្ងៃឈប់ប្រើអគ្គិសនី។
② បញ្ចប់កិច្ចសន្យាប្រើប្រាស់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់អគ្គិសនីតាមអ៊ីនធើណែតឬទូរស័ព្ទ។

នៅថ្ងៃបញ្ឈប់ការប្រើប្រាស់ ជាទូទៅមិនចាំបាច់អ្នកប្រើប្រាស់នៅជួបក៏បាន។ ប៉ុន្តែក្នុងករណីដែលកុងទ័រស្ថិតនៅកន្លែងដែលមិនអាចមើលពីក្រៅផ្ទះបាន មានករណីតម្រូវអោយនៅជួប។ ក្នុងករណីនោះមានការណែនាំពីក្រុមហ៊ុនអគ្គិសនី សូមប្រុងប្រយ័ត្ន។

ដើម្បីជៀសវាងបញ្ហាសម្រាប់អ្នកជួលបន្ទាប់ សូមប្រាកដថាត្រូវបំពេញនីតិវិធីបញ្ចប់កិច្ចសន្យាចាំបាច់ឱ្យបានល្អមុនកាលបរិច្ឆេទរើចេញរបស់អ្នក។

ចំពោះអ្នកដែលមានបញ្ហាពាក់ព័ន្ធនឹងសកម្មភាពលក់ ឬធ្វើកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនអគ្គិសនី សូមទៅពិគ្រោះតាមកន្លែងខាងក្រោមនេះ។

https://www.emsc.meti.go.jp/general/consult.html

* ពួកគេមិនផ្តល់ព័ត៌មានអំពីព័ត៌មានលម្អិតនៃកិច្ចសន្យាបុគ្គលជាមួយក្រុមហ៊ុនថាមពលអគ្គិសនី ឬរបាយការណ៍វិក្កយបត្រទេ។ សូមទាក់ទងក្រុមហ៊ុនអគ្គិសនីដែលអ្នកចុះកិច្ចសន្យា។
លើសពីនេះ ពួកគេមិនផ្តល់សេវាសម្របសម្រួល ឬអាជ្ញាកណ្តាលរវាងអ្នកប្រឹក្សា និងអាជីវកម្មទេ។

## (2) ហ្គាស

### ប្រភេទហ្គាស



- ហ្គាសដែលអាចប្រើបានតាមផ្ទះទូទៅមានប្រភេទមួយចំនួនដូចជា ហ្គាស13Aសម្រាប់ទីក្រុង ឬហ្គាស LP ជាដើមទៅតាមលក្ខណៈពិសេសនៃចំហេះ។
- ចំពោះឧបករណ៍ប្រើហ្គាសនៅផ្ទះ សូមជ្រើសរើសឧបករណ៍ដែលអាចប្រើបានទៅតាមប្រភេទនៃហ្គាស។

* ការប្រើប្រាស់ឧបករណ៍ដែលដែលមិនត្រូវនឹងប្រភេទហ្គាស ជាការគ្រោះថ្នាក់ខ្លាំងណាស់ព្រោះវាអាចនាំអោយមានអគ្គីភ័យ ឬចំហេះមិនសព្វ។
នៅពេលប្រើប្រាស់ហ្គាស សូមបើកបង្អួចសម្រាប់ខ្យល់ចេញចូល។ ប្រសិនបើអ្នកធុំក្លិនហ្គាស ពេលកំពុងប្រើឧបករណ៍ហ្គាស សូមឈប់ប្រើហ្គាសជាបន្ទាន់ បើកបង្អួចឱ្យមានខ្យល់ចេញចូលគ្រប់គ្រាន់ ហើយកុំប្រើដែកកេះ ឬប្រភពបញ្ឆេះផ្សេងទៀត។ កុំប៉ះកុងតាក់អគ្គិសនី។ ទាក់ទងក្រុមហ្គាសរបស់អ្នកភ្លាមៗ។

### ការចាប់ផ្តើមប្រើហ្គាស

- ដើម្បីចាប់ផ្តើមប្រើប្រាស់ហ្គាសចាំបាច់ត្រូវធ្វើដូចខាងក្រោម៖

① កំណត់ថ្ងៃចាប់ផ្តើមប្រើប្រាស់ហ្គាស។
② ចុះឈ្មោះប្រើប្រាស់ជាមួយក្រុមហ៊ុនហ្គាសនៅតំបន់រស់នៅ ឬតាមអ៊ីនធើណែតឬទូរស័ព្ទ។

* នៅថ្ងៃចាប់ផ្តើមប្រើប្រាស់ បុគ្គលិកក្រុមហ៊ុនហ្គាសមកដល់កន្លែង ត្រួតពិនិត្យសម្ភារៈរួច ចាប់ផ្តើមផ្គត់ផ្គង់ហ្គាស និងពន្យល់ណែនាំអំពីរបៀបប្រើប្រាស់ឧបករណ៍ប្រើហ្គាស។

### ថ្លៃហ្គាសនិងវិធីបង់ថ្លៃហ្គាស

- ក្រុមហ៊ុនហ្គាសនៅតំបន់រស់នៅ មានជំរើសតំលៃប្រើហ្គាសទៅតាមរបៀបប្រើផ្សេងៗ។
- ជាទូទៅតំលៃហ្គាសបានមកពីតំលៃមូលដ្ឋានដែលជាតំលៃថេរ បូកជាមួយនឹងតំលៃសមាមាត្រនឹងបរិមាណប្រើជាក់ស្តែង ដែលត្រូវបានគណនានិងគិតថ្លៃរៀងរាល់ខែ។
- វិធីបង់ថ្លៃហ្គាសមាន វិធីដកពីគណនីធនាគារដោយស្វ័យប្រវត្តិ វិធីបង់នៅផ្សារម៉ាត ឬនៅធនាគារ បង់តាមកាតក្រេឌីតជាដើម។

* ស្តីពីខ្លឹមសារនៃកិច្ចសន្យាប្រើប្រាស់ហ្គាស គេអាចត្រួតពិនិត្យមើលឯកសារដែលក្រុមហ៊ុនហ្គាសបានផ្តល់អោយនៅក្នុងអំឡុងពេលចុះកិច្ចសន្យា(ពេលខ្លះផ្តល់ជូននៅលើគេហទំព័រ)។

### នៅពេលឈប់ប្រើហ្គាស

- ដើម្បីបញ្ចប់ការប្រើប្រាស់ហ្គាស គេត្រូវធ្វើដូចខាងក្រោម៖

① កំណត់ថ្ងៃដែលអ្នកចង់ចាប់ផ្តើមប្រើប្រាស់ហ្គាស។

② បញ្ចប់កិច្ចសន្យាប្រើប្រាស់ជាមួយក្រុមហ៊ុនផ្គត់ផ្គង់ហ្គាស តាមអ៊ីនធើណែតឬទូរស័ព្ទ។

* សូមត្រៀមវិក្កយបត្រដែលទទួលបានរៀងរាល់ខែ ហើយប្រាប់ទៅក្រុមហ៊ុនហ្គាសនូវ "លេខអតិថិជន" នោះនឹងធ្វើអោយនីតិវិធីមានភាពរលូន។លិខិតបញ្ជាក់ការគិតថ្លៃ (ពេលខ្លះផ្តល់ជូននៅលើគេហទំព័រ)។

នៅថ្ងៃបញ្ឈប់ការប្រើប្រាស់ បុគ្គលិកនឹងបញ្ឈប់កុងទ័រហ្គាស។ ប៉ុន្តែក្នុងករណីដែលកុងទ័រស្ថិតនៅកន្លែងដែលបុគ្គលិកមិនអាចចូលទៅបាន គឺត្រូវការអោយអ្នកប្រើប្រាស់ហ្គាស ឬអ្នកតំណាងនៅចាំជួប។

ដើម្បីជៀសវាងបញ្ហាសម្រាប់អ្នកជួលបន្ទាប់ សូមប្រាកដថាត្រូវបំពេញនីតិវិធីបញ្ចប់កិច្ចសន្យាចាំបាច់ឱ្យបានល្អមុនកាលបរិច្ឆេទរើចេញរបស់អ្នក។

ចំពោះអ្នកដែលមានបញ្ហាពាក់ព័ន្ធនឹងសកម្មភាពលក់ ឬធ្វើកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនហ្គាស សូមទៅពិគ្រោះតាមកន្លែងខាងក្រោមនេះ។

https://www.emsc.meti.go.jp/general/consult.html

* ពួកគេមិនផ្តល់ព័ត៌មានអំពីព័ត៌មានលម្អិតនៃកិច្ចសន្យាបុគ្គលជាមួយក្រុមហ៊ុនហ្គាស ឬរបាយការណ៍វិក្កយបត្រទេ។ សូមទាក់ទងក្រុមហ៊ុនហ្គាសដែលអ្នកចុះកិច្ចសន្យា
លើសពីនេះ ពួកគេមិនផ្តល់សេវាសម្របសម្រួល ឬអាជ្ញាកណ្តាលរវាងអ្នកប្រឹក្សា និងអាជីវកម្មទេ។

## (3) ទឹកស្អាត

### ការប្រើប្រាស់ទឹកស្អាត



នៅពេលដែលត្រូវការប្រើទឹកស្អាតដោយសារមូលហេតុដូចជាផ្លាស់ទីលំនៅមកថ្មីជាដើម អ្នកដែលប្រើទឹកស្អាតត្រូវចុះឈ្មោះអំពីការចាប់ផ្តើមប្រើប្រាស់ទឹកស្អាតជាមុនទៅការិយាល័យទទួលបន្ទុកផ្នែកទឹកស្អាតនៃភូមិឃុំស្រុកដែលអ្នករស់នៅ ឬក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត។

សូមទាក់ទងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។

### ថ្លៃប្រើប្រាស់ទឹកស្អាត

ការបង់និងគិតថ្លៃទឹកស្អាតគឺដូចខាងក្រោម៖

① ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតនៅភូមិឃុំស្រុកដែលអ្នករស់នៅនីមួយៗជាអ្នកកំណត់តំលៃឯកតា។ ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតធ្វើការត្រួតពិនិត្យបរិមាណទឹកស្អាតដែលអ្នកប្រើប្រាស់បានប្រើតាមរយៈកុងទ័រទឹក ហើយគិតថ្លៃទៅតាមបរិមាណទឹកដែលបានប្រើប្រាស់។

② ថ្លៃទឹកស្អាតត្រូវបានគិតដោយយក "តំលៃមូលដ្ឋាន" បូកជាមួយ "តំលៃតាមបរិមាណប្រើប្រាស់"។ "តំលៃមូលដ្ឋាន" ត្រូវបានគិតទៅតាមទំហំទុយោផ្គត់ផ្គង់នៃកុងទ័រទឹក ទំហំទុយោកាន់តែធំតំលៃកាន់តែថ្លៃ។ ចំពោះ "តំលៃតាមបរិមាណប្រើប្រាស់" គឺកំណត់ដោយបរិមាណទឹកស្អាតដែលបានប្រើប្រាស់ជាក់ស្តែង ការប្រើប្រាស់ បរិមាណទឹកប្រើប្រាស់កាន់តែច្រើន ទឹកប្រាក់ក៏ច្រើនតាមនោះដែរ។

③ វិធីបង់ថ្លៃប្រើប្រាស់ទឹកស្អាតខុសៗគ្នាទៅតាមក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត។ ជាទូទៅគេអាចជ្រើសរើសក្នុងចំណោម វិធីផ្ទេរតាមគណនីធនាគារ និងវិធីបង់នៅធនាគារ ឬផ្សារម៉ាតជាដើម។

# 3-4 ការប្រើប្រាស់ទូរស័ព្ទចល័ត



## (1) កិច្ចសន្យាទូរស័ព្ទចល័ត

- នៅពេលចុះកិច្ចសន្យាទូរស័ព្ទចល័ត ចាំបាច់ត្រូវទទួលការបញ្ជាក់សមីខ្លួន។
- ដើម្បីបញ្ជាក់សាមីខ្លួន មានវិធីដូចតទៅ។

① បង្ហាញជូនអង្គភាពអាជីវកម្មទូរស័ព្ទចល័ត
② ផ្ញើឯកសារថតចម្លង តាមបុស្តិ៍ប្រៃសណីយ៍ ឬផ្ញើតាមអ៊ីនធឺណិត
នៃឯកសារជាផ្លូវការ (ឯកសារបញ្ជាក់សាមីខ្លួន) ដែលមានចុះអំពីឈ្មោះ ថ្ងៃខែឆ្នាំកំណើត។

- ឧទាហរណ៍ឯកសារដូចខាងក្រោមអាចប្រើធ្វើជាឯកសារបញ្ជាក់សមីខ្លួនបាន៖

① ប័ណ្ណស្នាក់នៅ
② ប័ណ្ណបើកបរ
③ កាតលេខសំគាល់បុគ្គល
④ លិខិតឆ្លងដែន (ចំពោះតែករណីមានសរសេរអាសយដ្ឋានបច្ចុប្បន្ន)

- ក្នុងករណីដែលអ្នកមិនទាន់គ្រប់អាយុ ឯកសារខាងក្រោមត្រូវការទាំងអស់៖

① ឯកសារបញ្ជាក់សមីខ្លួន
② ការយល់ព្រមពីអាណាព្យាបាល

- គេត្រូវការរបស់មួយក្នុងចំណោមខាងក្រោម ដើម្បីធ្វើនីតិវិធីបង់ប្រាក់៖

① កាតក្រេឌីត
② កាតATM នៃធនាគារណាមួយក្នុងប្រទេសជប៉ុន
③ សៀវភៅធនាគារនៃធនាគារណាមួយក្នុងប្រទេសជប៉ុន

- ក្រុមហ៊ុនទូរស័ព្ទចល័តខ្លះមានសេវាឆ្លើយតបតាមគេហទំព័រ ឬនៅហាងជាភាសាបរទេស។
- គេអាចបញ្ជាក់ជាមុនអំពីឯកសារត្រូវការចាំបាច់ក្នុងការចុះកិច្ចសន្យា ឬអាចសួរបញ្ជាក់អំពីសេវាកម្មនៃទូរស័ព្ទចល័តបាន។

## (2) ចំណុចប្រុងប្រយ័ត្ននៅពេលធ្វើកិច្ចសន្យា និងនៅពេលប្រើប្រាស់

- មានជនខិលខូចខ្លះព្យាយាមមកជិតអ្នកដោយនិយាយថា “នឹងចុះកិច្ចសន្យាទូរស័ព្ទចល័តជំនួសអ្នក” ហើយប្រើប្រាស់ឯកសារបញ្ជាក់សមីខ្លួនអ្នកចុះកិច្ចសន្យាទូរស័ព្ទចល័តតាមចិត្ត ហើយយកទៅប្រើសម្រាប់ប្រព្រឹត្តិបទល្មើស។
- ក្នុងករណីពឹងពាក់អ្នកដទៃអោយចុះកិច្ចសន្យាជំនួស សូមត្រួតពិនិត្យខ្លឹមសារដោយខ្លួនឯងផងដែរ។

- ការយកទូរស័ព្ទចល័តដែលខ្លួនបានចុះកិច្ចសន្យា អោយទៅអ្នកដទៃដោយគ្មានការយល់ព្រមពីក្រុមហ៊ុនទូរស័ព្ទចល័ត នឹងត្រូវផ្តន្ទាទោសដោយច្បាប់។
ក្នុងករណីដែលអ្នកនឹងលែងប្រើទូរសព្ទដៃរបស់អ្នកដោយសារហេតុផលនានា រួមទាំងការត្រឡប់ទៅប្រទេសកំណើតរបស់អ្នកវិញ សូមទាក់ទងមកអ្នកផ្តល់សេវាទូរសព្ទរបស់អ្នកដើម្បីលុបចោល ឬផ្ទេរសេវាកម្ម។



## 3-5 គណនីធនាគារ

### (1) បើកគណនីធនាគារ

- គេអាចបើកគណនីធនាគារនៅសាខាធនាគារបាន។ ចំពោះធនាគារខ្លះអាចធ្វើបែបបទតាមប្រៃសណីយ៍ កម្មវិធីក្នុងទូរស័ព្ទស្មាតហ្វូន ឬកុំព្យូទ័រក៏បាន។ ជាទូទៅកាត ATM នឹងត្រូវផ្ញើតាមប្រៃសណីយ៍មកផ្ទះតាមក្រោយ។
- នៅពេលទៅបើកគណនីធនាគារ សូមយកឯកសារខាងក្រោមទៅធនាគារ៖

① ឯកសារបញ្ជាក់សមីខ្លួន (ឧទាហរណ៍៖ ប័ណ្ណស្នាក់នៅ)
② ត្រា (មានធនាគារខ្លះចុះហត្ថលេខាក៏បាន។)
③ កាតបុគ្គលិកក្រុមហ៊ុន ឬកាតនិស្សិត (ក្នុងករណីគ្មាន សូមហៅមនុស្សក្នុងក្រុមហ៊ុន ឬមនុស្សនៅសាលាមកជាមួយ។)

- ក្នុងករណីមានការបារម្ភលើការទាក់ទងជាភាសាជប៉ុន សូមពឹងពាក់ទៅអ្នកដែលជួយគាំទ្រអ្នកជាប្រចាំ (មនុស្សនៅកន្លែងធ្វើការ ឬសាលារបស់អ្នក) អោយជួយបកប្រែ។

### (2) ពេលប្តូរអាសយដ្ឋាន ឬមានការប្រែប្រួលអំពីកម្លុងពេលស្នាក់នៅ ត្រូវជូនដំណឹងប្រាប់ធនាគារភ្លាមៗ

- ក្នុងករណីដែលមានការប្តូរព័ត៌មានស្តីពីអាសយដ្ឋាន កម្លុងពេលស្នាក់នៅ លក្ខណៈសម្បត្តិនៃការស្នាក់នៅ កន្លែងធ្វើការ ជាដើម សូមទាក់ទងទៅធនាគារដែលបានបង្កើតគណនីជាបន្ទាន់។ ក្រៅពីនេះ ដើម្បីបញ្ជាក់មើលថា អ្នកមិនបានប្តូរព័ត៌មានអ្វីទេ ធនាគារក៏អាចទាក់ទងទៅក៏មានដែរ។
- បើសិនជាមិនទាក់ទងទៅធនាគារអំពីការប្តូរព័ត៌មានស្តីពីអាសយដ្ឋាន កម្លុងពេលស្នាក់នៅលក្ខណៈសម្បត្តិនៃការស្នាក់នៅ កន្លែងធ្វើការជាដើម ឬក៏មិនបានឆ្លើយតបនៅពេលមានការសួរពីធនាគារទេ អាចមានករណីដែលមិនអាចប្រើគណនីធនាគារនោះតទៅទៀតបាន។

### (3) ការបិទគណនីធនាគារមិនប្រើប្រាស់

- ក្នុងករណីដែលអ្នកលែងប្រើគណនីធនាគារដោយសារត្រូវត្រឡប់ទៅប្រទេសវិញជាដើម សូមបិទគណនីធនាគារ។ គេអាចធ្វើបែបបទបិទគណនីនៅសាខាធនាគារបាន។

* ការលក់ ឬប្រគល់គណនីធនាគារ (កាត ATM សៀវភៅធនាគារ លេខសម្គាល់ចូល ពាក្យសម្ងាត់ជាដើម) គឺជាបទល្មើស។ សូមកុំប្រព្រឹត្តិអោយសោះ។ ក្នុងករណីល្មើស អាចទទួលទោសជាប់ពន្ធនាគាររយៈពេលក្រោម1ឆ្នាំ ឬពិន័យជាប្រាក់ក្រោម 1លានយ៉េន។

## (4) កុំប្រើប្រាស់ធនាគារខុសច្បាប់

- គឺតម្រូវអោយមានអាជ្ញាបណ្ណជាតិដើម្បីធ្វើអាជីវកម្មធនាគារ
អ្នកមិនអាចស្នើរសុំដូចជាការផ្ញើរប្រាក់ទៅបរទេស ដោយការបង់លុយទៅកាន់ធនាគារខុសច្បាប់ ឬបុគ្គលដែលមិនទទួលស្គាល់ដោយរដ្ឋាភិបាលឬធនាគារខុសច្បាប់ជាដើម។
- ប្រសិនបើអ្នកមិនប្រាកដអំពីធនាគារខុសច្បាប់ឬក៏អ្នកផ្តល់សេវាកម្មឬអត់ទេសូមកុំប្រើប្រាស់ សូមប្រឹក្សាជាមួយអ្នកនៅក្រុមហ៊ុនឬសាលា។

## (5) ផ្សេងៗ

- ទីភ្នាក់ងារសេវាកម្មហិរញ្ញវត្ថុបានបង្កើតខិត្តប័ណ្ណមួយដែលមានចំណងជើងថា "របៀបប្រើប្រាស់គណនីធនាគារ និងការផ្ទេរប្រាក់សម្រាប់ការរស់នៅក្នុងប្រទេសជប៉ុន" (បកប្រែជា 15 ភាសា រួមទាំងភាសាអង់គ្លេស និងចិន) សម្រាប់ជនបរទេសដែលមានគម្រោងស្នាក់នៅប្រទេសជប៉ុនរយៈពេលវែង ដោយសង្ខេបព័ត៌មានសំខាន់ៗអំពីការប្រើប្រាស់គណនីសន្សំ និងការផ្ទេរប្រាក់។ សូមប្រើប្រាស់ធនធាននេះ។For more details, please visit the following webpages below.

សម្រាប់ព័ត៌មានលម្អិតសូមចូលទៅកាន់គេហទំព័រខាងក្រោម

https://www.fsa.go.jp/news/30/20190411/20190411.html (ជប៉ុន)

https://www.fsa.go.jp/news/r1/20191004/20190411.html (អង់គ្លេស)

## 3-6 ការិយាល័យប្រៃសណីយ៍

- សញ្ញាសំគាល់ការិយាល័យប្រៃសណីយ៍ និងប្រអប់សំបុត្រប្រៃសណីយ៍របស់ជប៉ុនគឺ "〒" ដែលមានពណ៌ក្រហមជាគោល។
- នៅការិយាល័យប្រៃសណីយ៍ គេអាចទទួលសេវាកម្មខាងក្រោមបាន៖

① អាចផ្ញើសំបុត្រ កាតប៉ុស្តាល់ ឬកញ្ចប់ទំនិញទៅក្នុងនិងក្រៅប្រទេសបាន(*1)
② អាចសន្សំប្រាក់(*2) ផ្ទេរប្រាក់ បង់ប្រាក់ថ្លៃសេវាសាធារណៈជាដើមបាន។
③ អាចចូលធានារ៉ាប់រងជីវិតបាន។

*1 សម្រាប់ការសាកសួរទាក់ទងនឹងការផ្ញើសំបុត្រ កាតប៉ុស្តាល់ និងជាកញ្ចប់ ប្រៃសណីយ៍ជប៉ុនបានបង្កើតមជ្ឈមណ្ឌលប្រឹក្សាសេវាកម្មអតិថិជន (ភាសាអង់គ្លេស)។
គេហទំព័រប្រៃសណីយ៍ជប៉ុន (ភាសាអង់គ្លេស)៖
https://www.post.japanpost.jp/index_en.html

*2 សម្រាប់ការសាកសួរទាក់ទងនឹងការបើកគណនី ប្រៃសណីយ៍ជប៉ុនបានបង្កើតមជ្ឈមណ្ឌលទំនាក់ទំនងពហុភាសា។ (TEL: 0570-023170)
ភាសាដែលគាំទ្រ៖ អង់គ្លេស ចិន កូរ៉េ វៀតណាម ឥណ្ឌូនេស៊ី
គេហទំព័រព័ត៌មានមជ្ឈមណ្ឌលទំនាក់ទំនង៖
https://www.post.japanpost.jp/bank/account/multilanguage-callcenter.html

# 4 ចរាចរណ៍សាធារណៈ

## 4-1 កាត IC

### (1) មុខងារមូលដ្ឋាន

កាត ICសម្រាប់ធ្វើចរាចរណ៍អាចបង់ថ្លៃធ្វើដំណើរតាមរថភ្លើង ឬរថយន្តក្រុងរបស់ក្រុមហ៊ុនផ្សេងៗបាន។ នេះជាសេចក្តីពន្យល់អំពីមុខងារនៃកាត ICសម្រាប់ចរាចរណ៍ទូទៅ។

- តាមរយៈការបញ្ចូលប្រាក់ក្នុងកាត ICជាមុន (charge) គេអាចកាត់ចោលនូវពេលវេលាខាតក្នុងការទិញសំបុត្រនៅកន្លែងម៉ាស៊ីនលក់សំបុត្របាន។
- គេអាចរកទិញបាននៅម៉ាស៊ីនលក់សំបុត្រឬបញ្ជរនៃស្ថានីយ៍រថភ្លើង ឬកន្លែងលក់សំបុត្ររថយន្តក្រុងជាដើម។
- មានករណីដែលថ្លៃជិះថោកជាងករណីបង់ដោយសាច់ប្រាក់។

### (2) កាតមានឈ្មោះ

- ជាកាតដែលមានសរសេរឈ្មោះរបស់អ្នកប្រើ។
- ត្រូវបញ្ចូលទិន្នន័យឈ្មោះ លេខទូរស័ព្ទ ថ្ងៃខែឆ្នាំកំណើត ភេទប្រុសឬស្រី។
- ទោះជាបាត់កាត ក៏អាចចេញកាតថ្មីបានដែរ។

### (3) កាតគ្មានឈ្មោះ

- គ្មានសរសេរឈ្មោះរបស់អ្នកប្រើ។
- ទោះក្នុងករណីបាត់កាត គេមិនអាចចេញកាតថ្មីបានទេ។

### (4) ប្រាក់កក់ (deposit)

- ជាទូទៅនៅពេលទិញកាតគេត្រូវបង់ប្រាក់កក់។
- ជាប្រាក់ដែលនឹងទទួលបានមកវិញនៅពេលសងកាត IC។



## 4-2 ផ្លូវដែក



នៅប្រទេសជប៉ុនបណ្តាញផ្លូវដែកមានការរីកចំរើនខ្លាំង ដែលត្រូវបានប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរពេញនិយម រួមទាំងការទៅមកធ្វើការ ឬសាលាផងដែរ។

### (1) ការប្រើប្រាស់បណ្តាញផ្លូវដែក

លំដាប់លំដោយមូលដ្ឋានក្នុងការធ្វើដំណើរតាមផ្លូវដែកគឺដូចខាងក្រោម៖

① មើលបញ្ជាក់គោលដៅត្រូវទៅតាមផែនទីរថភ្លើង

② ទិញសំបុត្ររថភ្លើងនៅស្ថានីយ៍ក្នុងទឹកប្រាក់រហូតដល់គោលដៅ ហើយចូលតាមច្រកយកសំបុត្រ។ (ក្នុងករណីប្រើប្រាស់កាត ICសម្រាប់ចរាចរណ៍ គេអាចឆ្លងច្រកយកសំបុត្របានដោយគ្រាន់តែដាក់កាតនៅត្រង់កន្លែងម៉ាស៊ីនអាន។)

③ ធ្វើដំណើរក្នុងស្ថានីយ៍ទៅកាន់ច្រកដែលរថភ្លើងធ្វើដំណើរទៅកាន់គោលដៅរបស់អ្នកឈប់និងចេញដំណើរ។

④ សូមរង់ចាំរថភ្លើងនៅវេទិការង់ចាំ ដោយមិនត្រូវឆ្លងការ៉ូឡាពណ៌សឬពណ៌លឿងឡើយ។

⑤ នៅគោលដៅ សូមប្រើសំបុត្រជិះដែលបានទិញដើម្បីឆ្លងច្រកផែកសំបុត្រ។ (ក្នុងករណីប្រើប្រាស់កាត ICសម្រាប់ចរាចរណ៍ ថ្លៃធ្វើដំណើរត្រូវបានដកពីក្នុងទឹកប្រាក់ដែលបានបញ្ចូល ដោយគ្រាន់តែដាក់កាតនៅត្រង់កន្លែងម៉ាស៊ីនអាន។)

### (2) ប្រភេទនៃសំបុត្រ

| | |
|---|---|
| ① សំបុត្រជិះធម្មតា៖ | ជាសំបុត្រដែលត្រូវការនៅពេលជិះរថភ្លើង។ |
| ② សំបុត្រសម្រាប់រយៈពេលកំណត់៖ | គេប្រើសម្រាប់ជិះទៅធ្វើការ ឬទៅសាលារៀន ដែលត្រូវជិះក្នុងចន្លោះកំណត់មួយជាប្រចាំសម្រាប់ខែនីមួយៗ។ តំលៃត្រូវបានកំណត់ឱ្យថោកជាងការជិះដោយសំបុត្រធម្មតាក្នុងចន្លោះដូចគ្នា។ មានរយៈពេល 1ខែ 3ខែ 6ខែ។ល។ |

### (3) សំបុត្រផ្សេងទៀត

ក្នុងករណីដូចជាជិះរថភ្លើងលឿន ឬប្រើប្រាស់សម្ភារៈពិសេសនៃរថភ្លើង ក្រៅពីសំបុត្រជិះគេត្រូវទិញសំបុត្រ (សំបុត្រគិតថ្លៃ) ខាងក្រោម៖

| | |
|---|---|
| ① សំបុត្រលឿន៖ | ជាសំបុត្រដែលត្រូវការនៅពេលជិះរថភ្លើងស៊ីនកាន់សេន ឬរថភ្លើងលឿន។ |
| ② សំបុត្រកំណត់កៅអី៖ | ជាសំបុត្រដែលត្រូវការនៅពេលប្រើប្រាស់កៅអីកំណត់។ មានករណីខ្លះជាឈុតជាមួយសំបុត្រលឿន។ |
| ③ សំបុត្របៃតង៖ | ជាសំបុត្រដែលត្រូវការនៅពេលជិះក្នុងទូររថភ្លើងដែលមានលក្ខណៈល្អជាងទូររថភ្លើងធម្មតា។ |

# 4-3 រថយន្តក្រុង



## (1) រថយន្តក្រុងធ្វើដំណើរផ្លូវឆ្ងាយ (រថយន្តក្រុងផ្លូវឆ្ងាយ)

- ជាទូទៅចាំបាច់ត្រូវបង់ថ្លៃសោហ៊ុយមុនជិះរថយន្ត ដូចជាទិញសំបុត្រជាដើម។

## (2) រថយន្តក្រុងធ្វើដំណើរតាមផ្លូវកំណត់នៅតំបន់រស់នៅ (រថយន្តក្រុងក្នុងតំបន់)

① ក្នុងករណីថ្លៃជិះថេរទោះជិះទៅដល់ណាក៏ដោយ

- ដាក់ប្រាក់ចូលក្នុងប្រអប់ដាក់ថ្លៃសោហ៊ុយនៅពេលជិះរថយន្តក្រុង។
- ក្នុងករណីប្រើប្រាស់កាត ICសម្រាប់ចរាចរណ៍ ដាក់កាតនៅត្រង់ប្រអប់ដាក់ប្រាក់ថ្លៃជិះរថយន្ត។

② ក្នុងករណីថ្លៃជិះប្រែប្រួលតាមចំងាយ

- នៅពេលឡើងជិះរថយន្តក្រុង ដកយកសំបុត្រដែលមានសរសេរលេខសំគាល់ ហើយនៅពេលចុះ រកមើលលេខដូចលេខដែលមានសរសេរក្នុងសំបុត្រនៅលើក្តារផ្ទែកខាងលើអ្នកបើកបរ ហើយបង់ថ្លៃជិះក្នុងចំនួនដូចដែលមានបង្ហាញលើក្តារនោះ។
- ក្នុងករណីប្រើប្រាស់កាត ICសម្រាប់ចរាចរណ៍ ត្រូវដាក់អោយម៉ាស៊ីនអានកាតនៅពេលឡើងនិងពេលចុះសរុបចំនួន 2ដង។s